ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ◆ គោលគំនិតនៃការស្រាវជ្រាវ
- ◆ ព្រឹត្តិការណ៍សំខាន់ៗទាក់ទិននឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៩២ ខែសីហា ឆ្នាំ២០០៧

**ស្វែងរកការពិត**

លេខ៩២ ខែសីហា ឆ្នាំ២០០៧

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រ ៖ គោលគំនិតថ្មីនៃការស្រាវជ្រាវ ....................................១

**ផ្នែកឯកសារ**

◆ ពិការជើងដោយការធ្វើបដិវត្តន៍ ....................................២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ គុកខ្មែរក្រហម ....................................៦

◆ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ....................................១១

◆ ជាប់គុកទួលស្លែងដោយសារការមិនទុកចិត្ត ....................................១៥

◆ យុវជនកម្ពុជាត្រូវការយុត្តិធម៌ ....................................១៩

◆ ការជួបប្រជុំរបស់បញ្ញវន្តនៃអំពើប្រល័យពូជសាសន៍....................................២៣

**ផ្នែកច្បាប់**

◆ ព្រឹត្តិការណ៍សំខាន់ៗ ទាក់ទិននឹងអង្គជំនុំជម្រះវិសាមញ្ញ ....................................៣២

◆ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ....................................៤០

**វេទិកាពិភាក្សាសាធារណៈ**

◆ ការកែប្រែរចនាសម្ព័ន្ធតុលាការកូនកាត់ ....................................៤៧

**ទំព័រស្រាវជ្រាវរកក្រួសារ**

◆ ការលំបាកដែលខ្ញុំ ....................................៥៤





សកម្មភាពប្រជាជនចូលទស្សនាមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្មេរលេខនេះ ៖** អេង កុកថាយ, ផេង ពង្សរ៉ាស៊ី, ឌី ខាំបូលី, ប៊ីដូ ម៉ុនយ៉ាស, ព្រំ ផល្លា, វ៉ាន់ថាន់ ពៅដារ៉ា, យូ ប៊ុនឡេង និង ម៉ារសែល ឡឺម៉ុង, អេតែល ហ៊ីហ្គូនេត, ភី ប៊ុនថាន់ **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** តាត លក្ខិណា, សោម ប៊ុនថន **អ្នកបកប្រែ ៖** ឃុត តារាសោភា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** លី សុផល **ក្រាហ្វិកកុំព្យូទ័រ ៖** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ ៖** រ័ត្ន តារាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ ៖*

# គោលគំនិតថ្មីនៃការស្រាវជ្រាវ

នៅក្នុងរយៈពេលដប់ឆ្នាំដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានកំពុងដំណើរការយ៉ាងជោគជ័យ មជ្ឈមណ្ឌលបានខិតខំបំពេញការងារទៅតាមគោលដៅគ្រោះរបស់យើងគឺយុត្តិធម៌និងការចងចាំ ។ លើសពីនេះយើងបានកំណត់វិសាលភាពការងាររបស់យើងឲ្យឋិតនៅត្រឹមប្រវត្តិសាស្ត្រនិងរឿងរ៉ាវដែលទាក់ទងទៅនឹងរបបខ្មែរក្រហម ។ បច្ចុប្បន្ន មជ្ឈមណ្ឌលកំពុងតែគិតគូរអំពីការបង្វែរបុព្វគ្រឹកទិសដៅនៃការស្រាវជ្រាវដើម្បីឲ្យមជ្ឈមណ្ឌលអាចមានតួនាទីកាន់តែសំខាន់ក្នុងការរួមចំណែកដោះស្រាយបញ្ហាសង្គមនិងនយោបាយក្នុងប្រទេសកម្ពុជាជាលក្ខណៈអព្យាក្រឹត ។ ពោលគឺប្រើប្រាស់អព្យាក្រឹតភាពរបស់ខ្លួនក្នុងការស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីទាមទារឲ្យមានការទុកចិត្តពីសាធារណជនក្នុងការវិភាគវិបត្តិសង្គម ។

កន្លងមកមជ្ឈមណ្ឌលបានក្លាយខ្លួនជាស្ថាប័នក្រៅរដ្ឋាភិបាលនាំមុខខាងផ្នែកស្រាវជ្រាវនិងការចងក្រងឯកសារទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ មជ្ឈមណ្ឌលបានបោះពុម្ពផ្សាយសៀវភៅទស្សនាវដ្តីនិងអត្ថបទផ្សេងៗជាភាសាខ្មែរនិងភាសាអង់គ្លេស ទាក់ទងទៅនឹងរបបខ្មែរក្រហមនិងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លើសពីនេះមជ្ឈមណ្ឌលបានបន្តឲ្យមានការពិភាក្សាឡើងវិញនូវអ្វីដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ។

នៅឆ្នាំ១៩៩៧ នៅពេលដែលមជ្ឈមណ្ឌលបានប្រឡូកក្នុងការងារជាលើកដំបូង កម្រិតយល់ដឹងរបស់ប្រជាជនខ្មែរនៅតាមភូមិឃុំ ទាក់ទងទៅនឹងរបបខ្មែរក្រហមមានលក្ខណៈជាបុគ្គលហើយច្រើនតែដឹងតែអំពីអ្វីដែលបានកើតឡើងក្នុងសហករណ៍របស់ខ្លួនក្នុងភូមិឃុំ និងពេលវេលាណាមួយប៉ុណ្ណោះ ។ ផ្ទុយទៅវិញការបកស្រាយជាលក្ខណៈជ្រួការអំពីរបបខ្មែរក្រហមច្រើនតែមានលក្ខណៈលម្អៀងទៅរកបក្សនយោបាយណាមួយ និងធ្ងន់ធ្ងរជាងការពិត ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានកែប្រែចំណុចខ្វះខាតទាំងពីរនេះ ហើយបណ្តុះឲ្យមានការយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហមមួយដែលមានភាពត្រឹមត្រូវទៅតាមតថភាពជាក់ស្តែងនិងទៅតាមភ័ស្តុតាងច្បាស់លាស់ ។

នៅក្នុងអំឡុងពេល១០ឆ្នាំមុន មជ្ឈមណ្ឌលបានខំប្រឹងរើបម្រះខ្លួនពីភាពខ្ទេចខ្ទាំនៃសង្គ្រាមស៊ីវិល ។ សេដ្ឋកិច្ចជាតិបានចាប់ផ្តើមមានដំណើរការឡើងវិញ ។ កម្រិតប្រាក់ចំណូលកើនឡើងបន្តិចបន្តួច ប៉ុន្តែនៅមានកម្រិតទាប ។ អត្រាអ្នកមិនចេះអក្សរមានកម្រិតខ្ពស់ ហើយអ្នកដែលមានចំណេះដឹង ផ្នែកភាសាបរទេសដូចជាភាសាអង់គ្លេសកាន់តែមានកម្រិតទាបថែមទៀត ។ ក្នុងអំឡុងពេលនោះ កម្ពុជានៅតែមិនទាន់បើកទ្វារទូលាយទៅរកសហគមន៍អន្តរជាតិ ។ ហេតុនេះ ទស្សនៈនិងការយល់ឃើញរបស់ប្រជាជនខ្មែរទូទៅមិនទាន់មានភាពទូលំទូលាយនៅឡើយ ។ ផ្ទុយទៅវិញនៅក្នុងអំឡុងពេលជាមួយគ្នា កម្រិតការងារជាលក្ខណៈអាជីពរបស់មជ្ឈមណ្ឌលមានលក្ខណៈខ្ពស់ជាងលក្ខខណ្ឌទូទៅ ។

បច្ចុប្បន្ន អ្វីៗហាក់បីដូចជាកំពុងតែផ្លាស់ប្តូរ ។ សាធារណជនទាមទារឲ្យមានការងារដែលមានគុណភាពកាន់តែខ្ពស់ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបន្តប្រែប្រួលនិងបង្កើនសមត្ថភាពខ្លួន ប៉ុន្តែកម្រិតនៃការប្រែប្រួលរបស់យើងមានលក្ខណៈទាបជាងកម្រិតទូទៅ ។ ហេតុនេះនៅថ្ងៃអនាគត មជ្ឈមណ្ឌលនឹងមិនអាចរក្សាភាពនាំមុខគេជាអង្គភាពស្រាវជ្រាវនិងបោះពុម្ពផ្សាយដ៏ឆ្នើមទៀតបានឡើយ ។ ដោយសារមូលហេតុនេះ មជ្ឈមណ្ឌលកំពុងតែរៀបចំក្របខ័ណ្ឌនៃការស្រាវជ្រាវថ្មីមួយដែលអាចបត់បែនទៅតាមកាលៈទេសៈជាក់ស្តែងនាពេលអនាគត ។

ចំណុចសំខាន់មួយទៀតដែលអាចជះឥទ្ធិពលអាក្រក់ដល់គោលដៅបច្ចុប្បន្នរបស់យើងគឺថា គោលបំណងសំខាន់នៃការរើកកាយនិងការវិភាគអំពីភាពជូរចត់ពីអតីតកាលគឺដើម្បីរៀនសូត្រឲ្យបានច្បាស់លាស់នូវអ្វីដែលបានកើតឡើងនិងដើម្បីកសាងអនាគតថ្មី ។ នៅពេលដែលគោលដៅនេះត្រូវបានបំពេញ ការរើកកាយគួរតែត្រូវចៀសវាង ពីព្រោះការធ្វើបែបនោះបណ្តាលឲ្យមានការឈឺចាប់ឡើងវិញអំពីអ្វីដែលបានកើតឡើងយូរមកហើយ ។ ហេតុផលទាំងនេះបញ្ជាក់ថាគោលដៅបច្ចុប្បន្នរបស់មជ្ឈមណ្ឌលមានដែនកំណត់ពេលវេលា ។ **ឆេង កុកថាយ**

# ពិការជើងដោយការធ្វើបដិវត្តន៍

ក្រោមការគ្រប់គ្រងរបស់របបថ្មីដែលមានឈ្មោះជាផ្លូវការ «កម្ពុជាប្រជាធិបតេយ្យ» រចនាសម្ព័ន្ធគ្រប់គ្រងនៃរបបចាស់ ក្រសួង មន្ទីរ រោងចក្រ សាលារៀន មន្ទីរពេទ្យ វត្តអារាមត្រូវបានលុបបំបាត់ចោលទាំងស្រុង សិទ្ធិសេរីភាពក្នុងការនិយាយស្តី ធ្វើការងារ និងដើរហើរត្រូវបានរឹតបណ្តឹង។ ទន្ទឹមនេះការបង្ក្រាបទៅលើអ្នកសង្ស័យថាប្រឆាំងអង្គការ ហើយការសម្លាប់រង្គាលក៏កើតឡើងដែរនៅពេលនោះ។ នៅពាក់កណ្តាលឆ្នាំ១៩៧៨ ការបោសសម្អាតប្រជាជននិងកម្មាភិបាលគ្រប់តំបន់នានាៗកាន់តែមានភាពសាហាវ។ មិនយូរប៉ុន្មានរបបថ្មីនេះត្រូវបានផ្តួលរំលំដោយកងទ័ពវៀតណាមនិងកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជានៅថ្ងៃ៧មករា ឆ្នាំ១៩៧៩ ដោយបានបន្សល់ទុកនូវក្មេងកំព្រា ស្ត្រីមេម៉ាយ និងជនពិការជាច្រើន ហើយអ្នកទាំងនោះទទួលរងនូវការប៉ះទង្គិចទាំងផ្លូវកាយនិងផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ។

បុរសម្នាក់ពិការជើងឆ្វេងអង្គុយក្នុងតូបបញ្ចេញនូវស្នាមញញឹមប្រកបដោយទឹកមុខរាក់ទាក់ ប៉ុន្តែយើងមិនដឹងថាកាលពី៣០ឆ្នាំមុន បុរសម្នាក់នេះបានជួបប្រទះអ្វីខ្លះក្នុងឆាកជីវិតរបស់គាត់ឡើយ។ បន្ទាប់ពីជួបសន្ទនាអស់មួយសន្ទុះ ទើបដឹងថាគាត់ឈ្មោះ ព្រាំ ណោន ជាអតីតកងទ័ពខ្មែរក្រហម ហើយត្រូវពិការជើងម្ខាងដោយសារតែជាន់មីននៅពេលដែលគាត់ត្រឡប់មកពីដាក់មីនវិញ។


ព្រាំ ណោន

ណោន មានកំណើតនៅភូមិបឹងបាសាក់ ឃុំសំបួរមាស (បច្ចុប្បន្នឃុំកំពង់ចាម) ស្រុកកំពង់ចាម ខេត្តកំពង់ចាម។

ណោន កើតក្នុងត្រកូលកសិករ។ ពេលធំដឹងក្តីគាត់ជួយធ្វើការឪពុកម្តាយ ដូចជាប្រូតស្មៅគោ កាប់ខស មើលប្អូននិងដាំបន្លែ។ ក្រោយពីរដ្ឋប្រហារឆ្នាំ១៩៧០ ពេលមានអាយុ១២ឆ្នាំ ឪពុករបស់ ណោន ក៏បានបញ្ជូនឲ្យទៅរៀននៅវត្តនគរដែលស្ថិតក្នុងភូមិវត្តនគរ ឃុំអម្ពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម និងស្នាក់នៅក្នុងកុដិជាមួយលោក គាលួនជាចៅអធិការវត្ត។ នៅពេលព្រឹក ណោន ត្រូវរៀនបំបែកអក្សរ អានសាស្ត្រាស្លឹករិត ច្បាប់ស្រីនិងច្បាប់ប្រុស ហើយពេលយប់រៀនភាសាបាលីនិងសូត្រធម៌ ដោយមានលោកតា សោម ជាគ្រូបង្រៀន។ ក្រៅពីការសិក្សា ណោន ត្រូវជួយពុះឧសសម្រាប់ដាំទឹក បោសសំរាម និងដើរបិណ្ឌបាត្រជាមួយព្រះសង្ឃនៅតាមភូមិ។

នៅដើមឆ្នាំ១៩៧៣ ភូមិទាំងអស់ក្នុងឃុំអម្ពិលក្លាយទៅជាតំបន់ប្រទាញប្រទង់គ្នារវាងកងទ័ពខ្មែរក្រហម-វៀតកុង និងរដ្ឋាភិបាលលន់ នល់។ ដោយសារស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់បែបនេះ ព្រះចៅអធិការវត្តក៏ប្រកាសឲ្យព្រះសង្ឃនិងគ្រហស្ថនៅក្នុងវត្តចាកចេញទៅនៅផ្ទះរៀងៗខ្លួន។ ណោន ក៏ត្រូវត្រឡប់ទៅជួយធ្វើស្រែឪពុកម្តាយនៅភូមិបឹងបាសាក់វិញ។ ចុងឆ្នាំ១៩៧៣ កងទ័ពខ្មែរក្រហមចូលមកកាន់កាប់ភូមិនេះទាំងមូល ហើយក៏ប្តូរឈ្មោះទៅជាភូមិកោះសន្តិភាព ដោយបញ្ចូលគ្រួសារដែលជាប់សាច់ញាតិកម្មាភិបាលថ្នាក់ធំៗមករស់នៅវិញ។ ចំណែកប្រជាជនដែលរស់នៅក្នុងភូមិត្រូវជម្លៀសទៅនៅភូមិផ្សេងទៀតដូចជាទួលស្រែ ភូមិគរ ភូមិក្រូច និងនៅតាមមាត់ទន្លេជាដើម។ ណោន និងឪពុកម្តាយត្រូវបញ្ជាឲ្យទៅរស់នៅភូមិទួលស្រែ ឃុំក្រគរ ស្រុកកំពង់ចាម។ ប្រធានភូមិឈ្មោះ ពេជ្រ ឈាង មិនអនុញ្ញាតឲ្យគ្រួសារ ណោន រស់នៅក្នុងភូមិទេគឺឲ្យទៅរានព្រៃធ្វើផ្ទះឆ្ងាយពីភូមិ។ គ្រួសារ

ណោន បាននាំគ្នាដើរកាប់កូនឈើឫស្សី និងស្លឹកត្នោតយកមកសង់បានកូនខ្ទមមួយ ។ នៅទីនេះ ណោន បានជួយភ្ជួររាស់ដកស្ទូង ច្រូតកាត់ ឃ្វាលគោ និងដឹកដំឡូង ហើយនៅពេលយប់ដាក់មង ចងសន្ទូចដើម្បីរកប្រាក់មកផ្គត់ផ្គង់គ្រួសារ ព្រោះនៅក្នុងភូមិនេះប្រជាជននៅចាយលុយនៅឡើយ ។

## ជ័យជម្នះថ្ងៃ១៧ មេសា ១៩៧៥

នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនទាំងក្មេងទាំងចាស់ដែលរស់នៅក្នុងភូមិទួលស្រែនាំគ្នាទះដៃហ៊ោកញ្ជៀវស្រែកច្រៀងនិងវាយប៉ោតធ្វើជាបទភ្លេងនៅពេលឮសេចក្ដីប្រកាសតាមវិទ្យុជាតិថា «កងទ័ពខ្មែរក្រហមរំដោះបានទីក្រុងទាំងមូល ហើយប្រទេសជាតិនឹងសម្បូរសប្បាយលែងមានសង្គ្រាមទៀតហើយ» មិនតែប៉ុណ្ណោះថែមទាំងមានចាក់ចម្រៀងជូនពរជាបន្តបន្ទាប់ទៀតផង ។ ក្រុមគ្រួសាររបស់ ណោន នាំគ្នារៀបចំអីវ៉ាន់ដាក់រទេះធ្វើដំណើរត្រឡប់មករស់នៅភូមិបាសាក់វិញ ។ ប៉ុន្តែពេលធ្វើដំណើរមកដល់ភូមិទួលចំប៉ី ប្រធានឈ្មោះ ថុន បានឃាត់ដំណើរឲ្យស្នាក់នៅភូមិនេះមួយរយៈសិន ដោយប្រាប់ថា នៅភូមិបឹងបាសាក់មិនទាន់រៀបចំស្រួលបួលនៅឡើយ ។ ក្រោយមកប្រធានភូមិប្រាប់ឲ្យគ្រួសារ ណោន ប្រមូលយករបស់របរប្រើប្រាស់ដូចជាចានឆ្នាំងគោក្របី រទេះនិងនង្គ័លដាក់រួម ។ ការហូបចុកគឺហូបរួមនៅរោងបាយ ប៉ុន្តែត្រូវសម្រាកនៅផ្ទះរៀងៗខ្លួន ។ មិនយូរប៉ុន្មាន ណោន ត្រូវប្រធានកងបញ្ជូនទៅធ្វើការនៅក្នុងកងចល័តភូមិ ដោយត្រូវភ្ជួររាស់ ច្រូតកាត់ រើសលាមកសត្វធ្វើជី និងច្រូតស្មៅឲ្យគោជាដើម ។

នៅឆ្នាំ១៩៧៦ គ្រួសាររបស់ ណោន ត្រូវប្រធានភូមិអនុញ្ញាតឲ្យមករស់នៅភូមិបាសាក់វិញ ព្រោះជាគ្រួសារអ្នកមូលដ្ឋាន ។ ប៉ុន្តែមិនបានទៅរស់នៅក្នុងផ្ទះចាស់របស់ខ្លួនឡើយ ព្រោះផ្ទះនោះអគ្គការបានរុះរើគ្មានសល់ ។ ទោះជាយ៉ាងណាក៏ខ្មែរក្រហមបានបែងចែកផ្ទះមួយធ្វើពីឫស្សីប្រក់ស្លឹកនៅចុងភូមិឲ្យគ្រួសារ ណោន រស់នៅវិញដែរ ។ នៅទីនេះ ណោន ត្រូវប្រធានកងឈ្មោះ ទាប ជ្រើសរើសឲ្យចូលកងចល័តភូមិនិងចាត់តាំងឲ្យកាប់ឆ្ការព្រៃ លើកភ្លឺស្រែ ដឹកប្រឡាយ ស្ទូងដក និងភ្ជួររាស់ ។

## ចូលបដិវត្តន៍ដំបូង

ថ្ងៃមួយពេលកំពុងច្រូតស្រូវនៅទួលច្រៀក និរសារនៅភូមិក្រឡា ឃុំអម្ពិល ស្រុកកំពង់សៀម មកប្រាប់ថា មានសំបុត្រមួយច្បាប់ផ្ញើមកពីឃុំកោះរកា សុំឲ្យឈ្មោះ ណោន ចូលធ្វើយោធា ។ បន្ទាប់ពីអានសំបុត្រចប់ ណោន បានរៀបចំខោអាវធ្វើដំណើរទៅភូមិក្រឡា ហើយត្រូវបាននិរសារបញ្ជូនបន្តទៅបន្ទាយអន្លង់ញដី ស្រុកកំពង់សៀម ។ ស្នាក់នៅបាន២យប់ គណៈស្រុកកំពង់សៀមឈ្មោះ យាយយ៉ុត បានបញ្ជូន ណោន ទៅកន្លែងប្រមូលផ្ដុំទ័ពតំបន់៤១ នៅម្តុំវត្តតាមៈ ភូមិព្រៃទទឹង ស្រុកព្រៃឈរ ដើម្បីហាត់ក្បួនយុទ្ធសាស្ត្រ ។ មួយសប្ដាហ៍ក្រោយមក ណោន ត្រូវចាត់បញ្ចូលទៅក្នុងវរសេនាតូច៧០៩ ដោយមាន រាប ជាប្រធានវរៈ និង សេន ជាប្រធានកងពលធំ៣០៦ ភូមិភាគឧត្ដរ ។ បន្ទាប់មក ណោន ត្រូវបានបញ្ជូនទៅហាត់ក្បួនយុទ្ធសាស្ត្រថែមទៀត ។ ក្រៅពីនេះ ណោន ត្រូវចុះជួយដឹកប្រឡាយ លើកភ្លឺស្រែនិងកាប់ដីស្ទូង ។ មានពេលខ្លះ ណោន បានកាប់ចំគ្រាប់ពីរ-បីប្រភេទ ប៉ុន្តែមិនបណ្ដាលឲ្យមានគ្រោះថ្នាក់ទេ ។

## នៅសមរភូមិប្រយុទ្ធ

នៅខែសីហា ឆ្នាំ១៩៧៧ ប្រធានវរសេនាតូច៧០៩របស់ ណោន ត្រូវបានចាប់ខ្លួនជាមួយនឹងប្រធានកងពលមួយចំនួនទៀតដូចជា ឈិន និង សី តាមបញ្ជាពី កែ ពក លេខាភូមិភាគឧត្ដរ ដោយចោទប្រកាន់ថាក្បត់ ។ បន្ទាប់ពីអ្នកទាំងនោះត្រូវចាប់ខ្លួន វ៉ាន់ ក៏បានមកជំនួសតំណែងនេះហើយថែមទាំងបញ្ចូល សុន, សេន និងឆាយ មកពីខាងនិរតីគ្រប់គ្រងកងពលនេះ ។ ដោយសារមានការវាយប្រយុទ្ធគ្នារវាងកងទ័ពវៀតណាមនិងកងទ័ពខ្មែរក្រហមតាមបណ្ដោយព្រំដែន នៅខែមករា ឆ្នាំ១៩៧៨ ណោន ត្រូវបញ្ជូនឲ្យទៅឈរជើងនៅបន្ទាយកណ្ដាលជ្រៃក្នុងស្រុកត្បូងឃ្មុំ ។ វ៉ាន់ បានចែកកាំភ្លើងដែលទើបនិងគាស់ចេញពីកេសឲ្យ ណោន មួយដើម រួចចាត់តាំងឲ្យទៅប្រចាំការនៅភូមិត្រពាំងព្រៃពេលយប់ ។ ក្រៅពីការធានាសន្តិសុខ ណោន ត្រូវហាត់លូនក្រាប ដោះកាំភ្លើង និងដោះគ្រាប់បែកនៅបន្ទាយសម្រាប់វាយជាមួយខ្មាំង ។ សិក្ខាកាមដែលបានចូលរួមវគ្គហ្វឹកហ្វឺននេះមានគ្នាសរុបជាង ៣០០នាក់ ក្រោមការបង្ហាត់បង្រៀនពី អ៊ិន វ៉ៃ និងទ្រី ។ ពេលទំនេរ ណោន ចុះជួយប្រជាជនច្រូតស្រូវនិងបោកបែននៅតាមភូមិនានាដូចជា ភូមិកន្ទួត ភូមិកោងកាង និងភូមិស៊ឹង ។

ខែមករា ឆ្នាំ១៩៧៨ វរៈទាំងអស់ត្រូវបញ្ជាឲ្យដកមកប្រមូលផ្តុំនៅបន្ទាយកណ្ដាលជ្រៃវិញ ។ កងទ័ពទាំងអស់ត្រូវធ្វើ

ដំណើរដោយថ្មើរជើងតាំងពីព្រលប់ដល់ជិតភ្លឺទើបទៅដល់សមរភូមិ ជីទ័យថ្មី ស្រុកពញាក្រែក ។ នៅទីនោះ ណោន និងកងទ័ពទាំងអស់ បានជីកលេណដ្ឋានសម្រាប់លាក់ខ្លួន ។ ក្រោយពីរៀបចំរួចរាល់ ហើយ អង្គការបានបែងចែកកងទ័ពជាផ្នែកៗដើម្បីបំពេញការងារ ។ ណោន ត្រូវបញ្ចូលទៅក្នុងកងដឹកជញ្ជូនដែលក្នុងមួយកងមានសមាជិក ៣០នាក់ ដោយមាន ពល ជាប្រធានកង ។ ភារកិច្ចរបស់ ណោន គឺ ជញ្ជូនបាយពំនូតនិងសម្ភៀទៅឲ្យកងទ័ពនៅសមរភូមិមុខ ។ នៅក្នុង កងនេះបានរយៈពេលជាង២ខែ ប្រធានកងឈ្មោះ ពល ប្រាប់ ណោន ឲ្យ «ឡើងប្រយុទ្ធនៅសមរភូមិមុខ ដើម្បីប្តូរវេនឲ្យអ្នកនៅខាង មុខមកមុជទឹកម្តង» ។ ណោន ឡើងវាយពីសមរភូមិមួយទៅសមរភូមិ មួយ តាមរាំ វាលថាស់ រហូតដល់វាលក្រដាស់អស់រយៈពេល២ខែ ទើបផ្លាស់ទៅវាយនៅសមរភូមិត្នោតនិងបន្ទាយស្វាយវិញ ។ រយៈពេល៣យប់៣ថ្ងៃ កងទ័ពខ្មែរក្រហមបាញ់ឆេះរថក្រោះ វៀតណាមមួយគ្រឿងនិងធ្វើឲ្យទាហានវៀតណាមស្លាប់មួយ ចំនួន ។ ចំណែកឈ្លើយសឹកដែលនៅរស់ត្រូវបានចាប់បញ្ជូនមក ព្យាបាលនិងសួរចម្លើយ ។ កងទ័ពខ្មែរក្រហមវិញក៏មានខ្លះស្លាប់ របួស និងត្រូវទាហានវៀតណាមសម្លាប់ចោលនៅនឹងកន្លែងដែរ ដោយខ្លះត្រូវអារ-កនឹងផាងត្នោត ។

### ទៅសមរភូមិផ្គាវ

នៅដើមខែមេសា ឆ្នាំ១៩៧៨ ណោន ផ្លាស់ទៅវាយ នៅសមរភូមិផ្គាវ ។ ថ្ងៃទី១៣ ក្នុងខែឆ្នាំដដែល បន្ទាប់ពីប្រយុទ្ធគ្នា ជាមួយវៀតណាម មេកងបានចាត់តាំង ណោន និងមិត្តភក្តិម្នាក់ ទៀតទៅដាក់មីនបីគ្រាប់ក្នុងពេលយប់នៅតាមបណ្តោយខ្សែត្រៀម និងតាមផ្លូវរថក្រោះរបស់ខ្មាំង ។ ពេលត្រឡប់មកវិញមេឃងងឹត មើលអ្វីលែងឃើញ ធ្វើឲ្យគាត់និងមិត្តភក្តិរបស់គាត់វង្វេងផ្លូវ ហើយដើរជាន់មីនបណ្តាលឲ្យដាច់ជើងម្ខាង ចំណែកមិត្តភក្តិរបស់ គាត់ដែលត្រូវរបួសស្រាលបានរត់ទៅបន្ទាយដើម្បីនាំកម្លាំងមក ជួយសង្គ្រោះ ។ ម៉ោង៣ទៀបភ្លឺ ទើបមានមនុស្សមកសែង ណោន ត្រឡប់មកបន្ទាយ ។ ពេទ្យចាប់ផ្តើមរុំរបួសរួចដាក់តាមឡាន បញ្ជូន មកពេទ្យចុងអង្រ្គង (ពេទ្យកងពល)ក្នុងស្រុកអូររាំងឪ ។ គ្រូពេទ្យ បានចាក់ថ្នាំស្ពឹកឲ្យគាត់ រួចយករណារអារកាត់ជើងដែលរបួសនោះ ចេញ ។ មួយថ្ងៃបន្ទាប់ ណោន ត្រូវបញ្ជូនបន្តទៅព្យាបាលនៅពេទ្យ ភូមិភាគឧត្តរក្នុងទីរួមខេត្តកំពង់ចាម ។ ដោយសារមុខរបួសរលួយ ពេទ្យនៅទីនោះបានសម្រេចចិត្តកាត់ជើងរបស់គាត់ម្តងទៀត ។ ប៉ុន្តែរបួសនេះនៅតែរលួយដដែល ពេទ្យភូមិភាគក៏សម្រេចបញ្ជូន ណោន តាមរថយន្តមកព្យាបាលនៅភ្នំពេញបន្តទៀត ។

### នៅពេទ្យ១៧មេសា (ពេទ្យរុស្ស៊ី)

ណោន សម្រាកនៅមន្ទីរពេទ្យ១៧មេសា នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៨ ដែលមាន ជួន ជឿន ប្រធានពេទ្យធំនៅទីនោះ ។ ណោន ត្រូវបានបញ្ជូនទៅសម្រាកនៅក្នុងបន្ទប់សង្គ្រោះបន្ទាន់ជាន់ ទី២ ក្នុងបន្ទប់នោះមានវេជ្ជបណ្ឌិតជាតិចិនម្នាក់ជាអ្នកព្យាបាល ជើងរបស់គាត់ ។ ពេលពិនិត្យរួច វេជ្ជបណ្ឌិតនោះបានប្រាប់ទៅ អ្នកបកប្រែថា មិនល្អនិងឲ្យកត់ត្រាលើក្រដាសសម្គាល់នៅចុងគ្រែ របស់ ណោន ។ កន្លះម៉ោងក្រោយមក គ្រូពេទ្យជនជាតិខ្មែរបាន យកប្រង់កាមកសែង ណោន ទៅដាក់បន្ទប់វះកាត់ ។ ណោន ដឹងខ្លួន ឯងថា គាត់ត្រូវកាត់ជើងម្តងទៀត ។ ណោន «បានសុំអង្វរគ្រូពេទ្យ នោះថាកុំកាត់ជើងខ្ញុំខ្លីពេក» ប៉ុន្តែគ្រូពេទ្យមិនបាននិយាយអ្វីទេ ដោយដំបូងគ្រូពេទ្យខ្មែរចាប់ផ្តើមចាក់ថ្នាំសន្លប់ បន្ទាប់មកមាន វេជ្ជបណ្ឌិតជាតិចិនបីនាក់ទៀតជាអ្នកវះកាត់ ។ ក្រោយពីវះកាត់ រួច ពេទ្យចាប់ផ្តើមបញ្ចូលឈាមបន្ថែម (ឈាមបានមកពីកម្មករ ដែលធ្វើការនៅតាមរោងចក្រក្នុងទីក្រុងភ្នំពេញ) រួចបញ្ជូនគាត់ទៅ បន្ទប់អ្នកជំងឺដែលពោរពេញទៅដោយអ្នករបួសមកពីភូមិភាគ ផ្សេងៗទូទាំងប្រទេស ។ នៅទីនោះ ណោន ទទួលបានរបបអាហារ បីពេលក្នុងមួយថ្ងៃ ពេលព្រឹកហូបបបរ ពេលថ្ងៃហូបបាយ និង ពេលល្ងាចហូបបាយ បន្ថែម ទឹកដោះគោ និងស្ករស ។ ដោយសារ ណោន មិនអាចហូបបានដោយខ្លួនឯង មានពេទ្យនារីម្នាក់នៅប្រចាំ ការថែរក្សា លាងរបួស ចាក់ថ្នាំ និងចាំបញ្ចុកបាយ ។ ជារឿយៗ ណោន ឃើញមានគណៈប្រតិភូមកពីប្រទេសចិននិងប្រទេសថៃមក ទស្សនកិច្ចនៅក្នុងពេទ្យនិងដើរពិនិត្យមើលអ្នករបួសជាមួយនឹង វេជ្ជបណ្ឌិត ជួន ជឿន ។ រយៈពេល៤ខែទើប ណោន បានជាសះ ស្បើយអាចងើបអង្គុយនិងហូបបាយដោយខ្លួនឯង ។ បន្ទាប់មក ពេទ្យចាប់ផ្តើមឲ្យ ណោន រៀនដើរតោងបង្កាន់ដៃតិចៗ ។ នៅអំឡុង ពេលសម្រាកព្យាបាលនោះ ណោន បានឃើញអ្នករបួសម្នាក់ ក្រោយពីវះកាត់រួចស្លាប់ដោយសារពេទ្យ ភ្លេចកំប្រេះនៅក្នុង ពោះ ។ ក្រោយមកថ្នាក់លើស្រាវជ្រាវដឹង ក៏ចាប់ខ្លួនពេទ្យដែល វះកាត់នោះ ហើយចោទប្រកាន់ថា ជាពួកបូព៌ា មានផែនការក្បត់

ព្រោះពេលនោះខាងភូមិភាគបូព៌ាកំពុងបះបោរនិងផ្ទុះអាវុធនៅភាគខាងកើតក្នុងខេត្តកំពង់ចាម ចំណែកពេទ្យផ្សេងទៀតដែលមិនពាក់ព័ន្ធ ប៉ុន្តែមកពីខាងបូព៌ាដែរ ក៏ត្រូវបានដកចេញ រួចបញ្ជូនទៅធ្វើស្រែអំបិលទាំងអស់ រួចផ្លាស់ពេទ្យពីតាកែវនិងកំពតមកជំនួសវិញ ។ អ្នករបួសមកពីខាងភូមិបូព៌ាដែលកំពុងសម្រាកព្យាបាលក៏ត្រូវបញ្ជូនទៅតាខ្មៅទាំងអស់ ។

**នៅពេទ្យ៦មករា**

នៅខែតុលា ឆ្នាំ១៩៧៨ ពេទ្យបានមកប្រាប់ ណេន ថាជំងឺរបស់គាត់បានធូរស្រាលជាងមុន ហើយត្រូវតែផ្លាស់ទៅព្យាបាលនៅមន្ទីពេទ្យ៦មករាវិញ ពីព្រោះជាកន្លែងសម្រាប់ព្យាបាលអ្នកជំងឺស្រាល ។ ណេន សម្រាកនៅបរិវេណអ្នកជំងឺទូទៅដែលមានគ្រែគម្រៀបគ្នា មានគ្រូពេទ្យដើរឲ្យថ្នាំលេប ចាក់ថ្នាំ និងផ្តល់របបអាហារបីពេលក្នុងមួយថ្ងៃ ហើយរបបអាហារនេះអាចសុំបន្ថែមបានទៅតាមសេចក្តីត្រូវការរបស់អ្នកជំងឺ ។ នៅទីនេះ ណេន បានឃើញ ខៀវ សំផន និងភ្ញៀវចិនមួយចំនួនក្នុងពេលធ្វើពិធីមីទ្ទីង ។ ខៀវ សំផន បានឡើងថ្លែងសុន្ទរកថា អំពីការរីកចម្រើនខាងវិស័យកសិកម្ម ការលើកប្រព័ន្ធភ្លឺស្រែ ប្រព័ន្ធប្រឡាយនិងអាងស្តុកទឹក ។ លើសពីនេះទៀត គាត់លើកឡើងពីការឈ្លានពានលេបទឹកដីរបស់វៀតណាមដោយបង្ហាញផែនទីដែលវៀតណាមចូលក្នុងទឹកដីខ្មែរ និងបញ្ចាំងភាពយន្តឯកសារស្តីពីការវាយលុករបស់កងទ័ពវៀត-ណាមផង ។ ក្រោយពីព្យាបាលនៅទីនេះមួយរយៈ ស្ថានភាពជំងឺរបស់គាត់កាន់តែប្រសើរជាងមុន ដោយគាត់អាចដើរកាន់ឈើច្រត់និងហូបបាយដោយខ្លួនឯងបាន ។

**ត្រឡប់ទៅកំពង់ចាម**

នៅពាក់កណ្តាលខែ១១ ពេទ្យបានអនុញ្ញាតឲ្យ ណេន ត្រឡប់ទៅបន្ទាយស៊ុបវិញ ។ នៅទីនោះ ណេន ត្រូវអង្គុយរង់ចាំរហូតថ្ងៃត្រង់ ទើបមាននិរសារម្នាក់ហៅគាត់ទៅហូបបាយ ។ និរសារនោះបានសួរ ណេន ថា÷ ចង់ទៅនៅកន្លែងពិការទេ? ណេន ប្រាប់ទៅវិញថា គាត់មិនចង់ទៅនៅកន្លែងពិការទេ ចង់ទៅសម្រាកនៅពេទ្យវិញ ។ និរសារនោះក៏ដឹកគាត់ទៅដាក់នៅពេទ្យកងពល៣០៧ ដែលនៅទីនោះ ណេន ត្រូវបន្តការព្យាបាលនិងចាក់ថ្នាំដូចពីមុនៗ ។ នៅដើមខែធ្នូ ពេទ្យបានបញ្ជូន ណេន ទៅមន្ទីរជនពិការដែលមានទីតាំងនៅក្នុងវត្តថ្មគោល ស្រុកកំពង់សៀម ក្រោមការគ្រប់គ្រងរបស់គណៈស្រុកឈ្មោះ ជា ។ ស្នាក់នៅបានកន្លះខែអង្គការចាប់ផ្តើមបែងចែកជនពិការទៅនៅតាមតំបន់ ដោយហេតុថាកងទ័ពវៀតណាមវាយចូលដល់ជប់ ហើយនិងកំពុងវាយចូលបន្តមកទៀត ។ ណេន ត្រូវបញ្ជូនទៅនៅព្រៃទទឹង បន្ទាប់មកផ្លាស់ទៅនៅអន្លង់ញជីនិងវិហារធំ ។ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមវាយចូលដល់ទីរួមខេត្តកំពង់ចាមទាំងមូលនិងវាយតាមបណ្តោយផ្លូវជាតិឆ្ពោះទៅកាន់ទីក្រុងភ្នំពេញ ។ ណេន និងជនពិការមួយចំនួន ព្រមទាំងគណៈស្រុកឈ្មោះ ជា បានរត់ភៀសខ្លួនទៅក្តុលស្ថិតនៅខាងជើងព្រែកក្តាម ។ បន្តិចក្រោយមកស្រាប់តែឮសំឡេងហ៊ោកញ្ជ្រៀវនិងការប្រកាសពីជ័យជម្នះរបស់កងទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជាពីប៉ុស្តិ៍វិទ្យុទីក្រុងភ្នំពេញ ។ ដោយសារកងទ័ពខ្មែរក្រហមទទួលបរាជ័យ ជា ដែលជាគណៈស្រុកបានប្រាប់ឲ្យជនពិការវិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ។

**វិលត្រឡប់មករស់ក្នុងភូមិកំណើត**

ក្រោយថ្ងៃ៧ មករា ១៩៧៩ ណេន បានវិលត្រឡប់មករស់នៅជួបជុំឪពុកម្តាយនិងបងប្អូនដែលស្ថិតនៅក្នុងឃុំសំបួរ (បច្ចុប្បន្នស្ថិតក្នុងឃុំកំពង់ចាម) ស្រុកកំពង់ចាម ។ ពិតមែនតែពីមុន ណេន ធ្លាប់ចូលតស៊ូធ្វើកងទ័ពខ្មែរក្រហមរហូតដល់ពិការជើងម្ខាងមែន ប៉ុន្តែ ណេន នៅតែទទួលបានការស្រឡាញ់រាប់អាននិងអាណិតអាសូរពីប្រជាជនគ្រប់គ្នានៅក្នុងភូមិដដែល ។ ទោះជាយ៉ាងណា ណេន នៅតែតូចចិត្តនិងអស់សង្ឃឹមក្នុងជីវិតដោយសារតែពិការជើង ។ ណេន ហាក់ដូចជាមនុស្សវង្វេងស្មារតីលែងខ្វល់ខ្វាយអ្វីទាំងអស់ ទោះបីមានការលើកទឹកចិត្តពីអ្នកភូមិដែលរស់នៅជាមួយគ្នាក្តី ។ នៅឆ្នាំ១៩៨៣ ដោយឃើញស្ថានភាពដូច្នេះ ឪពុកម្តាយរបស់ ណេន បានបញ្ជូនគាត់ទៅរៀនមុខជំនាញជួសជុលកង់នៅខេត្តកំពង់ចាម ។ មុខរបរនេះអាចជួយឲ្យ ណេន រកប្រាក់ចំណូលបានជាមធ្យមអាចឲ្យគាត់ចិញ្ចឹមឪពុកម្តាយចាស់ជរាបាន ។ ឆ្នាំ១៩៩៣ ណេន បានចាប់ចិត្តស្រឡាញ់ស្ត្រីមេម៉ាយកូនបួនឈ្មោះ ទូន យាម ដែលរស់នៅក្នុងភូមិឃុំជាមួយគ្នា ហើយក៏បានសុំឪពុកម្តាយចូលស្តីដណ្តឹងនិងរៀបការតាមប្រពៃណី ។ សព្វថ្ងៃនេះ ណេន មានកូន៣នាក់ និងបន្តមុខរបរជាជាងធ្វើកង់និងដាំដំណាំបន្តិចបន្តួច សមល្មមសម្រាប់គ្រួសារនិងឧបត្ថម្ភកូនឲ្យបានទៅរៀនគ្រប់ៗគ្នា ។ **សោម ប៊ុនថន**

# គុកខ្មែរក្រហម

## ខេត្តពោធិសាត់

### ស្រុកបាកាន

### ១) មន្ទីរសន្តិសុខស្វាយជ្រុំ ឬ បឹងបត់កណ្តាល

មន្ទីរសន្តិសុខស្វាយជ្រុំ ឬបឹងបត់កណ្តាលស្ថិតនៅក្នុងឃុំបឹងបត់កណ្តាល ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ មន្ទីរនេះបង្កើតឡើងដោយខ្មែរក្រហមនៅឆ្នាំ១៩៧៥ ដើម្បីឃុំឃាំងប្រជាជនមូលដ្ឋាន មន្ត្រីរាជការនិងទាហាននៃរបបសាធារណរដ្ឋខ្មែរនិងប្រជាជនជម្លៀសមកពីខេត្តព្រៃវែង ស្វាយរៀង ស្រុកក្រគរ និងស្រុកពោធិ៍សាត់ ។

ចាន់ ប៉េង អាយុ៥៦ឆ្នាំ បាននិយាយថា គាត់បានឃើញកងសន្តិសុខបញ្ជូនអ្នកទោសមកកាន់មន្ទីរសន្តិសុខនេះជារៀងរាល់ថ្ងៃ ។ នៅ សាន អតីតរដ្ឋអំណាចភូមិដូងជ្រុំកាលពីឆ្នាំ១៩៧៧ ហើយក្រោយមកជាសមាជិកសហករណ៍ភូមិព្រៃផ្តៅបានបញ្ជាក់ប្រាប់ថា តាឃឹន ជាប្រធានសន្តិសុខបឹងបត់កណ្តាល ។

### ស្រុកកណ្តៀង

### ២) មន្ទីរសន្តិសុខទួលពោធិ៍ជ្រៃ ឬ បន្ទាយពោធិ៍ជ្រៃ

ទួលពោធិ៍ជ្រៃ ជាអតីតបន្ទាយទាហានជំនាន់សាធារណរដ្ឋខ្មែរដែលកសាងឡើងតាំងពីឆ្នាំ១៩៧០ ម៉េះ ។ កាលនោះឈ្មោះ នន ជា ជាអ្នកគ្រប់គ្រងបន្ទាយទាំងមូល ។ ទីតាំងនេះស្ថិតនៅក្នុងភូមិព្រីងខ្ពស់ ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ។

នៅក្នុងរបបខ្មែរក្រហមទួលពោធិ៍ជ្រៃ ជាមន្ទីរសន្តិសុខសម្រាប់ឃុំឃាំងអ្នកទោសរយៈពេលខ្លី និងជាទីតាំងសម្រាប់មនុស្សដែលកងឈ្លបចាប់មកពីគ្រប់ទីកន្លែងក្នុងស្រុកកណ្តៀងទាំងមូល ។ ដោយសារតែគ្មានកន្លែងគ្រប់គ្រាន់សម្រាប់ដាក់អ្នកទោស កងសន្តិសុខបានឲ្យអ្នកទោសនៅក្រោមម្លប់ដើមពោធិ៍និងដើមជ្រៃជាបណ្តោះអាសន្នសិន ។ មន្ទីរសន្តិសុខនេះមានរបង៤ជាន់ កម្ពស់រហូតដល់ទៅ៣ម៉ែត្រ ធ្វើឡើងការពារមិនឲ្យអ្នកទោសលួចរត់ចេញ ។ អណ្តូងទឹកធំមួយនៅខាងក្នុងបរិវេណបន្ទាយនេះដែលទាហានសាធារណរដ្ឋខ្មែរធ្លាប់យកទឹកមកប្រើប្រាស់ បានក្លាយទៅជារណ្តៅកប់សាកសពអ្នកទោសក្នុងសម័យខ្មែរក្រហមទៅវិញ ។

នៅឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៦ មានអ្នកទោសចៅហ្វាយខេត្តពោធិ៍សាត់ ពលទាហាន នាយទាហាន នាយទាហានរង មន្ត្រីរដ្ឋការ គ្រូបង្រៀន សាស្ត្រាចារ្យ ពេទ្យ ប្រជាជនដែលមានជាប់និន្នាការនយោបាយពីសង្គមមុននិងក្រុមកុម្ម៉ង់ដូទូទាំងខេត្តពោធិ៍សាត់ ត្រូវខ្មែរក្រហមដឹកតាមរថយន្តធំៗមកកាន់បន្ទាយពោធិ៍ជ្រៃដើម្បីសម្លាប់ចោល ។

លុះដល់ឆ្នាំ១៩៧៧ដល់ឆ្នាំ១៩៧៨ ប្រជាជនដែលអង្គការជម្លៀសមកពីខេត្តស្វាយរៀង និងខេត្តព្រៃវែង ត្រូវកងឈ្លបចាប់បញ្ជូនមកកាន់មន្ទីរសន្តិសុខបន្ទាយពោធិ៍ជ្រៃដើម្បីឃុំឃាំងនិងសម្លាប់ចោលជាបន្តបន្ទាប់តាមវិធីប្រើកាំភ្លើងយន្តបាញ់រះរួចយកគ្រាក់ទ័ររុញសាកសពទម្លាក់ក្នុងរណ្តៅ ។



សកម្មភាពប្រជុំមន្ត្រីនៅក្នុងសាលាខេត្ត

### ៣) មន្ទីរសន្តិសុខក្បាលឈើពុក ឬ មន្ទីរ ស-៨

ក្បាលឈើពុកស្ថិតនៅក្នុងភូមិក្បាលឈើពុក ឃុំស្យា ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ ។

ភាគច្រើនជាប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញ ខេត្តតាកែវ ខេត្តព្រៃវែង និងខេត្តស្វាយរៀង ត្រូវបានខ្មែរក្រហមសម្លាប់នៅក្នុងភូមិក្បាលឈើពុក ឃុំស្យា ស្រុកកណ្ដៀង ។ សាក្សីនិយាយថា ទោះជាការធ្វើទារុណកម្មអ្នកទោសមានកម្រិតធ្ងន់ខ្លះនិងស្រាលខ្លះ នៅក្នុងមន្ទីរសន្តិសុខក្បាលឈើពុកយ៉ាងណាក៏ដោយ ក៏អ្នកទាំងនោះគង់តែស្លាប់ដូចគ្នា ។ ការសម្លាប់មនុស្សនៅក្នុងភូមិក្បាលឈើពុកបានប្រព្រឹត្តឡើងតែក្នុងរយៈពេលមួយថ្ងៃប៉ុណ្ណោះ ។


បូជនីយដ្ឋាននៅខេត្តពោធិសាត់

ញឹក ប៉ាន់ អាយុ៥៣ឆ្នាំ រស់នៅភូមិបឹងចក ឃុំស្យា ស្រុកកណ្ដៀង និយាយថា ក្នុងរយៈពេលមួយថ្ងៃគត់ដែលកងសន្តិសុខខ្មែរក្រហមសម្លាប់មនុស្សអស់ជាង៨០០នាក់ ។ ម៉ុក នី ក៏ត្រូវនាំយកមកសម្លាប់នៅទីតាំងនេះដែរ ប៉ុន្តែមិនស្លាប់ ហើយបច្ចុប្បន្នគាត់រស់នៅទីក្រុងភ្នំពេញ ។ ញឹក ប៉ាន់ បានរំឭកសម្ដីរបស់ ម៉ុក នី ថា «វា (ម៉ុក នី) ធ្វើពុតជាស្លាប់នៅពេលដែលកងឈ្លបខ្មែរក្រហមយកដំបងវាយវាយ៉ាងខ្លាំងលើមាត់រណ្ដៅជាមួយអ្នកឯទៀត» ។ កាលនោះ ម៉ុក នី ស្ថិតក្នុងសភាពរបួសយ៉ាងធ្ងន់ ព្រោះលលាដ៍ក្បាលរបស់គាត់ត្រូវបែកនិងហូរឈាមយ៉ាងច្រើន ។ ម៉ុក នី ខំប្រឹងព្យាយាមវារចេញពីគំនរសាកសពទាំងត្រដាបត្រដួសក្នុងពេលរាត្រី ។ ញឹក ប៉ាន់ និយាយថា «ខ្ញុំភ្ញាក់ព្រើត នៅពេលដែលឃើញវាលូនមកដល់ខ្ទមរបស់ខ្ញុំទាំងកណ្ដាលអធ្រាត្រ» ។

ការសម្លាប់មនុស្សនៅភូមិក្បាលឈើពុកនេះបានប្រព្រឹត្តទៅនៅពេលយប់ ហើយក៏គ្មានសម្លាប់ទៀតដែរ នៅពេលក្រោយមក ។ អ្នកទោសដែលត្រូវខ្មែរក្រហមសម្លាប់ទាំងអស់ហើយមួយចំនួនជាអ្នកទោសដែលកងសន្តិសុខបញ្ជូនមកពីមន្ទីរសន្តិសុខភូមិក្បាលឈើពុក ដែលមានឈ្មោះ ឈាង សព្វថ្ងៃរស់នៅ (ភូមិផ្លាអម្ពិល) ឃុំអន្លង់វិល ស្រុកកណ្ដៀង ឈ្មោះ ជៅ (បច្ចុប្បន្នស្លាប់) និងឈ្មោះ មី (បាត់ខ្លួន) ជាជនដៃដល់ ។

### ៤) មន្ទីរសន្តិសុខទួលតាប៉េវ ឬ មន្ទីរស-៧

មន្ទីរសន្តិសុខនិងទីតាំងសម្លាប់ទួលតាប៉េវ ឬមន្ទីរ ស-៧ ស្ថិតនៅភូមិផ្លូវពោធិវង្ស ឃុំស្វាយលួង ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ ។ បរិវេណជុំវិញមន្ទីរសន្តិសុខត្រូវអង្គការហាមមិនឲ្យប្រជាជនណាម្នាក់ទៅក្បែរឡើយ ។ ប្រជាជនប្រហែលពី៣០០ទៅ៥០០នាក់ ត្រូវកងឈ្លបចាប់ខ្លួនមកដាក់មន្ទីរសន្តិសុខទួលតាប៉េវ ហើយនាំយកទៅសម្លាប់ចោលនៅជុំវិញមន្ទីរតែម្ដង ។ ហែម ជា ភេទប្រុស អាយុ៤៦ឆ្នាំ រស់នៅភូមិផ្លូវពោធិ៍វង្ស ឃុំស្វាយលួង ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ បានប្រាប់ថា មូលហេតុដែលខ្មែរក្រហមនាំយកប្រជាជនមកដាក់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខនេះ ព្រោះអ្នកទាំងនោះខ្ជិលច្រអូស មិនប្រឹងប្រែងធ្វើការងារ ។

កម្មាភិបាលខ្មែរក្រហមដែលធ្វើការនៅក្នុងមន្ទីរសន្តិសុខទួលតាប៉េវរួមមាន ហួយ ប៊ិល និង ផន ។ ហួយ និង ប៊ិល បានបាត់ខ្លួន ចំណែក ផន បច្ចុប្បន្នជាជនពិការដៃម្ខាង រស់នៅក្នុងភូមិស្ពោជ្រៃ ឃុំស្រែស្ដុក ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ ។ ក្រៅពី

អ្នកទាំងបី មានកម្មាភិបាលមួយចំនួនទៀត ប៉ុន្តែមិនចាំឈ្មោះ ដែលបច្ចុប្បន្នមិនដឹងរស់នៅកន្លែងណា ។

## ស្រុកក្រគរ

### ៥) មន្ទីរសន្តិសុខទួលលៀប

ទួលលៀប ជាឈ្មោះទីតាំងមួយស្ថិតក្នុងឃុំបឹងកន្ទួត ស្រុកក្រគរ ខេត្តពោធិ៍សាត់ ត្រូវខ្មែរក្រហមបង្កើតឡើងនិងដាក់ឈ្មោះថា មន្ទីរសន្តិសុខទួលលៀប ។ មន្ទីរនេះកសាងឡើងតាំងពីឆ្នាំ ១៩៧៦ ហើយត្រូវបញ្ចប់នៅចុងឆ្នាំ១៩៧៨ ។ ញ៉ែម ឌុល ជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខទួលលៀបនិងបច្ចុប្បន្នរស់នៅភូមិជ្រលង ឃុំអន្លង់ត្នោត ស្រុកក្រគរបាននិយាយថាក្នុងរយៈពេលពីរខែចុងក្រោយនៃឆ្នាំ១៩៧៨ គាត់ត្រូវកងសន្តិសុខចាត់តាំងឲ្យទទួលការងារជាអ្នកកប់សាកសពអ្នកទោសនៅមន្ទីរសន្តិសុខទួលលៀប ។ ឌុល បានប៉ាន់ស្មានពីចំនួនសាកសពទាំងអស់ថាមានប្រហែល៤.០០០នាក់ បូករួមទាំងប្រជាជនជាច្រើនទៀតដែលខ្មែរក្រហមបាននាំយកមកសម្លាប់នៅទួលលៀបដែរ ។

### ៦) មន្ទីរសន្តិសុខតាវិត

តាវិត ជាឈ្មោះរបស់មន្ទីរសន្តិសុខនិងកន្លែងសម្លាប់មនុស្សមួយស្ថិតក្នុងភូមិត្រពាំងកន្ទួត ឃុំបឹងកន្ទួត ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។ អ្នកទោសដែលជាប់នៅក្នុងមន្ទីរសន្តិសុខនេះត្រូវខ្មែរក្រហមចាប់យកមកពីសហករណ៍នានាក្នុងស្រុកក្រគរ ដែលមានទាំងអាចារ្យវត្ត ប្រជាជនជម្លៀស ប្រជាជនមូលដ្ឋាន អ្នកជាប់ពូជពង្សត្រកូលអភិជន ខ្មែរស្រឡាយចិន យួន និងចាម ។ ការសម្លាប់អ្នកទោសច្រើនប្រព្រឹត្តទៅនៅពេលយប់ដើម្បីបិទបាំងកុំឲ្យប្រជាជនដឹង ។

ញ៉ែម ឌុល បាននិយាយថា មន្ទីរតាវិតគ្មានបន្សល់ទុកវត្ថុតាងអ្វីមួយឡើយរហូតដល់បច្ចុប្បន្ននេះ ក្រៅតែពីដីព្រៃមានដើមឈើល្អិតល្អោចដុះស្អេកស្កុះប៉ុណ្ណោះ ។


មន្ទីរសន្តិសុខវត្តកណ្ដាល

ចំនួនជនរងគ្រោះដែលត្រូវកងសន្តិសុខសម្លាប់គឺមានពី១០០ ទៅ១៥០នាក់ ។

### ៧) មន្ទីរសន្តិសុខអណ្ដូងតាប៉ក់

មុនខ្មែរក្រហមអណ្ដូងទឹកនេះជាកម្មសិទ្ធរបស់តាប៉ក់ ។ អណ្ដូងទឹកនេះមានទីតាំងនៅក្នុងភូមិសំរោង ឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់ ត្រូវខ្មែរក្រហមយកធ្វើជាកន្លែងសម្លាប់មនុស្ស ។ នៅជុំវិញអណ្ដូងនេះគឺជាមន្ទីរសន្តិសុខដែលមានឃុំឃាំងអ្នកទោសប្រមាណពី១០០ទៅ១៥០នាក់ ។ ក្រោយមកអ្នកទោសទាំងនេះត្រូវកងសន្តិសុខនាំយកទៅសម្លាប់ទម្លាក់ក្នុងអណ្ដូងទឹកតាប៉ក់និងអណ្ដូងទឹកពីរទៀតដែលស្ថិតនៅក្បែរៗនោះ ។ អ៊ិន សាវី ប្រធានការិយាល័យវប្បធម៌ស្រុកក្រគរនិយាយថា គាត់ពួននៅលើដើមត្នោតលបមើលឃើញកងសន្តិសុខសម្លាប់អ្នកទោសនៅទីតាំងអណ្ដូងតាប៉ក់នេះ ។ ប៉ុន្តែ បច្ចុប្បន្នទីតាំងនេះបានត្រូវអាជ្ញាធរកសាងជាមន្ទីរពេទ្យប្រចាំស្រុកក្រគរ ។

## ស្រុកភ្នំក្រវាញ

### ៨) មន្ទីរសន្តិសុខវត្តកណ្ដាល

វត្តកណ្ដាលដែលស្ថិតនៅក្នុងភូមិគល់ទទឹង ឃុំសន្ទ្រែ ស្រុកក្រវាញ ត្រូវបានខ្មែរក្រហមយកធ្វើជាមន្ទីរសន្តិសុខប្រចាំឃុំ ដោយយកកុដិលោកសង្ឃធ្វើជាមន្ទីរឃុំឃាំងនិងសួរចម្លើយ ។ អ្នកទោសទាំងអស់ត្រូវកងសន្តិសុខធ្វើទារុណកម្មនិងសម្លាប់ចោល

គ្មានប្រណី ។ សុខ សាន ជាអនុសេនីយ៍ឯកការិយាល័យទី៥នៃកងពលធំលេខ៨ ប្រចាំខេត្តពោធិ៍សាត់បាននិយាយថា នៅឆ្នាំ១៩៧៥ គាត់ត្រូវខ្មែរក្រហមជម្លៀសមកកាន់ខេត្តពោធិ៍សាត់ ហើយនៅខែមករា ឆ្នាំ១៩៧៨ គាត់ត្រូវកងឈ្លបចាប់ខ្លួនមកដាក់នៅក្នុងមន្ទីរសន្តិសុខវត្តកណ្តាលដោយមិនដឹងពីមូលហេតុ ។ សុខ សាន សង្កេតឃើញថាមានអ្នកទោសច្រើននាក់ណាស់លាយចម្រុះគ្នាទាំងប្រជាជនជម្លៀស ប្រជាជនមូលដ្ឋាន និងកម្មាភិបាលខ្មែរក្រហមដូចជា គណៈស្រុក ប្រធានពាណិជ្ជកម្មតំបន់ជាដើម ។

ឈឹម លន់ អាយុ៦៦ឆ្នាំ មានស្រុកកំណើតនៅឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាលបាននិយាយថា ខ្លួនគាត់ត្រូវខ្មែរក្រហមចាប់យកមកដាក់ឃុំឃាំងនៅវត្តកណ្តាលពីបទមើលងាយអង្គការ ។ ប៉ុន្តែតាមពិត ឈឹម លន់ គ្រាន់តែបំពេញភារកិច្ចមិនបានសម្រេចតាមផែនការដែលអង្គការដាក់ចុះប៉ុណ្ណោះ ។ អ្នកទោសទាំងអស់ត្រូវកងសន្តិសុខសម្លាប់ស្ទើរគ្មានសល់នៅជុំវិញបរិវេណវត្តកណ្តាល ។ សុខ សាន និងអ្នកទោសប្រមាណ២៦០នាក់ទៀត ត្រូវកងសន្តិសុខចងភ្ជាប់គ្នា រួចបណ្តើរយកទៅសម្លាប់នៅចុងឆ្នាំ១៩៧៨ ។ ប៉ុន្តែគាត់បានរួចខ្លួនមកវិញ ដោយសារកើតមានចលាចលរវាងអតីតគណៈស្រុកខ្មែរក្រហមឈ្មោះ ម៉ាល់ និងកងសន្តិសុខដែលជាជនដៃដល់ ។ សាន រំឭកថា មុនពេលគាត់រត់ចេញពីកន្លែងសម្លាប់ គាត់បានឃើញអ្នកទោសមួយចំនួនត្រូវកងឈ្លបសម្លាប់រួចស្រេច ដោយវាយនឹងដំបងព្រនង់ ចាក់នឹងកាំបិត និងចំពុះទុងកាំភ្លើង ។



មន្ទីរសន្តិសុខបន្ទាយអាទៀរី

ឈឹម លន់ ត្រូវជាប់ឃុំឃាំងនៅវត្តកណ្តាលអស់រយៈពេលជាងមួយឆ្នាំ គិតមកដល់ថ្ងៃរំដោះ ខែមករា ឆ្នាំ១៩៧៩ ។ យាយ មុំ ត្រូវជាប់ឃុំឃាំងអស់រយៈពេលជាងបីខែ បន្ទាប់ពីគាត់បេះផ្លែល្ហុងដែលគាត់បានដាំមួយផ្លែយកមកស្ល ។ ប្រជាជនជាច្រើននាក់ទៀតក៏ជាប់ឃុំឃាំងនៅក្នុងគុកវត្តកណ្តាលនេះ ដោយសារតែរឿងកំប៉ិកកំប៉ុកដូចយាយមុំដែរ ។

ឡុក ជាប្រធានសន្តិសុខនៅវត្តកណ្តាល ហើយ ចាន់ ជាអនុប្រធាន ។ សព្វថ្ងៃ ចាន់ រស់នៅភូមិព្រែក១ ឃុំសំរោង ស្រុកភ្នំក្រវាញ ។ ម៉េត ជុំ និង ប៉ត ដែលជាកងសន្តិសុខបានសម្លាប់មនុស្សអស់ជាច្រើននាក់ ។ ឈឹម លន់ បានប្រាប់ថា អ្នកទាំងបីនេះបានសម្លាប់អ្នកទោសអស់ជាង៣.០០០នាក់នៅជុំវិញបរិវេណវត្តកណ្តាល ។

## ស្រុកសំពៅមាស

### ៩) មន្ទីរសន្តិសុខបន្ទាយអាទៀរី

បន្ទាយអាទៀរី ជាបន្ទាយទាហានរបស់ខេត្តពោធិ៍សាត់ នាពេលបច្ចុប្បន្នដែលស្ថិតនៅក្នុងភូមិព្រៃញី ឃុំព្រៃញី ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ។ នៅក្នុងអំឡុងឆ្នាំ១៩៧៦ ខ្មែរក្រហមបានយកទីតាំងនេះធ្វើជាមន្ទីរសន្តិសុខ ។ ប៉ុន្តែនៅចុងឆ្នាំ១៩៧៨ មន្ទីរសន្តិសុខនេះត្រូវបាត់បង់អត្ថិភាពបន្ទាប់ពីមានការផ្លាស់ប្តូររបបនយោបាយ ។

តាំងពីបន្ទាយនេះក្លាយទៅជាមន្ទីរសន្តិសុខ ស្រះទឹក១ អណ្តូងទឹក៥ និងអាងទឹក១ បានត្រូវខ្មែរក្រហមប្រើប្រាស់ធ្វើជារណ្តៅកប់សាកសពអ្នកទោសដែលជាប់ឃុំឃាំងនៅក្នុងបន្ទាយនេះ ។ ផ្ទះរបស់អតីតមេទាហាន (សម័យអាណានិគមបារាំង) ត្រូវបានប្រើប្រាស់ធ្វើជាមន្ទីរឃុំឃាំង ។ អ្នកទោសដែលជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខបន្ទាយអាទៀរី គឺប្រជាជន១៧មេសា ហើយបន្ទាប់មកប្រជាជនមូលដ្ឋាន ទាហាននិងមន្ត្រីរដ្ឋការសម័យសាធារណរដ្ឋខ្មែរ អ្នកលួចរបស់របរបន្តិចបន្តួច និងចុងក្រោយបំផុតគឺកម្មាភិបាល

ខ្មែរក្រហមខ្លួនឯងដែលត្រូវអង្គការចោទថាក្បត់ ។ អ្នកទោសត្រូវកងឈ្លបនាំយកទៅសម្លាប់នៅជុំវិញបរិវេណមន្ទីរសន្តិសុខអាទៀរី ហើយយកសាកសពទាំងនោះទៅទម្លាក់ចោលក្នុងស្រះទឹក អណ្តូងទឹក និងអាងទឹក ។ ការសម្លាប់នៅទីតាំងបន្ទាយអាទៀរីបាន ចាប់ផ្តើមតាំងពីឆ្នាំ១៩៧៦ ។ នៅចុងឆ្នាំ១៩៧៨ សកម្មភាពសម្លាប់បានកើនឡើងខ្លាំងមុនពេលមន្ទីរសន្តិសុខនេះត្រូវរំលាយចោល ។ តាមការបូកសរុបរបស់សាក្សីបីនាក់ (យុន វឿន ជាវរសេនីយ៍ទោធ្វើការនៅក្នុងបន្ទាយអាទៀរី បច្ចុប្បន្ន អ៊ុក សាវុធ ជាអនុប្រធានការិយាល័យវប្បធម៌ខេត្ត និង អ៊ុំ សាឡាត់ ជាប្រធានវប្បធម៌ខេត្ត) បានឲ្យដឹងថា សាកសពជនរងគ្រោះមានចំនួនជាង ៧០០នាក់ ។

នៅក្រោយឆ្នាំ១៩៧៩ អាថ៌កំបាំងរបស់បន្ទាយអាទៀរី បានត្រូវប្រជាជនដឹងឮគ្រប់គ្នាដោយសារឃើញខ្មោះឃ្លាងជាច្រើនស្ថិតនៅរាយប៉ាយពាសពេញមន្ទីរ ។ ប្រជាជនជាច្រើនរយនាក់បាននាំគ្នាទៅរើកកាយរកមាសប្រាក់ និងខ្លះទៀតស្វែងរកសាកសពដែលជាសាច់ញាតិរបស់ខ្លួនយកទៅធ្វើបុណ្យតាមប្រពៃណីដោយសំអាងទៅលើសម្លៀកបំពាក់ដែលជាប់នឹងរាងកាយ ។ បច្ចុប្បន្នបន្ទាយអាទៀរីមានបន្សល់ទុកវត្តុតាងដែលមិនអាចប្រកែកបានឡើយ គឺអណ្តូងទឹកមួយដែលនៅតែមានសេសសល់ឆ្អឹងខ្លះៗនៅបាតអណ្តូងនិងទម្រង់អគារចាស់មួយខ្នងដែលជាអតីតមន្ទីរឃុំឃាំងហើយដែលបច្ចុប្បន្នត្រូវបានជួសជុលជាថ្មីឡើងវិញ ។

## ១០) មន្ទីរសន្តិសុខវត្តកោះដុំ

វត្តកោះដុំស្ថិតនៅភូមិស្តុកខ្ញុំ ឃុំកោះដុំ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ។ ការអត់ឃ្លាន និងការបាត់ខ្លួនជារៀងរាល់ថ្ងៃ បានធ្វើឲ្យអ្នកទោសនៅក្នុងមន្ទីរឃុំឃាំងវត្តកោះដុំ បង្ខំចិត្តប្រឹងប្រែងធ្វើការទាំងត្រដរដើម្បីប្តូរយករបបអាហារបន្តិចបន្តួចក្រែងរស់បានមួយថ្ងៃថែមទៀត ។ អ្នកទោសម្នាក់ៗបានទទួលរបបរាវមួយបុពីរវែកប៉ុណ្ណោះក្នុងមួយថ្ងៃ។ ប៊ួយ អ៊ូផល អាយុ ៥៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិស្តុកខ្ញុំ ឃុំកោះដុំ ស្រុកសំពៅមាសបាននិយាយថារបបអង្ករប្រចាំថ្ងៃសម្រាប់អ្នកទោសមានតែអង្ករ១០កំប៉ុង សម្រាប់បបរចែកឲ្យអ្នកទោសចំនួនប្រហែល៤០០នាក់ ។ អ៊ូផល បានបន្តថាអ្នកទោសដែលជាប់នៅមន្ទីរវត្តកោះដុំនេះត្រូវខ្មែរក្រហមបែងចែកឲ្យហូបនៅតាមរោងបាយធំៗចំនួនបី ។ អ្នកទោសសរុបជាងមួយពាន់នាក់ ត្រូវកងសន្តិសុខបណ្តើរទៅដកស្ទូងនិងច្រូតកាត់ទាំងដើងជាប់ច្រវាក់ ។ នៅចុងឆ្នាំ១៩៧៨ អ្នកទោសទាំងនោះត្រូវកងសន្តិសុខនាំយកទៅសម្លាប់ចោលទាំងអស់ ។

ថ្វាង ភឹម អាយុ៤៣ឆ្នាំ សព្វថ្ងៃរស់នៅភូមិស្តុកខ្ញុំ ឃុំកោះដុំ ស្រុកសំពៅមាស បានរៀបរាប់ថា គាត់ឃើញកងសន្តិសុខវ័យក្មេងៗអាយុប្រហែល១៥ឬ១៦ឆ្នាំ បណ្តើរអ្នកទោសចេញពីវត្តកោះដុំយកទៅសម្លាប់ បន្ទាប់ពីធ្វើទារុណកម្មយ៉ាងសាហាវរួច ។ អ្នកទោសភាគច្រើនជាប្រជាជនជម្លៀសនិងប្រជាជនដែលមានជាប់និន្នាការនយោបាយពីជំនាន់សាធារណរដ្ឋខ្មែរ ។ ការសម្លាប់ច្រើនធ្វើឡើងនៅពេលយប់ ។ អ៊ូផល បានប្រាប់ថា នៅក្នុងរណ្តៅជាង១០០ កងសន្តិសុខបានសម្លាប់អ្នកទោសជាង១.០០០នាក់ទម្លាក់ចូលរណ្តៅ ដែលក្នុងនោះមានទាំងកូនបង្កើតរបស់ អ៊ូផល ៦នាក់ផង ។ ថ្វាង ភឹម ហៅ ផន ថា «តាមុខពីរ» ដែលជាប្រធានសន្តិសុខវត្តកោះដុំនេះ ។ **ផេង ពង្សរ៉ាស៊ី**



មន្ទីរសន្តិសុខវត្តកោះដុំ

# ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## ជំពូកទី៤
## ការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

### ១) *អង្គការ*

*ទោះបីជាខ្មែរក្រហមបានធ្វើចម្បាំងប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែររបស់លោកសេនាប្រមុខលន់ នល់អស់រយៈពេលប្រាំឆ្នាំក៏ដោយក៏ចលនានិងមេដឹកនាំសំខាន់ៗរបស់ខ្មែរក្រហមមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈទេ ។ បក្សកុម្មុយនីស្តកម្ពុជាបានរក្សាការសម្ងាត់នេះស្ទើរតែពេញរយៈពេលដែលខ្លួនគ្រប់គ្រងប្រទេសកម្ពុជា ។*

*អង្គការបដិវត្តន៍ត្រូវបានបង្កើតឡើងដោយសមាជិកបក្សកុម្មុយនីស្តកម្ពុជា ។ អ្នកទាំងនេះត្រូវបានដឹកនាំជាសម្ងាត់ពីសំណាក់ ប៉ុល ពត ។*

*នៅខែកញ្ញា ឆ្នាំ១៩៧៥ គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជារួមមាន ៖ ប៉ុល ពត, នួន ជា, សោ ភឹម, អៀង សារី, សុន សេន, តាម៉ុក, និង វន វេត ។ នៅឆ្នាំ១៩៧៧ សមាជិកបីនាក់ទៀត ញឹម រស់, ខៀវ សំផន និងកែ ពក ត្រូវបានបញ្ចូលទៅក្នុងគណៈកម្មាធិការនេះ ។ ប៉ុល ពត, អៀង សារី, សុន សេន និង ខៀវ សំផន បានទទួលការអប់រំនៅប្រទេសបារាំង*



**មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ និងជាសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា** *(ពីឆ្វេងទៅស្តាំរួមមាន៖ ប៉ុល ពត (លេខាបក្សកុម្មុយនីស្តកម្ពុជានិងជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យ), នួន ជា (អនុលេខាបក្សកុម្មុយនីស្តកម្ពុជានិងជាប្រធានសភាតំណាងប្រជាជនកម្ពុជា), អៀង សារី (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស), សុន សេន (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ), វ៉ន វេត (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកផ្នែកសេដ្ឋកិច្ច)*

# ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាពីឆ្នាំ១៩៧៦-១៩៧៨




*វន វ៉េត និង ញឹម រស់ ត្រូវបានសម្លាប់នៅឆ្នាំ១៩៧៨ ។ សោ ភឹម ធ្វើអត្តឃាតនៅឆ្នាំ ១៩៧៨ ។ សុន សេន ត្រូវបានសម្លាប់ក្នុងឆ្នាំ១៩៩៧ ។ កែ ពក ស្លាប់ដោយសារជំងឺនៅ ឆ្នាំ២០០២ ។ តាម៉ុកស្លាប់ដោយជំងឺនៅឆ្នាំ២០០៦ ។

ចំណែក នួន ជា ធ្លាប់បានសិក្សារៀនសូត្រនៅប្រទេសថៃនិង វៀតណាម ។សមាជិកផ្សេងទៀតនៃគណៈកម្មាធិការមជ្ឈិមមាន ចំណេះដឹងបន្តិចបន្តួចប៉ុណ្ណោះ ។

## ២) ការយាងនិវត្តន៍មកកម្ពុជារបស់សម្តេចព្រះនរោត្តម សីហនុ

រហូតដល់ចុងឆ្នាំ១៩៧៥ ខ្មែរក្រហមនៅតែហៅខ្លួនឯងថា ជារាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (រដ្ឋាភិបាលដែលត្រូវបាន បង្កើតឡើងនៅទីក្រុងប៉េកាំងនៅឆ្នាំ១៩៧០ ដែលមានសម្តេច ព្រះនរោត្តម សីហនុ ជាព្រះប្រធាន) ។ មកដល់ឆ្នាំ១៩៧២ ខ្មែរក្រហមបានត្រួតត្រាលើចលនាតស៊ូស្ទើរតែទាំងស្រុងទៅហើយ ប៉ុន្តែដើម្បីបានការទទួលស្គាល់ពីអន្តរជាតិនិងការគាំទ្រពីប្រជាជន នៅក្នុងប្រទេស ចលនានេះនៅបន្តស្ថិតក្រោមអធិបតីភាពរបស់ សម្តេចព្រះនរោត្តម សីហនុ និងរាជរដ្ឋាភិបាលនិរទេសរបស់ ព្រះអង្គដដែល ។

នៅខែកក្កដាឆ្នាំ១៩៧៥ ខ្មែរក្រហមបានសុំយាងសម្តេច ព្រះនរោត្តម សីហនុ ដែលនៅពេលនោះ កំពុងគង់និរទេសនៅ ទីក្រុងព្យុងយ៉ាង ប្រទេសកូរ៉េខាងជើងមកកម្ពុជា ។ មុនយាងនិវត្តន៍ មកកម្ពុជា ព្រះអង្គបានយាងមកកាន់ទីក្រុងប៉េកាំង ដើម្បីសុំលា ប្រធានាធិបតីចិន ម៉ៅ សេទុង និងនាយករដ្ឋមន្ត្រី ជូ អេនឡាយ ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ ។ ក្រោយមកព្រះអង្គ បានមានព្រះបន្ទូលថា៖ «ការសម្រេចព្រះទ័យរបស់ខ្ញុំក្នុងការវិល ត្រឡប់មកកម្ពុជាវិញ មិនមានន័យថា ខ្ញុំយល់ព្រមទទួលស្គាល់ ខ្មែរក្រហមទាំងនោះទេ ប៉ុន្តែខ្ញុំត្រូវតែធ្វើពលិកម្មដើម្បីជាកិត្តិយស ដល់ប្រទេសចិន ហើយជាពិសេសដល់លោកនាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ ដែលបានជួយប្រទេសកម្ពុជានិងខ្លួនខ្ញុំយ៉ាងច្រើន លើសលប់» ។ ព្រះអង្គបានយាងត្រឡប់ជាមួយព្រះមហេសីនៅ ដើមខែកញ្ញាដោយមានសម្តេច ប៉ែន នុត (នាយករដ្ឋមន្ត្រីនៃ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា) ខៀវ សំផន, អៀង ធីរិទ្ធ និង រាជវង្សានុវង្សមួយចំនួនអមព្រះរាជដំណើរទៀតផង ។

បន្ទាប់ពីយាងនិវត្តន៍មកដល់កម្ពុជាភ្លាមព្រះអង្គបានធ្វើជា អធិបតីក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រីមួយ ប៉ុន្តែមិនត្រូវបាន អនុញ្ញាតឲ្យមានព្រះបន្ទូលអ្វីទាំងអស់ ។ តំណែងជាព្រះប្រមុខរដ្ឋ ដែលក្រុមមេដឹកនាំកុម្មុយនីស្តថ្វាយព្រះអង្គនោះមិនមានអំណាច ទេ ។ បីសប្តាហ៍ក្រោយការយាងត្រឡប់មកដល់កម្ពុជា ព្រះអង្គ ត្រូវបានបញ្ជូនទៅអង្គការសហប្រជាជាតិដើម្បីទាមទារយក អាសនៈរបស់កម្ពុជានៅមហាសន្និបាតអង្គការសហប្រជាជាតិ ។ នៅក្នុងប្រទេសឯណោះវិញ ក្រុមអ្នកគាំទ្ររបស់ព្រះអង្គជាច្រើន

នាក់បានបាត់ខ្លួនដោយគ្មានដំណឹង ។ សមាជិករាជវង្សានុវង្សប្រហែលម្ភៃអង្គបានចូលទិវង្គតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយយ៉ាងតិចមានព្រះរាជវង្សានុវង្សប្រាំពីរអង្គផ្សេងទៀតត្រូវបានធ្វើគុតនៅគុកទួលស្លែង ។



កិច្ចប្រជុំជាមួយគណៈប្រតិភូបរទេស

### ៣) រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ

ពីថ្ងៃទី១៥ដល់ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៥ សំណេររដ្ឋធម្មនុញ្ញមួយត្រូវបានអនុម័តដោយសមាជិកចំនួនមួយពាន់នាក់ ក្នុងមហាសន្និបាតជាតិនៅទីក្រុងភ្នំពេញ ហើយត្រូវបានប្រកាសឲ្យប្រើជាផ្លូវការនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ។ ប្រទេសកម្ពុជាត្រូវបានប្តូរឈ្មោះជាផ្លូវការថា «កម្ពុជាប្រជាធិបតេយ្យ» ។ រដ្ឋធម្មនុញ្ញបានបង្កើតសភាតំណាងប្រជាជនចំនួន ២៥០អាសនៈ ដែលក្នុងនោះ១៥០រូបតំណាងឲ្យវណ្ណៈកសិករ ៥០រូបតំណាងឲ្យវណ្ណៈកម្មករនិងពលករ និង៥០រូបទៀតតំណាងឲ្យកងទ័ពបដិវត្តន៍កម្ពុជា ។ រដ្ឋធម្មនុញ្ញមិនមានចែងអ្វីទាំងអស់ទាក់ទងនឹងបក្សកុម្មុយនីស្តកម្ពុជា ហើយរដ្ឋសភាបានបើកសម័យប្រជុំតែម្តងគត់នៅខែមេសា ឆ្នាំ១៩៧៦ ។

ចម្រៀងជាតិថ្មីមានឈ្មោះថា«១៧មេសាមហាជោគជ័យ» ។ បទចម្រៀងនេះនិពន្ធដោយ ប៉ុល ពត ។ ទង់ជាតិថ្មីមានផ្ទៃពណ៌ក្រហម ហើយមានរូបប្រាសាទអង្គរវត្តកំពូលបីពណ៌លឿងនៅចំកណ្តាល ។

### ៤) សម្តេចព្រះនរោត្តម សីហនុ លាលែងពីតំណែងប្រមុខរដ្ឋ

នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីសកម្ពុជាបានជួបពិភាក្សាគ្នាអំពីបញ្ហាសុំលាលែងពីតំណែងរបស់សម្តេចព្រះនរោត្តម សីហនុ។ គណៈអចិន្ត្រៃយ៍បានព្រមព្រៀងទទួលយកសំណើសុំលាលែងរបស់ព្រះអង្គ ប៉ុន្តែនឹងមិនអនុញ្ញាតឲ្យព្រះអង្គចាកចេញពីប្រទេស ធ្វើសេចក្តីថ្លែងការណ៍ឬជួបពិភាក្សាជាមួយអ្នកទូតបរទេសណាមួយឡើយ ។ របបរាជានិយមនៅកម្ពុជាដែលកើតមានឡើងអស់រយៈពេលជិតពីរពាន់ឆ្នាំមកហើយនោះត្រូវបានបញ្ចប់ ។

នៅខែមេសា ឆ្នាំ១៩៧៦ សភាតំណាងប្រជាជនកម្ពុជាបានបើកសម័យប្រជុំលើកទីមួយនិងតែម្តងគត់របស់ខ្លួន ។ អង្គប្រជុំបានព្រមព្រៀងគ្នាជាឯកច្ឆន្ទទៅលើសំណើសុំយាងចូលនិវត្តន៍




**សញ្ញាជាតិ** មាត្រា១៧នៃរដ្ឋធម្មនុញ្ញកម្ពុប្រជាធិបតេយ្យចែងថាសញ្ញាជាតិគឺមានប្រព័ន្ធស្រែនិងប្រឡាយទឹកជានិមិត្តរូបនៃកសិកម្មជឿនលឿនមានរោងចក្រជានិមិត្តរូបនៃឧស្សាហកម្មមានកម្រងកួរស្រូវ ជាស្នែងក្របព័ទ្ធពីក្រៅ ហើយមានអក្សរ«កម្ពុជាប្រជាធិបតេយ្យ” នៅពីក្រោម ។

របស់សម្តេចព្រះនរោត្តម សីហនុ ដោយផ្តល់ថ្វាយព្រះអង្គនូវប្រាក់សោធននិវត្តន៍ចំនួនប្រាំបីពាន់ដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ ដែលមិនដែលបើកថ្វាយព្រះអង្គទាល់តែសោះ ។ ព្រះអង្គនិងព្រះរាជវង្សានុវង្សត្រូវបានឃុំឃាំងនៅក្នុងគេហដ្ឋានតូចមួយក្នុងព្រះបរមរាជវាំង ។ ព្រះអង្គបានជាប់ឃុំនៅទីនោះរហូតដល់ខែមករា ឆ្នាំ១៩៧៩ គឺរហូតដល់ថ្ងៃដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

## ៥) រចនាសម្ព័ន្ធចាត់តាំងរបស់កម្ពុជាប្រជាធិបតេយ្យ

បក្សកុម្មុយនីស្តកម្ពុជាគឺជាអង្គការតែមួយគត់ដែលមានអំណាចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រសួងដែលមានសកម្មភាពការងារច្រើន ដែលត្រូវបានបង្កើតឡើងនៅទីក្រុងភ្នំពេញរួមមានក្រសួងការបរទេសដឹកនាំដោយ អៀង សារី ក្រសួងការពារជាតិដឹកនាំដោយ សុន សេន ក្រសួងឧស្សាហកម្មដឹកនាំដោយ ចេង អន និងក្រសួងសេដ្ឋកិច្ចដឹកនាំដោយ វន វ៉េត ។ គណៈកម្មាធិការតែមួយគត់ដែលមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងអនុម័តគោលនយោបាយរដ្ឋាភិបាលនិងលក្ខន្តិកៈផ្សេងៗ គឺគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាដែលមាន ប៉ុល ពត ជាលេខា និងនួន ជា ជាអនុលេខា ។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាមិនដែលយកចិត្តទុកដាក់គោរពរដ្ឋធម្មនុញ្ញនិងបទបញ្ញត្តិនានាដែលមេដឹកនាំទាំងនេះជាអ្នកអនុម័តបង្កើតឡើងដោយខ្លួនឯងម្តងណាទេ ។ សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍និងគណៈកម្មាធិការមជ្ឈិមបក្សក៏មានតំណែងនៅក្នុងរដ្ឋាភិបាលដែរ ។

## ៦) ការផ្លាស់ប្តូរថ្ងៃកំណើតបក្ស

នៅខែមីនាឆ្នាំ១៩៧៦ គណៈកម្មាធិការមជ្ឈិមបក្សបានសម្រេចយកឆ្នាំ១៩៦០ (មិនយកឆ្នាំ១៩៥១) ជាឆ្នាំកំណើតបក្សកុម្មុយនីស្តកម្ពុជា ។ មេដឹកនាំទាំងនោះបានសម្រេចថា អ្នកទាំងឡាយណាដែលចូលជាសមាជិកមុនឆ្នាំ១៩៦០ នឹងមិនត្រូវបានចាត់ទុកថាជាសមាជិកបក្សទៀតទេ ។ មជ្ឈិមបក្សមិនចង់ទទួលស្គាល់សារសំខាន់នៃការជួយជ្រោមជ្រែងរបស់វៀតណាមមុនឆ្នាំ១៩៦០ឡើយ ហើយចង់បដិសេធចោលឥទ្ធិពលរបស់វៀតណាមមកលើបក្សកុម្មុយនីស្តកម្ពុជា និងចង់កាត់ផ្តាច់ទំនាក់ទំនងទាំងឡាយដែលធ្លាប់មានជាមួយវៀតណាមផង ។

បក្សកុម្មុយនីស្តកម្ពុជាបានបន្តដឹកនាំប្រទេសជាសម្ងាត់នៅក្រោមឈ្មោះថា «អង្គការ» ។ ទោះជាយ៉ាងនេះក្តី នៅខែកញ្ញា ឆ្នាំ១៩៧៧ គឺមុនដំណើរទស្សនកិច្ចទៅប្រទេសចិនបន្តិច ប៉ុល ពត បានប្រកាសជាសាធារណៈនូវអត្ថិភាពរបស់បក្សកុម្មុយនីស្តកម្ពុជា និងតួនាទីរបស់ខ្លួនជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យ ។

**(នៅមានត)**

**ឌី ខាំបូលី**

## រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ



# ជាប់គុកទួលស្លែងដោយសារការមិនទុកចិត្ត

ទួលស្លែងដែលមានឈ្មោះផ្លូវការថា «មន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង» ជាកន្លែងមួយឆ្លុះបញ្ចាំងពីប្រវត្តិរឿងរ៉ាវជាច្រើនដែលកើតមានឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ មេដឹកនាំនៃរបបនេះបានជ្រើសយកទីតាំងនេះធ្វើជាគុកមជ្ឈិមសម្រាប់ឃុំឃាំងនិងសម្លាប់មនុស្សបន្ទាប់ពីត្រូវបានចោទប្រកាន់ថាក្បត់នឹងអង្គការ ។ ជាធម្មតា អ្នកទោសដែលត្រូវអង្គការបញ្ជូនមកទួលស្លែងតែងទទួលរងទារុណកម្ម ភាគច្រើនបានបាត់បង់ជីវិតនៅទីនោះ ដោយសារការបង្អត់អាហារ ការធ្វើអត្តឃាត និងមួយចំនួនត្រូវបញ្ជូនទៅសម្លាប់នៅវាលពិឃាតជើងឯក ។ អ្នកទោសតិចតួចណាស់ដែលមានវាសនារស់រានមានជីវិតរហូតដល់សព្វថ្ងៃ ។



អគារមន្ទីរស-២១

សុក សុជាត ដែលមានស្រុកកំណើតនៅខេត្តកំពង់ឆ្នាំង បានជាប់គុកទួលស្លែងអស់រយៈពេលជាងពីរឆ្នាំ ។ ការឃុំឃាំង សុជាត មិនមែនដោយសារគាត់ប្រព្រឹត្តកំហុសធ្ងន់ធ្ងរក្នុងជួរកងទ័ពនោះទេ កំហុសរបស់គាត់គឺដោយសារការមិនទុកចិត្តគ្នា ។

## ការងារមុនពេលចាប់ខ្លួន



សុក សុជាត

នៅឆ្នាំ១៩៧៣ សុជាត បានទៅរៀននៅសាលាវត្ត ខ្ទង់ពពកនិងស្នាក់នៅជាមួយលោកសង្ឃ ស្របពេលដែលខ្មែរក្រហមចាប់ផ្តើមជ្រើសរើសយុទ្ធជនឲ្យចូលធ្វើទាហានដែរ ។ ព្រះសង្ឃនៅក្នុងវត្តត្រូវអង្គការបង្ខំឲ្យសឹកទាំងអស់ដើម្បីចូលបម្រើបដិវត្តន៍ ។ ចៅអធិការព្រះនាម អាចារ្យ ខុន ត្រូវបង្ខំឲ្យសឹកមុនគេ ហើយ សុជាត ក៏មានឈ្មោះនៅក្នុងនោះដែរ ។ សុជាត ត្រូវបញ្ជូនឲ្យទៅហាត់រៀនក្បួនយុទ្ធសាស្ត្រនិងរៀនអំពីរចនាសម្ព័ន្ធយោធានៅស្រុកទឹកផុសរយៈពេលបីខែ ។ ខ្លឹមសារសំខាន់នៅក្នុងឯកសារស្តីពីការអប់រំសតិអារម្មណ៍នោះគឺមិនឲ្យរត់ទៅផ្ទះ ។ ឯកសារដែលរៀនសូត្រមានប្រភពចេញមកពីក្រសួងការពារប្រទេសនិងអគ្គសេនាធិការស្នងការនយោបាយរដ្ឋ ។ សុជាត ជាយុទ្ធជននៅក្នុងកងអនុសេនាធំ៣០៣ មានកម្លាំង១០០នាក់ ក្រោមការគ្រប់គ្រងរបស់ប្រធានវរសេនាតូចឈ្មោះ កៃ ប្រធានអនុសេនាធំឈ្មោះ ទឹប និងអនុប្រធានឈ្មោះ រ៉េត ។ ក្រោយពីរៀនចប់ កងទ័ពទាំងអស់ត្រូវចេញទៅហ្វឹកហ្វឺនប្រយុទ្ធនៅសមរភូមិ ។ មូលដ្ឋានទ័ពតាំងនៅទំនប់ចាប្រ៉ង់ឆ្ងាយពីវត្តខ្ទង់ពពក៧គីឡូម៉ែត្រ ។ អាវុធសម្រាប់ប្រយុទ្ធធុនធ្ងន់មានកាំភ្លើងត្បាល់៨២ និងដេការហ្វេត យកមកពីប្រទេសចិន ។ សុជាត កាន់កាំភ្លើងធុនស្រាលម៉ាកអឹមសី ។ សុជាត និងកងអនុសេនាធំ៣០៣ទាំងអស់ត្រូវបញ្ជូនឲ្យទៅវាយប្រយុទ្ធនៅត្រពាំងឫស្សីជិតព្រៃមូលដែលជាបន្ទាយរបស់កងទ័ព លន់ នល់ ។ កងទ័ពនេះវាយតែមួយយប់ទទួលបានជ័យជម្នះ ។ សុជាត និយាយថាពេលច្បាំងម្តងៗមិនដែលចាប់បានទាហាន លន់ នល់ ទាំងរស់ទេ ។ អ្នកដឹកនាំប្រយុទ្ធនៅទីនោះឈ្មោះ សុង ជាមេបញ្ជាការ ។ នៅក្នុងកងអនុសេនាធំមានបែងចែកជាបីទៀតគឺកងអនុសេនាតូចលេខ១ លេខ២ និងលេខ៣ ។ ប្រធានអនុសេនាតូចលេខ១ឈ្មោះ វ៉ាត ។ ដើមឆ្នាំ១៩៧៤ សុជាត បានផ្លាស់ទៅវាយនៅបន្ទាយ

លផ្នែក ប៉ុន្តែវាយបែកបានតែពាក់កណ្តាល ។ ដូចនេះអង្គការបានរំសាយទ័ពបញ្ចូលជាមួយកងពិសេសភូមិភាគបស្ចិមឈរជើងនៅអមលាំងដែលមាន ជឹប ជាប្រធានកងពិសេស ។ កងពិសេសនេះមានមួយវរសេនាតូចស្មើនឹងបីអនុសេនាធំមានកម្លាំង៣០០នាក់ និងមានអាវុធយុទ្ធភណ្ឌទំនើបៗជាងអង្គភាពមុនៗ សុផាត កាន់កាំភ្លើងម៉ាកអាកានៅក្នុងកងអនុសេនាធំលេខ៣ដែលមានប្រធានឈ្មោះ យាន និង មេន ជាអនុប្រធាននិងក្នុងអនុសេនាតូចលេខ២ ប្រធានឈ្មោះ តា អន និង តាស ជាអនុប្រធាន។ មួយកងអនុសេនាតូចមានសមាជិក៣០នាក់ ។ ពេលឡើងប្រយុទ្ធម្តងៗ សុផាត ទទួលបញ្ជាពីតាជឹប ឲ្យកងអនុសេនាធំបញ្ជាទៅកងអនុសេនាតូចអនុវត្ត ហើយកងអនុសេនាតូចបញ្ជាឲ្យក្រុមរបស់ខ្លួនអនុវត្តបន្តទៀត ។ កងពិសេសទាំងបីអនុសេនាធំត្រូវបញ្ជូនឲ្យទៅប្រយុទ្ធនៅតាមផ្លូវជាតិលេខ១ ។ កងពិសេសនេះមានកម្លាំងខ្លាំងសមរភូមិណារឹងមាំវាយមិនបែក ត្រូវដកកងពិសេសទៅវាយជាជំនួយ ។ ចំពោះអ្នករបួស ក្រោយពីប្រយុទ្ធ អង្គការមានរៀបចំឲ្យមានទីស្នាក់ការសម្រាប់សែងអ្នករបួសយកទៅព្យាបាល ។ ពេលចេញច្បាំង កងទ័ពទាំងអស់ស្លៀកឯកសណ្ឋានខោពណ៌ខៀវនិងអាវពណ៌ស្វែ ។ ឆ្នាំ១៩៧៥ អង្គការបានផ្លាស់ប្តូរកម្លាំងដោយចម្រាញ់យកទ័ពល្អៗចេញពីអង្គភាពផ្សេងៗបញ្ចូលក្នុងកងពល៧០៣ ។ ដំបូងកងពលនេះ មានកម្លាំងតែ១០.០០០នាក់ ក្រោយពីបញ្ចូលរួចមានកម្លាំងសរុបឡើងដល់៣០.០០០នាក់ ។ កងពលនេះរៀបចំទីតាំងនៅក្រាំងល្វា ខេត្តកំពង់ឆ្នាំង ដែលមានប្រធានកងពលឈ្មោះ តាណាត និងតាពីន ។ សុផាត ត្រូវបានបញ្ចូលទៅក្នុងកងពលពិសេស៧០៣នេះដែរ ប៉ុន្តែនៅក្នុងផ្នែកកងអន្តរាគមន៍ដែលមានកម្លាំង៤០០នាក់ ក្រោមការគ្រប់គ្រងរបស់តាស៊ី ។ កងអន្តរាគមន៍នេះត្រូវបែងចែកជាបីកងអនុសេនាធំទៀត សុផាតនៅក្នុងកងអនុសេនាធំលេខ២ ប្រធានឈ្មោះ តាឡូន និងអនុប្រធានឈ្មោះ ផន ។ នៅពេលនោះកងអន្តរាគមន៍ត្រូវទៅវាយនៅខាងលិចពោធិ៍ចិនតុង ហើយចូលទីក្រុងភ្នំពេញតែម្តង ។ ក្រោយពីទទួលបានជ័យជម្នះ កម្លាំងទ័ពត្រូវបែងចែកជាពីរគឺ កងពល៥០២និងកងពល៧០៣ ។ កងពល៥០២ គ្រប់គ្រងពីខាងកើត គុកទួលស្លែងមកពោធិ៍ចិនតុង ចំណែកកងពល៧០៣



បន្ទប់គុកតូចៗ នៅក្នុងមន្ទីរស-២១

គ្រប់គ្រងពីផ្សារថ្មីទៅផ្លូវមាត់ទន្លេ ។ កងរបស់ សុផាត ត្រូវដកមកនៅវត្តកុល ខាងត្បូងរោងចក្រកែវ សម្រាប់ត្រៀមប្រយុទ្ធ ។ ទីកន្លែងស្នាក់នៅរបស់ សុផាត នៅក្បែរផ្សារថ្មីនិងមានដាំបន្លែត្រកួន ស្ពៃ និងចិញ្ចឹមសត្វសម្រាប់ដោះស្រាយជីវភាពកងពលផង ។

## មុនពេលចាប់ចូលទួលស្លែង

សុផាត មិនបានដឹងខ្លួនថាត្រូវបញ្ជូនទៅគុកទួលស្លែងទេ ដោយគិតថាគ្រាន់តែទៅរៀនអំពីយុទ្ធវិធីបច្ចេកទេសយោធាប៉ុណ្ណោះ ព្រោះធ្លាប់ទៅរៀននៅសាលាអង្គភាព៧០៣នៅតាខ្មៅដែរ ។ ហេតុការណ៍នេះកើតឡើងបន្ទាប់ពីគាត់ (ចុងឆ្នាំ១៩៧៧) បបួលបងប្អូននៅក្នុងអង្គភាពជាមួយគ្នាទៅលេងឪពុកម្តាយនៅឯស្រុកកំណើត ប៉ុន្តែប្រធានឈ្មោះ ស៊ី មិនអនុញ្ញាត ។ បន្ទាប់ពីនោះមានកម្មាភិបាលដែលចុះពិនិត្យប្រវត្តិរូបប្រាប់ថា បងប្អូនដែលជាប់និន្នាការនយោបាយត្រូវប្រមូលឲ្យទៅរៀនសូត្រ ។ ស៊ីមកប្រាប់ សុផាត ឲ្យត្រៀមសម្ភារៈសម្លៀកបំពាក់ផ្ទាល់ខ្លួន ប៉ុន្តែមិនឲ្យយកអាវុធតាមខ្លួនទេ ។ សុផាត សម្គាល់ឃើញថាមាន

មនុស្សស្រឡែវក្អែកម្នាក់ស្លៀកពាក់ខោអាវខ្មៅ និងបង់ក្រមាសូត្រ មានកាន់បញ្ជីឈ្មោះមកហៅគាត់ឲ្យទៅប្រជុំនៅលើថ្នល់ ។ ម៉ោងប្រហែល៣រសៀល រថយន្តពីរគ្រឿងបានមកដឹកអ្នកដែលត្រូវចាប់ខ្លួនទាំងអស់ ក្នុងនោះមានកងវរសេនាធំនិងវរសេនាតូចប្រហែលជា៣០នាក់ ។ នៅអង្គភាពរបស់ សុផាត មានបីនាក់រួមទាំងគាត់ផង ចំណែកពីរនាក់ទៀតឈ្មោះ កត និងថាត ។ រថយន្តបានដឹក សុផាត និងអ្នកផ្សេងផ្តោះទៅក្រុងតាខ្មៅដើម្បីបង្វែងដានកុំឲ្យសង្ស័យ ។ ទីនោះមានផ្ទះមួយខ្នងដែលកាលពីមុនជាមន្ទីរពេទ្យឆ្កួត ។ ម៉ោងប្រហែល៧យប់ អង្គការបានមកហៅឲ្យចូលម្តង១០នាក់ ។ កត និង ថាត ត្រូវអង្គការហៅចូលលើកទី២ ហើយ សុផាត ត្រូវអង្គការហៅឲ្យចូលលើកទី៣ ។ នៅក្នុងផ្ទះមានបន្ទប់សម្ងាត់មួយនិងកងការពារសម្រាប់ចាប់ដាក់ខ្នោះដៃ ។ កម្លាំងចាប់មានពីរនាក់ម្នាក់ចាំចាប់ដៃម្ខាងនិងម្នាក់ទៀតចាំក្របួចដៃម្ខាងទៀតមកក្រោយ ដាក់ខ្នោះប្រភេទអូតូម៉ាទិចលេខ៨ ។ បន្ទាប់មក រថយន្តដដែលនោះបានដឹកបញ្ជូន សុផាត និងអ្នកទាំងអស់មកកាន់ទួលស្លែងទាំងយប់ ។ រថយន្តនោះមានរូបរាងដូចឡានចិនឃុបបិទជិត មិនអាចមើលឃើញខាងក្រៅឡើយ ហើយអ្នកទោសទាំងអស់ត្រូវបិទមុខជិត ។ នៅពេលនោះ ថាត បានបបួល សុផាត ឲ្យហក់ចេញពីក្នុងរថយន្ត ប៉ុន្តែគាត់មិនហ៊ាន ស្រាប់តែភ្លាមនោះ ថាត ត្រូវទាហានខ្មែរក្រហមវាយនឹងស្នូកកាំភ្លើងចំក្បាលដោយសារឮខ្សឹបខ្សៀវគ្នា ។

## ស្ថានភាពនៅទួលស្លែង

សន្តិសុខបានបណ្តើរអ្នកទោសចេញពីរថយន្តម្តងមួយៗ ទៅកាន់បន្ទប់ឃុំឃាំងដែលមានប្រឡោះតូចៗនៅដាច់ដោយឡែកពីគ្នា ។ សុផាត ត្រូវឆ្មាំគុកដោះខ្នោះដៃចេញហើយដាក់ខ្នោះជើងជំនួសវិញ ។ ព្រឹកឡើងអ្នកសួរចម្លើយបានកាន់បញ្ជីឈ្មោះមកហៅទៅសួរចម្លើយនៅក្នុងបន្ទប់មួយដែលនៅឆ្ងាយពីទីកន្លែងដែលគាត់សម្រាក ។ សុផាត ត្រូវបិទរុំមុខដោយក្រណាត់មួយផ្ទាំង រួចបណ្តើរចូលទៅក្នុងបន្ទប់មួយ បន្ទាប់មកអ្នកយាមគុកបានស្រាយក្រណាត់រុំមុខនិងដោះខ្នោះជើងចេញ ប៉ុន្តែដាក់ខ្នោះដៃជំនួសវិញ ។ សុផាត សង្កេតឃើញមានរំពាត់ ខ្សែលួស ប៊ិច និងសៀវភៅសម្រាប់កត់ចម្លើយ ។ បន្ទាប់មកអ្នកសួរចម្លើយបានសួរគាត់អំពី



ប្រជាជនទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

តួនាទីឪពុកម្តាយគាត់នៅសម័យ លន់ នល់ ។ សុផាត ឆ្លើយថា ឪពុកម្តាយគាត់ជាអ្នកស្រែចម្ការ ។ ដោយឆ្លើយមិនចំគោលដៅ អ្នកសួរចម្លើយបានឆក់ខ្សែភ្លើងគាត់រហូតដល់សន្លប់បាត់ស្មារតី ពេលដឹងខ្លួនឡើងវិញអ្នកសួរចម្លើយបានសួរគាត់បន្តទៀត ។ ការសួរចម្លើយបានចាប់ផ្តើមតាំងពីព្រលឹមដល់ម៉ោង១១ថ្ងៃត្រង់ ។ នៅពេលដំបូង អ្នកសួរចម្លើយជាអ្នកកត់ត្រាចម្លើយ ប៉ុន្តែនៅលើកបន្តបន្ទាប់ សុផាត ត្រូវសរសេរចម្លើយសារភាពដោយខ្លួនឯងដោយរៀបរាប់ពីប្រវត្តិសកម្មភាពរបស់ខ្លួនតាំងពីដើមរហូតដល់ថ្ងៃដែលត្រូវអង្គការចាប់យកមកដាក់នៅទួលស្លែង ។ បន្ទាប់ពីសួរចម្លើយជាច្រើនលើកច្រើនសា សុផាត ត្រូវបញ្ជូនទៅថតរូបនៅក្នុងបន្ទប់សម្ងាត់មួយដែលក្នុងបន្ទប់នោះមានតែ សុផាត អ្នកថតរូបនិងអ្នកកត់បញ្ជីប៉ុណ្ណោះ ។

ស្ថានភាពរស់នៅរបស់ សុផាត ពេលនៅក្នុងគុកគឺបានទទួលបបរត្រកួនមួយវែកដែលស្ទើរតែគ្មានគ្រាប់អង្ករសោះ ។ ចាប់តាំងពីជាប់នៅទីនោះ សុផាត មិនដែលដឹងថានរណាជាប្រធានគ្រប់គ្រងនៅទីនេះទេ ប៉ុន្តែគាត់គ្រាន់តែឮថាឈ្មោះ ឌុច និង ហ៊ី ។

សុផាត បានឃើញមិត្តភក្តិរបស់គាត់ឈ្មោះ កត ត្រូវបញ្ជូនទៅព្រៃស ។ ប្រហែលជាមួយឆ្នាំក្រោយ ទើបអង្គការដកសុផាត ឲ្យមកវែកបបរចែកអ្នកទោសវិញ ។ ពេលនោះជើងរបស់សុផាត លែងជាប់ខ្នោះទៀតហើយ ប៉ុន្តែនៅមានសន្តិសុខកាន់កាំភ្លើងតាមពីក្រោយជាប់ជានិច្ច ។ ក្រោយពីវែកបបររួច ជើងរបស់សុផាត ត្រូវដាក់ខ្នោះបញ្ចូលវិញ ។ សុផាត ធ្លាប់ឃើញអ្នកទោសដែលជាប់នៅបន្ទប់ផ្សេងទៀត ត្រូវឆ្មាំគុកធ្វើទារុណកម្មដើម្បីឲ្យឆ្លើយសារភាពដូចជារូបគាត់ដែរ ហើយមួយចំនួនត្រូវចាក់សម្លាប់ ។

សុផាត ត្រូវសន្តិសុខរុំមុខបណ្តើរយកទៅសម្លាប់នៅរណ្តៅខាងលិចរបងគុកចំនួនបីដងតែមិនស្លាប់ ។ សុផាត រំឭកថា ពេលទៅដល់រណ្តៅគ្រាន់តែស្រាយក្រណាត់ចេញពីមុខ គាត់ធុំក្លិនស្អុយដែលជះចេញពីរណ្តៅឆ្អួលច្រមុះ ។ រណ្តៅមានច្រើននៅក្បែរៗគ្នា ។ ពេលនោះសន្តិសុខបម្រុងសម្លាប់គាត់ស្រាប់តែមានមនុស្សមកប្រាប់ថា ចាប់យកមកច្រឡំហើយ ព្រោះឈ្មោះនេះនៅមិនទាន់បានសួរចម្លើយអស់ ។ សុផាត ក៏ត្រូវឆ្មាំគុកនាំយកមកដាក់នៅកន្លែងដើមវិញ ។ ទោះជាបែបនេះក៏ដោយ សុផាត នៅតែភិតភ័យដដែល ព្រោះអ្នកទោសនៅទីនេះជាច្រើនបានបាត់ខ្លួនជាបន្តបន្ទាប់ ហើយឃើញរថយន្តដឹកចេញដឹកចូលជារៀងរាល់ថ្ងៃ ។

## រួចផុតពីសេចក្តីស្លាប់

ឆ្នាំ១៩៧៩គឺជាឆ្នាំដែលជីវិតរបស់ សុផាត បានរួចផុតពីសេចក្តីស្លាប់ ។ ពេលគ្រាប់ផ្ទុះឡើងភ្លាម សុផាត បានព្យាយាមដោះខ្នោះចេញពីជើងរបស់គាត់ ។ ម៉ោងប្រហែល៨ឬ៩យប់ សុផាត បានលោតពីលើអគារជាន់ទី២ចុះមកក្រោម សំណាងល្អគាត់បានធ្លាក់មកទើរលើពូកចាស់មួយ គាត់គ្រាន់តែសន្លប់បាត់ស្មារតីប៉ុណ្ណោះ ។ ពេលដឹងខ្លួន សុផាត បានរត់ទៅលាក់ខ្លួននៅក្នុងផ្ទះដែលគរពូកចាស់ៗប្រហែលជា១សប្តាហ៍ មិនទាន់ហ៊ានចេញពីបរិវេណទួលស្លែងនៅឡើយ ។ សន្តិសុខការពារបានតាមរក សុផាត នៅក្នុងផ្ទះនោះដែរ ថែមទាំងយកកាំបិតចាក់រុកក្នុងពូកទៀតផង ។ ក្រោយពីដឹងថាមិនមានមនុស្ស សុផាត បានរត់គេចចេញពីទីនោះភ្លាម ។ តាមផ្លូវ សុផាត បានជួបយុទ្ធមិត្តនៅកងពល៧០៣ដូចគ្នាដែលបើករថក្រោះមកពីវាយវៀតណាមវិញ ហើយ សុផាត ក៏សុំធ្វើដំណើរមកជាមួយអ្នកទាំងនោះដែរ ។ ឃីម ជាមិត្តជិតស្និទ្ធរបស់គាត់ស្ទើរតែមិនជឿថា គាត់អាចរស់រានមានជីវិតត្រឡប់មកផ្ទះវិញសោះ ។ កងពល៧០៣ពេលនោះកំពុងរៀបចំប្រមូលកម្លាំងទ័ពសាជាថ្មី សុផាតគ្រាន់តែឮដូច្នេះក៏កើតការភ័យខ្លាច ហើយលួចរត់ចេញពីអង្គភាពសំដៅមកផ្ទះវិញភ្លាម ។

ពេលត្រឡប់មកដល់ផ្ទះ ស្រាប់តែមានការជ្រើសរើសទ័ពឡើងវិញដើម្បីឡើងសមរភូមិប្រយុទ្ធជាមួយក្រុមខ្មាំងខ្មែរក្រហម ហើយ សុផាត បានស្ម័គ្រចិត្តចូលធ្វើទាហានម្តងទៀត ។ នៅឆ្នាំ១៩៩០ សុផាត បានរៀបការប្រពន្ធឈ្មោះ សារុន ។ សព្វថ្ងៃនេះមានកូន៤នាក់ ដោយប្រកបមុខរបរធ្វើស្រែចម្ការដើម្បីផ្គត់ផ្គង់ជីវភាព ។ ចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម សុផាត យល់ដឹងព័ត៌មានតិចតួចណាស់ ព្រោះគាត់មមាញឹកនឹងការរករចិញ្ចឹមជីវិត ប៉ុន្តែទោះជាយ៉ាងណា សុផាត មានយោបល់ថាត្រូវតែបង្កើតតុលាការ វាជារឿងស្របច្បាប់និងយុត្តិធម៌សម្រាប់អ្នកដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបនោះ ។

**គាត លក្ខិណា**

# យុវជនកម្ពុជាត្រូវការយុត្តិធម៌

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលជាទូទៅត្រូវបានស្គាល់ថាជាតុលាការខ្មែរក្រហមបានក្លាយទៅជាប្រធានបទសម្រាប់ការពិភាក្សាជាសាធារណៈអស់មួយរយៈពេលមកហើយក្នុងប្រទេសកម្ពុជា ។ ចាប់តាំងពីពេលដែលរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងបង្កើតតុលាការខ្មែរក្រហមនៅក្នុងឆ្នាំ២០០០ ប្រជាជនបានធ្វើការជជែកពិភាក្សាលើលិខិតព្រមព្រៀងអំពីអ្វីដែលនឹងអាចប្រតិបត្តិក៏ដូចជាអ្វីដែលនឹងកើតមានឡើង ។ ប្រជាជនភាគច្រើនដែលបានចូលរួមនៅក្នុងការពិភាក្សា សុទ្ធតែជាអ្នកនៅរស់រានពីរបបខ្មែរក្រហមដែលជាអ្នកមានក្ដីសង្ឃឹមនិងការភ័យខ្លាចអំពីរឿងក្ដី ។ ក្រៅពីនេះមានរាប់បញ្ចូលទាំងអ្នកនយោបាយផ្សេងទៀតសមាជិកបណ្ឌិតសភានិងអ្នកតំណាងឲ្យសង្គមស៊ីវិលផង ។ ទោះបីជាយ៉ាងណាក៏ដោយ ការពិភាក្សាបន្តិចបន្តួចត្រូវបានឮពីយុវជនកម្ពុជាក្នុងការពិភាក្សាដ៏ធំនិងសំខាន់ជាសាធារណៈ ។

តាមរយៈស្ថិតិស្រង់ចំនួនប្រជាជនក្នុងឆ្នាំ១៩៩៨ ប្រជាជនកម្ពុជា ៦៨,៩ភាគរយ មានអាយុក្រោម៣០ឆ្នាំ និង ២៦,១ភាគរយមានអាយុនៅចន្លោះពី១៨ទៅ៣០ឆ្នាំ ។ ភាគច្រើននៃប្រជាជនវ័យក្មេងទាំងនេះគឺជាកូនរបស់ប្រជាជនកម្ពុជា (ទាំងជនរងគ្រោះនិងអ្នកប្រព្រឹត្តបទឧក្រិដ្ឋ) ដែលជាក្មេងជំទង់និងមានអាយុ២០ឆ្នាំក្នុងអំឡុងឆ្នាំកម្ពុជាប្រជាធិតេយ្យ (ឆ្នាំ១៩៧៥ដល់១៩៧៩) ។ ការសិក្សាមួយចំនួនត្រូវបានធ្វើឡើងសម្រាប់តែអ្នកដែលនៅរស់ពីរបបខ្មែរក្រហមដើម្បីធ្វើការសិក្សាពីអារម្មណ៍របស់អ្នកដែលនៅរស់ចំពោះបញ្ហានៃយុត្តិធម៌ ការទទួលខុសត្រូវនិងការផ្សះផ្សាជាតិ ប៉ុន្តែការយកចិត្តទុកដាក់បន្តិចបន្តួចត្រូវបានផ្ដល់ឲ្យកូនរបស់អ្នកដែលនៅរស់ ។ ខណៈដែលអ្នកដែលមានការទាក់ទងសំខាន់នៅក្នុងអនាគតរបស់ប្រទេសកម្ពុជា ក៏ដូចជាសមាជិករបស់សង្គម ដែលទទួលផលប៉ះពាល់ផ្ទាល់ដោយប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍របស់ប្រទេសកម្ពុជា នេះគឺជាការសំខាន់ដែលអ្នកជំនាន់ទី២និងទី៣ទាំងនេះត្រូវបានធ្វើការបញ្ឈប់និងបានទាក់ទងនៅក្នុងការពិភាក្សាជាសាធារណៈអំពីការជិតមកដល់របស់តុលាការខ្មែរក្រហម ។

ទោះបីជាយ៉ាងណាក៏ដោយ ការសិក្សាមួយក្នុងគោលបំណងដើម្បីនាំយកសំឡេងរបស់យុវជនកម្ពុជាចូលទៅក្នុងការពិភាក្សាពីតុលាការខ្មែរក្រហម ក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍ការយល់ដឹងពី ÷

- ◆ កម្រិតយល់ដឹងអត្តចរិតនិងអារម្មណ៍របស់យុវជនកម្ពុជាអំពីសម័យកម្ពុជាប្រជាធិបតេយ្យ ។
- ◆ វិធីនៃការចងចាំអំពើប្រល័យពូជសាសន៍ត្រូវបានផ្ទេរទៅកាន់អ្នកជំនាន់ទី២និងទី៣ ។
- ◆ អ្នកជំនាន់ទី២និងទី៣នេះឆ្លើយតបទៅនឹងបទពិសោធន៍នៃការប៉ះទង្គិចផ្លូវចិត្តពីជំនាន់អ្នកដែលនៅរស់ ។
- ◆ វិធីដែលប្រទេសកម្ពុជាបានជ្រើសរើសដើម្បីធ្វើការដោះស្រាយជាមួយនឹងបញ្ហាពីមុន ។

គម្រោងស្រាវជ្រាវអំពើប្រល័យពូជសាសន៍ដែលមាននៅក្នុងចិត្តយុវជនកម្ពុជាត្រូវបានរៀបចំដោយអ្នកនិពន្ធនិងបានប្រាក់ឧបត្ថម្ភពីក្រុមបម្រើសាសនាកាតូលិកកម្ពុជា ហើយនិងប្រតិបត្តិដោយអង្គការក្រៅរដ្ឋាភិបាលគឺអង្គការយុវជនកម្ពុជាដើម្បីសន្តិភាព ។ ការស្រាវជ្រាវនេះបានធ្វើឡើងនៅក្នុងឆ្នាំ២០០៥ ដែលមានយុវជនប្រហែល២០០នាក់មានអាយុពី១៨ទៅ២៧ឆ្នាំ ។ យុវជនចំនួន១០២នាក់ (ប្រុស៦៥នាក់ និងស្រី៣៧នាក់) នៅភ្នំពេញ, ព្រៃវែង តាកែវ កណ្ដាល និងខេត្តបាត់ដំបងបានបំពេញការស្ទាបស្ទង់មតិ នៅខណៈនោះយុវជន១០០នាក់ទៀតបានចូលរួមជាក្រុមដែលបានទទួលការចាប់អារម្មណ៍ ។ មួយចំនួនតូចក្រោម២ភាគ៣នៃអ្នកឆ្លើយតបការស្ទង់មតិគឺជាសិស្សវិទ្យាល័យ (៣៩/១០២) និងជានិស្សិតមហាវិទ្យាល័យ(២៣/១០២) ។ ចំនួននេះគឺសមរម្យដើម្បីទៅដល់ទីកន្លែងដែលយុវជនដើម្បី

សន្តិភាពបានធ្វើការនិងបានបង្កើតក្រុមមួយដែលចាប់អារម្មណ៍នៅក្នុងសកម្មភាពរបស់យុវជនដើម្បីសន្តិភាព ។

អត្ថបទនេះរាយការណ៍អំពីលទ្ធផលរបស់ការស្ទាបស្ទង់មតិដែលទាក់ទងទៅនឹងចំណេះដឹង និងការយល់ឃើញរបស់យុវជនចំពោះតុលាការខ្មែរក្រហម ។ របាយការណ៍នេះផ្តល់នូវចម្លើយមួយចំនួនចំពោះសំណួរដូចជាការស្ទាបស្ទង់មតិយុវជនធ្លាប់បានឮអំពីតុលាការខ្មែរក្រហមឬទេ? តើអ្វីដែលជាប្រភពព័ត៌មានរបស់យុវជន? តើយុវជនមានការយល់ឃើញយ៉ាងណាចំពោះសាលាក្តី? ហើយការគិតរបស់យុវជនដែលថា មេដឹកនាំខ្មែរក្រហមគួរតែទទួលការកាត់ទោសឬទេ? ជាបន្ទាប់ លទ្ធផលនៃការស្ទាបស្ទង់មតិគឺ ត្រូវបានប្រៀបធៀបជាមួយនឹងលទ្ធផលនៃការស្ទង់មតិ២របស់អ្នកដែលនៅរស់ៈ ការស្ទាបស្ទង់មតិរបស់វិទ្យាស្ថានខ្មែរដើម្បីប្រជាធិបតេយ្យទៅលើរបបខ្មែរក្រហមនិងតុលាការខ្មែរក្រហមដែលបានរៀបចំនៅក្នុងឆ្នាំ២០០៤ និងការស្ទង់មតិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទៅលើការផ្សះផ្សាជាតិដែលបានធ្វើឡើងនៅក្នុងឆ្នាំ២០០២ ។

នៅខណៈពេលដែលលទ្ធផលនៃការស្ទាបស្ទង់មតិផ្តល់នូវចម្លើយដំបូង យុវជនមិនបានទាមទារធ្វើជាអ្នកតំណាងយុវជនកម្ពុជាទាំងអស់នោះទេ ពីព្រោះការស្ទង់មតិនេះជាចំនួនតូច ។ ការសិក្សាបន្ថែមត្រូវការរៀបចំជាមួយនឹងចំនួនអ្នកតំណាងបន្ថែមដើម្បីបំពេញលទ្ធផលនៃការស្ទាបស្ទង់មតិដំបូងនេះ ។

***សំណួរស្ទាបស្ទង់មតិៈ តើអ្នកបានដឹងពីតុលាការខ្មែរក្រហមដោយវិធីណា?***

ក្នុងការស្ទាបស្ទង់មតិឆ្នាំ២០០៥ ភាគច្រើននៃការស្ទាបស្ទង់មតិរបស់យុវជនគឺបានដឹងអំពីសាលាក្តីៈ ៨២ភាគរយនៃអ្នកដែលរស់នៅតាមជនបទ និង៨៥ភាគរយនៃអ្នកដែលនៅទីក្រុងបានដឹងអំពីសាលាក្តីនេះ ។ នៅពេលដែលសួរអំពីប្រភពព័ត៌មានដែលបានដឹងយុវជនបាននិយាយថា ខ្លួនបានដឹងអំពីសាលាក្តីតាមរយៈវិទ្យុ ទូរទស្សន៍ កាសែតនិងសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាល ។ វាទំនងជាថា ភាគច្រើនចំនួនភាគរយនៃយុវជនកម្ពុជាដែលបានដឹងអំពីសាលាក្តីបានកើនឡើងតាំងពីឆ្នាំ២០០៥ ។

***សំណួរស្ទាបស្ទង់មតិៈ តើអ្នកគិតយ៉ាងណាចំពោះតុលាការខ្មែរក្រហម?***

ក្នុងការឆ្លើយតបទៅនឹងសំណួរនេះ យុវជនភាគច្រើនបានសម្តែងនូវការចាប់អារម្មណ៍ថា ការកាត់ទោសនឹងកើតមានឡើងអាស្រ័យដោយហេតុផលថា តុលាការនឹងនាំនូវការពិតយុត្តិធម៌និងការធូរស្បើយសម្រាប់អ្នកដែលនៅរស់ ។ លទ្ធផលមានតិចតួចដូចគ្នាទៅនិងការស្ទង់មតិរបស់យុវជនវិទ្យាស្ថានខ្មែរដើម្បីប្រជាធិបតេយ្យដែលបានបង្ហាញថា មួយភាគធំនៃអ្នកដែលនៅរស់ (៦១,៣ភាគរយ) ទទួលស្វាគមន៍សាលាក្តីនេះហើយ ហើយសង្ឃឹមថា «តុលាការខ្មែរក្រហមនឹងផ្តល់យុត្តិធម៌» ។ យុវជនមួយចំនួនយល់ស្របពីតុលាការខ្មែរក្រហមៈ

- «ខ្ញុំគិតថាការកាត់សេចក្តីនឹងឲ្យប្រជាជនដឹងពីអាថ៌កំបាំង (តើអំពើនេះកើតឡើងដោយរបៀបណា អ្នកណាដែលបានជាប់ទាក់ទងនៅក្នុងរបបនិងអ្នកណាដែលត្រូវស្តីបន្ទោស)» ។
- «ខ្ញុំគិតថា នេះជាការត្រឹមត្រូវដែលមានតុលាការខ្មែរក្រហមពីព្រោះអាចជួយឲ្យប្រជាជនខ្មែរមានអារម្មណ៍ប្រសើរនិងធូរស្រាល» ។

ស្របគ្នានិងគោលបំណងនេះ មានប្រជាជនមួយចំនួនដែលមានសំឡេងខឹងនិងសូមឲ្យមានចងពារៈ

- អ្នកឆ្លើយទី១៦ឆ្លើយថា «ខ្ញុំមានអារម្មណ៍រីករាយនិងខ្ញុំចង់ឲ្យមេដឹកនាំខ្មែរក្រហមត្រូវសម្លាប់សម្រាប់អំពើឃោរឃៅរបស់ខ្លួន» ។
- អ្នកឆ្លើយទី១៧ឆ្លើយថា «ខ្ញុំចង់ឃើញមេដឹកនាំខ្មែរក្រហមត្រូវបានកាត់ទោសសម្លាប់ដោយតុលាការខ្មែរក្រហម» ។

**ការយល់ដឹងពីសាលាក្តី**

យុវជនមួយចំនួនបានបញ្ចេញសំឡេងខ្វាយខ្វល់ពីភាពយុត្តិធម៌ ឯករាជ្យនិងសមត្ថភាពរបស់សាលាក្តីដែលនឹងមកដល់ការការពារ ការចូលរួមនិងគាំទ្រពីអន្តរជាតិ ។ ឧទាហរណ៍ៈ

- «ខ្ញុំមិនច្បាស់អំពីភាពយុត្តិធម៌និងឯករាជ្យនៃការកាត់សេចក្តី ។ ខ្ញុំឆ្ងល់ប្រសិនបើតុលាការអាចនាំអ្នកនិងប្រទេសដែលពាក់ព័ន្ធទៅតុលាការ ហើយនិងប្រសិនបើការកាត់សេចក្តីនឹងធ្វើឡើងពិតប្រាកដ» ។
- «ខ្ញុំគិតថា ការកាត់សេចក្តីរបស់ខ្មែរនឹងមិនអាចរកឃើញ

*អ្នកដែលជាឃាតករពិតប្រាកដទេ ដូច្នេះខ្ញុំសូមឲ្យការកាត់សេចក្តីអន្តរជាតិជួយទទួលខុសត្រូវ» ។*

◆ *«ប្រហែលជាមិនអាចពេញចិត្តនឹងការកាត់សេចក្តី ពីព្រោះមេដឹកនាំខ្មែរក្រហមមួយចំនួនបានស្លាប់ ឬក៏ចាស់ពេក និងមួយចំនួនបានក្លាយទៅជាមន្ត្រីរដ្ឋាភិបាល ខ្ញុំគិតថាសាលាក្តីនេះមិនឯករាជ្យ» ។*

*ប្រជាជនមួយចំនួនបានសង្កេតឃើញពីកង្វះឆន្ទៈនយោបាយ និងបានសម្តែងការសង្ស័យថាការកាត់សេចក្តីនឹងកើតមានឡើងឬទេ?*

◆ *«ខ្ញុំគិតថា ជាការពិបាកក្នុងការប្រតិបត្តិការកាត់សេចក្តី ពីព្រោះថារដ្ឋាភិបាលគ្មានសង្ឃឹមនឹងកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ទោះបីជាយ៉ាងណាក៏ដោយការកាត់សេចក្តីនឹងត្រូវធ្វើឡើង ខ្ញុំមិនដឹងពីចំនួនមេដឹកនាំប៉ុន្មាននាក់ដែលនឹងប្រឈមមុខទៅនឹងការកាត់សេចក្តីទេ ពីព្រោះមេដឹកនាំមួយចំនួនបានស្លាប់ ឬក៏មានវ័យចំណាស់ទៅហើយ» ។*

◆ *«ខ្ញុំគិតថា តុលាការខ្មែរក្រហមគួរតែធ្វើការឲ្យបានឆាប់រហ័ស ពីព្រោះមេដឹកនាំខ្មែរក្រហមកាន់តែមានវ័យចំណាស់ ។ បន្ថែមលើនេះទៀត សាលាក្តីគួរតែទទួលស្គាល់ដោយអន្តរជាតិ» ។*

◆ *«ខ្ញុំគិតថាកាន់តែឆាប់កាន់តែល្អ ។ អ្នកធ្វើអំពើបាបទាំងអស់ត្រូវតែនាំទៅតុលាការ ទោះបីជាសព្វថ្ងៃអ្នកធ្វើបាបទាំងនោះមានឋានៈខ្ពស់ក៏ដោយ ។ ខ្ញុំបានដឹងអំពីការកាត់សេចក្តីជាច្រើនឆ្នាំមកហើយ ខ្ញុំក៏មិនឃើញអ្វីដែលកើតមានយ៉ាងត្រឹមត្រូវដែរ» ។*

◆ *«ខ្ញុំយល់ថាការកាត់ទោសយឺតពេល ពីព្រោះខ្ញុំបានឮពីសាលាក្តីជាយូរមកហើយ ។ ខ្ញុំមិនដឹងថា រដ្ឋាភិបាលកំពុងគិតអ្វី» ។*

*សិស្សមួយចំនួនតូចមិនមានការគាំទ្រចំពោះសាលាក្តី ÷*

◆ *«ខ្ញុំគិតថា ការកាត់សេចក្តីដូចជាការដាក់ទោសខ្មែរខ្លួនឯងផ្ទាល់ ពីព្រោះថាប្រទេសដែលធ្លាប់ទាក់ទងនៅក្នុងរបបខ្មែរក្រហមគឺមិនអាចធ្វើការកាត់ទោស ហើយការកាត់សេចក្តីត្រូវការថវិកាជាច្រើន» ។*

*អ្នកតំណាងមួយចំនួនបានសម្តែងការយល់ឃើញថាសាលាក្តីនឹងមានតែនិមិត្តរូបប៉ុណ្ណោះ ÷*

◆ *«គ្រាន់តែជាការកាត់សេចក្តីប្រជាជនដែលបានស្លាប់ដើម្បីជួយឲ្យប្រជាជនអាចកាត់បន្ថយការឈឺចាប់» ។*

◆ *«ខ្ញុំគិតថា ជាការត្រឹមត្រូវដែលអតីតមេដឹកនាំខ្មែរក្រហមគួរតែទទួលការកាត់ទោស ប៉ុន្តែការកាត់ទោសមេដឹកនាំតែម្នាក់មិនអាចបំពេញបំណងប្រជាជនដែលបានស្លាប់រាប់លាននាក់ទេ» ។*

*យុវជនម្នាក់បាននិយាយអំពីការប្រឆាំងដែលអាចទៅរួចនៃការកាត់សេចក្តី ÷*

◆ *«ប្រសិនបើការកាត់សេចក្តីអនុញ្ញាតឲ្យអ្នកទោសរួចពីការកាត់ទោស ការអនុញ្ញាតនេះនឹងធ្វើឲ្យជនរងគ្រោះឆ្ងល់ ប៉ុន្តែអាចនឹងធ្វើឲ្យមិនមានមន្ទិលសង្ស័យប្រសិនបើដំណើរនាំឲ្យមានភាពយុត្តិធម៌និងអាចឲ្យជនរងគ្រោះស្ងប់ចិត្ត» ។*

## ***សំណួរស្ទង់មតិៈ តើអ្នកគិតថាមេដឹកនាំខ្មែរក្រហមគួរតែទទួលបានការកាត់ទោសឬទេ?***

*មួយភាគធំនៃអ្នកឆ្លើយតប (៩៧/១០២) គិតថាមេដឹកនាំខ្មែរក្រហមគួរតែទទួលការកាត់ទោស ដូច្នេះមេដឹកនាំទទួលខុសត្រូវសម្រាប់ «សកម្មភាពដែលមិនអាចអត់ឱនឲ្យបាន» ដូច្នេះភាពយុត្តិធម៌នឹងអាចមានសម្រាប់ជនរងគ្រោះ ។ ប្រជាជនមួយចំនួនបាននិយាយថា ការកាត់ទោសនឹងបញ្ជាក់ថាកម្ពុជាមានច្បាប់ហើយក៏ជាគំរូសម្រាប់អ្នកជំនាន់ក្រោយ ។*

*ការសាកសួរមិនបានបញ្ចូលសំណួរមួយអំពីមុខងារឬក៏កម្រិតនៃការទទួលខុសត្រូវដែលគួរតែទទួលបានការកាត់ទោស ។ ៧១.២៨ភាគរយនៃអ្នកឆ្លើយតបក្នុងការស្ទាបស្ទង់មតិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិយាយថា អ្នកឆ្លើយតបបានឃើញយុទ្ធជនថ្នាក់ទាបក៏ដូចជាជនរងគ្រោះស្លូតបូតមួយចំនួន ។ អ្នកឆ្លើយតបមិនបានយល់ថា ការបំបាត់ការផ្សព្វផ្សាយចំពោះចំណុចនេះនឹងមានប្រយោជន៍សម្រាប់សង្គម ។ ប្រហាក់ប្រហែលគ្នានឹងអ្នកឆ្លើយតបរបស់វិទ្យាស្ថានកម្ពុជាប្រជាធិបតេយ្យ៧៥,៣ភាគរយ បាននិយាយថា មេដឹកនាំខ្មែរក្រហមតែម្នាក់ដែលគួរតែទទួលបានការកាត់ទោស ។ នៅក្នុងឆ្នាំ២០០៥ ក្នុងការស្ទង់មតិបានទទួលចម្លើយប្រហាក់ប្រហែលគ្នាៈ ភាគតិចនៅក្នុងក្រុមនីមួយៗនិយាយថា យុទ្ធជនថ្នាក់ទាបគួរតែទទួលការកាត់ទោស ។ អ្នកមួយចំនួនទៀតនឹងមិនយល់ស្របដោយហេតុផលថា «យុទ្ធជនថ្នាក់ទាប*

គ្រាន់តែស្តាប់តាមបញ្ជា» ឬក៏ «អ្នកទាំងនេះត្រូវបានរាប់បញ្ចូលទៅក្នុងសង្គម» ។

បុរសម្នាក់នៅក្រុងភ្នំពេញបានរៀបរាប់ថា នៅក្នុងភូមិរបស់គាត់ មានស្ត្រីម្នាក់បានឃើញបុរសម្នាក់ដែលបានសម្លាប់សាច់ញាតិរបស់គាត់ ។ ប៉ុន្តែស្ត្រីមិនអាចធ្វើអ្វីបានទេ ពីព្រោះតែគ្មានភ័ស្តុតាង ។ «ពីព្រោះតែគ្មានភ័ស្តុតាង» បុរសបាននិយាយថា «ប្រជាជនគិតថាតុលាការនឹងមិនអាចដាក់ទោសចំពោះអ្នកធ្វើខុស ។ ដូច្នេះមួយចំនួនបានសម្រេចសម្លាប់អតីតខ្មែរក្រហមដោយខ្លួនឯងផ្ទាល់ ។ នេះជារឿងពិបាកដើម្បីរកយុត្តិធម៌ ។ ដោយសារតែគ្មានភ័ស្តុតាងត្រូវចំណាយរយៈពេលយូរ ។ រឿងដែលយើងអាចធ្វើគឺគ្រាន់តែកាត់ទោសតែមេដឹកនាំកំពូល» ។ នៅចំណុចនេះ ក្រុមអ្នកស្ទង់មតិបានសួរទៅក្រុមថា ការទទួលខុសត្រូវកម្រិតណាដែលគួរតែទទួលការកាត់ទោស ។ ភាគច្រើនគឺសម្រាប់ការកាត់ទោសតែមេដឹកនាំកំពូលៗប៉ុណ្ណោះ ។ ប្រជាជនមួយចំនួននិយាយថា «ប្រសិនបើកាត់ទោសទាំងអស់ សង្គ្រាមនឹងផ្ទុះឡើងម្តងទៀតនៅក្នុងប្រទេសកម្ពុជា» ។

យុវជនមួយចំនួនគិតថា ប្រទេសដែលគាំទ្ររបបខ្មែរក្រហមក៏គួរតែប្រឈមមុខនឹងការកាត់ទោសដែរ ។

◆ «ប៉ុន្តែការកាត់ទោសមិនគ្រាន់តែកាត់ទោសខ្មែរក្រហមទេ គួរតែកាត់ទោសប្រទេសដែលបានជាប់ទាក់ទងនៅក្នុងរបបខ្មែរក្រហមផង» ។

◆ បានឃើញសាលាក្តីក៏ដូចជាឱកាសសម្រាប់ការពិភាក្សា៖ «បាទ! ការកាត់ទោសនឹងជាការព្រមានដល់មេដឹកនាំក្រោយៗ ដើម្បីកុំឲ្យមេដឹកនាំហ៊ានប្រព្រឹត្តមិនសមហេតុសមផលក្នុងអំឡុងពេលដឹកនាំប្រទេស ហើយការកាត់ទោសនឹងជាពេលវេលាល្អមួយដើម្បីធ្វើការពិភាក្សាអំពីរបបខ្មែរក្រហមផងដែរ» ។

អ្នកឆ្លើយតបពីរនាក់បាននិយាយថាមិនគួរកាត់ទោសមេដឹកនាំខ្មែរក្រហមទេ៖

◆ «ទេ! ដូចដែលបានរៀបរាប់មុននេះ ទោះបីជាតុលាការប្រើការកាត់ទោសប្រហារជីវិតដើម្បីកាត់ទោសខ្មែរក្រហមក៏ដោយ តុលាការមិនអាចធ្វើការផ្លាស់ប្តូរអ្វីទាំងអស់ ។ តុលាការមិនអាចឲ្យកំណើតអ្នកស្លាប់ម្តងទៀត និងធ្វើឲ្យប្រទេសកម្ពុជាប្រសើរឡើង» ។ (គួរកត់សម្គាល់ថា ប្រទេសកម្ពុជាមិនមានការកាត់ទោសប្រហារជីវិតទេ) ។

◆ «ទេ! ដោយសារខ្ញុំគិតថា ខ្មែរក្រហមបានទទួលបញ្ជាពីមេដឹកនាំជាន់ខ្ពស់» ។

លើសពីនេះទៀត ចំពោះយុវជនដែលបានចូលរួមនៅក្នុងការស្ទាបស្ទង់មតិ យុវជននៅក្នុងក្រុមដែលទទួលបានការចាប់អារម្មណ៍បានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនទៅលើអង្គជំនុំជម្រះវិសាមញ្ញ ។ យុវជនមានសំណួរជាច្រើនអំពីដំណើរការតុលាការខ្មែរក្រហម៖ យុវជនចង់ដឹងពីដីកានិងនីតិវិធីរបស់តុលាការខ្មែរក្រហម ។ យុវជនបានសួរសំណួរជាច្រើន ទោះបីជាគ្មានគោលបំណងឬការកំណត់រយៈរបស់ក្រុមស្រាវជ្រាវនេះក៏ដោយ ។ តុលាការបានទទួលប្រភពព័ត៌មាននៅក្នុងសាលាក្តីដែលបានរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជានិងបានចែកចាយព័ត៌មានទាំងនោះទៅអ្នករាល់គ្នាដែលជាយុវជននៅក្នុងក្រុមដែលទទួលបានការចាប់អារម្មណ៍ ។

គំនិតរបស់យុវជនដែលបានធ្វើការស្ទង់មតិចំពោះតុលាការខ្មែរក្រហមហាក់ដូចជាឆ្លុះបញ្ចាំងពីគំនិតជាច្រើននៅក្នុងសង្គមកម្ពុជា ។ ទោះបីជាយ៉ាងណាក៏ដោយគំនិតមួយដែលត្រូវទុកនៅក្នុងចិត្តថា ក្រុមរបស់យុវជនស្ទាបស្ទង់មតិ ជាទូទៅត្រូវបានបង្ហាញពីគុណសម្បត្តិធំជាមួយនឹងការចូលទៅដល់ការអប់រំ ។ លទ្ធផលមួយនៅក្នុងការស្រាវជ្រាវនេះ គឺថាការស្ទាបស្ទង់មតិរបស់យុវជនមិនបានគ្រប់គ្រាន់បញ្ជាក់ពីប្រវត្តិសាស្ត្រអំពើប្រល័យពូជសាសន៍នោះទេ ។ ដូច្នេះការពិភាក្សាអំពីតុលាការខ្មែរក្រហមផ្សារភ្ជាប់នឹងសំណួរជាច្រើនសម្រាប់យុវជនអំពីសម័យកម្ពុជាប្រជាធិបតេយ្យនិងពង្រឹងការស្វែងរកយុត្តិធម៌សម្រាប់គ្រួសាររបស់យុវជន ។ ខណៈដែលជាអ្នកមានការទាក់ទងសំខាន់នៅក្នុងអនាគតរបស់ប្រទេសកម្ពុជា ក៏ដូចជាសមាជិករបស់សង្គមដែលមានឥទ្ធិពលដោយផ្ទាល់នៅអំឡុងពេលនេះ យុវជនចាំបាច់ត្រូវទទួលបានសំណួរអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងចម្លើយបច្ចុប្បន្នរបស់តុលាការខ្មែរក្រហម ។ សមាជិករបស់សង្គមស៊ីវិលនៅកម្ពុជាគួរតែចាប់ផ្តើមទទួលខុសត្រូវដើម្បីរួមចំណែកជួយសម្រួលបញ្ហានេះ ។ **ប៊ីវ៉ូ ម៉ុនយ៉ាស**

# ការជួបប្រជុំរបស់បញ្ញវន្តជំនាញប្រល័យពូជសាសន៍ របាយការណ៍ការប្រជុំនៅឆ្នាំ២០០៧

ក្រោមជួរភ្នំទឹកកកដេឡាសនីកានិងក្បែរផ្ទះក្រាលឥដ្ឋក្រហមដែលមានដើមឈើកំពុងផ្លែលម្អភ្នំពណ៌បៃតងនៅទីក្រុងសារ៉ាជីវូ គឺជាទីតាំងសម្រាប់ការប្រជុំពីប្រធានបទអំពើប្រល័យពូជសាសន៍ ។ តើហេតុអ្វីបានជាសមាគមអន្តរជាតិនៃបញ្ញវន្តជ្រើសរើសទីក្រុងរបស់ប្រទេសបូស្នៀ-ហ្សឺហ្សេហ្គោវីណា ជាកន្លែងសម្រាប់ការជជែកជាអន្តរជាតិស្តីពីអំពើប្រល័យពូជសាសន៍ ។ នៅក្នុងឆ្នាំ ១៩៩០ គម្រោងមិនបានសម្រេចរបស់អតីតប្រធានាធិបតីយូហ្គោស្លាវី ស្លូបូដាន មីឡូសូវិក ដើម្បីបង្កើតទីតាំងជនជាតិស៊ែបដ៏ធំមួយ ក្រោយពេលដែលលទ្ធផលនៃការបែងចែកមួយចំនួននៅក្នុងការសម្លាប់ដ៏ច្រើនសន្ធឹកសន្ធាប់ឆ្លងកាត់តំបន់បាល់កង់និងការប្រល័យពូជសាសន៍ដែលមិនអាចប្រកែកបាន ។ ប្រទេសបូស្នៀ-ហ្សឺហ្សេ ហ្គោវីណា គឺជាផ្នែកមួយរបស់អតីតប្រទេសយូហ្គោស្លាវីរហូតដល់ឆ្នាំ១៩៩០ ។ ប្រទេសនេះមានប្រជាជនបីក្រុមសំខាន់ៗៈ ជនជាតិបូស្នៀមូស្លីម, ស៊ែប ៣២ភាគរយ និងជនជាតិក្រូអាត ។ បូស្នៀបានប្រកាសឯករាជ្យពីប្រទេសយូហ្គោស្លាវី នៅក្នុងឆ្នាំ១៩៩២ ដែលធ្វើឲ្យប្រជាជនស៊ែបប្រឆាំងជំទាស់ ។ សង្គ្រាមបានផ្ទុះឡើង ហើយការបោសសម្អាតជាតិពន្ធុបានកើតមាន ។ សង្គ្រាមនៅតែបន្តឆាបឆេះដោយជនជាតិស៊ែប-បូស្នៀប្រឆាំងនឹង ជនជាតិដែលមិនមែនជាជនជាជនជាតិស៊ែប-បូស្នៀ ។ ជាលទ្ធផលប្រជាជនប្រហែល២០ម៉ឺននាក់ត្រូវបានសម្លាប់នៅក្នុងការប្រយុទ្ធប្រឆាំងនេះ ។ ការសម្លាប់យ៉ាងជាក់ស្តែងបំផុតបានកើតមានឡើងនៅក្នុង «ជម្រកសុវត្ថិភាព» របស់អង្គការសហប្រជាជាតិនៅស្រ៊ីប្រេនីស្សា ជាកន្លែងដែលប្រជាជនរាប់ពាន់នាក់ត្រូវបានសម្លាប់ដោយទាហានស៊ែបនៅខែកក្កដា ឆ្នាំ ១៩៩៥ ។ជាងមួយទសវត្សរ៍ក្រោយមក ផ្នូរខ្មោចជាច្រើននៅមិនទាន់បានរកឃើញតាមតំបន់មួយចំនួននៃទីក្រុងនេះជាហេតុធ្វើឲ្យប្រជាជនបូស្នៀមួយចំនួនយល់ថា «ការសម្លាប់ដោយស្ងាត់ៗ» គឺកំពុងតែប្រព្រឹត្តទៅ ។

នៅអាហ្វ្រិកនិងអាស៊ី ក៏បានធ្វើការប្រជុំអំពីការសម្លាប់ដែលគួរឲ្យកត់សម្គាល់បំផុតនៅក្នុងប្រទេសរ៉្វាន់ដានិងប្រទេសកម្ពុជាដែរ ។ បច្ចុប្បន្នប្រទេសទាំងពីរកំពុងស្វែងរកយុត្តិធម៌តាមគំរូផ្សេងគ្នា ។ ប្រទេសរ៉្វាន់ដាកំពុងដាក់ការវិនិច្ឆ័យបីនៅថ្នាក់អន្តរជាតិ ជាតិ និងនៅក្នុងស្រុក ខណៈពេលដែលប្រទេសកម្ពុជានាពេលបច្ចុប្បន្នកំពុងតែនិយាយពីច្បាប់យុត្តិធម៌តាមរយៈអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលរួមបញ្ចូលតុលាការជាតិនិងអន្តរជាតិ ។ ខណៈពេលដែលប្រព័ន្ធច្បាប់ស្វែងរកយុត្តិធម៌សម្រាប់អ្វីដែលបានកើតឡើងនៅក្នុងអតីតយូហ្គោស្លាវី រ៉្វាន់ដា និងកម្ពុជា អំពើប្រល័យពូជសាសន៍កំពុងតែធ្វើឡើងនៅទីក្រុងដាហ្វ័រប្រទេសស៊ូដង់នាពេលបច្ចុប្បន្ន ។ ជាការចំអកមួយដែលចំណងជើងរបស់ការប្រជុំរយៈពេលជាច្រើនសប្តាហ៍ក្នុងឆ្នាំនេះគឺសមាគមអន្តរជាតិនៃបញ្ញវន្តជំនាញប្រល័យពូជសាសន៍គឺ «ការការពារអំពើប្រល័យពូជសាសន៍មុនពេលកើតមានឡើង» ។ នៅក្នុងឆ្នាំ២០០៤ អតីតរដ្ឋមន្ត្រីក្រសួងការបរទេសនៃសហរដ្ឋអាមេរិក ខូលីនផូវែល បានប្រកាសថាការរំលោភនិងសម្លាប់ជាច្រើននៅដាហ្វ័រគឺដូចគ្នាទៅនឹងអំពើប្រល័យពូជសាសន៍ ។ ប៉ុន្មានឆ្នាំក្រោយមក នៅក្នុងខែសីហា ឆ្នាំ ២០០៧ អង្គការសហប្រជាជាតិបានប្រកាសថា នឹងបញ្ជូនកម្លាំងទៅដាហ្វ័រ ។ នៅពេលនោះតាមការប៉ាន់ស្មានមានប្រជាជនចំនួន ២០ម៉ឺននាក់បានស្លាប់និង២លាននាក់ទៀតត្រូវផ្លាស់ទីលំនៅតាំងពីឆ្នាំ២០០៣ ។ ការជួបប្រជុំរបស់បញ្ញវន្តអំពើប្រល័យពូជសាសន៍នៅសារ៉ាជីវូក្នុងគោលបំណងដើម្បីជជែកពីបញ្ហានេះនិងបញ្ហាផ្សេងៗទៀត ។ តាមរយៈការពិភាក្សាទៅលើទីក្រុងដាហ្វ័រ អំពើប្រល័យពូជសាសន៍ពីអតីតកាលជាតួនាទីរបស់សហគមន៍អន្តរជាតិនិងអង្គការសហប្រជាជាតិជាបញ្ញត្តិនិងទ្រឹស្តី វិធីប្រព័ន្ធច្បាប់យុត្តិធម៌ ហើយនិងសាក្សីផ្ទាល់ខ្លួន, ការប្រជុំរបស់សមាគមអន្តរជាតិនៃបញ្ញវន្តអំពើប្រល័យពូជសាសន៍គឺជាជំហានមួយសម្រាប់ការលើកកម្ពស់ការយល់ដឹងទៅលើអំពើប្រល័យពូជសាសន៍និងការ

បង្កើតអាហារូបករណ៍ស្តីពីអំពើប្រល័យពូជសាសន៍និងតំបន់ដែលមានការទាក់ទង ។

ការប្រជុំដែលប្រារព្ធឡើងពីថ្ងៃទី៩-១៣ ខែកក្កដា នៅភាគខាងត្បូងតំបន់អាយលីហ្សា ត្រូវបានទទួលស្វាគមន៍ដោយវិទ្យាស្ថានស្រាវជ្រាវបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិនិងសាកលវិទ្យាល័យច្បាប់អន្តរជាតិរបស់សារ៉ាជីវ៉ូ និងត្រូវបានរំឭកចំពោះការចងចាំរបស់សាស្ត្រាចារ្យ អេរិក ម៉ាកូសេន នៅក្នុងស្មារតីនៃការលះបង់ខ្ពស់ដើម្បីការសិក្សាពីវិធីសម្លាប់ដែលបានប្រព្រឹត្តឡើងដោយប្រជាជនជាច្រើន ដែលអ្នកទាំងនោះពីមុនឬក្រោយមកជាជនរងគ្រោះ ។

សាស្ត្រាចារ្យនិងបញ្ញវន្តដែលមានចំនួនប្រហែល៣០០ នាក់បានចូលរួមក្នុងការប្រជុំនេះមានមកពីប្រភពផ្សេងៗគ្នា ដោយហេតុនេះបង្កើតបានជាពីរក្រុម គឺក្រុមដែលមានការយល់ដឹងនៅក្នុងតំបន់ផ្សេងៗនិងក្រុមដែលចាប់អារម្មណ៍ ។ ប្រធានបទទាក់ទងនឹងការសម្តែងល្ខោន សិល្បៈ និងភាពយន្តក៏ត្រូវបានលើកយកមកពិភាក្សាដែរ ។ ការប្រជុំបានបង្ហាញពីឱកាសជាច្រើនសម្រាប់អ្នកចូលរួមគ្រប់កម្រិត និងជាឱកាសសម្រាប់និស្សិតដែលមិនទាន់បញ្ចប់ការសិក្សាដើម្បីយល់និងអាចជួបបញ្ញវន្តដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញដូចជា ហ្វ្រែង ឆក និង អ៊ីស្រាអែល ឆារនី ។ ការប្រជុំបានផ្តល់ឲ្យនូវមុខមាត់និងសំឡេងរៀមច្បងដែលមានចំណេះដឹងជ្រៅជ្រះពីអំពើប្រល័យពូជសាសន៍ដែលភាគច្រើនជាមនុស្សមិនទម្រើសខ្លួន ។ ការប្រជុំនេះក៏បានផ្តល់ជាវេទិកាមួយសម្រាប់សមាជិករបស់សមាគមអន្តរជាតិនៃបញ្ញវន្តអំពើប្រល័យពូជសាសន៍ឡើងថ្លែងការងាររបស់សមាគមនិងលើកកម្ពស់ឲ្យមានការចូលរួមកាន់តែដុសដុលពីសំណាក់និស្សិត ។ គួរឲ្យកត់សម្គាល់បំផុតថា ការប្រជុំនេះបាននាំឲ្យមានការជួបជុំគ្នាជាសមាគមមួយរបស់អ្នកសិក្សា គ្រូបង្រៀននិងអ្នកស្រាវជ្រាវបានបង្ហាញទៅលើការវិភាគនិងស្វែងយល់ពីបទឧក្រិដ្ឋដ៏ឃោរឃៅបំផុតនៅសតវត្សរ៍ទី២០ជាមួយនឹងក្តីសង្ឃឹមក្នុងការបញ្ចប់អំពើប្រល័យសម្លាប់ ។

តាមច្រកចូលដែលមានទ្វារបន្ទប់ប្រជុំបានដាក់ឈ្មោះមនុស្សពីក្រោយរូបភាពសោកក្នុងការសិក្សាអំពើប្រល័យពូជសាសន៍ ដូចជា លីមគិន រ៉ូម (បានដាក់ឈ្មោះក្រោយអ្នកសកម្មនិយម រ៉ាហ្វារអេល លីមគិន ដែលបានបង្កើតក្រុមសិក្សាអំពើប្រល័យពូជសាសន៍ មុនពេលមានការសម្លាប់ដាក់ស្តែងរបស់ជនជាតិជ្វីហ្វនិងក្រុមជនជាតិភាគតិចផ្សេងទៀតនៅក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២) អ្នកចូលរួមបានជ្រើសរើសក្រុមដែលខ្លួនចូលចិត្ត ។ អ្នកបង្ហាញម្នាក់ៗមានពេលវេលាឡើងនិយាយតែ១០នាទី ដូច្នេះម្នាក់ៗប្រញាប់ប្រញាល់ធ្វើការសរុបសេចក្តីរបស់ខ្លួន ហើយអ្នកផ្សេងទៀតគ្រាន់តែអាចលើកយកផ្នែកសំខាន់ៗពីក្រដាសស្រាវជ្រាវរបស់ខ្លួនប៉ុណ្ណោះ ។ ការសិក្សាសំណួរនិងចម្លើយខ្លីៗបានផ្តល់ឲ្យនូវពេលវេលាសមរម្យសម្រាប់តែសំណួរមួយចំនួនដែលត្រូវបានសួរនិងឆ្លើយ ។ ទោះបីជាយ៉ាងណាក៏ដោយមានការផ្លាស់ប្តូរ ការជជែករបស់បញ្ញវន្តនៅអំឡុងពេលប្រជុំ ហើយការកំណត់ពេលវេលាបានបញ្ឈប់ទៅតាមលទ្ធភាពចំពោះការអូសបន្លាយការសន្ទនានៅក្នុងពេលកំពុងធ្វើការបង្ហាញនេះ ។ ការជជែកទាំងនេះនឹងបន្តក្រោយពេលដែលការប្រជុំសម្រាកដើម្បីផឹកកាហ្វេបូស្សៀ ឬស្រាបៀរ ។ សរុបមក សន្និសីទនេះធ្វើឡើងរយៈពេលបួនថ្ងៃដែលក្នុងមួយថ្ងៃមាន៦ក្រុម ហើយជាមធ្យមក្នុងមួយក្រុមមានបញ្ញវន្ត៥នាក់ឡើង និយាយអំពីការងាររបស់ខ្លួនជារួមអ្នកឡើងនិយាយអំពីការងាររបស់ខ្លួនមានចំនួនទាំងអស់ ១២០នាក់ ។ នេះមិនបូកបញ្ចូលទាំងការបញ្ចាំងភាពយន្តក្រោយពេលអាហារពេលល្ងាចរាល់យប់ផង ។ នៅក្នុងចំណោមអ្នកឡើងបង្ហាញជាមួយការស្រូបយកព័ត៌មាននិងការណែនាំខ្លួនបានសំដៅច្រើនទៅលើហេតុផលនៃអំពើប្រល័យពូជសាសន៍ផ្សេងៗគ្នា ប៉ុន្តែអ៊ីលេចធ្លោជាងគេនោះ គឺអ្នកទាំងនេះបង្ហាញពីអារម្មណ៍ឈឺចាប់នឹងអំពើទាំងអស់នោះ ។

ការធ្វើសាក្សីដោយផ្ទាល់ចំពោះការធ្វើទារុណកម្មនិងការនៅរស់គឺជាប់ទាក់ទងជាមួយនឹងអារម្មណ៍ជាពិសេសនៅពេលដែលសាក្សីនៅវ័យក្មេង ។ នៅយប់ថ្ងៃច័ន្ទនៅក្នុងបន្ទប់ម៉ាគុសិន និស្សិតក្លាហានរបស់ជនជាតិបូស្នៀ៨នាក់បានបង្ហាញខ្លួន អ្នកទាំងអស់ចាំស្តាប់អំពីបទពិសោធន៍ដ៏គួរឲ្យរន្ធត់របស់ខ្លួននៅក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍ ។ និស្សិតបាននិយាយអំពីអារម្មណ៍លាក់ពុតរបស់កងកម្លាំងអគ្គការសហប្រជាជាតិហូល្លង់ដែលនិស្សិត

ជឿជាក់ថា នឹងអាចការពារប្រជាជនបាន ប៉ុន្តែវាបានជំនួសមកវិញនូវការសម្លាប់យ៉ាងរង្គាលនូវក្រុមគ្រួសាររបស់និស្សិតអ្នកជិតខាង និងអ្នករស់នៅស្រុកក្រៅទៅវិញ ។ ក្រុមនិស្សិតក៏បាននិយាយអំពីក្តីសង្ឃឹមរបស់ខ្លួនថា នឹងអាចរកឃើញឆ្អឹងអ្នកជាទីស្រឡាញ់ដើម្បីយកមកធ្វើបុណ្យសពយ៉ាងពិតប្រាកដ ។ ក្នុងអំឡុងពេលដែលនិស្សិតធ្វើការបង្ហាញ អ្នកចូលរួមទាំងចាស់ ទាំងក្មេងរំជួលចិត្តដោយសាររឿងរបស់និស្សិត ។ លីហ្សាប៊ែត មេយ័រ ជានិស្សិតដែលជិតនឹងបញ្ចប់ការសិក្សានៅសាលាសេដ្ឋកិច្ចនិងវិទ្យាសាស្ត្រនយោបាយក្នុងក្រុងឡុងដ៍ ដែលបង្ហាញពីការចងចាំយ៉ាងច្បាស់នូវពាក្យសម្តីរបស់បុរសម្នាក់ «ដែលបានរៀបរាប់អំពីម្តាយរបស់គាត់ដែលព្យាយាមសម្លាប់ខ្លួននិងកូនរបស់គាត់ដោយសារលំបាកវេទនាខ្លាំងពេក» ហើយក្រោយមក «ដោយសារមិនអាចបញ្ចុះបញ្ចូលកូនរបស់ខ្លួនបាន គាត់ក៏បានលោតចូលទៅក្នុងទន្លេសម្លាប់ខ្លួនតែម្នាក់ឯង» ។ចម្លើយផ្ទាល់ពីសាក្សី និងសាក្សីផ្សេងទៀតដែលចេញពីនិស្សិត៨នាក់ទៀតបានធ្វើឲ្យយើងនឹកឃើញពីការលំបាកដែលអង្គការសហប្រជាជាតិនិងគណៈអន្តរជាតិផ្សេងទៀតបានធ្វើការការពារនិងបញ្ឈប់អំពើប្រល័យពូជសាសន៍ ហើយដែលចុងក្រោយបានជួយសង្គ្រោះជីវិតរាប់ពាន់នាក់បើទោះជាមិនបានជួយសង្គ្រោះជីវិតរាប់លាននាក់ក៏ដោយ ។ ប្រជាជនបូស្នៀមិនបានបំភ្លេចភាពបរាជ័យរបស់អង្គការសហប្រជាជាតិនៅស្រ៊ីប្រេនីស្សា និងកន្លែងផ្សេងទៀតឡើយ ។ របួសនៃអំពើប្រល័យពូជសាសន៍នៅស្រស់ៗនៅឡើយនៅក្នុងប្រទេសបូស្នៀដោយសារផ្នូរសាកសពជាច្រើនគឺនៅតែកំពុងធ្វើការស្វែងរកនៅក្នុងផ្នែកមួយនៃប្រទេសនេះ ។

នៅយប់បន្ទាប់នៅពេលដែលអ្នកថ្លែងសុន្ទរកថាប្រកបដោយការគោរពឈ្មោះ កាឡា ដេល ប៉ុនតេ បានមកដល់ដើម្បីទទួលរង្វាន់ បានបង្ហាញថា មានអ្នកមួយចំនួនដែលអាចយល់បានបង្ហាញពីការខកចិត្តរបស់ខ្លួនចំពោះការងារបច្ចុប្បន្នរបស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិរបស់អតីតយូហ្គោស្លាវី ។ នៅលើឆាកមានមន្ត្រីជាន់ខ្ពស់សមាគមអន្តរជាតិនៃបញ្ញវន្តអំពើប្រល័យពូជសាសន៍អង្គុយជាមួយប្រធានព្រះរាជអាជ្ញា កាឡា ដេល ប៉ុនតេ និងគណៈមេធាវីនៅឯការិយាល័យព្រះរាជអាជ្ញាឈ្មោះ ន័រមិន ហ្វារេល ។ ហ្វារេល បានចាប់ផ្តើមដំបូងដោយការពន្យល់អំពីតួនាទីនិងការលំបាកដែលទាក់ទងនឹងការងារនៅការិយាល័យរបស់លោក រួមទាំងភាពស្មុគស្មាញទាក់ទងនឹងការផ្តល់ករណីច្បាប់នៃអំពើប្រល័យពូជសាសន៍ ។ ព្រះរាជអាជ្ញា ដេល ប៉ុនតេ បានមកដល់តាមក្រោយនិងបាននិយាយ ។ បន្ទាប់មានការសួរសំណួរ ហើយមានអ្នកលើកដៃជាច្រើន ។ សំណួរមួយចំនួនព្រះរាជអាជ្ញា ដេល ប៉ុនតេ បានឆ្លើយដោយខ្លួនឯង និងសំណួរផ្សេងទៀត ព្រះរាជអាជ្ញាបានប្រគល់ជូនលោក ហ្វារេល ដែលបានឆ្លើយយ៉ាងស្ងៀមស្ងាត់និងឥតលម្អៀង ។

ការទាមទារមួយចំនួននៅក្នុងច្បាប់និងទិដ្ឋភាពពិតប្រាកដនៅក្នុងករណីដូចជាការបង្ហាញ «បំណង» ចាត់ជា «ធាតុនៃអំពើប្រល័យពូជសាសន៍» និងបញ្ហានៃគ្រោះថ្នាក់ដល់គំនិតនិងរាងកាយ ។ អ្នកខ្លះទៀតបានសួរលម្អិតអំពីអ្នកទាំងនោះត្រូវបានចាប់ខ្លួនឬក៏មូលហេតុដែលអ្នកមួយចំនួនផ្សេងទៀតមិនត្រូវបានចាប់ខ្លួន ហើយមួយចំនួនទៀតបានសួរអំពីគុណភាពអំពីវិធីនៃការប្រើប្រាស់រឿងក្តីនិងភ័ស្តុតាងដ៏ច្រើន ។ នៅក្នុងសំណួរដែលទាក់ទងនឹងភ័ស្តុតាងមួយផ្នែក ស្ត្រីម្នាក់បានសួរទៅកាន់ប្រធានព្រះរាជអាជ្ញាថា «តើលោកសោកស្តាយចំពោះការថែរក្សាសោឯកសារសម្ងាត់របស់ប្រជាជនស៊ែបទេ» បន្ថែមលើនេះថា នាងចង់ឲ្យព្រះរាជាអាជ្ញាឆ្លើយ «មិនមែនក្នុងនាមជាប្រធានព្រះរាជអាជ្ញាទេ ប៉ុន្តែក្នុងនាមជាមនុស្សជាតិ» ។ អ្នកផ្សេងទៀតបានសួរទៅ ដេល ប៉ុនតេ ថា «ខ្ញុំចង់ដឹងថាហេតុអ្វីបានជាអ្នកមិនបានធ្វើការងាររបស់អ្នកឲ្យបានត្រឹមត្រូវ» ។ សំណួរនេះគឺយោងបញ្ជាក់ទៅមេដឹកនាំកំពូលរបស់ទាហានស៊ែបដែលមិនត្រូវបានចោទប្រកាន់ ។ នៅចុងបញ្ចប់ការប្រជុំ ដេល ប៉ុនតេ ត្រូវបានបង្ហាញជាមួយនិងរង្វាន់មួយរបស់គាត់សម្រាប់«វិភាគទានដ៏ល្អដើម្បីការអភិវឌ្ឍន៍របស់ប្រព័ន្ធច្បាប់អន្តរជាតិដើម្បីបញ្ចប់និទ្ទណ្ឌភាពសម្រាប់ឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍» ។

នៅថ្ងៃពុធ សមាជិកសន្និសីទបានទៅទស្សនាផ្នូរសាកសពជាច្រើននិងបានចូលរួមពិធីបុណ្យសពរបស់ជនរងគ្រោះ៤៦៥នាក់ ដែលសាកសពត្រូវបានគាស់ចេញពីដីនៅប៉ូតូការី ជាយក្រុងស្រ៊ីប្រេនីស្សា ដែលទីតាំងនេះអាចជិះរថយន្តក្រុងរយៈពីរម៉ោងពីទីក្រុងសារ៉ាជីវ៉ូ ។

ពេលបានមកដល់កន្លែងផ្នូរសាកសព សមាជិកប្រជុំបានណែនាំពីជនជាតិបូស្នៀសំខាន់ពីររូបដែលមានជាប់ទាក់ទងយ៉ាងជ្រៅជាមួយនឹងការគាស់សាកសពជាច្រើនចេញពីរណ្តៅនេះ ។ ទីមួយគឺសុភាពបុរសដែលបានលះបង់ជីវិតរបស់ខ្លួនក្នុងការរកឃើញនិងការជីករណ្តៅនេះដែលឬពុំមានការខុបត្ថម្ភពីអាជ្ញាធរប្រចាំតំបន់នោះ ។ អ្នកទីពីរគឺចៅក្រមម្នាក់ទទួលខុសត្រូវការស្តាបនាករណីរបស់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ស្រ៊ីប្រេនីស្សា ។ ដូចនេះក្រុមសមាជិកប្រជុំបានប្រមូលផ្តុំគ្នានៅជុំវិញដីដែលបានជីកដោយជនទាំងពីរនេះដែលបានពន្យល់អំពីការងាររបស់ខ្លួននិងឆ្លើយទៅនឹងសំណួរជាច្រើន ។

ផ្នូរសាកសពមានរាងជាចតុកោណកែងមានទទឹង៥ម៉ែត្រនិងបណ្តោយ១៥ម៉ែត្រ ។ គួរឲ្យកត់សម្គាល់គឺភាគខ្លះនៃសាកសពកប់នៅក្នុងសម្លៀកបំពាក់ដែលកខ្វក់ជាច់រយ៉ីរយ៉ៃដែលមានក្រហម ខ្មៅនិងខៀវ រួមទាំងឆ្អឹងនិងលលាដ៍ក្បាល ។ តំបន់នេះត្រូវបានរកឃើញដោយចៃដន្យ ។ គ្មាននរណាម្នាក់ស្មានដល់ថា មានផ្នូរសាកសពនៅទីនេះទេ ពីព្រោះតែមានស្មៅនិងដើមឈើតូចៗដុះនៅពីលើ ។ ក្មេងៗដែលរស់នៅតំបន់នេះក៏បានលេងបាល់ទាត់នៅទីនេះដែរ ។ ក៏ប៉ុន្តែមានស្ត្រីម្នាក់ដែលរស់នៅក្បែរជើងភ្នំបានសម្គាល់ឃើញអ្វីដែលចម្លែកនៅលើភ្នំៈ វាដូចជាមិនរាបស្មើ ។ នេះគឺខុសប្លែកពីធម្មតា ។ ក្រោយមកមានការបញ្ជូនក្រុមមួយទៅធ្វើការពិនិត្យតំបន់នេះ ហើយក៏បានរកឃើញផ្នូរសាកសពជាច្រើន ។

ទិដ្ឋភាពដែលគួរឲ្យចម្លែកមួយទៀតគឺផ្នូរសាកសពនៅក្នុងតំបន់ប៉ូតូការី អ្វីដែលនៅសេសសល់ទាំងស្រុងរបស់ជនរងគ្រោះម្នាក់គឺមិនបានរកឃើញនៅក្នុងផ្នូរតែមួយនោះទេ ។ គឺអាចថាផ្នែកនៃរាងកាយមួយត្រូវបានកប់នៅក្នុងពីរ-បីកន្លែងផ្សេងគ្នា ។ ការបកស្រាយចំពោះបញ្ហានេះគឺថា អ្នកប្រព្រឹត្តបទឧក្រិដ្ឋមួយចំនួនបានត្រឡប់ទៅកាន់ផ្នូរសាកសពជាមួយម៉ាស៊ីនឈូសឆាយក្នុងគោលបំណងដើម្បីបំផ្លាញនិងកប់បំណែកដែលនៅសល់របស់ជនរងគ្រោះ ។ ការធ្វើដូច្នេះពួកគេជឿជាក់ថា នឹងធ្វើឲ្យអាជ្ញាធរ ឬអ្នកដែលនៅរស់ពិបាកកសាងសំណុំរឿងប្រឆាំងនឹងខ្លួន ។ ទោះបីជាយ៉ាងណាក៏ដោយ ជាលទ្ធផលនៃការបំផ្លាញនេះ សមាជិករបស់ជនរងគ្រោះមួយចំនួនត្រូវរង់ចាំជាច្រើនសប្តាហ៍ឬច្រើនខែដើម្បីធ្វើការប្រមូលរបស់របរដែលនៅសល់ពីអ្នកដែលជាទីស្រឡាញ់ ។ នេះមិនគ្រាន់តែជាការបំផ្លាញអារម្មណ៍ចំពោះគ្រួសារទេ ប៉ុន្តែថែមទាំងបានបង្កើតភាពស្មុគស្មាញជាច្រើនដូចជាថាតើគួរតែកប់ឆ្អឹងដែលនៅសល់ពីការរកឃើញ ឬក៏ត្រូវរង់ចាំលុះត្រាតែរកឃើញឆ្អឹងទាំងអស់ ។ បញ្ហានេះជាអ្វីដែលបុរសម្នាក់ប្រចាំតំបន់នោះបានលះបង់ជីវិតរបស់គាត់ក្នុងការស្វែងរកផ្នូរសាកសពដើម្បីលាតត្រដាងថាជា «ការសម្លាប់ដោយស្ងាត់ស្ងៀម» ។


ពិធីបញ្ចុះសពជនរងគ្រោះរបស់ស្រ៊ីប្រេនីស្សានៅប៉ូតូការី

នៅពេលថ្ងៃត្រង់ ពិធីបុណ្យដែលប្រារព្ធឡើងសម្រាប់ជនរងគ្រោះនៅស្រ៊ីប្រេនីស្សា៤៦៥នាក់ពីការសម្លាប់ដ៏សាហាវនៅប៉ូតូការីត្រូវបានធ្វើពិធីរំឭកនៅកន្លែងកប់សាកសព ។ បូជនីយដ្ឋាននេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០០ និងបច្ចុប្បន្ននៅសេសសល់សាកសពចំនួន២៥០០នាក់នៃចំនួនប៉ាន់ស្មានជនជាតិម៉ូស្លីមបូស្នៀចំនួន៨០០០-៩០០០នាក់ដែលត្រូវបានសម្លាប់ដោយទាហានស៊ែបនៅក្នុងឆ្នាំ១៩៩៥ ។ មួយឆ្នាំៗសាកសពដែលទើបបានរកឃើញថ្មី ត្រូវបានកប់នៅទីនោះ ។ នៅឆ្នាំនេះប្រជាជនប្រហែលបីម៉ឺននាក់បានជួបជុំគ្នាដើម្បីចូលរួមការកប់សាកសព ។ នៅខាងចុងបំផុតនៃទីវាលក្តារមឈូសចំនួន៤៦៥

បានគុបតែងនិងគ្របដណ្ដប់ដោយក្រណាត់ពណ៌បៃតង ក្រាលនៅជាប់គ្នា ។ នៅចុងម្ខាងទៀតនៃទីវាលមានផ្លាកថ្មចំនួន៤៦៥ដុំ សម្រាប់ដាក់ពីមុខផ្នូរ និងផ្នូរដែលទើបតែជីកកំពុងរង់ចាំទទួលក្ដាររមឈូសទាំងអស់នេះ ។ នៅចំកណ្ដាលនៃទីវាលមានថ្មកែវមួយដ៏ធំរាងជារង្វង់ដែលមានឆ្លាក់ឈ្មោះជនរងគ្រោះនៅចំកណ្ដាលរង្វង់ ។ ឈ្មោះជនរងគ្រោះត្រូវបានហៅម្ដងមួយៗដាក់តាមឈ្មោះយ៉ាងត្រឹមត្រូវ ។ ក្ដាររមឈូសត្រូវបានដាក់ចុះថ្នមៗចូលទៅក្នុងរណ្ដៅដែលមានបុរសពីរ-បីនាក់ចាប់ផ្ដើមលើកដីលុបមឈូស



នោះ ។ នៅពេលដែលបុរសម្នាក់អស់កម្លាំង បុរសម្នាក់ផ្សេងទៀតបានចូលធ្វើជំនួស ។ សូម្បីតែក្មេងប្រុសអាយុប្រហែល១៣ឆ្នាំ ក៏បានរួមចំណែកក្នុងការកប់ជនរងគ្រោះដែរ ។ សមាជិកគ្រួសារបានប្រមូលផ្ដុំគ្នានៅជុំវិញថ្មដែលដាក់ពីមុខផ្នូរបានយំកាន់ទុក្ខ ។

សម្រែករបស់ស្ត្រីម្នាក់បានផ្ទុះឡើង ហាក់ដូចជាគាត់បានបាត់បង់ស្មារតីនៅក្នុងពេលដែលកើតទុក្ខ ហើយរាងកាយក៏ចាប់ផ្ដើមទន់ខ្សោយ ។ អ្នកផ្សេងទៀតបានគ្រាហ៍គាត់ទៅម្ខាង ។ ស្ត្រីវ័យចំណាស់ម្នាក់កំពុងអង្គុយលើកៅអីក្រណាត់បត់ជូតទឹកភ្នែក ក្នុងខណៈដែលមានមនុស្សមួយចំនួនកំពុងព្យាយាមលួងលោមគាត់ ។

បន្ទាប់មកឈ្មោះសាកសពនោះត្រូវបានអាន ហើយមានការឈប់មួយភ្លែតទៅតាមសូរសៀងរបស់បុរសម្នាក់ច្រៀងចម្រៀងបទ ការប៉េឡា ។ សាកសពរបស់ជនរងគ្រោះ៤៦៥នាក់ត្រូវបានកប់នៅទីនោះ ហើយសាកសពជាច្រើនពាន់នាក់ទៀតកំពុងរង់ចាំធ្វើការស្វែងរកនិងបញ្ចុះ ។

ការបញ្ចុះសពអ្នកដែលជាទីស្រឡាញ់ បានធ្វើឲ្យមានការរំជួលចិត្តនិងធូរស្រាលពីការឈឺចាប់ចំពោះអំពើប្រល័យពូជសាសន៍នេះ លើសពីនេះទៀតក៏អាចជួយជនរងគ្រោះទទួលបានអារម្មណ៍ស្ងប់ស្ងាត់ឬក៏អាចទទួលបានយុត្តិធម៌ដែរ ។ ប្រធានបទយុត្តិធម៌និងការផ្សះផ្សាជាតិបានលេចឡើងនៅក្នុងចំណោមអ្នកដែលបានធ្វើការបង្ហាញមួយចំនួន ។ លោក មូតាន់ហ្គាណា ជីនបូស្កូ ព្រះរាជអាជ្ញារបស់សាលាក្ដីជាតិបានផ្ដល់ចំណងជើងពីការបង្ហាញថាៈ «យុត្តិធម៌ឧក្រិដ្ឋកម្មនៅក្រោយអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាៈ ការសិក្សាពីករណីរបស់សាលាក្ដីកាឆាឆា» លោក បូស្កូ បាននិយាយអំពីចំនួនដែលជនដៃដល់ប្រព្រឹត្តយុត្តាធិការ និងធនធានមានកំណត់របស់សាលាក្ដីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដានិងការកាត់ទោសអំពើប្រល័យពូជសាសន៍ថ្នាក់ជាតិហៅថាតុលាការកាឆាឆា អាចនឹងធ្វើការដោះស្រាយចំពោះយុត្តិធម៌នៅថ្នាក់ក្រោម ។ តាមរយៈអ្នកបង្ហាញអំពីដំណើរការរបស់កាឆាឆា គឺផ្អែកលើប្រពៃណីរបស់រ៉្វាន់ដាក្នុងការដោះស្រាយជម្លោះរវាងសមាជិកសហគមន៍ ។ រចនាសម្ព័ន្ធរបស់តុលាការដែលអ្នកបង្ហាញឈ្មោះ ស៊ីវុន ប៊ីយ៉ាមុកាម៉ា បានរៀបរាប់នៅពេលអនុវត្តលើករណីអំពើប្រល័យពូជសាសន៍ទាក់ទងនឹងការស៊ើបអង្កេតអំពីប្រភេទបទឧក្រិដ្ឋមួយ ហើយបន្ទាប់មកចង់ជ្រើសរើសអ្នកសច្ចធម៌ម្នាក់ («អ្នកដែលមានសេចក្ដីសុចរិត») ដើម្បីថ្កោលទោសអ្នកប្រព្រឹត្តបទឧក្រិដ្ឋ ។ ការកាត់ទោសមានកម្រិតផ្សេងៗគ្នាទៅតាមការសារភាពបទឧក្រិដ្ឋ និងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តជាក់ស្ដែង ។ ទាំងពីរនេះបានចង្អុលបង្ហាញពីអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រព័ន្ធដូចនៅក្នុងប្រទេសរ៉្វាន់ដា ។

អ្នកចូលរួមម្នាក់បានសួរថាតើដំណើរការរបស់តុលាការកាឆាឆាអាចប្រើក្នុងករណីអំពើប្រល័យពូជសាសន៍ផ្សេងទៀតនៅក្នុងពិភពលោកដែរទេ? លោក បូស្កូ បានពន្យល់អះអាងថា អាចយកទៅប្រើបាន ។ ចម្លើយរបស់គាត់បានទទួលការទះដៃអបអរ ។

ការលើកឡើងបែបនេះអាចធ្វើទៅបានដោយមិនមានការផ្លាស់ប្តូរ សម្រាប់ករណីអំពើប្រល័យពូជសាសន៍នៅបូស្នៀនិងកម្ពុជា ប្រសិនបើពិនិត្យដោយប្រុងប្រយ័ត្នទៅលើភាពខុសគ្នាលើប្រពៃណីក្នុងការដោះស្រាយបញ្ហានៅក្នុងប្រទេសទាំងពីរនេះដោយគិតពីកន្លែងរស់នៅរបស់ជនរងគ្រោះនិងជនដៃដល់អំពីអារម្មណ៍និងការគិតរបស់ជនរងគ្រោះចំពោះជនដៃដល់ និងករណីដូចគ្នានេះជនដៃដល់គិតពីដំណើរការយុត្តិធម៌អន្តរជាតិក្នុងពេលបច្ចុប្បន្ន (សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) ឆន្ទៈរបស់ជនដៃដល់ក្នុងការចូលរួមនៅក្នុងដំណើរការនេះពីទម្រង់យុត្តិធម៌ក្នុងស្រុកនិងហេតុការណ៍នៃអំពើប្រល័យពូជសាសន៍នោះឋិតក្នុងចំណោមការពិចារណាផ្សេងៗជាច្រើនទៀត ។

នៅក្នុងបរិបទរបស់ប្រទេសកម្ពុជា យុត្តិធម៌សម្រាប់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍គឺជាបញ្ហាស្មុគស្មាញមួយទាក់ទងនឹងកត្តានយោបាយជាតិនិងអន្តរជាតិ ការពន្យារពេលឲ្យកន្លងហួសតាំងពីបទឧក្រិដ្ឋបានប្រព្រឹត្ត«វប្បធម៌និទ្ទណ្ឌភាព» និង«វប្បធម៌នៃការមិននិយាយស្តី» និងការយល់ដឹងរបស់អ្នកដែលនៅរស់ (ឬក៏កង្វះខាត) អំពីមូលហេតុដែលធ្វើឲ្យអំពើប្រល័យពូជសាសន៍បានកើតឡើង ។ ទោះបីយ៉ាងណាក៏ដោយ វាហាក់ដូចជាអ្នកនៅរស់ភាគច្រើននៅប្រទេសកម្ពុជាមានសុទិដ្ឋិនិយម ជាសុទិដ្ឋិនិយមប្រកបដោយការប្រយ័ត្នប្រយែងអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ឬហៅថាសាលាក្តីខ្មែរក្រហម) ។ អ្នកនិពន្ធបានបង្ហាញពីយុត្តិធម៌នៅក្នុងស្រុកនៅក្រុមទី១ (ហើយយុត្តិធម៌ក៏មាននិយាយនៅក្រុមទី២ដែរ) លើទស្សនវិស័យរបស់ប្រជាជនកម្ពុជាចំពោះយុត្តិធម៌ដូចជាសាលាក្តីខ្មែរក្រហម ។


អេង កុកថាយ

អេង កុកថាយ ប្រធានផ្នែកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងក៏ជានិស្សិតថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យរ៉ាត់ហ្គ័របានបង្ហាញពីប្រធានបទស្រដៀងគ្នាដោយសន្និដ្ឋានពីគំនិតប្រជាជនកម្ពុជានៅក្រុមមួយផ្សេងទៀត ។

យោងតាមកិច្ចសម្ភាសន៍ជាមួយសង្ឃជាន់ខ្ពស់អំពីយុត្តិធម៌និងការផ្សះផ្សាជាតិដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងឆ្នាំ២០០៣ កុកថាយ បានបង្ហាញពីទស្សនៈមួយផ្សេងទៀតទៅកាន់ក្រុមមនុស្សផ្អែកលើទ្រឹស្តីព្រះពុទ្ធសាសនាទាក់ទងទៅនឹងបញ្ហាកម្មផលនិងបែងចែកជាពីរក្រុម គឺអ្នកដែលយល់ថាការកាត់ទោសក្នុងន័យជាកម្មផល ដែលប្រព្រឹត្តដោយជនដៃដល់ និងក្រុមអ្នកយល់ថាសាលាក្តីមិនចាំបាច់ ពីព្រោះវដ្តកម្មផលនឹងត្រឡប់មកអ្នកប្រព្រឹត្តបទឧក្រិដ្ឋវិញមិនថាជាតិនេះឬក៏ជាតិក្រោយឡើយ ។ កុកថាយ បានពន្យល់ថា ព្រះសង្ឃជឿជាក់ថា ទោះបីជាអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមឬក៏កម្មាភិបាលថ្នាក់ទាបត្រូវបាននាំខ្លួនទៅកាន់តុលាការនៅពេលនេះក្តី តែជនទាំងនោះកំពុងតែទទួលរងការឈឺចាប់ពីអ្វីដែលខ្លួនបានប្រព្រឹត្ត ។ ទិដ្ឋភាពនៃការដាក់ទោសមួយដែលកំពុងតែធ្វើគឺត្រូវបានគិតនៅក្នុងសង្គមកម្ពុជាថាជាឃាតករ ។ នេះគឺជាការដាក់ទោសធ្ងន់ធ្ងរ ពីព្រោះនៅក្នុងសង្គម «មុខមាត់» គឺមានសារសំខាន់សម្រាប់ភាពជោគជ័យ និងការងារនាពេលអនាគតរបស់មនុស្សម្នាក់ ។ អ្នកភូមិប្រាកដជាគេចមិនព្រមរកស៊ីដូរជាមួយទេ និងទុកឲ្យជនទាំងនោះស្ថិតនៅក្រោមសង្គមចុះ ។ កុកថាយ បានវិភាគទៅលើការរំពឹងទុករបស់ប្រជាជនកម្ពុជា ដោយបានបញ្ចូលពីការប៉ះប៉ូវខាងសេដ្ឋកិច្ចថា «ប្រជាជនកម្ពុជាមួយចំនួនជឿជាក់ថា ទោះបីជាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមអាចនឹងផ្តល់យុត្តិធម៌មួយកម្រិតចំពោះជនរងគ្រោះក៏ដោយ ជាធម្មតាគាត់ទទួលបានចំណែកតូចមួយសម្រាប់ស្ថានភាពសេដ្ឋកិច្ចគ្រួសារគាត់ដែរ» ។

កុកថាយ ក៏បានបង្ហាញពីការយល់ឃើញផ្ទាល់ខ្លួនចំពោះយុត្តិធម៌ ដែលគួរតែមានចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ ការយល់ឃើញថាការស្វែងយល់ដឹងផ្សេងៗគ្នាពីអ្វីដែលជាយុត្តិធម៌នៅក្នុងប្រទេសកម្ពុជាទទួលឥទ្ធិពលធំធេងដែលប្រជាជនយល់ដឹងអំពីប្រវត្តិសាស្ត្រអំពើប្រល័យពូជសាសន៍របស់ខ្លួន ។ កុកថាយ បង្កើតការយល់ឃើញរបស់ខ្លួនអំពីយុត្តិធម៌ប្រល័យពូជសាសន៍តាមរយៈការយល់ដឹងពីអំពើប្រល័យពូជសាសន៍ជាទូទៅនិងជាពិសេសអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។

នៅក្នុងក្រុមជាមួយគ្នា កុកថាយ និងលោកស្រី ហេខ្សែនចារីស

(ប្រធានកិច្ចការសាធារណៈនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) ក៏បានបង្ហាញដូចគ្នាអំពីសាលាក្ដីខ្មែរក្រហមដោយរៀបរាប់ពីការចរចាដែលនាំដល់ការបង្កើតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការបង្ហាញរបស់លោកស្រី ហេឡែន ចារីស ផ្ដោតសំខាន់ទៅលើការខ្វែងគំនិតគ្នាលើការបង្កើតសាលាក្ដីរវាងជាតិនិងអន្តរជាតិ ។ ប្រធានថ្មីរបស់សមាគមអន្តរជាតិនៃបញ្ញវន្តអំពើប្រល័យប្រល័ពូជសាសន៍ គ្រេហ្គហ្គោរី ស្ដែនតុន បានពិភាក្សាពីសកម្មភាពផ្ទាល់ខ្លួនដែលបាននាំទៅកាន់ការបង្កើតកម្មវិធីស្ដីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាដោយសាកលវិទ្យាល័យយែល ។ បុគ្គលិកការិយាល័យកម្ពុជារបស់កម្មវិធីនេះដែលដឹកនាំដោយលោក ឆាំង យុ ដែលក្រោយមកការិយាល័យនេះបានក្លាយជាអង្គការឯករាជ្យមួយមានឈ្មោះថាមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងឆ្នាំ១៩៩៧ ។ មជ្ឈមណ្ឌលបច្ចុប្បន្ននេះជាកន្លែងរក្សាទុកឯកសារខ្មែរក្រហមដ៏ធំបំផុតនៅក្នុងពិភពលោកនិងក៏ជាអ្នកផ្ដល់ឯកសារទាក់ទងនឹងរបបខ្មែរក្រហមទៅអង្គជំនុំជម្រះវិសាមញ្ញ ។ គ្រេហ្គហ្គោរី ស្ដែនតុន បានបញ្ជាក់ថា គាត់មានការជឿជាក់យ៉ាងមុតមាំនៅក្នុង «ការបង្កើតស្ថាប័ន» ជាភ័ស្តុតាងនៅក្នុងការអត់ទ្រាំតស៊ូរបស់គាត់នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០និងឆ្នាំ១៩៩០ ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាហៅ គ្រេហ្គហ្គោរី ស្ដែនតុន ជាស្ថាបនិកម្នាក់ក្នុងការបង្កើតអង្គការរបស់លោក ។ នៅក្នុងការគិតរបស់លោកប្រធាន ស្ដែនតុន ត្រូវបានបញ្ចប់ ។ ជាការពិត នេះគឺជាការរំភើបមួយដែលឃើញស្ថាបនិកដ៏ឆ្នើមនៃអំពើប្រល័យពូជសាសន៍របស់កម្ពុជាចាប់ដៃជាមួយបញ្ញវន្តនិងបញ្ញវន្តក្មេងខ្ចីរបស់មជ្ឈមណ្ឌលនេះគឺលោក អេង ។

អេង កុកថាយ បានធ្វើការបង្ហាញទៅកាន់ក្រុមពីរទៀតនៅក្នុងសន្និសីទ ។ នៅក្នុងការធ្វើឲ្យទៅជាសមាគមអន្តរជាតិនៃបញ្ញវន្តអំពើប្រល័យពូជសាសន៍ កុកថាយ បានលើកយកពីការចាំបាច់សម្រាប់ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍ប្រចាំតំបន់អាស៊ីអាគ្នេយ៍ ដោយផ្លាស់ប្ដូរពីមជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យទៅជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការយ៉ាងសកម្មនៅក្នុងប្រទេសកម្ពុជាអស់រយៈពេល១០ឆ្នាំ ។ វាជាការចងចាំមួយរបស់ប្រជាជនកម្ពុជាអំពីជម្លោះដើម្បីផលប្រយោជន៍មួយពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាដែលត្រូវបានបំភ្លេចអស់រយៈពេលជាង១០ឆ្នាំ ។ ជាមួយនឹងការបោះពុម្ពសៀវភៅថ្មីអំពីប្រល័យពូជសាសន៍នៅកម្ពុជាសម្រាប់ការអប់រំនៅវិទ្យាល័យ មជ្ឈមណ្ឌលឯកសារកម្ពុជាបានក្លាយជាមជ្ឈមណ្ឌលដ៏សំខាន់សម្រាប់ការអប់រំអំពើប្រល័យពូជសាសន៍ ។ទស្សនាវដ្ដីស្វែងរកការពិតរបស់មជ្ឈមណ្ឌលបានចាប់ផ្ដើមតាំងពីឆ្នាំ២០០០ ដោយធ្វើការស្រាវជ្រាវគ្រប់ទីកន្លែងនៅប្រទេសកម្ពុជា និងជាចំណែកសំខាន់មួយនៅក្នុងការអប់រំអំពើប្រល័យពូជសាសន៍និងដំណើរការស្វែងរកការពិត ។ តាមរយៈបទពិសោធន៍នេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានព្យាយាមផ្លាស់ប្ដូរខ្លួនឲ្យទៅអង្គការសម្រាប់អប់រំអំពើប្រល័យពូជសាសន៍មិនត្រឹមតែនៅប្រទេសកម្ពុជាទេ តែថែមទាំងនៅតាមតំបន់ផងដែរ ។ ការអប់រំនឹងជាធាតុថ្មីមួយរបស់មជ្ឈមណ្ឌល ប៉ុន្តែការស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍និងការឃ្លាំមើលជាទូទៅសម្រាប់តំបន់នឹងជាជារឿងសំខាន់មួយទៀត ។ ការបង្ហាញតែមួយនេះបានផ្ដោតទៅលើការបង្កើតមជ្ឈមណ្ឌលថ្មី ។ ដូចនៅតំបន់ផ្សេងទៀតក្នុងពិភពលោក អាស៊ីអាគ្នេយ៍គឺនៅក្រោមការគំរាមកំហែងពីអំពើប្រល័យពូជសាសន៍ ។ អាស៊ីអាគ្នេយ៍គឺជាតំបន់ដែលមានជាតិពន្ធលាយឡំគ្នាជាច្រើន ។ ប្រទេសដែលជាទីប្រជុំកោះដូចជាឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន និងប្រទេសផ្សេងទៀតគឺងាយនឹងរងគ្រោះជាពិសេសពីព្រោះប្រទេសទាំងនេះនៅដាច់ឆ្ងាយពីគ្នានិងមានវប្បធម៌ខុសគ្នា ។ ថ្ងៃនេះក្រោមឥទ្ធិពលរបស់សាកលភាវូបនីយកម្មនិងសមាហរណកម្មសេដ្ឋកិច្ច និងសង្គម ក្រុមជាតិផ្សេងគ្នានេះបានជួបជុំគ្នា ។ វានឹងមានសក្ដានុពលក្នុងការបង្កើតជម្លោះ ។ បន្ថែមលើនេះទៀតការវិវត្តន៍ និងការរស់នៅជាមួយគ្នានៅតែជាបាតុភូតបន្តនៅប្រទេសផ្សេងទៀត ។ ក្រុមជាតិពន្ធដែលកើតក្នុងស្រុកនៅភាគឦសានប្រទេសកម្ពុជា នៅវៀតណាមកណ្ដាល និងនៅភាគខាងត្បូងប្រទេសឡាវកំពុងប្រឈមមុខនឹងការធ្វើសមាហរណកម្មទៅជាក្រុមតំបន់ ។ ការសិក្សានិងការយល់ដឹងពីរឿងនេះ វាចាំបាច់ក្នុងការការពារជម្លោះនៅពេលខាងមុខដែលអាចបណ្ដាលឲ្យកើតអំពើប្រល័យពូជសាសន៍ ។

នៅក្នុងក្រុមពិភាក្សាពីអំពើប្រល័យពូជសាសន៍និងអនុ

សញ្ញាអង្គការសហប្រជាជាតិ កុកថាយ បានបង្ហាញទៅលើការកំណត់ហៅពាក្យប្រល័យពូជសាសន៍ ។ កុកថាយ បានលើកពីការរិះគន់មួយចំនួនលើការកំណត់និយមន័យអំពើប្រល័យពូជសាសន៍ ប៉ូករួមទាំងការរាប់បញ្ចូលនិងមិនរាប់បញ្ចូលរបស់អង្គការសហ-ប្រជាជាតិលើការទាមទារឲ្យមានចេតនានិងក្រុមត្រូវបានការពារ ។ អត្ថបទក៏បានបញ្ជាក់ពីគោលគំនិតល្អមួយរបស់អំពើប្រល័យពូជសាសន៍ដែលនិយាយពី «ការសម្លាប់សមាជិកមនុស្សជាតិពីព្រោះតែអត្តសញ្ញាណរបស់គេ» ។ ការសម្លាប់បែបនេះមានសក្តានុពលចំពោះការសម្លាប់រាលដាលពីការសម្លាប់ទ្រង់ទ្រាយតូចទៅធំនៃក្រុមជនរងគ្រោះ ។ អ្នកស្តាប់ម្នាក់ជឿជាក់ថា ការសម្លាប់ទ្រង់ទ្រាយធំក្នុងអំឡុងពេលជម្លោះនៅបូស្នៀគឺជាអំពើប្រល័យពូជសាសន៍មានការប៉ុនប៉ង ជាជាងអំពើប្រល័យពូជសាសន៍ទ្រង់ទ្រាយតូចពីព្រោះមានសមាជិកមួយចំនួនតូចនៃក្រុមជនរងគ្រោះដែលត្រូវបានសម្លាប់ ។ ចំពោះការសម្លាប់ជនរងគ្រោះរាប់ពាន់នាក់ និងការសម្លាប់ប្រជាជន២លាននាក់មិនមានអ្វីខុសគ្នាទេ ហើយទាំងពីរនេះគឺអាក្រក់ទាំងពីរ ។ តាមការពិតការសម្លាប់ក្នុងទម្រង់ទាំងពីរដូចគ្នា ព្រោះករណីទីមួយនឹងក្លាយជាករណីទីពីរប្រសិនបើមិនបានបញ្ឈប់ ។ នៅក្នុងអត្ថន័យអំពើប្រល័យពូជសាសន៍ អន្តរាគមន៍គួរតែបានធ្វើឡើងនៅដើមដំបូងនៃការសម្លាប់ទ្រង់ទ្រាយតូចពីព្រោះនេះក៏ជាអំពើប្រល័យពូជសាសន៍ដែរ ។

ការប្រជុំបានបញ្ចប់ជាមួយនឹងការបង្ហាញពីជីវិតរបស់ រ៉ាហ្វាអែល ឡេមគីន ដោយ រ៉ូប៊ឺត ក្លូត ដែលជាសាស្ត្រាចារ្យនៅសកលវិទ្យាល័យ វីកុនស៊ីន ម៉ាឌីសាន់ មានចំណងជើងថា «ប្រសិនបើរាងកាយទាំងមូលស្លាប់៖ ឡេមគីន និងសន្ធិសញ្ញាប្រឆាំងនឹងអំពើប្រល័យពូជសាសន៍» ។ ឡេមគីនគឺជាបុរសម្នាក់ដែលបានរកឃើញអំពើប្រល័យពូជសាសន៍និងតាមរយៈសកម្មភាពតស៊ូរបស់គាត់បាននាំឲ្យមានអនុសញ្ញាអង្គការសហប្រជាជាតិនៅឆ្នាំ១៩៤៨ ។ ការអានដោយសាស្ត្រាចារ្យ ក្លូត និងសមាជិកផ្សេងទៀតដែលអង្គប្រជុំបានជ្រើសរើសគឺបានបន្តទៅយ៉ាងសកម្ម ។ ជាការបរិយាយពីបុរសម្នាក់ដែលមានការអត់ធ្មត់ ការគិតគូរ និងការតស៊ូដ៏ជ្រាលជ្រៅសម្រាប់ហេតុផលផ្ទាល់ខ្លួននិងអន្តរជាតិរហូតដល់ថ្ងៃចុងក្រោយរបស់គាត់ ។ ទោះបីជាយ៉ាងណាក៏ដោយអំពើប្រល័យពូជសាសន៍បានកើតមានឡើងជាច្រើនដងក្រោយការស្លាប់របស់ឡេមគីន ។ បញ្ហាដែលធ្វើឲ្យមានការជំរុញដល់រឿងមនុស្សធម៌គឺការកើតមានអំពើប្រល័យពូជសាសន៍នៅដាហ្វួរ ។ ដូច្នេះចាំបាច់មានចម្លើយច្បាស់លាស់ចំពោះ«ការការពារអំពើប្រល័យពូជសាសន៍មុនពេលកើតមានឡើង» ដែលជារបៀបវារៈប្រជុំ សមាជិកមួយចំនួនជឿជាក់លើការ«បង្កើតស្ថាប័ន»និងសមាជិកផ្សេងទៀតជឿក្នុងការបង្កើតអង្គការ នៅក្នុងអង្គការនិងយន្តការដែលអាចបន្ថយនូវអធិបតេយ្យភាពរបស់រដ្ឋក្នុងករណីចាំបាច់និងសមាជិកផ្សេងទៀតជឿក្នុងការបង្កើតតុលាការឧក្រិដ្ឋកម្មជាអចិន្ត្រៃយ៍ ។

នៅខណៈពេលដែលមានការបង្ហាញដោយអ្នករស់រានជីវិតជនជាតិបូស្នៀចំណាស់នៅរាត្រីថ្ងៃព្រហស្បតិ៍ បុរសម្នាក់នៅក្នុងចំណោមអ្នកស្តាប់បានក្រោកឡើងនិងរាក់ទាក់សរសើរសាក្សីក្នុងការនិយាយប្រឆាំងនឹងអំពើឃោរឃៅ និងបានចាត់គាត់ជាគន្លឹះសំខាន់ដើម្បីបញ្ចប់អំពើប្រល័យពូជសាសន៍នៅពេលអនាគត ។ អ្នកចូលរួមមួយចំនួនបានទះដៃអបអរដោយការយល់ស្របនិងការសរសើររបស់គាត់ ។ បន្ទាប់មក បុរសម្នាក់ទៀតបានក្រោកឡើងហើយនិយាយថា ការថ្លែងរបស់សាក្សីជាការពិត មិនអាចការពារឬបញ្ឈប់អំពើប្រល័យពូជសាសន៍បានទេ វាពឹងផ្អែកលើមេដឹកនាំនយោបាយឯណោះទេ ។ នៅក្នុងករណីនៅដាហ្វួរ អ្នកដឹកនាំនយោបាយរបស់អង្គការសហប្រជាជាតិ ជាចុងក្រោយបានយល់ព្រមធ្វើសកម្មភាពដោយបញ្ជូនទាហានរក្សាសន្តិភាពចំនួន២៦.០០០នាក់ និងទាហានមកពីសហគមន៍អាហ្វ្រិកទៅកាន់ទីនោះ ។ ទាហានទាំងនេះបំពាក់ដោយអាវុធនិងមានសិទ្ធិការពារខ្លួន និងការពារជនភៀសខ្លួននិងអ្នកធ្វើការខាងមនុស្សធម៌នៅទីនោះ ។ ពេលនេះពិភពលោករង់ចាំរដ្ឋាភិបាលស៊ូដង់ និងជីវពលអារ៉ាប់ដែលកំពុងតែប្រព្រឹត្តហិង្សា (ត្រូវបានគាំទ្រដោយរដ្ឋាភិបាលស៊ូដង់) ដើម្បីឆ្លើយតបទៅនឹងការធ្វើការរបស់អង្គការសហប្រជាជាតិ ។ ដូច្នេះព្រឹត្តិការណ៍សោកនាដកម្មនឹងត្រូវបានលាតត្រដាង ដាហ្វួរនឹងក្លាយទៅជាការសាកល្បងដ៏សំខាន់មួយក្នុងការប្តេជ្ញាចិត្តរបស់សហគមន៍អន្តរជាតិនិងសមត្ថភាពក្នុងការបញ្ចប់អំពើប្រល័យពូជសាសន៍ ។

**ភែង ជាស៊ីល**

# ការិយាល័យព័ត៌មានសាធារណៈ

"ការិយាល័យព័ត៌មានសាធារណៈ" នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្ដើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្ដុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្ដៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

"ការិយាល័យព័ត៌មានសាធារណៈ" មានផ្ដល់ជូននូវសេវា៣យ៉ាង ៖

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្ដី ស្ដាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្ដល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង លី សុខឃាង តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។





# ព្រឹត្តិការណ៍សំខាន់ៗទាក់ទិននឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅក្នុងទំព័រទស្សនាវដ្តី«ស្វែងរកការពិត»លេខ៨៦ ខែកុម្ភៈ ឆ្នាំ២០០៧ ក៏មានចុះផ្សាយព័ត៌មានអំពីកិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការស៊ើបអង្កេតចោទប្រកាន់និងនាំដល់ការបើកសវនាការកាត់សេចក្តីអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងអំឡុងពេលពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដោយរង់ចាំតែការអនុម័តវិធានផ្ទៃក្នុងដែលនឹងធ្វើឡើងក្នុងខែមិថុនាប៉ុណ្ណោះ ។

វិធានផ្ទៃក្នុងនេះត្រូវបានអនុម័តដោយគណៈកម្មាធិការពិនិត្យបទបញ្ជាផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងកិច្ចប្រជុំពេញអង្គ កាលពីថ្ងៃទី១២ ខែមិថុនា ។ យោងតាមវិធានមួយស្តីពីការចូលជាធរមាន «វិធានផ្ទៃក្នុងនេះត្រូវចូលជាធរមានតាមរយៈការបោះពុម្ពផ្សាយជាផ្លូវការដោយការិយាល័យរដ្ឋបាល និងក្នុងរយៈពេលមិនលើសពី១០ថ្ងៃ ក្រោយពីឯកសារដូចគ្នាដែលមានជាភាសាខ្មែរ អង់គ្លេស និងបារាំងត្រូវបានអនុម័តដោយកិច្ចប្រជុំពេញអង្គ» ។

រយៈពេលជាងមួយខែបន្ទាប់ពីវិធានផ្ទៃក្នុងចូលជាធរមាន (នៅថ្ងៃទី២២ ខែមិថុនា) អង្គជំនុំជម្រះវិសាមញ្ញបានបង្ហាញពីការរីកចម្រើនគួរឲ្យកត់សម្គាល់ទាក់ទិននឹងការស៊ើបអង្កេត ការប្រមូលភ័ស្តុតាងចោទប្រកាន់ ការបញ្ជូនសំណុំរឿងឲ្យស៊ើបសួរបន្ត ការចេញដីកាឃុំខ្លួនបណ្តោះអាសន្ននិងការងារការពារក្តីរបស់អង្គភាពគាំពារការពារក្តី ។ ក្នុងចំណោមការវិវត្តន៍ទៅមុខទាំងអស់នេះមានព្រឹត្តិការណ៍បីសំខាន់ ហើយដែលជនរងគ្រោះនៃរបបខ្មែរក្រហមក៏ដូចជាប្រជាជនកម្ពុជាទូទៅចង់ដឹងដើម្បីជាប្រយោជន៍សម្រាប់ភាពងាយស្រួលក្នុងការតាមដានព្រឹត្តិការណ៍ជាបន្តបន្ទាប់ទៀតទាក់ទិននឹងអង្គជំនុំជម្រះវិសាមញ្ញ ។

**ព្រឹត្តិការណ៍ទី១៖**

ទាក់ទិននឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ នេះជាដំណាក់កាលមួយសំខាន់នៅក្នុងនីតិវិធីទម្រាំឈានដល់ការកាត់សេចក្តី ទៅលើបទឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយជនសង្ស័យជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ។ ដំណាក់កាលនេះក៏អាចចាត់ទុកថា ជាដំណាក់កាលមុនឈានទៅដល់ការបើកសវនាការជាសាធារណៈ ។

កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ កន្លងទៅថ្មីៗ សហព្រះរាជអាជ្ញាទាំងពីររូបគឺលោកស្រី ជា លាង និង លោក ពេទី បានចេញសេចក្តីថ្លែងការណ៍មួយសម្រេចចេញដីកាមួយដែលតាមភាសាច្បាប់ហៅថា «ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ» ។ ដីកានេះត្រូវបានបញ្ជូនទៅសហចៅក្រមស៊ើបអង្កេតដែលមានចៅក្រមខ្មែរ យូ ប៊ុនឡេង និងចៅក្រមបរទេស ម៉ាកសែល ឡឺម៉ុង (ជនជាតិបារាំង) ដើម្បីធ្វើការស៊ើបសួរបន្ត ។

ប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជារបស់យើងគឺមានន័យថាបន្ទាប់ពីទទួលបានពាក្យបណ្តឹង ព្រះរាជអាជ្ញាចាប់ផ្តើមប្រមូលភ័ស្តុតាងអាចល្មមគ្រប់គ្រាន់ក្នុងការកំណត់ជនសង្ស័យនិងបទល្មើសដើម្បីអាចធ្វើការចោទប្រកាន់បាន ។ បន្ទាប់មក ព្រះរាជអាជ្ញាបញ្ជូនសំណុំរឿងនោះទៅចៅក្រមស៊ើបអង្កេតធ្វើការស៊ើបសួរបន្តឲ្យកាន់តែច្បាស់ ។ ដោយអនុវត្តតាមនីតិវិធីនេះ ទើបសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញសម្រេចបញ្ជូនរឿងឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបសួរបន្ត ។

តាមធម្មតា ដីការបៀបនេះមិនត្រូវបានអនុញ្ញាតឲ្យធ្វើការផ្សព្វផ្សាយជាសាធារណៈឡើយ ហើយជាការពិតនៅក្នុងតុលាការកម្ពុជាពេលបច្ចុប្បន្ន យើងមិនដែលឃើញមានការផ្សាយបែបនេះដែរ ។ ក៏ប៉ុន្តែដោយអង្គជំនុំជម្រះវិសាមញ្ញមានលក្ខណៈវិសាមញ្ញ (ពិសេស) និងដោយសារការតម្រូវឲ្យផ្តល់ព័ត៌មានដល់សាធារណជនអំពីការវិវត្តន៍នៅក្នុងដំណើរនីតិវិធីដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាបានសម្រេចធ្វើការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានសង្ខេបតែប៉ុណ្ណោះ ហើយធានានូវការការពារ «បូរណភាពនៃការស៊ើបអង្កេតអត្តសញ្ញាណ(របស់)

ជនរងគ្រោះនិងសាក្សី ហើយនិងសច្ចធារណ៍នៃនិរទោសរបស់ជនសង្ស័យ» (សច្ចធារណ៍នៃនិរទោសរបស់ជនសង្ស័យជាសិទ្ធិមួយរបស់ជនសង្ស័យតាមផ្លូវច្បាប់ដែលមានន័យថា ការសន្មតទុកជាមុនថាគ្មានទោសទៅលើជនសង្ស័យ) ។ ពាក្យថា «បូរណភាពនៃការស៊ើបអង្កេត» នៅទីនេះគឺមកពីពាក្យអង់គ្លេសថា «integrity of the investigation» ដែលមានន័យថា សេចក្តីសុចរិតត្រឹមត្រូវនៃការស៊ើបអង្កេត ។

នៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួន សហព្រះរាជអាជ្ញាទាំងពីរបានបញ្ជាក់ថា វាជាលទ្ធផលដែលកើតចេញពីការស៊ើបអង្កេតបឋម ហើយដែលតាមដឹងកន្លងមកថា ការបើកការស៊ើបអង្កេតបឋមនេះធ្វើឡើងអស់រយៈកាលមួយឆ្នាំរួចមកហើយគឺចាប់ពីខែកក្កដាឆ្នាំកន្លងទៅ ។ សហព្រះរាជអាជ្ញាទាំងពីររូបមានទំនុកចិត្តថា «មានការរំលោភយ៉ាងធ្ងន់ធ្ងរនិងធំធេងទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ជាតិដែលបានកើតឡើងនៅក្នុងប្រទេសនេះ (ប្រទេសកម្ពុជា)» ដែល«រួមបានជាឧក្រិដ្ឋកម្មផ្សេងៗ» ។ ជាការពិតថាសហព្រះរាជអាជ្ញានឹងធ្វើការស៊ើបអង្កេតបឋមចោទប្រកាន់តែទៅលើរាល់ការរំលោភបំពានណាដែលកើតឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៦ មករា ១៩៧៩ ហើយឧក្រិដ្ឋកម្មនោះទៀតសោតមានត្រឹមតែចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញប៉ុណ្ណោះ (សូមអានមាត្រា ៣ ដល់ ៨) ។

នៅក្នុងខ្លឹមសារនៃសេចក្តីថ្លែងការណ៍ដដែលនេះ សហព្រះរាជអាជ្ញាបានធ្វើការសន្និដ្ឋានជាលើកដំបូងដោយវាយតម្លៃជារួមថា «ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តឡើងជាផ្នែកមួយនៃផែនការឧក្រិដ្ឋកម្មរួម» ដោយសំអាងថា សង្គមកម្ពុជាទាំងមូលកាលជំនាន់នោះបានផ្លាស់ប្តូរទៅតាមបន្ទាត់មនោគមវិជ្ជានយោបាយ ។ សហព្រះរាជអាជ្ញាបានធ្វើការសន្និដ្ឋានទៀតថា ក្នុងចំណោម «ជនដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនិងគោលនយោបាយ» គឺមានមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនេះឯង ។ បន្ថែមពីលើនេះទៀត សហព្រះរាជអាជ្ញាបានរកឃើញថាមានអង្គហេតុចំនួន២៥ ផ្សេងៗគ្នាដែលអាចផ្សំបានជាឧក្រិដ្ឋកម្មដូចជា «ឃាតកម្ម ការធ្វើទារុណកម្ម ការជម្លៀសដោយបង្ខំ ការឃុំឃាំងដោយខុសច្បាប់ ការបង្ខំឲ្យធ្វើពលកម្ម ព្រមទាំងការធ្វើទុក្ខបុកម្នេញលើសាសនា នយោបាយ និងជនជាតិភាគតិច» ដែលឧក្រិដ្ឋកម្មទាំងអស់នេះបានកើតចេញពីការអនុវត្តផែនការឧក្រិដ្ឋកម្មរួមដូចខាងលើ ។

ដោយយោងតាមអង្គហេតុខាងលើនេះ សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញបានចោទប្រកាន់ជារួមទៅលើជនសង្ស័យចំនួន៥រូបដោយជឿជាក់ថា អ្នកទាំងនេះជាមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និង/ឬជាជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម ។ សូមបញ្ជាក់ថា សហព្រះរាជអាជ្ញាមិនបានបញ្ចេញឈ្មោះជនសង្ស័យឡើយ ។ សហព្រះរាជអាជ្ញាមានហេតុផលជាច្រើនចំពោះការណ៍ដែលមិនបញ្ចេញឈ្មោះចំៗដែលក្នុងនោះរួមមានការធានាដល់ការការពារសេចក្តីសុចរិតត្រឹមត្រូវនៃការស៊ើបអង្កេតនិងសិទ្ធិរបស់ជនសង្ស័យជាសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសដូចដែលបានផ្តល់ជូនពីខាងដើម ។ ទោះបីជាយ៉ាងនេះក្តី សហព្រះរាជអាជ្ញាបានផ្តល់អត្តសញ្ញាណជនសង្ស័យទាំង៥រូបឲ្យដល់សហចៅក្រមស៊ើបអង្កេតរួចហើយ ។

ច្បាស់ជាងនេះទៀត នៅក្នុងសេចក្តីថ្លែងការណ៍សហព្រះរាជអាជ្ញាបានបញ្ជាស់យ៉ាងច្បាស់ថា ខ្លួនធ្វើការចោទប្រកាន់ដោយយោងតាមអង្គហេតុខាងលើពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (មាត្រា៥) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (មាត្រា៤) អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ (មាត្រា៦) មនុស្សឃាត ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញផ្នែកសាសនា (មាត្រា៣) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដើម្បីគាំទ្រដល់ការចោទប្រកាន់នេះ សហព្រះរាជអាជ្ញាបានសម្អាងលើឯកសារជាង១០០០ច្បាប់ស្មើនឹង១៨ម៉ឺនទំព័រ ដោយរួមទាំងបទសម្ភាសន៍ជាមួយសាក្សីជាង៣៥០នាក់ មានសាក្សីសំខាន់ៗចំនួន៤០នាក់ ឯកសារសម័យខ្មែរក្រហមជាច្រើនម៉ឺនទំព័រ ទីតាំងរណ្តៅសាកសពរួមដែលមិនទាន់គាស់កកាយជាង៤០រណ្តៅ ។ ក្នុងសេចក្តីថ្លែងការណ៍នេះ សហព្រះរាជអាជ្ញាបានផ្តល់គុណសម្បត្តិដល់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងការរួមចំណែកក្នុងកិច្ចការនេះ ដោយគូសបញ្ជាក់បន្ថែមទៀតថា «ភស្តុតាងមួយចំនួនធំត្រូវបានប្រមូលឡើងដោយមានការជួយ

ជ្រាមជ្រែងពីសំណាក់មជ្ឈមណ្ឌលឯកសារកម្ពុជា» ។

សរុបមក សហព្រះរាជអាជ្ញាបានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតចាត់ការតាមផ្លូវច្បាប់ជាបន្ត ដោយខ្លួនជឿជាក់ថា «មានអង្គហេតុដែលអាចផ្សំបានជាឧក្រិដ្ឋកម្ម [និង] កំណត់ជនសង្ស័យដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម» ។ សូមស្វែងរកសេចក្តីថ្លែងការណ៍នេះនៅក្នុងគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញ តាមរយៈអាសយដ្ឋាន *http://www.eccc.gov.kh/khmer/cabinet/press/25/Statement_of_Co-Prosecutors_18-July-2007_.pdf* ។

## ព្រឹត្តិការណ៍ទី២

ទាក់ទិននឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតខ្មែរលោក យូ ប៊ុនឡេង និងចៅក្រមបរទេស លោក ម៉ាកសែល ឡឺម៉ុង កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧កន្លងទៅនេះ ។ នៅក្នុងប្រព័ន្ធច្បាប់របស់កម្ពុជា ចៅក្រមស៊ើបអង្កេតនឹងបើកការស៊ើបសួរបន្ថែមបានដរាបណាព្រះរាជអាជ្ញាចេញដីកាបញ្ជូនសំណុំរឿងឲ្យស៊ើបសួរ ហើយការស៊ើបសួរនេះទៀតសោត ព្រះរាជអាជ្ញានឹងបញ្ជាក់យ៉ាងច្បាស់នៅក្នុងដីកាអំពីនរណាជាជនសង្ស័យ ហើយបទល្មើសអ្វីដែលជនសង្ស័យជាប់ពាក់ព័ន្ធ ។

សូមក្រឡេកមើលដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នដែលធ្វើឡើងប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ កាលពីចន្លោះឆ្នាំ១៩៧៥ និង៧៩ កាំង ហ្គេកអ៊ាវ ហៅ ឌុច គឺជាប្រធានគុកទួលស្លែងដែលជិនាន់នោះ គុកនេះត្រូវបានដាក់ឈ្មោះថា «មន្ទីរសន្តិបាល ស-២១» ។ យោងតាមឯកសារដែលបន្សល់ទុកដោយរបបកម្ពុជាប្រជាធិបតេយ្យ គុកនេះជាកន្លែងឃុំឃាំងមនុស្សសួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់យ៉ាងអមនុស្សធម៌បំផុត ។ ជនរងគ្រោះប្រមាណជាងមួយម៉ឺននាក់ ត្រូវចាប់បញ្ជូនមកដាក់នៅក្នុងគុកនេះ ហើយក្រោយមក មានមនុស្សមិនដល់នាក់ផងដែលនៅរស់រានមានជីវិតរួចផុតពីគុកនេះ ក្រោយរបបខ្មែរក្រហមដួលរលំទៅនៅខែមករា ឆ្នាំ១៩៧៩ ។

យោងតាមដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាដូចបានបង្ហាញខាងលើ សហចៅក្រមស៊ើបអង្កេតក៏ចាប់ផ្តើមចាត់ការច្បាប់តាមការស្នើសុំ ។ នៅក្នុងស្នើសុំនោះ សហព្រះរាជអាជ្ញាបានបញ្ជាក់យ៉ាងច្បាស់ថា «ស្នើឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន» លើជនសង្ស័យដែលក្នុងដីកានេះគឺធ្វើឡើងប្រឆាំងនឹងឌុច ។ សហព្រះរាជអាជ្ញាបានឲ្យហេតុផលក្នុងន័យថា ឌុច ពិតជាបានចូលរួមក្នុងឧក្រិដ្ឋកម្ម បង្ការ ឌុច មិនឲ្យធ្វើការគាបសង្កត់សាក្សី ធានាការរក្សា ឌុច សម្រាប់ដំណើរការសវនាការនិងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ ។ នៅពេលព្រលឹមថ្ងៃទី៣១ ខែកក្កដា ឌុច ត្រូវបានផ្ទេរចេញពីមន្ទីរឃុំឃាំងរបស់តុលាការយោធានិងដឹកជញ្ជូនតាមរថយន្តមកដាក់នៅក្នុងមជ្ឈមណ្ឌលឃុំខ្លួនបណ្តោះអាសន្ននៃអង្គជំនុំជម្រះវិសាមញ្ញដែលមជ្ឈមណ្ឌលត្រូវប្រគល់ឲ្យជាផ្លូវការនៅថ្ងៃទី១៨ក្នុងខែដដែល ។ ការដែលធ្វើដូច្នេះគឺដោយសារតែ ឌុច ត្រូវរដ្ឋាភិបាលចាប់ខ្លួនតាំងពីឆ្នាំ១៩៩៩ តាមអំណាចច្បាប់ដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់(ច្បាប់ឆ្នាំ១៩៩៤) ហើយបញ្ជូនខ្លួនទៅឃុំឃាំងជាបណ្តោះអាសន្ននៅមន្ទីរឃុំឃាំងរបស់តុលាការយោធាដើម្បីរង់ចាំការកាត់ក្តី ។ ឌុច ត្រូវបានតុលាការយោធាធ្វើការចោទប្រកាន់ជាលើកដំបូងពីបទ«ឧក្រិដ្ឋកម្មប្រឆាំងសន្តិសុខក្នុងប្រទេស» ។ បួនខែក្រោយមកទៀត បន្ទាប់ពីការស៊ើបអង្កេត ឌុច ត្រូវបានចោទប្រកាន់ពីបទ «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍» និងក្រោយមកទៀតពីបទ «ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» ។ ឌុច ត្រូវបានដាក់នៅក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្នអស់រយៈពេលជាង៨ឆ្នាំ ដើម្បីរង់ចាំការកាត់ក្តីដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ឌុច សារភាពតាំងពីនៅតុលាការយោធាមកម្ល៉េះថា ខ្លួនឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច កើតថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅភូមិពោធិ៍រវៀយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ ។

នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ចៅក្រមស៊ើបអង្កេតជាអ្នកសម្រេចឃុំខ្លួនបណ្តោះអាសន្នក្នុងរយៈពេលវែងរហូតដល់មួយឆ្នាំ ហើយនឹងពន្យារការឃុំខ្លួនរហូតដល់បីឆ្នាំដោយត្រូវឡើងក្នុងមួយឆ្នាំម្តងៗប្រសិនបើចាំបាច់សម្រាប់ធ្វើការស៊ើបអង្កេត ។ ជនជាប់ចោទមានសិទ្ធិប្តឹងឧទ្ធរណ៍ចំពោះការសម្រេចបែបនេះទៅសាលាឧទ្ធរណ៍ ។ ដូច្នេះនៅពេលដែលទទួលបានការស្នើសុំឲ្យឃុំខ្លួនបណ្តោះអាសន្ន សហចៅក្រមស៊ើបអង្កេតនឹងធ្វើការសម្រេចភ្លាមថាចាំបាច់ឃុំខ្លួន ឬឲ្យនៅក្រៅឃុំដើម្បីរង់ចាំការចាត់ការជាបន្ត

បន្ទាប់រហូតដល់ថ្ងៃបើកសវនាការ ។ ក្នុងរឿងក្តីព្រហ្មទណ្ឌនេះ ចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានសម្រេចកាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ថា «យើងបង្គាប់ឲ្យឃុំខ្លួន កាំង ហ្កេកអ៊ាវ ហៅ ឌុច បណ្តោះអាសន្នរយៈពេលអតិបរមាមួយឆ្នាំ» ។ ឥឡូវនេះ ឌុច កំពុងស្ថិតនៅក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញរង់ចាំការចាត់ការបន្តបន្ទាប់ទៀតរហូតដល់ពេលការបើកសវនាការ ។

*ខាងក្រោមនេះជាការពន្យល់អំពីថា តើសហចៅក្រមស៊ើបអង្កេតប្រើប្រាស់ច្បាប់អ្វីខ្លះ? មេធាវីការពារ ឌុច មានអំណះអំណាងសម្រាប់ការពារកូនក្តីរបស់គាត់ដែរឬទេ? តើសហចៅក្រមស៊ើបអង្កេតបង្ហាញហេតុផលយ៉ាងដូច្នេះ?*

សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញមានអំណាចសម្រេចធ្វើការឃុំខ្លួនជាបណ្តោះអាសន្ន ឬដោះលែងឲ្យនៅក្រៅឃុំ ដោយអនុលោមតាមវិធាន៦៣នៃវិធានផ្ទៃក្នុង ។ វិធាននេះចែងថា «*សហចៅក្រមស៊ើបអង្កេតអាចសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ក្រោយពេលមានសវនាការតទល់គ្នា*»... ។ យោងតាមអំណាចដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ០០២, ១៤-០៨-២០០៦ លេខស៊ើបសួរ ០០១,១៨-០៧-២០០៧ ឌុច «*ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ៥, ២៩(ថ្មី) និង៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤*» ។

នៅក្នុងសវនាការតទល់គ្នា លោក កា សាវុធ ជាមេធាវីរបស់ ឌុច បានលើកយកទឡ្ហីករណ៍ជាច្រើនដើម្បីឲ្យសហចៅក្រមស៊ើបអង្កេតសម្រេចដោះលែងកូនក្តីរបស់ខ្លួនឲ្យនៅក្រៅឃុំ ។ ហេតុផលទីមួយ លោកលើកឡើងថា ឌុច ជាប់ឃុំខ្លួនជាបណ្តោះអាសន្នលើសពី៨ឆ្នាំហើយ ។ នេះជារឿងពិតដូចដែលបានបង្ហាញពីខាងដើមនៅឯតុលាការយោធា មិនមែនអង្គជំនុំជម្រះវិសាមញ្ញឡើយ ។ លោក កា សាវុធ បន្តថា ការឃុំខ្លួនលើសពី៨ឆ្នាំ គឺជាការរំលោភទៅលើច្បាប់ជាតិនិងបទដ្ឋានអន្តរជាតិ ។ នៅក្នុងដីកានេះយើងពុំឃើញមានការចង្អុលបង្ហាញច្បាប់ជាតិមួយណាជាក់លាក់នៅឡើយទេ ក៏ប៉ុន្តែនៅហេតុផលទី២ លោកបានលើកឡើងអំពីការគោរពបទដ្ឋានអន្តរជាតិផ្នែកយុត្តិធម៌ ដោយលើកយកមាត្រាជាពិសេស ១៤(៣)-គ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយឆ្នាំ១៩៦៦ ។ មាត្រានេះមានដាក់បញ្ចូលរួចហើយទៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងមាត្រា៣៥(ថ្មី) ដែលខ្លឹមសារនេះធានានូវសិទ្ធិរបស់ជនជាប់ចោទគឺសិទ្ធិ «ត្រូវបានទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយ» ។ មេធាវីរបស់ ឌុច ក៏លើកឡើងផងដែរអំពីមាត្រា៩(៣) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (អនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន) ដែលមាត្រានេះមានខ្លឹមសារថា «ជនគ្រប់រូបដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួន... ត្រូវបញ្ជូនទៅឲ្យចៅក្រមឬមន្ត្រីដែលមានសមត្ថកិច្ចផ្សេងទៀតភ្លាមៗតាមច្បាប់ដើម្បីអនុវត្តអំណាចផ្លូវតុលាការបាន ហើយត្រូវមានសិទ្ធិឲ្យមានការកាត់ក្តីក្នុងរយៈពេលមួយសមស្រប ឬត្រូវដោះលែងឲ្យនៅក្រៅឃុំដើម្បីរង់ចាំការកាត់ក្តី...» ។ ហេតុផលទី៣ លោក កា សាវុធ បានលើកឡើងថា វិធាន៦៣ ដែលសហចៅក្រមស៊ើបអង្កេតបានសំអាងដល់នោះមិនត្រូវបានបំពេញឡើយ ហើយ «ឌុច រស់នៅមានសេរីភាពតាំងពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩៩ ដោយមិនមានបង្កនូវភាពវឹកវរណាមួយឡើយ ហើយជាពិសេសក៏មិនមានការគាបសង្កត់ណាមួយកើតមានដែរ» ។ ហេតុផលទី៤ លោកបានលើកយកបញ្ហាដែលថា ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យទេ ។ មេធាវីកំពុងព្យាយាមទាញទឡ្ហីករណ៍ធ្វើយ៉ាងណាឲ្យឃើញថា ប្រសិនបើ ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់នោះ អង្គជំនុំជម្រះវិសាមញ្ញនឹងពុំមានដែនសមត្ថកិច្ចក្នុងការដោះស្រាយរឿងនេះទេ ដោយផ្អែកលើមាត្រា២នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ លោកមេធាវី បានលើកឡើងគួរឲ្យចាប់អារម្មណ៍ទៀតថា «មានមនុស្សជាងពីរពាន់នាក់ដែលធ្លាប់ស្ថិតនៅក្នុងស្ថានភាពជាប្រធានមជ្ឈមណ្ឌលសន្តិសុខដូចរូបជនត្រូវចោទ» ដែរ ដែលន័យនេះចង់បង្កប់ន័យថាវាហាក់បីដូចជាអយុត្តិធម៌សម្រាប់ ឌុច បើប្រៀបធៀបនឹងមនុស្សរាប់ពាន់នាក់ដែលមានឋានៈស្មើ ឌុច ប្រសិនបើការអះអាងរបស់មេធាវីពិតជាត្រឹមត្រូវ ។ យើងមិនដឹងថា មេធាវីរូបនេះមានឯកសារក្នុងដៃសម្រាប់បង្ហាញ

សហចៅក្រមដែរឬយ៉ាងណានោះទេ ។ ហេតុផលទី៥ លោកមេធាវីលើកឡើងជាលក្ខណៈប្រណែនទីផជនសង្ស័យដទៃទៀតដែលស្ថិតនៅក្នុងសេរីភាព ដោយនៅក្នុងដីកានេះសហចៅក្រមស៊ើបអង្កេតពុំបានទម្លាយឲ្យដឹងអំពីថាតើនរណាមួយជាក់លាក់ដែលមេធាវីរបស់ ឌុច និយាយយោងដល់នោះទេ ។

ដោយជួយគាំទ្រនូវអំណះអំណាងមេធាវីរបស់ខ្លួន ឌុច និយាយថា គាត់ធ្លាប់ជាប្រធានមន្ទីរសន្តិសុខ ស-២១ ហើយត្រៀមខ្លួនជាស្រេចដើម្បីឡើងស្រាយបំភ្លឺឲ្យឃើញអំពីឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តដោយពួកខ្មែរក្រហម ។ បើដូច្នេះតើមានហេតុផលអ្វីទៅធ្វើការគាបសង្កត់សាក្សី? ម្យ៉ាងទៀតខ្លួនមិនទាំងដឹងថា នរណាជាសាក្សីផងនោះទេ ។ បើស្តាប់មួយភ្លែតសម្តីរបស់ ឌុច ហាក់ដូចជាសមហេតុផលណាស់ ប៉ុន្តែតុលាការមិនចេះតែជឿងាយៗនោះទេ ។

ចំណែកសហចៅក្រមស៊ើបអង្កេតវិញ ជាដំបូងសហចៅក្រមទាំងពីរទទួលស្គាល់ថា ជាស្ថានភាពពិសេសដោយឡែកដែលទាក់ទងនឹងបុគ្គល ឌុច ហើយថាតើត្រូវសម្រេចឃុំខ្លួនឬយ៉ាងណា? ពីព្រោះថាអង្គហេតុដែលអាចផ្សំបានជាឧក្រិដ្ឋកម្មប្រឆាំង ឌុច មួយផ្នែកស្ថិតក្នុងដែនសមត្ថកិច្ចរបស់តុលាការយោធាដែលកំពុងចាត់ការតាមនីតិវិធីនៅឡើយ ហើយមួយផ្នែកទៀតស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ សហចៅក្រមស៊ើបអង្កេតក៏ទទួលស្គាល់ផងដែរថា ការឃុំខ្លួន ឌុច ជាបណ្តោះអាសន្នអស់រយៈពេលយ៉ាងយូរនៅក្នុងតុលាការយោធាគឺពិតជាមានបញ្ហាបើអនុលោមតាមស្តង់ដារអន្តរជាតិផ្នែកយុត្តិធម៌ ។ សហចៅក្រមស៊ើបអង្កេត លើកយកមាត្រា ៩(៣) និង១៨(៣)-គនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយមកបង្ហាញជាពិសេស ។

សហចៅក្រមស៊ើបអង្កេតលើកឡើងថា ដោយសារតែកិច្ចព្រមព្រៀងតម្រូវឲ្យអង្គជំនុំជម្រះវិសាមញ្ញអនុវត្តដែនយុត្តាធិការឲ្យស្របនឹងស្តង់ដារអន្តរជាតិផ្នែកយុត្តិធម៌នេះហើយ ទើបខ្លួនត្រូវធ្វើការពិនិត្យមើលលើការឃុំខ្លួនរបស់ ឌុច ពីពេលមុនថា តើអាចប៉ះពាល់ដល់នីតិវិធីផ្សេងៗដែរឬទេ? ដើម្បីស្វែងរកបញ្ហានៅចំពោះមុខខ្លួន សហចៅក្រមស៊ើបអង្កេតបានចោទសួរខ្លួនឯងថា តើការឃុំខ្លួនរយៈពេលជាង៨ឆ្នាំ ដែលធ្វើទៅលើ ឌុច ក្នុងក្របខ័ណ្ឌនីតិវិធីដោយឡែកមួយ(ចង់សំដៅលើតុលាការយោធា)ប៉ះពាល់ដល់នីតិវិធីពេលបច្ចុប្បន្នដែរឬទេ? (ចង់សំដៅដល់នីតិវិធីដែលកំពុងអនុវត្តក្នុងក្របខ័ណ្ឌអង្គជំនុំជម្រះវិសាមញ្ញ) ។ ម្យ៉ាងវិញទៀតថាតើការឃុំខ្លួនលើសរយៈពេលច្រើន នឹងបំពានដល់សិទ្ធិការពារខ្លួនដែលប៉ះពាល់ទៅដល់លទ្ធភាពក្នុងការប្តឹងមកក្នុងដែនសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញមិនត្រូវអនុញ្ញាតឲ្យឃុំខ្លួន ឌុច ឬបន្តនីតិវិធីដោយអង្គជំនុំជម្រះវិសាមញ្ញ? ដោយសហចៅក្រមស៊ើបអង្កេតពន្យល់បន្ថែមថា បើទោះបីជាអង្គជំនុំជម្រះវិសាមញ្ញបង្កើតឡើងនៅក្នុងក្របខ័ណ្ឌអង្គតុលាការកម្ពុជាក៏ដោយក៏ប៉ុន្តែវាគឺជាស្ថាប័នឯករាជ្យមួយដោយមានរចនាសម្ព័ន្ធដោយឡែកពីដែនយុត្តាធិការកម្ពុជា ។

បន្ទាប់ពីបានចោទសួរដើម្បីស្វែងរកបញ្ហាឲ្យឃើញសហចៅក្រមស៊ើបអង្កេតបានសិក្សាលើគោលការណ៍ច្បាប់សំខាន់ៗពីរ ។ ទី១) សហចៅក្រមស៊ើបអង្កេតសិក្សាលើគោលការណ៍ច្បាប់មួយដែលជាភាសាឡាតាំង *male captus, bene detentus* (អានថា មែលី ខែបទុស បែណី ឌីតេនទុស) សម្រួលមកថា តុលាការអាចអនុវត្តដែនយុត្តាធិការរបស់ខ្លួនបានទៅលើជនជាប់ចោទ ដោយមិនចាំបាច់គិតដល់របៀបដែលជនជាប់ចោទនោះត្រូវបានបញ្ជូនមកក្នុងដែនយុត្តាធិការរបស់តុលាការឡើយ ។ និយាយឲ្យងាយយល់ជាងនេះទៀតនោះគឺថា បើទោះបីជាជនជាប់ចោទត្រូវបានចាប់បញ្ជូនមកដល់តុលាការតាមវិធីណាក៏ដោយ (រួមទាំងការចាប់មកនោះមានលក្ខណៈខុសនីតិវិធីច្បាប់) តុលាការនៅតែមានសិទ្ធិចាត់ការតាមនីតិវិធីរបស់ខ្លួនដដែល ។ នៅក្នុងដីកាឃុំខ្លួន ឌុច បណ្តោះអាសន្ននេះ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញពិនិត្យមើលថា តើគោលនេះអាចយកមកអនុវត្តបានដែរឬទេ? សហចៅក្រមស៊ើបអង្កេតយល់ថា គោលការណ៍នេះអាចយកមកអនុវត្តទៅលើចំណាត់ការរឿងឃុំខ្លួន ឌុច បានដោយយល់ថា "ស្ថានភាពដែលជនជាប់ចោទត្រូវបានបញ្ជូនមកចំពោះមុខតុលាការមិនមានផល(ប៉ះពាល់)អ្វីបន្តិចឡើយលើការជំនុំជម្រះជនជាប់ចោទ (ពីព្រោះថាភាគច្រើននៃស្ថានការណ៍ដែលកើតពីមុនៗគឺច្រើនទាក់ទងនឹងលក្ខខណ្ឌនៃការចាប់ខ្លួនជនត្រូវចោទនៅដើមដំបូង

ហើយ) មិនសូវមានទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួនដែលមាននៅពេលក្រោយនេះទេ» ។

ការអះអាងនៅក្នុងការសម្រេចបែបនេះ សហចៅក្រមស៊ើបអង្កេតបានលើកយកគំរូនៃការសម្រេចរបស់តុលាការផ្សេងៗទៀតមកបង្ហាញដែលរឿងក្តីទាំងនោះស្ថិតនៅក្នុងស្ថានភាពប្រហាក់ប្រហែលគ្នានឹងរឿងក្តីប្រឆាំងនឹង ឌុច ដែរ ។ តុលាការទាំងនោះបានយកគោលការណ៍ *male captus, bene detentus* មកអនុវត្ត ។ ជាក់ស្តែងរឿងក្តីប្រឆាំងនឹងស្កុត (Scott) ដែលជាស្ត្រីជនជាតិអង់គ្លេសបានធ្វើសក្ខីកម្មក្លែង (ការភូតភរតុលាការ...) ត្រូវបានចាប់ខ្លួននៅប្រទេសប៊ែលហ្ស៊ិក ហើយក្រោយមកបញ្ជូនទៅចក្រភពអង់គ្លេសដើម្បីធ្វើការកាត់សេចក្តី ។ មេធាវីការពារក្តីជំទាស់នឹងដែនយុត្តាធិការរបស់តុលាការអង់គ្លេស ក៏ប៉ុន្តែតុលាការបានសម្រេចយ៉ាងដូច្នេះថា «អាស្រ័យហេតុនេះ បញ្ហានៅត្រង់ថាតើជនត្រូវចោទពីបទឧក្រិដ្ឋកម្មដែលរកឃើញនៅក្នុងប្រទេសត្រូវតែតុលាការធ្វើការពិចារណាអំពីស្ថានភាពផ្សេងៗទាក់ទិននឹងការនាំខ្លួនមកកាន់តុលាការដែរឬយ៉ាងណា» ។ ចៅក្រមម្នាក់បានសម្រេចថា «ខ្ញុំបានគិតនិងនៅតែគិតថា យើងមិនអាចស៊ើប

អង្កេតលើស្ថានភាពនោះបានទេ» ។ ផ្ទុយពីការសម្រេចបែបនេះបន្តិចត្រង់ថានៅក្នុងរឿងក្តី អែលលៀត (Elliott) ចៅក្រម *Lord Goddard* សរសេរថា «វាអាចជះឥទ្ធិពលដល់តុលាការ (ក្នុងសាលក្រមរបស់ខ្លួន) ប្រសិនបើមានការគិតថាមានបញ្ហាមិនប្រក្រតី ឬមិនត្រឹមត្រូវចំពោះការចាប់ខ្លួន» ។ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញបានព្យាយាមលើកយកគំរូនៃការសម្រេចទាក់ទិននឹងរឿងក្តីស្រដៀងៗគ្នា ដែលតុលាការផ្សេងៗបានសម្រេចជាយូរមកហើយ មានដូចជាតុលាការកំពូលសហរដ្ឋអាមេរិកក្នុងរឿងក្តី *Ker* ប្រឆាំងនឹង *Illinois*, រឿងក្តី *Frisbie* ប្រឆាំងនឹង *Collins* ។ ក្នុងរឿងក្តី *Toscanino* បើទោះបីសាលាឧទ្ធរណ៍សហព័ន្ធបដិសេធការអនុវត្តវិធានក្នុងរឿងក្តី *Ker* និង *Frisbie* ក៏ដោយ តុលាការកំពូលសហរដ្ឋអាមេរិកនៅតែសម្រេចក្នុងរឿងក្តីផ្សេងមួយទៀត (រឿងក្តី *Alvarez Machain*) ដោយប្រកាន់ជំហររបស់ខ្លួនដដែល ។

ខ្ញុំសូមមិនលើកយកឈ្មោះតុលាការនិងរឿងក្តីផ្សេងៗទៀតដែលសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញបានលើកយកមកសំអាងនៅក្នុងការសម្រេចឃុំខ្លួន ឌុច បណ្តោះអាសន្ននោះទេ ពីព្រោះដីកានេះក៏ត្រូវបានចុះផ្សាយនៅក្នុងទំព័រទស្សនាវដ្តីនេះដែរ ។ ចំណុចសំខាន់នៅទីនេះ គឺគ្រាន់តែចង់ពន្យល់ឲ្យងាយស្រួលយល់អំពីគោលការណ៍ច្បាប់ដែលសហចៅក្រមស៊ើបអង្កេតបានយកមកអនុវត្ត ជាពិសេសគោលការណ៍ច្បាប់ *male captus, bene detentus* ។

ដូចគ្នានេះសហចៅក្រមស៊ើបអង្កេតក៏បានលើកយកគោលការណ៍ច្បាប់មួយទៀតមកបង្ហាញនៅក្នុងការសម្រេចរបស់ខ្លួនគឺគោលការណ៍ «ការរំលោភបំពាននីតិវិធី» (*abuse of process*) ។ តើគោលការណ៍នេះមានន័យយ៉ាងដូចម្តេច ហេតុអ្វីបានជាសហចៅក្រមស៊ើបអង្កេតលើកយកមកពិនិត្យយ៉ាងដូច្នេះ?

ការរំលោភបំពាននីតិវិធីត្រូវបានកំណត់និយមន័យថា ជាបញ្ហាដែលមានលក្ខណៈអយុត្តិធម៌ និងកំហុសឆ្គងនឹងការកាត់សេចក្តីដែលតុលាការមិនគួរអនុញ្ញាតឲ្យព្រះរាជអាជ្ញាបន្តនីតិវិធីតទៅទៀត ។ តុលាការត្រូវសម្រេចលើអ្វីដែលមានភាពអយុត្តិធម៌និងកំហុសឆ្គងដោយសំអាងលើអង្គហេតុនីមួយៗដែលមាននៅក្នុងរឿងក្តី ។ អាចមានប្រភេទរឿងក្តី២យ៉ាង ដែលតុលាការមានសិទ្ធិមិនបន្តនីតិវិធីរបស់ខ្លួន ទី១) ការរំលោភបំពាននីតិវិធីកើតឡើងដែលធ្វើឲ្យតុលាការមិនអាចផ្តល់ឲ្យជនជាប់ចោទនូវការកាត់សេចក្តីប្រកបដោយសុចរិតយុត្តិធម៌ និងទី២) ការរំលោភបំពាននីតិវិធីធ្វើឲ្យការឈានដល់ដំណើរការទាំងមូលខុសតែម្តង ពីព្រោះការរំលោភបំពាននឹងប្រមាថយ៉ាងធ្ងន់ធ្ងរដល់ខ្លឹមសារយុត្តិធម៌របស់តុលាការនិងភាពសមរម្យដែលសុំឲ្យមានការកាត់សេចក្តីលើចុងចោទក្នុងស្ថានភាពពិសេសផ្សេងៗនៃរឿងក្តីដោយឡែក ។

នៅក្នុងចំណុចនេះ ដូចគ្នានឹងចំណុចមុនដែរ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញបានព្យាយាមលើកយកទស្សនៈយល់ឃើញរបស់តុលាការផ្សេងៗទៅលើរឿងក្តីខុសៗគ្នាមកបង្ហាញ និងឆ្លុះបញ្ចាំងថាតើតុលាការទាំងនោះអនុវត្តទ្រឹស្តី «ការរំលោភបំពាននីតិវិធី» យ៉ាងដូចម្តេច? តាមការសង្កេតរបស់ខ្ញុំ ភាគច្រើននៃការលើកយកទស្សនៈយល់ឃើញរបស់តុលាការផ្សេងៗលើរឿងក្តីខុសៗគ្នារបស់សហចៅក្រមស៊ើបអង្កេតគឺ

ទាក់ទិននឹងការបដិសេធច្រើនជាងការគាំទ្រ ។ មានន័យថា ប្រសិនបើមានការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិរបស់ចុងចោទឬនីតិវិធីនៃការចាប់បញ្ជូនជនជាប់ចោទមកកាន់តុលាការមួយផ្សេងទៀតត្រូវបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរនោះ តុលាការក្រោយនឹងសម្រេចមិនចាត់ការរឿងក្តី ឬប្រកាសអសមត្ថកិច្ច (តុលាការក្រោយពុំមានដែនយុត្តាធិការលើរឿងក្តីនោះ) ឬក៏យល់ឃើញថា គួរដោះលែងជនជាប់ចោទ ។

សូមលើយកឧទាហរណ៍មួយមកបង្ហាញដើម្បីងាយស្រួលយល់និងសូមអានដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នត្រង់ចំណុច «ខ» ចាប់ពីទំព័រ៧ ដល់ទំព័រ១០ ក្នុងចំណុច១២ ដល់១៩ ។ សហចៅក្រមស៊ើបអង្កេតបានលើកយកការយល់ឃើញរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា លើរឿងក្តី *Barayagwiza* មកបង្ហាញថា «ដោយមានការរំលោភបំពានធ្ងន់ធ្ងរនិងជាក់ស្តែងលើសិទ្ធិរបស់ជនជាប់ចោទការអនុវត្តសមត្ថកិច្ចលើករណីបែបនេះអាចបណ្តាលឲ្យមានព្យសនកម្ម (ការខូចខាតឬប៉ះពាល់) ដល់សុចរិតភាពរបស់តុលាការ» ការបន្តដំណើរការក្តីនៅក្នុងករណីនេះគឺ «ផ្ទុយទៅនឹងទស្សនៈដែលថាតុលាការមានយុត្តិធម៌» ។

សូមធ្វើការកត់សម្គាល់បន្តិចអំពីការណ៍ដែលសហចៅក្រមធ្វើបែបនេះ មុននឹងឈានដល់ការបង្ហាញអំពីថាតើសហចៅក្រមស៊ើបអង្កេតទាំងពីរមានទស្សនៈផ្ទាល់ខ្លួនលើអង្គហេតុនៃការឃុំខ្លួនឌុចដែរទេ ។ នៅក្នុងប្រទេសជឿនលឿនដែលប្រព័ន្ធច្បាប់ក៏មានការជឿនលឿនដែរនោះ ចៅក្រមតែងតែស្វែងរកសេចក្តីសម្រេចពីតុលាការផ្សេងៗមកបង្ហាញមុននឹងធ្វើការសម្រេចសេចក្តីចំពោះរឿងក្តីណាដែលមានលក្ខណៈស្មុគស្មាញ ហើយដែលខ្លួនពុំធ្លាប់ជួបប្រទះ ។ របៀបនេះហៅថាការស្វែងរកយុត្តិសាស្ត្រដែលសម្រេចឡើងចំពោះរឿងក្តីមុនៗដែលកើតឡើងរួចហើយដើម្បីបង្ហាញថាចៅក្រមមិនមែនចេះតែសម្រេចសេចក្តីដោយមិនពិចារណាមុខក្រោយនោះទេ ។ ខ្ញុំមិនបានដឹងថានៅក្នុងប្រព័ន្ធតុលាការកម្ពុជាសព្វថ្ងៃនេះ មានការសម្រេចដែលធ្វើឡើងដោយរបៀបនេះដែរឬយ៉ាងនោះទេ គ្រាន់តែយល់ថា ការសម្រេចសេចក្តីរបៀបនេះនឹងធ្វើឲ្យអ្នកប្តឹងអស់ចិត្តដោយមិនបន្សល់នូវភាពសង្ស័យ ។ លើសពីនេះទៅទៀត សេចក្តីសម្រេចបែបនេះត្រូវបានផ្សព្វផ្សាយជាសាធារណៈដែលជាផលល្អប្រសើរសម្រាប់ឲ្យសាធារណជនក៏ដូចជាមន្ត្រីច្បាប់និងនិស្សិតច្បាប់ធ្វើការស្វែងយល់និងសិក្សាវិភាគជាប្រយោជន៍ក្នុងការពង្រីកចំណេះដឹងរបស់ខ្លួនទៅថ្ងៃអនាគតថែមទៀត ។

**ចំពោះសហចៅក្រមស៊ើបអង្កេតៈ**

ជាដំបូង សហចៅក្រមស៊ើបអង្កេតទាំងពីរប្រកាសបដិសេធភ្លាមអំពីសមត្ថកិច្ច ដោយខ្លួនយល់ឃើញថា «ខ្លួនមិនមានសមត្ថកិច្ចក្នុងការវាយតម្លៃពីភាពត្រឹមត្រូវតាមច្បាប់នៃការឃុំខ្លួនកន្លងមកដែលធ្វើលើ ឌុច...» ។ សហចៅក្រមស៊ើបអង្កេតនៅពេលនេះនិយាយសំដៅដល់ការឃុំខ្លួន ឌុច បណ្តោះអាសន្នអស់រយៈពេលជាង៨ឆ្នាំ ដែលធ្វើឡើងដោយតុលាការយោធា (តុលាការក្នុងស្រុក) ។ សហចៅក្រមស៊ើបអង្កេតបានបង្ការខ្លួនឯងពីការចោទប្រកាន់ ឬរិះគន់ណាមួយលើការយល់ឃើញរបស់ខ្លួនបែបនេះដោយនិយាយបន្ថែមក្នុងន័យថា ខ្លួនដែលជាសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញមិន«បានបំពេញការងារដោយរបៀបត្រូវរ៉ូវគ្នា»នឹង តុលាការយោធានោះឡើយ ។ គឺថា «នៅមុនពេលបើកការស៊ើបសួរបច្ចុប្បន្ន សហចៅក្រមស៊ើបអង្កេត... មិនមានលទ្ធភាពណាមួយក្នុងការធ្វើអន្តរាគមន៍នោះទេ» ។

សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញបានបដិសេធចំពោះការអនុវត្តទ្រឹស្តីនៃការរំលោភបំពាននីតិវិធីដោយយល់ថា «ទ្រឹស្តីនៃការរំលោភបំពានជានីតិវិធីមិនអាចអនុវត្តបានទេក្នុងករណីនេះ» ។ ផ្អែកតាមទ្រឹស្តីនេះ នីតិវិធីដែលសហចៅក្រមស៊ើបអង្កេតកំពុងអនុវត្តអាចផ្អាកបានដរាបណាមានការបង្ហាញឲ្យឃើញថា មាន«ការរំលោភបំពានធ្ងន់ធ្ងរនិងពិតប្រាកដលើសិទ្ធិរបស់ជនជាប់ចោទ» ជាពិសេសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ សហចៅក្រមស៊ើបអង្កេតទំនងជាយល់ថា ប្រសិនបើគ្មានការបង្ហាញថា «ឌុច បានទទួលរងនូវអំពើទារុណកម្ម ឬការធ្វើបាបអាក្រក់ធ្ងន់ធ្ងរ» ពីពេលមុនទេ «ការឃុំខ្លួនបន្តដែលមាននៅតុលាការយោធា បើប្រៀបធៀបទៅនឹងបទឧក្រិដ្ឋដែលដាក់បន្ទុកលើជននេះមិនអាចត្រូវចាត់ថា មានលក្ខណៈគ្រប់គ្រាន់ជាការបំពានធ្ងន់ធ្ងរនោះទេ» ។ ដោយសំអាងហេតុផលលើខាងនេះ សហចៅក្រម

ស៊ើបអង្កេតយល់ឃើញថា ដំណើរការនីតិវិធីក្នុងការសម្រេចឃុំខ្លួន ឌុច អាចបន្តធ្វើទៅបាន ។

ចុងបញ្ចប់សំណួរតែមួយគត់ដែលសហចៅក្រមស៊ើបអង្កេតចោទសួរខ្លួនឯងគឺ «តើការឃុំខ្លួន ឌុច បណ្តោះអាសន្នជាការចាំបាច់ដែរឬអត់? ...» ។ ដូចបានជម្រាបរួចមកហើយថាសហចៅក្រមស៊ើបអង្កេតបានសម្រេចឃុំខ្លួន ឌុច មិនឲ្យលើសពី១ឆ្នាំ ។ ប៉ុន្តែអ្វីដែលសំខាន់ជាងនេះ ប្រជាជនចង់ដឹងថា មានហេតុផលអ្វីខ្លះដែលសហចៅក្រមស៊ើបអង្កេតដើម្បីឈានដល់ការសម្រេចឃុំខ្លួនបែបនេះ ។ ខាងក្រោមនេះគឺជាការស្រង់ទាំងស្រុងចេញពីដីកា នៅត្រង់ចំណុច២២ ដូចតទៅ ÷

...ទាក់ទិននឹងចំណុចនេះ ចម្លើយរបស់សហចៅក្រមស៊ើបអង្កេតមានដូចតទៅ÷ អង្គហេតុដែលត្រូវដាក់បន្ទុកចំពោះជនត្រូវចោទមានលក្ខណៈធ្ងន់ធ្ងរ បទឧក្រិដ្ឋដែលបានកើតឡើងអស់រយៈ៣០ឆ្នាំមកនៅតែបន្តជាបញ្ហាធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈ ហេតុដូច្នេះ មិនមែនជាការហួសហេតុពេកទេដែលអះអាងថានៅក្នុងបរិបទដ៏ផុយស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន ការដោះលែងជននេះអាចនឹងបង្កឲ្យមានការសម្តែងនូវការមិនពេញចិត្តជាទូទៅដែលអាចបង្កឲ្យមានអំពើហិង្សា ឬអាចប៉ះពាល់ដល់សន្តិសុខផ្ទាល់របស់ជននេះ ។ ក្រៅពីនេះ ទោសឧក្រិដ្ឋមួយជីវិតដែល ឌុច ត្រូវប្រឈមមុខនាំឲ្យបារម្ភថា ជននេះអាចស្វែងរកការគេចខ្លួនពីដំណើរការតុលាការ ។

ចុងបញ្ចប់ សេចក្តីបារម្ភថា សាក្សីនិងជនរងគ្រោះពីអំពើប្រព្រឹត្តដ៏ធ្ងន់ធ្ងរបំផុតដែលដាក់បន្ទុកលើជននេះមានអារម្មណ៍ភ័យខ្លាច និងបដិសេធចូលរួមក្នុងដំណើរការតុលាការ ប្រសិនបើពុំមានការដាក់ឃុំខ្លួនជនត្រូវចោទ ។

**ព្រឹត្តិការណ៍ទី៣៖**

ទាក់ទិននឹងការចាត់តាំងមេធាវីការពារក្តីសម្រាប់ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ។ យោងតាមសេចក្តីប្រកាសចុះថ្ងៃទី២ ខែសីហាកន្លងទៅនេះ ឌុច បានសម្រេចយកមេធាវីខ្មែរម្នាក់គឺលោក កា សាវុធ និងលោក ហ្វ្រង់ស៊័រ រូស្សូ (Franscois Roux) ធ្វើជាមេធាវីការពារខ្លួននៅចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ច្បាប់បានកំណត់ឲ្យជនជាប់ចោទត្រូវមានមេធាវីការពារក្តីតាមការជ្រើសរើសរបស់ខ្លួន ។ ដោយសារជនជាប់ចោទពុំមានលទ្ធភាពនិងមធ្យោបាយបង់ថ្លៃសេវាមេធាវី អង្គជំនុំជម្រះវិសាមញ្ញនឹងទទួលខុសត្រូវលើការចំណាយសេវាមេធាវីទាំងអស់តាមរយៈការចាត់ចែងរបស់អង្គភាពគាំពារការពារក្តី ។

លោក កា សាវុធ ប្រកបមុខវិជ្ជាជីវៈជាមេធាវីតាំងពីឆ្នាំ១៩៨២ ហើយមានបទពិសោធន៍ច្រើនក្នុងការការពារកូនក្តីក្នុងរឿងព្រហ្មទណ្ឌ ។ លោកបានធ្វើជាមេធាវីការពារ ឌុច អស់រយៈពេល៨ឆ្នាំមកហើយ គឺចាប់តាំងពី ឌុច ត្រូវចាប់ខ្លួន និងបញ្ជូនទៅឃុំឃាំងបណ្តោះអាសន្ននៅតុលាការមន្ទីរឃុំឃាំងនៃតុលាការយោធានៅឆ្នាំ១៩៩៩ ។

លោក ហ្វ្រង់ស៊័រ រូស្សូ ជនជាតិបារាំង ធ្វើជាមេធាវីការពារក្តីជាង៣០ឆ្នាំមកហើយ ។ លោកមានឈ្មោះបោះសំឡេងដោយគាត់ធ្លាប់ការពារសំណុំរឿងទាក់ទងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា ហើយធ្លាប់ការពារឲ្យកូនក្តីទទួលបានការលើកលែងការចោទប្រកាន់ទៀតផង ។ រហូតមកទល់ពេលនេះ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានសម្រេចចុះឈ្មោះលោកក្នុងបញ្ជីគណៈមេធាវីកម្ពុជា ដូច្នេះលោកមានសិទ្ធិការពារកូនក្តីរបស់នៅមុខអង្គជំនុំជម្រះវិសាមញ្ញចាប់ពីពេលនេះតទៅ ។

**ង៉ាន់ថាន់ ពៅដារ៉ា**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម បាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
Email: dccam@online.com.kh
Home page: www.dccam.org

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Chambres Extraordinaires au sein
des Tribunaux Cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
Office of the Co-Investigating Judges
Bureau des Co-juges d'instruction
សំណុំរឿងព្រហ្មទណ្ឌ
Criminal Case File /Dossier pénal
លេខ/No: 002/14-08-2006

លេខស៊ើបសួរ/Investigation/Instruction

លេខ/No: 001/18-07-2007

# ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន
## Provisional detention Order
## Ordonnance de placement en détention provisoire

*យើង យូ ប៊ុនឡេង និង Marcel Lemonde សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*

◆ *បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤*

◆ *បានឃើញវិធាន ៦៣ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ*

◆ *បានឃើញការបើកការស៊ើបសួរលើឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ភេទប្រុស កើតថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ ភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ សញ្ជាតិខ្មែរ របររកស៊ីគ្រូបង្រៀន។ ឪពុកឈ្មោះ កាំង គី (ស្លាប់) ម្តាយឈ្មោះ មាស គឹមសៀវ (រស់) ប្រពន្ធឈ្មោះ ឈឹម សុផល (ស្លាប់) មានកូន៤នាក់ ទីលំនៅបច្ចុប្បន្ននៅភូមិអូរទន្ទឹម ឃុំតាសាញ់ ស្រុកសំឡូត ខេត្តបាត់ដំបង។*

*ត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៥, ២៩(ថ្មី) និង ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។ បានឃើញការជជែកដេញដោលដែលបានធ្វើនៅថ្ងៃនេះ។*

***សំអាងហេតុៈ*** *ដោយផ្អែកលើលទ្ធផលនៃការស៊ើបសួរដែលកំពុងដំណើរការៈ*

### I. *សេចក្តីថ្លែងនៃអង្គហេតុ និងអង្គច្បាប់*

*១) នៅក្នុងស្ថានភាព (ដោយមិនប៉ះពាល់ដល់លទ្ធផលនៃការស៊ើបសួរកំពុងដំណើរការ ដែលអាចនាំឲ្យកំណត់បទល្មើសផ្សេងទៀតដែលបានចង្អុលបង្ហាញនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ និងដែលអាចត្រូវដាក់ជាបន្ទុកចំពោះបុគ្គលពាក់ព័ន្ធនេះ) កាំង ហ្កេកអ៊ាវ ហៅ ឌុច ត្រូវបានប្តឹងចោទពីការបានគ្រប់គ្រងមជ្ឈមណ្ឌលសន្តិសុខ ស-២១ នៅចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ ជាកន្លែងដែលការរំលោភបំពានឥតគណនាត្រូវបានប្រព្រឹត្តនៅក្រោមអំណាចរបស់ខ្លួនប្រឆាំងនឹងប្រជាពលរដ្ឋស៊ីវិល (ការឃុំឃាំងដោយបំពាន ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត ការសម្លាប់រង្គាល ។ល។) ដែលស្ថិតក្នុងក្របខ័ណ្ឌនៃការអនុវត្តនយោបាយជាលក្ខណៈប្រព័ន្ធឬមានលក្ខណៈទូទៅដែលជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ។ កាំង ហ្កេកអ៊ាវ ត្រូវបានដាក់បន្ទុកតាមរយៈភស្តុតាងឯកសារ និងចម្លើយសាក្សីជាច្រើន។*

សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញ ស្នើឲ្យមានការឃុំខ្លួនបណ្ដោះអាសន្នដោយមូលហេតុថាៈ

◆ មានហេតុផលពិតប្រាកដឲ្យជឿជាក់ថា ឌុច បានចូលរួមក្នុងឧក្រិដ្ឋកម្មដែលបានរៀបរាប់ក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ។

◆ ការឃុំខ្លួនបណ្ដោះអាសន្នគឺជាការចាំបាច់ដើម្បីបង្ការមិនឲ្យមានការគាបសង្កត់គ្រប់បែបយ៉ាងលើសាក្សី ជាពិសេសអ្នកដែលធ្លាប់ស្ថិតនៅក្រោមអំណាចរបស់ជននេះ ។

◆ មានភាពចាំបាច់ផងដែរក្នុងការធានាការរក្សាទុកជនត្រូវចោទសម្រាប់ដំណើរការយុត្តិធម៌ ដោយពិចារណាដល់ស្ថានភាពដែលអាចមានការគេចខ្លួននិងដើម្បីការការពារសុវត្ថិភាពផ្ទាល់របស់ជនពាក់ព័ន្ធនេះ ។ និង

◆ ជាចុងក្រោយការរក្សាសណ្ដាប់ធ្នាប់សាធារណៈ តម្រូវជាចាំបាច់ ។

មេធាវីការពារជនត្រូវចោទលើកឡើងថាៈ

◆ ឌុច ត្រូវបានជាប់ឃុំលើសពី៨ឆ្នាំហើយ ដែលនេះជាការផ្ទុយនឹងច្បាប់ជាតិ និងបទដ្ឋានអន្តរជាតិ ។

◆ អង្គជំនុំជម្រះវិសាមញ្ញកម្ពុជាមានសមត្ថកិច្ចធានាឲ្យមានការគោរពបទដ្ឋានអន្តរជាតិផ្នែកយុត្តិធម៌និងជាពិសេសមាត្រា១៤ (៣-គ) នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងមាត្រា ៥-៣ នៃអនុសញ្ញាអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស ។

◆ លើសពីនេះការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងអង្គហេតុនេះមិនអាចធ្វើបានឡើយដោយហេតុលក្ខខណ្ឌនៃមាត្រា៦៣ នៃវិធានផ្ទៃក្នុងមិនត្រូវបានបំពេញ ដោយហេតុថា ឌុច រស់នៅមានសេរីភាពតាំងពីឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៩៩ ដោយមិនមានបង្កនូវភាពវឹកវរណាមួយឡើយ និងជាពិសេសក៏មិនមានការគាបសង្កត់ណាមួយកើតមានដែរ ។

◆ ឌុច មិនមែនជាអ្នកដឹកនាំជាន់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យ ហើយមានមនុស្សរាប់ពាន់នាក់ដែលធ្លាប់បានស្ថិតនៅក្រោមស្ថានភាពជាប្រធានមជ្ឈមណ្ឌលសន្តិសុខដូចរូបជនត្រូវចោទ ។

◆ ជនសង្ស័យដទៃទៀតស្ថិតនៅក្នុងសេរីភាព និងជាផលវិបាក ស្នើសុំឲ្យដោះលែងកូនក្ដីរបស់ខ្លួនដោយស្នើឲ្យដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

ការាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រកាសថា គាត់ធ្លាប់ជាប្រធានមជ្ឈមណ្ឌល ស-២១ ហើយគាត់ត្រៀមខ្លួនដើម្បីធ្វើការបង្ហាញឧក្រិដ្ឋកម្មទាំងឡាយណាដែលប្រព្រឹត្តដោយពួកខ្មែរក្រហមហើយថា ហេតុដូច្នេះមិនមានហេតុផលណាមួយឲ្យគិតថាគាត់អាចធ្វើការគាបសង្កត់លើសាក្សី ដែលលើសពីនេះគាត់មិនដឹងថានរណាជាសាក្សីនោះទេ ។

២) នៅមុនការសម្រេចការឃុំខ្លួន ឌុច ជាបណ្ដោះអាសន្ន យើងសូមធ្វើការរំឭកស្ថានភាពពិសេសរបស់បុគ្គលនេះដែលមានលក្ខណៈលំបាកដោយឡែក ដែលសហចៅក្រមស៊ើបអង្កេតដែលមានកាតព្វកិច្ចធ្វើការស៊ើបសួរដាក់បន្ទុកនិងដោះបន្ទុកត្រូវសម្រេចចំពោះស្ថានភាពនេះ ។ តាមពិតទៅ នៅពេលបច្ចុប្បន្ននេះ ឌុច ត្រូវបានចោទប្រកាន់នៅចំពោះមុខតុលាការយោធាភ្នំពេញដែលមានអង្គហេតុមួយផ្នែកមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញ និងមានអង្គហេតុមួយផ្នែកផ្សេងទៀតដែលចូលក្នុងសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ នៅក្នុងក្របខ័ណ្ឌនៃនីតិតុលាការយោធា ឌុច ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ននៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ហើយគាត់ត្រូវបានជាប់ឃុំតាំងពីពេលនោះមកនិងជាការប្រាកដណាស់ថា ការឃុំខ្លួននេះចោទជាបញ្ហាចំពោះការគោរពបទដ្ឋានអន្តរជាតិផ្នែកយុត្តិធម៌ និងដែលជាពិសេសចំពោះមាត្រា៩(៣) និង ១៤(៣-គ) នៃកតិកាសញ្ញាអន្តរជាតិទាក់ទងនឹងសិទ្ធិពលរដ្ឋ និងនយោបាយដែលផ្អែកតាមអត្ថន័យនៃមាត្រាទាំងនេះ គ្រប់បុគ្គលដែលត្រូវចាប់ខ្លួនឬឃុំខ្លួនពីបទចោទនៃបទល្មើសព្រហ្មទណ្ឌត្រូវទទួលការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប ឬត្រូវដោះលែងឲ្យមានសេរីភាព ។

៣) កិច្ចព្រមព្រៀងចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ រវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាចែងយ៉ាងច្បាស់នៅក្នុងមាត្រា១២ថា អង្គជំនុំជម្រះវិសាមញ្ញបំពេញមុខងាររបស់ខ្លួនស្របតាមបទដ្ឋានអន្តរជាតិផ្នែកយុត្តិធម៌ ។ ដូច្នេះគឺជាការចាំបាច់ក្នុងការពិនិត្យហេតុការណ៍ជាយថាហេតុនៃការឃុំខ្លួន ឌុច ដែលមានពីពេលមុន ដោយនៅពេលនេះនីតិវិធីសម្រាប់ ឌុច គឺជាកម្មវត្ថុនៅចំពោះមុខយើង ។ ចំណោទអាចត្រូវលើកឡើងក្នុង

ន័យថា៖ ហេតុដែលជនត្រូវចោទបានស្ថិតនៅក្នុងការឃុំខ្លួនអស់រយៈពេលជាង៨ឆ្នាំ នៅក្នុងក្របខ័ណ្ឌនីតិវិធីដាច់ដោយឡែកអនុវត្តនៅចំពោះមុខយុត្តាធិការមួយផ្សេងទៀតតើមានលក្ខណៈប៉ះពាល់ដល់នីតិវិធីបច្ចុប្បន្នដែរឬទេ? ឬលើសពីនេះទៀត ការឃុំខ្លួនបែបនេះមានលក្ខណៈហួសហេតុ និងបំពានដល់សិទ្ធិការពារខ្លួនដែលនឹងប៉ះពាល់ដល់ការប្តឹងមកយុត្តាធិការរបស់យើង យុត្តាធិការត្រូវបានបង្កើតនៅក្នុងអង្គតុលាការកម្ពុជា ប៉ុន្តែជាស្ថាប័នឯករាជ្យដែលមានរចនាសម្ព័ន្ធដាច់ដោយឡែកពីយុត្តាធិការជាតិដទៃទៀត និងនឹងមិនអនុញ្ញាតតទៅទៀតឲ្យមានការឃុំខ្លួនជាថ្មីចំពោះជនជាប់ចោទ ហើយអាចនឹងរហូតដល់តម្រូវឲ្យបញ្ចប់ការប្តឹងចោទប្រឆាំងនឹងជននេះឬយ៉ាងណា?

## II. ទ្រឹស្តីច្បាប់ និងយុត្តិសាស្ត្រ

៤) នៅពេលនេះជម្រើសដែលមានចំពោះសហចៅក្រមស៊ើបអង្កេតមានដូចតទៅ៖ នៅទីនេះ តើត្រូវអនុវត្តបុរាណភាសិត *Male captus, bene detentus* (តុលាការអាចមានយុត្តាធិការលើជនជាប់ចោទដោយមិនគិតដល់របៀបដែលបុគ្គលនោះត្រូវបានបញ្ជូនមកយុត្តាធិការរបស់តុលាការ) ឬ បញ្ច្រាសមកវិញ ត្រូវអនុវត្តតាមទ្រឹស្តីនៃការរំលោភបំពាននីតិវិធីឬយ៉ាងណា? ការរំឭកអំពីអត្ថន័យនៃសញ្ញាណទាំងពីរនេះគឺជាការចាំបាច់នៅមុនពេលធ្វើការសម្រេចបញ្ហានេះ ។

### ក) *Male captus, bene detentus*

៥) មានឧទាហរណ៍ជាច្រើនណាស់ ទាំងនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិនៅក្នុងការអនុវត្តសុភាសិតនេះ ដែលតាមន័យនៃសុភាសិត ស្ថានភាពដែលជនជាប់ចោទត្រូវបានបញ្ជូនមកចំពោះមុខតុលាការមិនមានផលអ្វីបន្តិចឡើយលើការជំនុំជម្រះជនជាប់ចោទ ។ ភាគច្រើននៃស្ថានភាពដែលកើតពីមុនៗ គឺច្រើនទាក់ទងនឹងលក្ខខណ្ឌនៃការចាប់ខ្លួនជនត្រូវចោទនៅដើមដំបូងមិនសូវមានទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួនដែលមាននៅពេលក្រោយនោះទេ ប៉ុន្តែក្នុងករណីទាំងពីរនេះ ការសំអាងហេតុផលគឺមានលក្ខណៈដូចគ្នា ។ នៅពេលនេះ ការរំឭកអំពីសេចក្តីសម្រេចសំខាន់ៗនៅក្នុងរឿងនេះ គឺជាការមួយដ៏មានប្រយោជន៍ ប៉ុន្តែយើងពុំមានបំណងបង្ហាញឲ្យបានល្អិតល្អន់នូវសេចក្តីសម្រេចទាំងអស់នោះទេ ។

៦) ចាប់តាំងពីដើមសតវត្សរ៍ទី១៩ នៅប្រទេសអង់គ្លេស គោលការណ៍ *Male captus, bene detentus* ត្រូវបានទទួលស្គាល់ស្គាល់ក្នុងរឿងក្តី Scott ៖ ជនសញ្ជាតិអង់គ្លេសដែលត្រូវគេស្វែងរកចំពោះការផ្តល់សក្ខីភាពក្លែងត្រូវបានចាប់ខ្លួននៅប្រទេសប៊ែលហ្ស៊ិក និងបញ្ជូនមកចក្រភពអង់គ្លេស ។ ជាការឆ្លើយតបនឹងអញ្ញត្រកម្ម អសមត្ថកិច្ចដែលលើកឡើងដោយមេធាវីការពារក្តី យុត្តាធិការអង់គ្លេសសម្រេចយ៉ាងដូច្នេះថា៖ «បញ្ហាដែលចោទឡើងគឺជាបញ្ហាដែលត្រូវស្វែងយល់ថាតើជាករណីយកិច្ចតុលាការ (...) ក្នុងការគិតគូរដល់ស្ថានភាពដែលបុគ្គលត្រូវបានបញ្ជូនមកចំពោះមុខតុលាការឬយ៉ាងណា ។ ខ្ញុំយល់ឃើញថាយើងមិនអាចធ្វើការអង្កេតលើស្ថានភាពទាំងនោះទេ» ។ ដំណោះស្រាយដូចគ្នាមាននៅក្នុងរឿងក្តី Elliott (ប៉ុន្តែមានភាពខុសគ្នាបន្តិចដោយប្រធានតុលាការលោក Lord Goddard បានបន្ថែមថា៖ «តុលាការនឹងអាចពិចារណានៅក្នុងការវិនិច្ឆ័យរបស់ខ្លួន ប្រសិនបើយល់ថាការចាប់ខ្លួនមានភាពមិនប្រក្រតី ឬរំលោភបំពាន») ។ នៅពេលក្រោយមកទៀត យុត្តិសាស្ត្រមានការវិវត្តដូចដែលមាននៅក្នុងការបកស្រាយនៅផ្នែកខាងក្រោមចំពោះរឿងរំលោភនីតិវិធី ។

៧) តុលាការកំពូលសហរដ្ឋអាមេរិកតែងតែអនុលោមតាមគោលការណ៍ *Male captus, bene detentus* ។ នៅក្នុងរឿងក្តី Ker. ប្រឆាំងនឹង Illinois ជនជាប់ចោទជាពលរដ្ឋអាមេរិកដែលត្រូវបាននាំខ្លួនដោយបង្ខំពីប្រទេសប៉េរូមកសហរដ្ឋអាមេរិកបន្ទាប់ពីមានអំពើចាប់ពង្រត់ បានជំទាស់សមត្ថកិច្ចរបស់យុត្តាធិការអាមេរិក ។ តុលាការបានធ្វើការឆ្លើយតបថា៖ «ការចាប់ពង្រត់ដោយបង្ខំបែបនេះ មិនមែនជាហេតុផលគ្រប់គ្រាន់សម្រាប់ជនជាប់ចោទមិនទទួលខុសត្រូវចំពោះបទល្មើសដែលជនជាប់ចោទត្រូវបានចោទប្រកាន់ឡើយ នៅពេលដែលជនជាប់ចោទត្រូវបានដាក់ឲ្យជំនុំជម្រះចំពោះមុខតុលាការដែលមានសិទ្ធិវិនិច្ឆ័យសេចក្តីចំពោះបទល្មើសបែបនេះ ហើយការចាប់ពង្រត់នេះមិនមែនជាឧបសគ្គដែលមានអានុភាពនាំឲ្យតុលាការមិនអាចជំនុំជម្រះជនជាប់ចោទនេះឡើយ» ។ នៅក្នុងឆ្នាំ១៩៥២ សេចក្តីសម្រេចរឿងក្តី Frisbie ប្រឆាំងនឹង Collins មានសំអាងហេតុប្រហែលគ្នាផងដែរ ។ ក្រោយមកទៀតបញ្ហានេះបានក្លាយជាប្រធានបទពិភាក្សាយ៉ាងខ្លាំងក្លានៅអាមេរិក៖ ដូច

ដែលមានរៀបរាប់ខាងក្រោម (CF B, No. 13) ក្នុងឆ្នាំ១៩៧៤ សាលាឧទ្ធរណ៍សហព័ន្ធបានបដិសេធការអនុវត្តរឿងក្តី Ker-Frisbie នៅក្នុងរឿងក្តី Toscanino ។ ប៉ុន្តែតុលាការកំពូលបានរក្សាជំហរដដែលរបស់ខ្លួនចំពោះរឿងក្តី Alvarez-Machain ប៉ុន្តែមានការបញ្ជាក់ដែរថា សេចក្តីសម្រេចនេះត្រូវបានចៅក្រមដែលមានយោបល់ជំទាស់ចាត់ទុកថាជា «សេចក្តីសម្រេចដ៏ចម្លែកមួយ»...) ។

៨) នៅក្នុងសេចក្តីសម្រេច Adolf EICHMANN ចុះថ្ងៃទី ១១-១២ ខែធ្នូ ឆ្នាំ១៩៦១ តុលាការដំបូងរបស់យេរូសាឡិម (Jerusalem) បានប្រកាសយកគោលជំហរដូចគ្នា ដោយសម្រេចថា÷ «នេះគឺជាវិធានច្បាប់គោលមួយដែលថាបុគ្គលម្នាក់កំពុងប្រឈមការជំនុំជម្រះពីបទល្មើសប្រឆាំងនឹងច្បាប់របស់រដ្ឋមួយ មិនអាចជំទាស់ការជំនុំជម្រះមកលើខ្លួនដោយលើកយកហេតុផលនៃភាពមិនស្របច្បាប់នៃការចាប់ខ្លួន ឬដោយលើកយកសំអាងមធ្យោបាយនៃការនាំខ្លួនជននោះមកកាន់ដែននៃយុត្តាធិការរបស់រដ្ឋបានឡើយ ។ តុលាការនៅប្រទេសអង់គ្លេស សហរដ្ឋអាមេរិក និង អ៊ីស្រាអែល បានចេញសេចក្តីសម្រេចជាបន្តបន្ទាប់ថា កាលៈទេសៈនៃការចាប់ខ្លួននិងមធ្យោបាយសម្រាប់ការនាំយកជនជាប់ចោទមកកាន់ទឹកដីនៃរដ្ឋមួយមិនមានការពាក់ព័ន្ធនឹងការជំនុំជម្រះលើជនជាប់ចោទឡើយ ហើយតុលាការខាងលើបានបដិសេធមិនពិនិត្យមើលកាលៈទេសៈទាំងនោះទេនៅក្នុងគ្រប់ករណីទាំងអស់» ។

៩) ដូចគ្នានេះដែរ តុលាការកំពូលប្រទេសបារាំងនៅក្នុងសាលដីកា ARGOUD ខែមិថុនា ឆ្នាំ១៩៦៤ បានសម្រេចថាៈ «លក្ខខណ្ឌដែលជនត្រូវចោទ(....) ត្រូវបានចាប់ខ្លួននិងបញ្ជូនមកតុលាការ ដែលជាការប៉ះពាល់ដល់ច្បាប់ព្រហ្មទណ្ឌឬគោលការណ៍ជាប្រពៃណីនៃច្បាប់យើង ដែលស្ថានភាពអាក្រក់នេះអាចនឹងលើកឡើងនោះ មិនមែនជាបញ្ហារហូតដល់អាចយកមកធ្វើជាមូលហេតុ មោឃភាពនៃបណ្តឹងចោទប្រកាន់ឡើយ នៅពេលដែលការស្រាវជ្រាវ និងការបង្ហាញការពិត មិនត្រូវបានរកឃើញថាមានវិការៈជាសារវន្ត ឬការការពារក្តី មិនត្រូវបានគេផ្តល់លទ្ធភាពគ្រប់គ្រាន់ក្នុងការអនុវត្តសិទ្ធិរបស់ជនត្រូវចោទនៅចំពោះមុខយុត្តាធិការស៊ើបអង្កេត និងយុត្តាធិការជំនុំជម្រះ» ។ នៅក្នុងសេចក្តីសម្រេច BARBIE នៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៨៣ តុលាការកំពូលបានបញ្ជាក់ឡើងវិញនូវការវិភាគរបស់ខ្លួនដោយប្រើប្រាស់ពាក្យស្ទើរតែដូចគ្នាថាៈ «មិនមានខុសគុណាមួយដល់ការអនុវត្តបណ្តឹងអាជ្ញាប្រឆាំងនឹងជនត្រូវចោទឡើយ...) នៅពេលដែលសិទ្ធិការពារក្តីដ៏ពេញលេញត្រូវបានធានាដោយសេរីដល់ជនត្រូវចោទនៅចំពោះមុខយុត្តាធិការស៊ើបអង្កេតនិងយុត្តាធិការជំនុំជម្រះ» ។

១០) តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា(Rwanda) បានប្រកាសជាច្រើនលើកថា តុលាការនេះមិនទទួលខុសត្រូវចំពោះភាពខុសច្បាប់នៃការចាប់ខ្លួននិងការឃុំខ្លួនជនជាប់ចោទឡើយ ប្រសិនបើករណីទាំងនេះមិនបានធ្វើឡើងតាមសំណើរបស់តុលាការនោះទេ ។ នៅក្នុងសេចក្តីសម្រេច Rwamakuba តុលាការបានបញ្ជាក់ថាតុលាការមិនមានសមត្ថកិច្ចជំនុំជម្រះលើលក្ខខណ្ឌនៃរយៈពេលឃុំខ្លួនរបស់ជនជាប់ចោទនៅមុនការតម្រូវការរបស់តុលាការឡើយ និងថាឧបាស្រ័យទាំងឡាយទាក់ទងទៅនឹងបញ្ហានេះត្រូវធ្វើនៅចំពោះយុត្តាធិការដែលបានសម្រេចអំពីការឃុំខ្លួននេះ ។

១១) ដូចនេះ មានប្រពៃណីដ៏រឹងមាំដែលគាំទ្រដល់ការបែងចែកច្បាស់លាស់រវាងនីតិវិធីអនុវត្តដោយស្របច្បាប់នៅចំពោះមុខយុត្តាធិការមួយ និងការចាប់ខ្លួន ឬការឃុំខ្លួនដែលបានសម្រេចពីមុនដែលមានភាពខុសច្បាប់ដោយអាជ្ញាធរផ្សេងទៀត ។ ប៉ុន្តែប្រពៃណីបែបនេះមានដែនកំណត់របស់ខ្លួននៅក្នុងទ្រឹស្តីនៃការរំលោភបំពាននីតិវិធី ។

## ១) ការរំលោភបំពាននីតិវិធី

១២) ទ្រឹស្តី «ការរំលោភបំពាននីតិវិធី» មានការវិវត្តជាបន្តបន្ទាប់នៅក្នុងប្រព័ន្ធកុម្មិនឡូ (Common Law) ។ នៅក្នុងសេចក្តីសម្រេច Barayagwiza, តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា (Rwanda) បានផ្តល់នូវនិយមន័យដូចខាងក្រោម តុលាការអាចនឹងឈានដល់ការប្រកាសអំពីអសមត្ថកិច្ចនៅពេលដែលៈ «ដោយមានការរំលោភបំពានធ្ងន់ធ្ងរនិងជាក់ស្តែងលើសិទ្ធិរបស់ជនជាប់ចោទ ការអនុវត្តសមត្ថកិច្ចលើករណីបែបនេះអាចបណ្តាលឲ្យមានព្យសនកម្មដល់សុច្ចរិតភាពរបស់តុលាការ» ការបន្តដំណើរ

ការក្តីនៅក្នុងករណីនេះគឺ «ផ្ទុយទៅនឹងទស្សនៈដែលថាតុលាការមានយុត្តិធម៌» ។

១៣) នៅក្នុងរឿងក្តី Toscanino នៅក្នុងឆ្នាំ១៩៧៤ សាលាឧទ្ធរណ៍ថ្នាក់ទី២ របស់សហរដ្ឋអាមេរិក បានយកទ្រឹស្តីនេះមកអនុវត្ត ។ ជនជាប់ចោទដែលជាពលរដ្ឋអ៊ីតាលីត្រូវបានចាប់ពង្រត់ពីអ៊ុយរូហ្គាយ(Uruguay) ដោយអាជ្ញាធររបស់អ៊ុយរូហ្គាយ(Uruguay) និងនាំខ្លួនដោយបង្ខំមកកាន់ប្រទេសប្រេស៊ីល ដែលនៅទីនោះជនជាប់ចោទ ត្រូវបានឃុំខ្លួននិងធ្វើទារុណកម្មប្រហែលជិតបីសប្តាហ៍ បន្ទាប់មកនាំមកកាន់សហរដ្ឋអាមេរិក ដែលនៅទីនោះជនជាប់ចោទត្រូវបានចោទពីបទឧក្រិដ្ឋទាក់ទងនឹងគ្រឿងញៀន ។ តុលាការបានសំអាងថា៖ «យើងយល់ឃើញថាការគោរពនីត្យានុកូលភាពបច្ចុប្បន្ននេះទាមទារឲ្យតុលាការត្រូវបដិសេធការអនុវត្តសមត្ថកិច្ចលើជនជាប់ចោទប្រសិនបើជននេះត្រូវបានចាប់ខ្លួនបន្ទាប់ពីការបំពានដ៏លើសលុប ដែលមានការគិតទុកជាស្រេចនិងគ្មានហេតុផលទៅលើសិទ្ធិមានចែងក្នុងរដ្ឋធម្មនុញ្ញពីសំណាក់អាជ្ញាធរ» ។ ចំពោះតុលាការសេចក្តីសម្រេចផ្សេងទៀតនៅក្នុងស្ថានភាពបែបនេះនាំឲ្យ «ធានាដល់ភាពឃោរឃៅ និងភាពខុសច្បាប់របស់នគរបាល ។

១៤) ក្នុងរឿងក្តី Harrley នូវែលហ្សេឡង់ ជាប្រទេសដំបូងក្នុងចំណោមប្រទេសដទៃទៀតដែលអនុវត្តគោលការណ៍ទាំងនេះ ។ នៅក្នុងរឿងក្តីនេះដែលមានពាក់ព័ន្ធនឹងបញ្ហាបត្យាប័នដែលមានលក្ខណៈបំភ័ន្តចៅក្រម Woodhouse បានបញ្ជាក់ថា៖ «បញ្ហានេះមិនត្រូវស្ថិតនៅក្នុងន័យដែលថាមានភាពគ្រប់គ្រាន់សមរម្យដើម្បីនឹងគិតដល់ការសម្រេចគោលដៅណាមួយនាំឲ្យអាចប្រើប្រាស់គ្រប់មធ្យោបាយនោះទេ ។ បញ្ហាដែលចោទក្នុងរឿងក្តីនេះគឺជាមូលដ្ឋាននៃទស្សនៈទានទាំងមូលនៃសេរីភាពនៅក្នុងសង្គម» ។

១៥) សាលាឧទ្ធរណ៍នៅអាហ្វ្រិកខាងត្បូង ក្នុងរឿងក្តី Ebrahim បានអះអាងយ៉ាងដូច្នេះថា៖ «បុគ្គលត្រូវទទួលការពារប្រឆាំងនឹងការឃុំខ្លួនដោយខុសច្បាប់ ទទួលការការពារប្រឆាំងនឹងការចាប់ពង្រត់ ។ ព្រំដែននៃយុត្តាធិការដែនដីនិងអធិបតេយ្យភាពនៃរដ្ឋត្រូវតែទទួលបានការគោរព ។ ភាពយុត្តិធម៌នៃដំណើរការក្តីត្រូវតែទទួលការធានានិងការបំពានសិទ្ធិត្រូវតែបញ្ចៀសមិនឲ្យមានការធ្វើយ៉ាងដូច្នេះគឺដើម្បីការពារនិងលើកស្ទួយសេចក្តីថ្លៃថ្នូរនិងសុចរិតភាពនៃប្រព័ន្ធយុត្តាធិការ ។ ហេតុនេះរដ្ឋត្រូវគោរពវិធានទាំងនេះ ហើយរដ្ឋត្រូវចូលកាន់មកតុលាការដោយភាពស្អាតស្អំ» ។

១៦) តុលាការកំពូលបានអនុវត្តគោលការណ៍ទាំងនេះដែរ ក្នុងរឿងក្តីប្រហែលគ្នា Bennett ។ ចៅក្រម Lord Bridge of Harwich សង្ខេបសេចក្តីសម្រេចដូចតទៅ៖ «តាមគំនិតរបស់ខ្ញុំ ការទទួលស្គាល់ថាតុលាការអាចបិទភ្នែកចំពោះការមិនគោរពច្បាប់ដែលអនុវត្តនៅក្រៅព្រំដែនយុត្តាធិការរបស់ខ្លួន គឺជាការយល់ឃើញដ៏ចង្អៀតចង្អល់ និងមិនអាចទទួលបាន ។ ដូច្នេះសម្រាប់រូបខ្ញុំ ការបានដឹងអំពីភាពខុសច្បាប់ហើយ ហើយទទួលស្គាល់ថាមានតែសំណងឬដំណោះស្រាយនៅក្នុងដំណើរការក្តីរដ្ឋប្បវេណីចេញពីបណ្តឹងរបស់ចុងចោទ ឬដំណើរការក្តីចំពោះវិន័យ ឬដំណើរការក្តីផ្នែកព្រហ្មទណ្ឌប្រឆាំងនឹងមន្ត្រីម្នាក់ៗនៃភ្នាក់ងារអនុវត្តច្បាប់ដែលពាក់ព័ន្ធនឹងចំណាត់ការខុសច្បាប់តែប៉ុណ្ណោះដែលអាចធ្វើបាន គឺជាចម្លើយមិនសមរម្យឡើយ ។ ដោយហេតុថាការចោទប្រកាន់មិនអាចប្រព្រឹត្តទៅកើតឡើយ ប្រសិនបើគ្មានការចាប់ពង្រត់ដោយខុសច្បាប់ទេនោះ ជាផលវិបាកដំណើរការនីតិវិធីទាំងមូលត្រូវទទួលរងការប៉ះពាល់ (...) ។ ការយល់ឃើញថា ក្នុងកាលៈទេសៈបែបនេះ តុលាការអាចបដិសេធមិនអនុវត្តយុត្តាធិការរបស់ខ្លួនដោយហេតុដំណើរការនីតិវិធីមានការរំលោភបំពានអាចកើតចេញពីការបកស្រាយពង្រាតទ្រឹស្តីនៃរំលោភបំពាននីតិវិធី ប៉ុន្តែនៅក្នុងគំនិតខ្ញុំការបដិសេធមិនអនុវត្តយុត្តាធិការនេះ គឺជាការចាំបាច់និងត្រឹមត្រូវទាំងស្រុង» ។

១៧) តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉ាន់ដា(Rwanda) បានអនុវត្តទ្រឹស្តីនេះដែរ ក្នុងរឿងក្តី Barayagwiza ដោយអះអាងនៅក្នុងសេចក្តីសម្រេចយ៉ាងដូច្នេះថា៖ «ទោះបីបើស្ថាប័នទាំងបីនៃតុលាការមានកំហុសរួមគ្នា ឬកំហុសកើតចេញពីសកម្មភាពនៃភាគីទីបី ដូចជាប្រទេសកាមេរូនក៏ដោយ ទង្វើនេះធ្វើឲ្យប៉ះពាល់ដល់សុចរិតភាពនៃដំណើរការជម្រះក្តីដែលត្រូវដំណើរការបន្ត ។ លើសពីនេះទៀត គឺជាភាពអយុត្តិធម៌ចំពោះជនជាប់ចោទក្នុងការប្រឈមមុខចំពោះការជម្រះក្តីលើបទចោទនៅពេលដែលមានការ

*រំលោភសិទ្ធិគាត់យ៉ាងធ្ងន់ធ្ងរបំផុត ។ ហេតុនេះផ្អែកតាមទ្រឹស្តីនៃការរំលោភបំពានលើដំណើរនីតិវិធី គឺមិនមានភាពពាក់ព័ន្ធជាមួយអង្គភាពណាដែលទទួលខុសត្រូវចំពោះការរំលោភបំពានលើសិទ្ធិរបស់ចុងចោទឡើយ ។ វាមានភាពចាំបាច់ក្នុងការកត់សម្គាល់ថាទ្រឹស្តីនៃការរំលោភបំពានអាចត្រូវលើកឡើងទៅតាមអំណាចឆន្ទានុសិទ្ធិ ។ នៅក្នុងដំណើរការក្តី តុលាការអាចមិនបំពេញយុត្តាធិការរបស់ខ្លួននៅពេលដែលមានការរំលោភបំពានសិទ្ធិជនជាប់ចោទដ៏ធ្ងន់ធ្ងរ និងដ៏អាក្រក់បំផុតដែលនេះជាការធ្វើឲ្យប៉ះពាល់សុចរិតភាពរបស់តុលាការ ។ បទឧក្រិដ្ឋដែលបានចោទប្រឆាំងនឹងចុងចោទគឺជាបទឧក្រិដ្ឋធ្ងន់ធ្ងរណាស់ ។ ក៏ប៉ុន្តែក្នុងរឿងក្តីនេះសិទ្ធិជាសារវន្តរបស់ជនជាប់ចោទត្រូវបានរំលោភបំពានម្តងហើយម្តងទៀត(...) ដោយមានការរំលោភបំពានជាច្រើន យើងសង្កេតឃើញថាការប្រព្រឹត្តនេះមានសភាពអាក្រក់បំផុត យើងសម្រេចថាដំណោះស្រាយតែមួយគត់ដែលអាចធ្វើបាន គឺដោះលែងចុងចោទនិងលើកលែងបទចោទប្រឆាំងនឹងចុងចោទ*[៩] ។

១៨) ប៉ុន្តែ ទ្រឹស្តីរំលោភបំពាននីតិវិធីត្រូវបានបដិសេធដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវីក្នុងរឿងក្តី ***NICOLIC*** ។ នៅក្នុងសេចក្តីសម្រេចនេះ តុលាការបានយល់ឃើញថាទ្រឹស្តីនេះយកមកអនុវត្តបានតែនៅពេលដែលជនជាប់ចោទទទួលរងការប្រព្រឹត្តដ៏អាក្រក់ និងធ្ងន់ធ្ងរដោយបញ្ជាក់ថា÷ *«ការសម្រេចបែបនេះអាស្រ័យទាំងស្រុងផងដែរទៅតាមអង្គហេតុនីមួយៗ ហើយមិនអាចយកមកអនុវត្តជាលក្ខណៈអរូបីនោះទេ ។ ជាផលវិបាកត្រូវតែមានការវាយតម្លៃកម្រិតហិង្សាដែលបានប្រព្រឹត្តចំពោះជនជាប់ចោទ ។ ផ្អែកតាមអង្គហេតុ អង្គជំនុំជម្រះកត់សម្គាល់ថា អង្គហេតុដែលបានសន្មតទោះបីបើបង្កើតនូវក្តីកង្វល់ខ្លះក៏ដោយ មិនមែនជាការប្រព្រឹត្តចំពោះជនជាប់ចោទដោយអញ្ញត្រជនដែលមានលក្ខណៈជាការរំលោភបំពានធ្ងន់ធ្ងរទាល់តែសោះ*[១០] ។

១៩) ដំណោះស្រាយបែបនេះ ក៏ត្រូវបានទទួលយកដោយតុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងរឿងក្តី ***Lubanga*** ផងដែរ ។ តុលាការយល់ឃើញថា ការរំលោភបំពានសិទ្ធិជនជាប់ចោទក្នុងពេលចាប់ខ្លួន ឬពេលឃុំខ្លួនដែលមានពីមុនអាចយកមកពិចារណាបានតែពីរករណីប៉ុណ្ណោះ ÷ បើតុលាការ និងអាជ្ញាធរផ្សេងបានប្រព្រឹត្តក្នុងរបៀបត្រូវរ៉ូវគ្នា ឬប្រសិនបើជនជាប់ចោទនេះជាជនរងគ្រោះពីអំពើទារុណកម្ម ឬអំពើធ្វើបាបអាក្រក់ធ្ងន់ធ្ងរ ។

## III. ដំណោះស្រាយក្នុងករណីនេះ

២០) ផ្អែកតាមធាតុផ្សំទាំងអស់ដែលបានរៀបរាប់ខាងលើ សហចៅក្រមស៊ើបអង្កេតយល់ឃើញថាខ្លួនមិនមានសមត្ថកិច្ចក្នុងការវាយតម្លៃពីភាពត្រឹមត្រូវតាមច្បាប់នៃការឃុំខ្លួនកន្លងមកដែលធ្វើលើ ឌុច នោះទេ ។ ហេតុដែលថាអង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតនៅក្នុងប្រព័ន្ធតុលាការកម្ពុជានោះ មិនអាចនាំឲ្យមានការលើកឡើងថាតុលាការពិសេសដែលមានលក្ខណៈអន្តរជាតិ និងតុលាការយោធាបានបំពេញការងារដោយរបៀបត្រូវរ៉ូវគ្នានោះទេ ÷ អង្គជំនុំជម្រះវិសាមញ្ញទើបតែបានចាប់ផ្តើមដំណើរការពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ប៉ុណ្ណោះ គឺជាកាលបរិច្ឆេទនៃការចូលធរមាននៃវិធានផ្ទៃក្នុង ។ នៅមុនពេលមានការបើកការស៊ើបសួរបច្ចុប្បន្ន សហចៅក្រមស៊ើបអង្កេត (ដែលជាអ្នកមានសមត្ថកិច្ចតែមួយគត់ក្នុងការធ្វើសេចក្តីសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន) មិនមានលទ្ធភាពណាមួយក្នុងការចូលធ្វើអន្តរាគមន៍នោះទេ ។ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញកិច្ចការ សហចៅក្រមស៊ើបអង្កេតទទួលបានបណ្តឹងអំពីចំណោទបញ្ហានេះ និងដោយពិចារណាដល់ពេលវេលាចាំបាច់សម្រាប់ការស្វែងយល់ពីសំណុំរឿងពេលវេលាដែលកន្លងទៅ(១២ថ្ងៃ) ចន្លោះពេលនៃការប្រគល់ដីកាបញ្ជូនរឿងឲ្យប្រគល់ដីកានាំខ្លួនមិនអាចត្រូវបានចាត់ទុកថាពេលវេលាយូរហួសហេតុ និងអាចចាត់ទុកជាការមិនយកចិត្តទុកដាក់នោះទេ ។

២១) ទ្រឹស្តីនៃការរំលោភបំពាននីតិវិធីមិនអាចអនុវត្តបានទេក្នុងករណីនេះ ។ យុត្តាធិការដែលប្រើប្រាស់សញ្ញាណនេះមិនមែនមិនគិតដល់ទាល់តែសោះអំពីសមាមាត្ររវាងការរំលោភបំពានដែលត្រូវចោទប្រកាន់និងដំណោះស្រាយដែលស្នើឡើងនោះទេ ។ ជាការពិតណាស់ដែលថានៅក្នុងរឿងក្តីនៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបញ្ចប់ការចោទប្រកាន់អាចកើតមានបានតែនៅក្នុងករណីប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនជាប់ចោទ ជាឧទាហរណ៍យ៉ាងហោចក្នុងកម្រិតអប្បបរមាដូចអ្វីដែលបានកើតមានឡើងនៅ

ក្នុងរឿងក្តី *Toscanino* ។ ហេតុនេះសហចៅក្រមស៊ើបអង្កេតបាន ជ្រើសរើសយកដំណោះស្រាយដែលបានប្រកាន់យកនៅក្នុងរឿង ក្តី *Nikolic* ឬ *Lubanga* ដែលតម្រូវថា៖ ដើម្បីអនុវត្តទ្រឹស្តីនៃ ការរំលោភបំពាននីតិវិធីត្រូវមានការបង្ហាញពីការរំលោភបំពាន ធ្ងន់ធ្ងរ និងពិតប្រាកដលើសិទ្ធិជនជាប់ចោទ ។ ដូច្នេះនៅពេលណា ដែលមិនមានរឿងបែបនេះទាល់តែសោះឬក៏រឿងចោទប្រកាន់ថា ឌុច បានទទួលរងនូវអំពើធ្វើទារុណកម្ម ឬការធ្វើបាបអាក្រក់ធ្ងន់ធ្ងរ នៅមុនពេលបញ្ជូនខ្លួនមកកាន់អង្គជំនុំជម្រះវិសាមញ្ញនោះទេ ការ ឃុំខ្លួនបន្តដែលមាននៅតុលាការយោធា បើប្រៀបធៀបជាមួយ នឹងបទឧក្រិដ្ឋដែលដាក់បន្ទុកលើជននេះ មិនអាចត្រូវចាត់ទុកថា មានលក្ខណៈគ្រប់គ្រាន់ជាការបំពានធ្ងន់ធ្ងរនោះទេ ។

នីតិវិធីបច្ចុប្បន្នដែលជនត្រូវចោទទទួលបានសិទ្ធិការពារខ្លួន ដ៏ពេញលេញនោះ នីតិវិធីនេះអាចដំណើរការបន្តបានគួរបញ្ជាក់ ថាអាចមានជាការជួសជុលចំពោះព្យសនកម្មដែលទទួលរងដោយ សារការឃុំខ្លួនពីមុន (តាមរយៈការបន្ថយទោស ឬតាមវិធីផ្សេង ទៀតដែលត្រូវសម្រេចដោយអង្គជំនុំជម្រះ) នោះនឹងមិនចោទជា បញ្ហាទេនៅក្នុងដំណាក់ស៊ើបសួរ ។

(២២) ដូច្នេះបញ្ហាតែមួយគត់ដែលត្រូវសម្រេចគឺ៖ តើការ ឃុំខ្លួន ឌុច បណ្តោះអាសន្ន ជាការចាំបាច់ដែរឬអត់នៅពេលនេះ នៅក្នុងក្របខ័ណ្ឌដំណើរការនីតិវិធីដែលត្រូវចាប់ផ្តើមធ្វើចំពោះ ឌុច នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ? ទាក់ទិននឹងចំណុចនេះ ចម្លើយរបស់សហចៅក្រមស៊ើបអង្កេតមានដូចតទៅ៖ អង្គហេតុ ដែលត្រូវដាក់បន្ទុកចំពោះជនត្រូវចោទមានលក្ខណៈធ្ងន់ធ្ងរ បទ ឧក្រិដ្ឋដែលបានកើតឡើងរយៈពេល៣០ឆ្នាំមកហើយនៅតែបន្ត ជាបញ្ហាធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈ ហេតុដូច្នេះមិនមែន ជាការហួសហេតុពេកទេដែលអះអាងថានៅក្នុងបរិបទដ៏ផុយ ស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន ការដោះលែងជននេះអាចនឹងបន្ត ឲ្យមានការសំដែងនូវការមិនពេញចិត្តជាទូទៅដែលអាចបង្កឲ្យមាន អំពើហិង្សា ឬអាចប៉ះពាល់ដល់សន្តិសុខផ្ទាល់របស់ជននេះ ។ ក្រៅពីនេះ ទោសឧក្រិដ្ឋមួយជីវិតដែល ឌុច ត្រូវប្រឈមនាំឲ្យ បារម្ភថាជននេះអាចស្វែងរកការគេចខ្លួនពីដំណើរការតុលាការ ។ ចុងបញ្ចប់ ដោយសេចក្តីបារម្ភថាសាក្សី និងជនរងគ្រោះពីអំពើ ប្រព្រឹត្តដ៏ធ្ងន់ធ្ងរបំផុតដែលដាក់បន្ទុកលើជននេះមានអារម្មណ៍ភ័យ ខ្លាចនិងបដិសេធចូលរួមក្នុងដំណើរការតុលាការប្រសិនបើពុំមាន ការដាក់ឃុំខ្លួនជនត្រូវចោទ ។

(២៣) ជាផលវិបាក ៖

◆ ដោយយល់ឃើញថាមានហេតុផលពិតប្រាកដឲ្យជឿជាក់ ថា កាំង ហ្កេកអ៊ាវ ហៅ ឌុច បានប្រព្រឹត្តបទឧក្រិដ្ឋដែលមាន បញ្ជាក់នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ។

◆ យល់ឃើញថា វាជាការចាំបាច់ផងដែរដើម្បីធានាការ រក្សាទុកជនត្រូវចោទសម្រាប់ដំណើរការតុលាការនិងដើម្បីការពារ សុវត្ថិភាពផ្ទាល់របស់ជននេះ ។

◆ យល់ឃើញថា ការរក្សាសណ្តាប់ធ្នាប់សាធារណៈជាការ ចាំបាច់ ។

◆ យល់ឃើញថា មិនមានវិធានការត្រួតពិនិត្យតាមផ្លូវ តុលាការណាមួយ ទោះជាមានលក្ខណៈតឹងរ៉ឹងបែបណាក៏ដោយ នឹងមានប្រសិទ្ធិភាពជាទីពេញចិត្តឆ្លើយតបនឹងស្ថានភាពតម្រូវទាំង នេះទេ ។ និង

◆ យល់ឃើញថា ការឃុំខ្លួននៅតែជាមធ្យោបាយតែមួយ គត់ដើម្បីសម្រេចគោលដៅទាំងនេះ ។

ផ្អែកតាមហេតុផលទាំងនេះ ៖

យើងបង្គាប់ឲ្យឃុំខ្លួន កាំង ហ្កេកអ៊ាវ ហៅ ឌុច បណ្តោះ អាសន្ន រយៈពេលអតិបរមាមួយឆ្នាំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧

សហចៅក្រមស៊ើបអង្កេត

Co-Investigating Judges

Co-juges d'instruction

ហត្ថលេខា និងត្រា

**យូ ប៊ុនឡេង Marcel LEMONDE**

***ដីកានេះធ្វើជាភាសាខ្មែរ និងភាសាបារាំង និងបកប្រែជា ភាសាអង់គ្លេស ។***

# ការកែប្រែរចនាសម្ព័ន្ធតុលាការកូនកាត់៖ កំណែទម្រង់គតិយុត្តិផ្នែកព្រហ្មទណ្ឌជាតិ និងការផ្ដល់អំណាចក្នុងតំបន់

## ១) សេចក្ដីផ្ដើម

ការចំណាយពេលដ៏ច្រើនលើសលប់កំហុសផ្នែកគ្រប់គ្រង និងការបរាជ័យក្នុងទំនាក់ទំនងរបស់សាលាក្ដីពិសេសនៅក្នុងប្រទេសរ៉្វាន់ដានិងអតីតយូហ្គោស្លាវី បានបណ្ដាលឲ្យម្ចាស់ជំនួយសំខាន់ៗ ងឿយណាយនិងមានមន្ទិលសង្ស័យទៅលើប្រសិទ្ធភាពនៃគតិយុត្តិព្រហ្មទណ្ឌអន្តរជាតិ ។ ចំពោះហេតុផលនេះ វាមិនទំនងថានឹងមានការបង្កើតសាលាក្ដីអន្តរជាតិពិសេសម្ដងទៀតទេ ។ ដូច្នេះចេញពីនេះទៅតើមានអ្វីនឹងកើតឡើងចំពោះយើង? តើអ្វីទៅដែលអាចបំពេញការខ្វះចន្លោះក្នុងផ្នែកយុត្តិធម៌ក្រោយអំពើយង់ឃ្នង? ដំណើរការជំនុំជម្រះក្ដីមេដឹកនាំ យោធាផ្ដាច់ការ ដូចជាដំណើរការក្ដីរបស់ពីណូជេ ដោយតុលាការអេស្ប៉ាញ ហាក់សិននៅតែជាបាតុភូតសើៗពុំសូវទទួលការអារម្មណ៍ ទោះបីជាមានការរួមចំណែកដ៏សំខាន់ក៏ដោយ ។ តុលាការជាតិមួយចំនួនបានត្រៀមខ្លួនជាស្រេចដើម្បីនឹងអនុវត្តដំណើរការកាត់សេចក្ដីឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយប្រើប្រាស់អំណាចជជីកសួរហេតុផលទូទាំងសកលលោក ហើយទទួលបានចំណាប់អារម្មណ៍ខ្លាំងពីប្រព័ន្ធផ្សព្វផ្សាយ ប៉ុន្តែតុលាការក្នុងស្រុកភាគច្រើននៅក្នុងរដ្ឋក្រោយអំពើយង់ឃ្នង់បានប្រឈមមុខទៅនឹងបញ្ហាធ្ងន់ធ្ងរជាច្រើន ។

ទោះបីជាយ៉ាងណា ការពឹងផ្អែកទៅលើសាលាក្ដីអន្តរជាតិពិសេសនិងតុលាការក្នុងស្រុកសុទ្ធសាធនឹងឆាប់នាំមកនូវភាពឥតប្រយោជន៍ដូចគ្នា ។ យើងត្រូវតែស្វែងរកជម្រើសផ្សេងដែលមានលក្ខណៈសន្សំសំចៃការចំណាយនិងជះឥទ្ធិពលខ្ពស់ ។ យន្តការកូនកាត់ដែលរួមបញ្ចូលផ្នែកក្នុងស្រុកជាមួយនឹងផ្នែកអន្តរជាតិធានាផ្ដល់នូវយុត្តិធម៌បានកាន់តែប្រសើរ ជាពិសេសក្នុងករណីដែលមានការភ្ជាប់កំណែទម្រង់តុលាការក្នុងស្រុកទៅនឹងការប្ដេជ្ញាក្នុងការទទួលខុសត្រូវផ្នែកច្បាប់ចំពោះឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងរដ្ឋក្រោយអំពើយង់ឃ្នង ។

***តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)***

ជានិច្ចកាលជាជម្រើសមួយដែលសក្ដិសមបំផុតសម្រាប់ជំនួសឲ្យសាលាក្ដីពិសេសអន្តរជាតិ ។ ទោះបីជាយ៉ាងណា គ្មានតុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានបង្កើតឡើងដើម្បីអាចសម្រេចនូវគោលដៅទាំងអស់ដែលតុលាការកូនកាត់អាចសម្រេចនោះឡើយ ហើយវាគ្រាន់តែផ្ដល់ដំណោះស្រាយដោយផ្នែកទាក់ទិនទៅនឹងអភ័យឯកសិទ្ធិប៉ុណ្ណោះ ។ ជាក់ស្ដែង ជោគជ័យរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិអាចត្រូវបានធានាដោយការបង្កើតតុលាការកូនកាត់បន្ថែម ។ ជាបឋម បទល្មើសព្រហ្មទណ្ឌជាច្រើនមិនអាចជំនុំជម្រះដោយតុលាការព្រហ្មទណ្ឌអន្តរជាតិទេ ។ សង្គ្រាមពីអតីតកាលដែលកើតមុនពេលច្បាប់ក្រុងរ៉ូមចូលជាធរមាននិងសង្គ្រាមបច្ចុប្បន្នដែលកើតឡើងនៅក្នុងប្រទេសដែលពុំមែនជាហត្ថលេខី គឺស្ថិតនៅក្រៅវង្វង់យុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ទីពីរ សូម្បីតែនៅក្នុងករណីដែលបទល្មើសស្ថិតនៅក្នុងវង្វង់យុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិក៏ដោយ ក៏តុលាការព្រហ្មទណ្ឌអន្តរជាតិមិនអាចជម្រះក្ដីណាមួយក្រៅពីបទល្មើសធ្ងន់ៗមួយក្ដាប់តូចដែលទាក់ទិននឹងសង្គ្រាមដែរ ។ ទីបីប្រហែលជាចំណុចសំខាន់បំផុតនោះគឺ ដោយមានការយល់ដឹងកាន់តែទូលំទូលាយអំពីតម្លៃនៃតុលាការកូនកាត់ វិធីសាស្ត្រទ្វេភាគរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលផ្ដល់យុត្តិធម៌ដោយផ្អែកលើអន្តរជាតិទាំងស្រុង បើមិនដូច្នេះទេ ទុកជម្រោះឲ្យតុលាការក្នុងស្រុកក្រោយអំពើយង់ឃ្នងដោះស្រាយកំណត់សមត្ថភាពរបស់ខ្លួនក្នុងការផ្ដល់នូវទំនុកចិត្តពិតប្រាកដមួយ ។ តុលាការក្នុងស្រុកសុទ្ធសាធជួបប្រទះនូវបញ្ហាជាច្រើនដែលក្នុងនោះមានចាប់ពីកង្វះខាតភ័ស្ដុភារ ឬហិរញ្ញវត្ថុ អំពើពុករលួយនិងនយោបាយកម្មក្នុងកម្រិតខ្ពស់ ។ រីឯតុលាការអន្តរជាតិសុទ្ធសាធ

វិញ បានបង្ហាញភាពដាច់ចេញពីតថភាពក្នុងស្រុកជាក់ស្តែង ហើយអាចទាំងត្រូវចាត់ទុកថាមានលក្ខណៈជាចក្រពត្តិនិយមផង ។ ទស្សនៈទ្វេភាគដ៏ទូលំទូលាយរបស់តុលាការអន្តរជាតិឬតុលាការក្នុងស្រុកថា តុលាការព្រហ្មទណ្ឌអន្តរជាតិគួរតែត្រូវបានយកមកប្រើប្រាស់ដើម្បីយកមកពិចារណាអំពីលទ្ធភាពបង្កើតតុលាការកូនកាត់ដែលជាជម្រើសទីបី ។ តុលាការកូនកាត់ មានលក្ខណៈស័ក្តិសមសម្រាប់ប្រើប្រាស់នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយការបង្កើតតុលាការកូនកាត់ទាំងនេះគួរត្រូវបញ្ចូលទៅក្នុងច្បាប់ទីក្រុងរ៉ូម ។

ឯកសារនេះនឹងវិភាគយ៉ាងល្អិតល្អន់អំពីគុណសម្បត្តិនិងគុណវិបត្តិរបស់តុលាការកូនកាត់ ដោយយកទ្រឹស្តីជាគោលព្រមទាំងពិនិត្យឡើងវិញអំពីតុលាការកូនកាត់ដែលមានស្រាប់និងសង្ខេបអំពីចំណុចខ្វះខាតដែលតុលាការកូនកាត់អាចកែតម្រូវពីសាលាក្តីពិសេសអន្តរជាតិ ។ ខ្លឹមសារចម្បងរបស់ឯកសារនេះគឺថាតុលាការកូនកាត់ត្រូវប្រើប្រាស់ជាកម្លាំងយុត្តិធម៌អន្តរជាតិនិងជាផលប្រយោជន៍របស់ដំណើរការជម្រះក្តីក្នុងស្រុក ។ តុលាការកូនកាត់អាចជួយរឹតបន្តឹងច្បាប់អន្តរជាតិដែលគួរឲ្យទុកចិត្តបាននិងច្បាប់របស់ស្ថាប័នអន្តរជាតិដែលអាចផ្តល់ឲ្យតុលាការកូនកាត់នូវអំណាចក្នុងកម្រិតមួយក្នុងនាមជាយន្តការប្រកបដោយយុត្តិធម៌ក្នុងការកាត់សេចក្តីឧក្រិដ្ឋជន ។ ម្យ៉ាងវិញទៀត តុលាការកូនកាត់អាចត្រូវបានបង្កើតឡើងដើម្បីប្រើប្រាស់ជំនាញក្នុងស្រុកទាក់ទងនឹងប្រជាជនក្នុងស្រុក និងកសាងប្រព័ន្ធតុលាការជាតិឡើងវិញ ដោយបង្កើតមូលដ្ឋានបណ្តុះបណ្តាលដើម្បីផ្តល់ការយល់ដឹងអំពីតម្លៃនៃបញ្ញត្តិច្បាប់ ។ ជាងនេះទៀត វាក៏អាចបញ្ចៀសការចំណាយដ៏ច្រើនលើសលប់ដូចក្នុងករណីតុលាការអន្តរជាតិសុទ្ធសាធនោះទេ ។ ដោយបញ្ចូលនូវនិយាមក្នុងស្រុកតុលាការកូនកាត់អាចផ្តល់នូវយុត្តិធម៌ដែលបានសម្រួលឲ្យមានលក្ខណៈស្របតាមវប្បធម៌ក្នុងស្រុកជូនប្រជាជនដែលតុលាការអន្តរជាតិអះអាងថានឹងរកយុត្តិធម៌ជូនប្រជាជន ប៉ុន្តែពុំទាន់អាចធ្វើទៅកើត ។ តុលាការកូនកាត់អាចភ្ជាប់ទំនាក់ទំនងរវាងអ្នកជំនាញច្បាប់អន្តរជាតិដែលសម្បូរដោយធនធានជាមួយនឹងជនរងគ្រោះដោយសារឧក្រិដ្ឋកម្មសង្គ្រាមក្នុងប្រទេសតតិយលោកដែលពីមុនក្រុមទាំងពីរនេះនៅដាច់ឆ្ងាយពីគ្នា ។

ប្រសិនបើតុលាការកូនកាត់ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធតុលាការក្នុងស្រុក ហើយបានពង្រីកអំណាចដើម្បីផ្តោតលើកំណែទម្រង់ប្រព័ន្ធតុលាការក្នុងស្រុកនោះវានឹងមានសក្តានុពលក្នុងការភ្ជាប់បទដ្ឋានយុត្តិធម៌អន្តរជាតិទៅក្នុងវប្បធម៌ក្នុងស្រុក ដោយផ្លាស់ប្តូរទាំងស្រុងនូវវដ្តនៃអភ័យឯកសិទ្ធិតាមរយៈការលម្អស្ថាប័នយុត្តិធម៌ក្នុងស្រុកតាមរបៀបមួយប្រកបដោយនិរន្តរភាព ។ ដូច្នេះគំរូតុលាការកូនកាត់អាចបញ្ចៀសពីយុត្តិធម៌ដោយការសងសឹកហើយបង្កើតបាននូវវប្បធម៌នៃការទុកចិត្តមួយ ។

ឯកសារនេះត្រូវបានបែងចែកជាប្រាំមួយជំពូក ។ ជំពូកទី១ នឹងបង្ហាញត្រួសៗអំពីនិយមន័យរបស់តុលាការកូនកាត់ ។ ជំពូកទី២ ពណ៌នាអំពីរបៀបដែលតុលាការកូនកាត់អាចឆ្លើយតបទៅនឹងអាជ្ញាបញ្ញត្តផ្តល់អំណាចក្នុងស្រុកនិងតម្រូវការកំណែទម្រង់វប្បធម៌របស់តុលាការក្នុងស្រុក នៅក្នុងស្ថានភាពក្រោយអំពើយង់ឃ្នង ។ ជំពូកទី៣ សង្ខេបអំពីតុលាការកូនកាត់ដែលមានរួចហើយព្រមទាំងវាយតម្លៃលើជោគជ័យនិងបរាជ័យរបស់តុលាការនេះ ។ ជំពូកទី៤ ពិភាក្សាអំពីចំណុចខ្វះខាតរបស់គំរូតុលាការកូនកាត់ ។ ជំពូកទី៥ វិភាគអំពីកំហុសរបស់សាលាក្តីពិសេសដែលតុលាការកូនកាត់មានសុពលភាពនិងអាចដោះស្រាយបាន ។ ជំពូកទី៦ សិក្សាអំពីលទ្ធភាពនៃការអនុវត្តរួមគ្នារវាងតុលាការកូនកាត់និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ឯកសារនេះពុំមែនប្រាកដថា គាំទ្រសាលាក្តីកូនកាត់ដែលមានស្រាប់នោះទេ ។ ផ្ទុយទៅវិញ វាគ្រាន់តែជាគំរូនៃសាលាក្តីដែលមានលក្ខណៈជាក្របខ័ណ្ឌសន្យាដែលជាជម្រើសមួយជំនួសឲ្យសាលាក្តីជាតិឬអន្តរជាតិសុទ្ធសាធប៉ុណ្ណោះ ។

ឯកសារនេះនឹងជំរុញឲ្យមានការពិភាក្សាអំពីរបៀបបង្កើតរចនាសម្ព័ន្ធមួយសម្រាប់តុលាការបែបនេះឲ្យកាន់តែមានលក្ខណៈប្រសើរដើម្បីអាចជះឥទ្ធិពលដល់ក្រុមប្រជាជនដែលតុលាការកូនកាត់មានបំណងជួយ ។ ថ្វីបើអត្ថបទស្តីពីតុលាការពាក់កណ្តាលអន្តរជាតិឬតុលាការកូនកាត់មានកំណើនយ៉ាងលឿនយ៉ាងណាក៏ដោយ ក៏សាលាក្តីទាំងនេះនៅទទួលបាននូវចំណាប់អារម្មណ៍តិចតួចណាស់បើប្រៀបធៀបទៅនឹងសាលាក្តីពិសេស ដូចជា សាលាក្តី

ព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) និងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិ សម្រាប់ប្រទេសរ៉ាន់ដា (ICTR) ឬតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ដែរ ។ ដោយពុំមានការវិភាគអំពីរចនាសម្ព័ន្ធ ចំណុចខ្លាំងនិងចំណុចខ្សោយឲ្យបានគ្រប់គ្រាន់ តុលាការកូនកាត់នឹងនៅតែមានចំណុចខ្វះខាត គ្រាន់តែជាការប្តូររូបសណ្ឋាននិងងាយទទួលការបរាជ័យយ៉ាងធ្ងន់ធ្ងរដោយមិនអាចចៀសផុត ។

## ជំពូកទី១ៈ និយមន័យនៃតុលាការកូនកាត់

ក្នុងអំឡុងចុងទសវត្សរ៍ឆ្នាំ១៩៩០និងឆ្នាំ២០០០ សាលាក្តីអន្តរជាតិ "ជំនាន់ទីបី" បានបង្កើតឡើងដោយផ្អែកលើអ្វីដែលសាលាក្តីជំនាន់ទីមួយនៅក្រុងនូរឹមប៊ឺក និងក្រុងតូក្យូបានបន្សល់ទុក និងផ្អែកលើសាលាក្តីអន្តរជាតិ ពិសេសសាលាក្តីព្រហ្មទណ្ឌអន្តរជាតិក្នុងអតីតប្រទេសយូហ្គោស្លាវី និងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិក្នុងប្រទេសរ៉ាន់ដា ។ តុលាការជំនាន់ទីបីមានឈ្មោះថា ស្ថាប័នព្រហ្មទណ្ឌ "កូនកាត់" ។ ដោយមានបញ្ចូលផ្នែកអន្តរជាតិនិងផ្នែកក្នុងស្រុក តុលាការកូនកាត់ដែលមានស្រាប់គឺជាសមិទ្ធផលបានមកពីការចែករំលែកការទទួលខុសត្រូវផ្នែកតុលាការរវាងរដ្ឋដែលកំពុងប្រតិបត្តិតុលាការនេះជាមួយនឹងស្ថាប័នអន្តរជាតិ ជាពិសេសអង្គការសហប្រជាជាតិ ។

រចនាសម្ព័ន្ធរបស់សាលាក្តីកូនកាត់មួយក្តាប់តូចពុំមានដែនកំណត់រឹងមាំដើម្បីតំណាងជាទម្រង់រួមសម្រាប់តុលាការកូនកាត់ទាំងអស់បន្តិចណាឡើយ ។ ប៉ុន្តែដោយមិនមានការគាំទ្រចំពោះតុលាការកូនកាត់ដែលមានស្រាប់ ឬមិនប្រើប្រាស់តុលាការទាំងនោះដើម្បីកំណត់គំរូតុលាការកូនកាត់ក្នុងវង្វង់ក្របខ័ណ្ឌជាក់លាក់នោះ ការវិភាគអាចធ្វើឲ្យយើងយល់ដឹងបានបន្ថែមអំពីសមត្ថភាពនិងកង្វះខាតរបស់គំរូតុលាការកូនកាត់ ។

បច្ចុប្បន្នពាក្យថា "តុលាការកូនកាត់" ត្រូវបានប្រើប្រាស់សម្រាប់ពិពណ៌នាអំពីយុត្តាធិការចំនួនប្រាំមួយដែលបានបង្កើតក្នុងរវាងឆ្នាំ១៩៩៩និងឆ្នាំ២០០១ៈ

នៅក្នុងប្រទេសទីម័រខាងកើត (គណៈវិនិច្ឆ័យព្រហ្មទណ្ឌកម្រិតធ្ងន់នៃតុលាការស្រុកឌីលី) ប្រទេសកូសូវ៉ូ ("បញ្ញត្តិ៦៤" គណៈវិនិច្ឆ័យក្នុងតុលាការរបស់ប្រទេសកូសូវ៉ូ) និងប្រទេសសៀរ៉ាឡេអូន (តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន) ។ តុលាការកូនកាត់ទីបួនសម្រាប់ជម្រះក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការនៃប្រទេសកម្ពុជា) ត្រូវបានបង្កើតឡើងដោយមានការចរចារវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា ព្រមទាំងបានផ្តល់សច្ចាប័នដោយរដ្ឋសភាជាតិនៃប្រទេសកម្ពុជា ។ សាលាក្តីទីប្រាំ គឺសាលាក្តីពិសេសសម្រាប់ប្រទេសអ៊ីរ៉ាក់ (ក្រោយមកប្តូរឈ្មោះទៅជាសាលាក្តីព្រហ្មទណ្ឌកំពូលនៃប្រទេសអ៊ីរ៉ាក់) អាចត្រូវបានពិពណ៌នាថា ជាតុលាការកូនកាត់ដោយផ្អែកឬសាលាក្តីក្នុងស្រុកដែលបានធ្វើឲ្យទៅជាលក្ខណៈអន្តរជាតិ ទោះបីជាផ្នែកអន្តរជាតិនៃសាលាក្តីពិសេសអន្តរជាតិ (IST) ជាចម្បងមានតែការចូលរួមដោយសហរដ្ឋអាមេរិកជាជាងពហុជាតិក៏ដោយ ។ សាលាក្តីកូនកាត់ទីប្រាំមួយនិងចុងក្រោយគឺអង្គជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមនៃតុលាការរដ្ឋរបស់ប្រទេសបូស្នៀ-ហឺហ្សេហ្គោវីណា តុលាការកូនកាត់បានចាប់បដិសន្ធិឡើងក្នុងស្ថានភាពក្រោយសង្គ្រាម ក្នុងពេលដែលផ្នែកក្នុងស្រុកពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការដោះស្រាយអំពើឃោរឃៅទ្រង់ទ្រាយធំ ដោយហេតុថាតុលាការជាតិដែលដំណើរការបានយ៉ាងពេញលេញនិងដែលការទទួលខុសរួមរបស់ខ្លួន មិនអាចត្រូវបានជនណាម្នាក់ទិតៀនបាននោះ អាចសម្រាលនូវសេចក្តីត្រូវការជំនួយពីខាងក្រៅ ។ ទោះបីជាយ៉ាងណា ក្នុងខណៈពេលដែលតុលាការក្នុងស្រុកដ៏ល្អមួយអាចបន្ថយសេចក្តីត្រូវការតុលាការកូនកាត់នោះ វត្តមាននៃសាលាក្តីអន្តរជាតិមិនធ្វើឲ្យតុលាការកូនកាត់អស់ឥទ្ធិពលនោះទេ ។ តុលាការកូនកាត់នៅប្រទេសកូសូវ៉ូនិងប្រទេសបូស្នៀ បានបំពេញបន្ថែមសម្រាប់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៅអតីតប្រទេសយូហ្គោស្លាវីដែលមិនអាចដោះស្រាយចំពោះចំនួនករណីជាក់ស្តែងនៅចំពោះមុខខ្លួន ។

អង្គការសហប្រជាជាតិបានទទួលខុសត្រូវមួយភាគក្នុងការជួយតុលាការកូនកាត់ឲ្យទទួលបានមូលនិធិ ធនធាន ចៅក្រម និងរដ្ឋអាជ្ញាតាមរយៈការចូលរួមវិភាគទាន "ដោយស្ម័គ្រចិត្ត" ពីម្ចាស់ជំនួយក្នុងប្រទេសផ្សេងៗទៀត ។ ក្នុងពេលដែលក្រុមប្រឹក្សាសន្តិសុខគ្រប់គ្រងលើសាលាក្តីព្រហ្មទណ្ឌអន្តរជាតិក្នុងអតីត

ប្រទេសយូហ្គោស្លាវី និងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិក្នុងប្រទេសរ៉្វាន់ដានោះ ការិយាល័យនៃកិច្ចការច្បាប់បានគ្រប់គ្រងលើតុលាការកម្ពុជា ហើយតំណាងពិសេសនីមួយៗនៃអគ្គលេខាធិការ (**SRSGs**) បានប្រើអំណាចគ្រប់គ្រងរបស់ខ្លួននៅក្នុងប្រទេសកូសូវ៉ូនិងប្រទេសទីម័រខាងកើត ។ ទោះបីជាយ៉ាងណាក៏ដោយ ចំពោះតុលាការកូនកាត់ រដ្ឋាភិបាលក្នុងស្រុកអាចត្រូវចំណាយមួយផ្នែក ដូចជាផ្តល់ធនធានផ្សេងៗ ព្រមទាំងតែងតាំងតុលាការ រដ្ឋអាជ្ញានិងបុគ្គលិកមួយចំនួន (ដូចជានៅក្នុងករណីប្រទេសសៀរ៉ាឡេអូននិងប្រទេសកម្ពុជាជាដើម) ។

ក្នុងខណៈដែលអង្គការសហប្រជាជាតិបានបង្កើតនិងគ្រប់គ្រងតុលាការកូនកាត់នៅក្នុងប្រទេសកូសូវ៉ូនិងប្រទេសទីម័រខាងកើត ដោយឯករាជ្យពីរដ្ឋាភិបាលក្នុងស្រុក រចនាសម្ព័ន្ធតុលាការកូនកាត់របស់ប្រទេសសៀរ៉ាឡេអូននិងប្រទេសកម្ពុជាគឺជាសមិទ្ធផលបានមកពីកិច្ចចរចារវាងអង្គការសហប្រជាជាតិនិងរដ្ឋមានអធិតេយ្យភាពដែលពាក់ព័ន្ធ ។ នៅតែមានការពិចារណាថាតើពាក្យ «តុលាការកូនកាត់» នឹងក្លាយទៅជានិយមន័យរួមសម្រាប់ស្ថាប័ននានាដែលស្ថិតនៅចន្លោះសាលាក្តីអន្តរជាតិនិងតុលាការក្នុងស្រុក ឬក៏វាអាចមាននិយមន័យកាន់តែច្បាស់ជាងនេះ ។ ជាការពិតតុលាការកូនកាត់អាចត្រូវបានបង្កើតឡើងតាមច្រើនរបៀបដោយភ្ជាប់អង្គការអន្តរជាតិទៅនឹងអង្គការក្នុងស្រុកនិងច្បាប់ ។ ឧទាហរណ៍ «តាមទ្រឹស្តីតុលាការកូនកាត់» អាចមានលក្ខណៈដាច់ឆ្ងាយពីអង្គការសហប្រជាជាតិ ដែលអាចត្រូវបង្កើតឡើងដោយរដ្ឋមួយចំនួន ឬដោយសម្ព័ន្ធមិត្តអន្តរជាតិដែលសហការគ្នាជាធ្លុងមួយនិងដោយមិនចាំបាច់មានការចូលរួមពីអង្គការសហប្រជាជាតិ ជាពិសេសដោយសារអង្គការសហប្រជាជាតិបានបន្សល់ទុកនូវកេរ្តិ៍ឈ្មោះមិនល្អជាច្រើនកន្លែង ហើយការជ្រោមជ្រែងរបស់ខ្លួនអាចបង្កគ្រោះថ្នាក់ជាក់ស្តែងទៅលើការយល់ឃើញអំពីធម្មានុរូបភាពរបស់តុលាការផងដែរ ។ ផ្ទុយមកវិញ ទោះបីជាក្រុមប្រឹក្សាសន្តិសុខពុំទាន់បានបង្កើតតុលាការកូនកាត់ណាមួយក៏ដោយ ក្រុមប្រឹក្សាសន្តិសុខអាចនឹងបង្កើតឡើងដោយឯករាជ្យពីអាជ្ញាធរក្នុងស្រុកនៅក្នុងរដ្ឋដែលបរាជ័យ ។

ថ្មីៗនេះតុលាការកូនកាត់ដែលនិយមន័យជាក់លាក់របស់វាក៏កំពុងតែវិវឌ្ឍផងដែរ ។ ជាការពិត បញ្ហាដែលពើបប្រទះទាក់ទិននៅនឹងនិយមន័យនេះ បង្ហាញឲ្យឃើញពីភាពច្របូកច្របល់ថាតើត្រូវអនុវត្តតាមគំរូមួយណា ព្រមទាំងបង្ហាញឲ្យឃើញពីគ្រោះថ្នាក់នៃការបង្កើតស្ថាប័ននេះដោយគ្មានការជជែកវែកញែកគ្នាយ៉ាងល្អិតល្អន់និងគ្រប់គ្រាន់រវាងអ្នកអនុវត្តឬអ្នកចេះដឹង ក្នុងប្រធានបទការអនុវត្តន៍ល្អបំផុតប្រឆាំងនឹងការអនុវត្តន៍អាក្រក់បំផុត ។ ទោះបីជាពុំមានភាពច្បាស់លាស់នៅក្នុងនិយមន័យរបស់ពាក្យថា តុលាការកូនកាត់នេះក៏ដោយ ក៏លក្ខណៈរួមមួយចំនួនបានលេចឡើងផងដែរ ។ តុលាការកូនកាត់រួមបញ្ចូលនូវផ្នែកអន្តរជាតិនិងក្នុងស្រុកជាមួយនឹងការបង្កើតច្បាប់ និងអង្គការដែលធ្វើឲ្យលេចឡើងនូវភាពខុសគ្នាពីសាលាក្តីពិសេសអន្តរជាតិ ។ នៅក្នុងករណីមួយចំនួនវារួមបញ្ចូលជាមួយនឹងតុលាការក្នុងស្រុកដោយប្រតិបត្តិទន្ទឹមគ្នា រីឯនៅក្នុងករណីផ្សេងទៀត វាបណ្តុះពន្លកថ្មីនៅក្នុងប្រព័ន្ធតុលាការក្នុងស្រុក ។ ប៉ុន្តែនៅគ្រប់ករណីទាំងអស់លក្ខណៈរបស់វាត្រូវរួមបញ្ចូលគ្នា ។ ជាទូទៅ សមាសភាពរបស់តុលាការនេះមានបុគ្គលិកក្នុងស្រុកនិងអន្តរជាតិ ធ្វើការជាមួយចៅក្រមបរទេសដែលអង្គុយជាប់ចៅក្រមក្នុងស្រុកក្នុងការកាត់សេចក្តីលើករណីដែលត្រូវបានចោទប្រកាន់និងការពារដោយក្រុមមេធាវីក្នុងស្រុកនិងបរទេស ។ ច្បាប់ក្នុងស្រុកដែលត្រូវបានធ្វើកំណែទម្រង់ដើម្បីបញ្ចូលនូវបទដ្ឋានបរទេសត្រូវបានអនុវត្តស្របទៅតាមច្បាប់អន្តរជាតិ ។ នៅទីបំផុត ស្ថាប័នព្រហ្មទណ្ឌកូនកាត់បង្កើតក្រុមផ្ទាល់ខ្លួនមួយដាច់ដោយឡែកពីស្ថាប័នតុលាការផ្សេងទៀត ។

មុននឹងធ្វើការវិភាគវែកញែកអំពីតុលាការកូនកាត់ដែលមានស្រាប់ ឬសាលាក្តីពិសេសអន្តរជាតិដែលតុលាការកូនកាត់បានដើរតួនាទីជំនួស យើងត្រូវពិចារណាអំពីហេតុផលរបស់វានិងអាចនឹងត្រូវកែប្រែទស្សនវិស័យលើតម្លៃជាទ្រឹស្តីនៃបច្ច័យក្នុងស្រុកនៅក្នុងការកាត់ក្តីឧក្រិដ្ឋកម្មសង្គ្រាមផង ។ ដំណើរការនេះផ្តល់ជំនួយផ្នែកគំនិតសម្រាប់ភាពចាំបាច់ក្នុងការផ្តល់អំណាចក្នុងស្រុកតាមរយៈការអនុវត្តន៍យន្តការយុត្តិធម៌ក្រោយអំពើយង់ឃ្នងនិងបង្ហាញអំពីរបៀបមួយចំនួនដែលគំរូតុលាការកូនកាត់អាចទាញយកចំណុចខ្លាំងចេញពីសមត្ថភាពរបស់ខ្លួនក្នុងការ

ជ្រាបចូលនិងជះឥទ្ធិពលលើវប្បធម៌ក្នុងស្រុក ។

### ***ក) ការការពារទស្សនៈចំពោះការផ្តល់អំណាចក្នុងស្រុកក្នុងយន្តការយុត្តិធម៌ក្រោយអំពើយង់ឃ្នងៈ សារសំខាន់នៃការបញ្ចូលគ្នារវាងផ្នែកក្នុងស្រុកនិងផ្នែកអន្តរជាតិ***

ការសិក្សាអំពីតុលាការកូនកាត់គឺទាក់ទិនទៅនឹងការចោទជាសំណួរលើគោលគំនិតដែលថាយុត្តិធម៌ ដែលមានប្រសិទ្ធភាពបំផុតគឺត្រូវទទួលជំនួយទាំងស្រុងពីអន្តរជាតិនិងអង្គការសហប្រជាជាតិ ។ ទស្សនៈដែលមានប្រជាប្រិយភាពខ្លាំងនៅក្នុងសហគមន៍សិទ្ធិមនុស្សអន្តរជាតិ បានរំលាយការទទួលស្គាល់ថា តុលាការក្នុងស្រុកនៅទន់ខ្សោយនិងមិនគ្រប់លក្ខណៈទៅជាការគាំទ្រដោយឥតលក្ខខណ្ឌពីតុលាការអន្តរជាតិសុទ្ធសាធ ។

តុលាការនិងរចនាសម្ព័ន្ធអភិបាលកិច្ចក្នុងស្រុកនៅក្នុងបរិបទក្រោយសង្គ្រាម ភាគច្រើនមានខ្វះចន្លោះច្រើន ហើយជួបប្រទះនូវបញ្ហាហិរញ្ញវត្ថុនិងកង្វះខាតផ្នែកភ័ស្តុភារក្នុងការដំណើរការជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមដ៏ធំ គឺជាការពិតមួយដែលមិនអាចប្រកែកបាន ។ ជាលទ្ធផលក្រោយសង្គ្រាមអសមត្ថភាពរបស់តុលាការក្នុងស្រុកក្រោយអំពើយង់ឃ្នងជាច្រើននៅក្នុងការកាត់ក្តីឧក្រិដ្ឋកម្មសង្គ្រាម ជារឿយៗដោយសារនៅមានកម្រិតមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធជារូបវ័ន្តបានខ្ទេចខ្ទាំដោយការបំផ្លិចបំផ្លាញដោយគ្រាប់បែក គ្រាប់កាំភ្លើងធំ ការលួចដុតបំផ្លាញ ការឆក់ប្លន់ ឬការបោះបង់ចោល ។ លើសពីនេះ បុគ្គលិកសំខាន់ៗអាចនឹងបានភៀសខ្លួនទៅរស់នៅឯបរទេសត្រូវបានសម្លាប់ឬបានចូលរួមសមគំនិតជាមួយនឹងរបបមុនដែលបណ្តាលឲ្យខ្លួនមិនអាចចោទប្រកាន់ ឬផ្តោលទោសក្រុមឃាតករ ក្រុមអ្នកបង្កការឈឺចាប់ ឬក្រុមបោសសម្អាតជនជាតិភាគតិច ។ នៅក្នុងករណីខ្លះ អ្នកដឹកនាំថ្មីអាចកាន់តំណែងជំនួសបុគ្គលិកចាស់ស្ទើរតែទាំងស្រុង ដែលជាហេតុនាំឲ្យមានឱនភាពខាងបទពិសោធន៍និងជំនាញ ក៏ដូចជាគ្រោះថ្នាក់មកពីការកាត់ក្តីបំភ័ន្តភ្នែកនិងការចោទប្រកាន់លើឧក្រិដ្ឋកម្មការពីអតីតកាលដោយការប្រណែនទាំងស្រុង ។

ទោះបីជាយ៉ាងណាក៏ដោយ នេះពុំមែនបង្កប់ន័យថាតុលាការអន្តរជាតិគឺជាជម្រើសតែមួយគត់នោះទេ ។ ទោះបីជាការធ្វើសមាហរណកម្មសមាសធាតុក្នុងស្រុកទៅក្នុងផ្នែកយុត្តិធម៌អន្តរជាតិនិងការបកស្រាយច្បាប់អន្តរជាតិក្នុងទិសដៅផ្សេងរបស់តុលាការកូនកាត់បង្កឲ្យមានគ្រោះថ្នាក់ក៏ដោយ ក៏គុណសម្បត្តិនៃការបោះបង់ចោលការប្រើប្រាស់វិធីសាស្ត្រអន្តរជាតិសុទ្ធសាធក្នុងការកាត់ក្តីឧក្រិដ្ឋកម្មសង្គ្រាមជាច្រើន មានច្រើនជាងគុណវិបត្តិទាំងនេះ ។

តុលាការក្នុងស្រុកនិងតថភាពជាក់ស្តែង ជាមូលដ្ឋានអាចនឹងមានបញ្ហាល្អក់កករនិងពោរពេញដោយគ្រោះថ្នាក់ ប៉ុន្តែការទាត់ចោលនូវបច្ច័យក្នុងស្រុករឹតតែមានបញ្ហាជាងការបញ្ចូលវាទៅទៀត ។ វប្បធម៌ក្នុងស្រុកបាននដើរតួនាទីយ៉ាងសំខាន់មិនអាចកាត់ថ្លៃបានទាក់ទិនទៅនឹងដំណោះស្រាយរយៈពេលវែងនានាសម្រាប់ការកសាងប្រទេសក្រោយអំពើយង់ឃ្នង ។ ប្រសិនបើប្រទេសម្ចាស់ជំនួយ ឬអង្គការសហប្រជាជាតិត្រូវការសម្រេចជោគជ័យក្នុងការកែលម្អប្រទេសមួយ អ្នកទាំងនោះ «មិនសម្តែងអាកប្បកិរិយាជាអធិបតីនិងបិតុនិយម» ទៅកាន់ជនរងគ្រោះដោយឧក្រិដ្ឋកម្មសង្គ្រាមនិងតុលាការជាតិឡើយ «មានន័យថាការចូលរួមក្នុងស្រុក គឺជាការចូលរួមមួយដែលមានលក្ខណៈលម្អៀង ចាស់គំរិល ខ្វះបទពិសោធន៍ និងល្ងីល្ងើ» ។ ការធ្វើដូច្នេះធ្វើឲ្យខូចខាតដល់គោលដៅកំណែទម្រង់និងផ្តល់អំណាចដល់ម្ចាស់ស្រុក ហើយបន្សល់ទុកឲ្យយើងនូវការធ្វេសប្រហែសជាអន្តរជាតិជាដរាប និយាយឲ្យខ្លីគឺគ្មានលក្ខណៈរឹងមាំទាក់ទិននឹងការអនុវត្តន៍ជាក់ស្តែងនិងគួរឲ្យសង្ស័យទាក់ទិននឹងសីលធម៌ដោយហេតុលក្ខណៈចក្រពត្តិនិយមពិតៗ ។

លើសពីនេះទៀត វាជាការសំខាន់ណាស់ដែលត្រូវទទួលស្គាល់ថា ដំណើរការកាត់ក្តីក្នុងស្រុកជាច្រើនលើឧក្រិដ្ឋកម្មអន្តរជាតិធ្លាប់បានអនុវត្តមក ហើយជាពិសេសនៅក្នុងប្រទេសដែលទសវត្សរ៍សន្តិភាពបានផ្តល់ឱកាសចំពោះការស្តារឡើងវិញនិងការកែទម្រង់មួយចំនួនចំពោះតុលាការក្នុងស្រុក ។

### ***ក១) សារសំខាន់នៃវត្តមានយុត្តាធិការក្នុងស្រុករឹងមាំនិងមានឥទ្ធិពលយូរអង្វែង***

ការវាយតម្លៃណាមួយទៅលើតុលាការឧក្រិដ្ឋកម្មសង្គ្រាមមិនគួរផ្តោតត្រឹមតែទៅលើការអនុវត្តភ្លាមៗនូវសេចក្តីសម្រេចរបស់តុលាការនោះទេ ប៉ុន្តែក៏ត្រូវគិតគូរដល់ឥទ្ធិពលយូរអង្វែងរបស់តុលាការនៅក្នុងប្រទេសមួយនោះផងដែរ ។ សូម្បីតែប្រព័ន្ធ

យុត្តិធម៌អន្តរកាលក្នុងរយៈពេលដ៏ខ្លី ក៏អាចទទួលបានជំនឿទុកចិត្តច្រើនដែរ នៅពេលដែលវាអាចមានឥទ្ធិពលទៅលើប្រព័ន្ធយុត្តិធម៌ក្នុងរយៈពេលវែងបាន។ លោក ហារូល កូហ៍ ឲ្យនិយមន័យអំពី «ដំណើរការច្បាប់អន្តរកាល» ថាជា «ដំណើរការស្មុគស្មាញនៃអន្តរកម្មផ្នែកស្ថាប័ន ដែលតាមរយៈនោះនិយាមពិភពលោកមិនត្រឹមតែត្រូវបានលើកយកមកពិភាក្សានិងបកស្រាយប៉ុណ្ណោះទេ តែថែមទាំងត្រូវបានធ្វើឲ្យមានលក្ខណៈជានិយាមអន្តរជាតិដោយប្រព័ន្ធច្បាប់ក្នុងស្រុកទៀតផង» ។

នៅក្នុងន័យនេះ តុលាការកូនកាត់អាចត្រូវបានមើលឃើញថាជាទម្រង់មួយមានប្រសិទ្ធភាពបំផុតនៃដំណើរការច្បាប់អន្តរជាតិនៅក្នុងបរិបទក្រោយពីមានអំពើឃោរឃៅកើតឡើង ។ តុលាការឧក្រិដ្ឋកម្មសង្គ្រាមត្រូវតែព្យាយាមធ្វើឲ្យមានច្រកចេញជាយុទ្ធសាស្ត្រមួយ ដែលអាចអនុញ្ញាតឲ្យខ្លួនចាកចេញពីប្រទេសនោះ ដោយមិនបន្សល់ទុកឲ្យមានករណីមិនទាន់កាត់ក្តី ឬមិនទាន់បានទូទាត់ប្រាក់បៀវត្សរ៍ជូនបុគ្គលិករបស់ខ្លួនឲ្យបានរួចរាល់ ។ សុភាសិតបុរាណចែងថា «ចូរបង្រៀនមនុស្សឲ្យចេះចាប់ត្រី ជាជាងឲ្យត្រីហូប» ។ ការកែលម្អប្រព័ន្ធតុលាការក្នុងស្រុករយៈពេលវែង ជួយបង្កើតឲ្យមានវប្បធម៌ យុត្តិធម៌និងគណនេយ្យភាព ព្រមទាំងធានាថាសេចក្តីសម្រេចបែបណាក៏ដោយ ដែលតុលាការឧក្រិដ្ឋកម្មសង្គ្រាមបានប្រកាន់យកនឹងមិនបាត់បង់ប្រសិទ្ធភាព ក្រោយពេលដែលតុលាការបញ្ចប់ភារកិច្ចរបស់ខ្លួន ។ បើពិនិត្យទៅលើការចំណាយថវិកានិងពេលវេលាសម្រាប់បង្កើតយន្តការក្រោយសង្គ្រាមបរាជ័យ ក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរធំធេងរយៈពេលយូរអង្វែង ធ្វើឲ្យជំនឿទុកចិត្តនិងគុណភាពតម្លៃនៃយន្តការទាំងនោះធ្លាក់ចុះ ។

នៅពេលបង្កើតឲ្យមានតុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូន សូម្បីតែក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិក៏ទទួលស្គាល់ភាពចាំបាច់ក្នុងការបង្កើតឲ្យមានគំរូមួយដែលអាចផ្តល់នូវមរតកដ៏រឹងមាំសម្រាប់ប្រទេសនេះដែរ រួមទាំងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ការគោរពនីតិរដ្ឋ ជំនឿជឿជាក់លើស្ថាប័នសាធារណៈនិងការកែលម្អស្តង់ដារវិជ្ជាជីវៈ ។ ជាការពិតក្រុមប្រឹក្សាសន្តិសុខសំដៅជាពិសេសទៅលើ «តម្រូវការខ្លាំងក្លាឲ្យមានកិច្ចសហប្រតិបត្តិការជាអន្តរជាតិដើម្បីជួយពង្រឹងប្រព័ន្ធយុត្តាធិការរបស់ប្រទេសសៀរ៉ាឡេអូន...» ។ តាមការពិតចំណុចដែលបានលើកឡើងនេះជារឿងពិតដែលបានកើតឡើងនៅក្នុងគ្រប់បរិបទក្រោយអំពើឃោរឃៅ ដែលនៅទីនោះប្រព័ន្ធក្នុងស្រុកមានតម្រូវការច្រើន ហើយការគិតគូរពីយុត្តិធម៌ក្នុងរយៈពេលវែងនឹងទទួលបានប្រយោជន៍ពីការផ្សារភ្ជាប់គ្នារវាងមូលនិធិអន្តរជាតិជំនាញនិងការគាំទ្រចំពោះការពង្រឹងស្ថាប័នក្នុងស្រុក ។

**ក២) ការសម្របសម្រួលទៅតាមទស្សនាទានយុត្តិធម៌ក្នុងស្រុកៈ គន្លឹះសម្រាប់ការជំរុញនីតិរដ្ឋ និងធ្វើឲ្យមានការគោរពច្បាប់**

ហេតុផលដែលតែងលើកឡើងជារឿយៗ ដើម្បីគាំទ្រតុលាការឧក្រិដ្ឋកម្មសង្គ្រាមពឹងផ្អែកលើទស្សនៈបង្កើតឲ្យមានវប្បធម៌គណនេយ្យភាពនិងជំរុញនីតិរដ្ឋ ។ បើទោះបីជាការសម្រេចគោលដៅទាំងនេះពិបាកនឹងកំណត់បានក៏ដោយ ក៏នៅតែអាចនិយាយបានដែរថា វាទាមទារឲ្យមនុស្សភាគច្រើនព្រមទទួលយកនិយាមមួយចំនួន (ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ដំណោះស្រាយជម្លោះដោយសន្តិវិធី និងអភិបាលកិច្ចល្អ ។ល។) ។ លើសពីនេះទៅទៀតឥទ្ធិពលជាវិជ្ជមានទៅលើសេចក្តីថ្លែងការណ៍នយោបាយ គំនិតដែលនិយមគាំទ្រនិងសក្តានុពលវប្បធម៌នៅក្នុងប្រទេសនានាដែលឆ្លងកាត់អំពើយង់ឃ្នងគឺជារឿងសំខាន់ ។ ដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរបែបនេះ ប្រជាជនពាក់ព័ន្ធភាគច្រើនត្រូវតែយល់ព្រមទទួលយកតុលាការ ឬយ៉ាងហោចណាស់ក៏មិនប្រឆាំងជំទាស់នឹងវត្តមានតុលាការនេះដែរ ។ ឥទ្ធិពលក្នុងស្រុករបស់យន្តការអន្តរកាលក្រោយជម្លោះមួយណាក៏ដោយ ក៏ពឹងផ្អែកលើសមត្ថភាពរបស់ខ្លួនក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរខ្លះនៅក្នុងអារម្មណ៍និងគំនិតរបស់ប្រជាជនក្នុងស្រុក ។

យុត្តិធម៌មានច្រើនសណ្ឋាននិងហាក់ដូចជាកើតឡើងម្តងហើយម្តងទៀតនៅលើពិភពលោក ។ ការសន្មតទុកជាមុនថាគ្រប់គ្នាអាចយល់និងព្រមទទួលយកនិយាមលោកខាងលិចដោយមិនចាំបាច់គិតនិងនៅគ្រប់ទីកន្លែងគឺជារឿងមួយដ៏ឆ្គួតលេលា ។ រឿងនេះត្រូវតែមានបញ្ជាក់ខ្លឹមសារឲ្យបានច្បាស់លាស់ព្រោះថាវានាំទៅរកសេចក្តីសន្និដ្ឋានមួយខុសពីអ្វីដែលបានព្រមព្រៀងគ្នាដែលថាមានអ្នកច្បាប់អន្តរជាតិមួយចំនួនតូចមានឆន្ទៈនឹងទទួលថាៈ

ដើម្បីឲ្យប្រជាជនមិនមែនលោកខាងលិចទទួលស្គាល់ថា យន្តការផ្តល់យុត្តិធម៌ក្រោយអំពើយង់ឃ្នង ជាយន្តការមានប្រសិទ្ធភាព ហើយយន្តការទាំងនោះត្រូវតែសម្របឲ្យទៅតាមរបៀបមួយដែលប្រជាជនក្នុងស្រុកព្រមទទួលនិងអាចយល់បាន ។ ការប្រឲ្យបញ្ចូលគ្នារវាងការប្រតិបត្តិរបស់រដ្ឋជាមួយនឹងការបារម្ភក្នុងស្រុក គឺជាគ្រឹះនៃភាពស្របច្បាប់ ។ មិនថាឡើយការធ្វើបែបនេះសមហេតុផលតាមផ្នែកបច្ចេកទេសក្នុងកម្រិតណានោះទេ ការអនុវត្តន៍ច្បាប់មិនអាចបំពេញសេចក្តីត្រូវការយុត្តិធម៌របស់ប្រជាជនដែលទទួលរងការប៉ះទង្គិចបានឡើយ ប្រសិនបើប្រជាជនក្នុងស្រុកមិនយល់អំពីវា ។ រចនាសម្ព័ន្ធច្បាប់ក្រោយអំពើយង់ឃ្នងត្រូវតែប្របាច់បញ្ចូលធាតុផ្សំយុត្តិធម៌និងវប្បធម៌ក្នុងស្រុកប៉ុយ៉ាងហោចណាស់ក៏ត្រូវយកចិត្តទុកដាក់គិតគូរដល់តថភាពនិងវិធានក្នុងស្រុកដែរ ។ រូបមន្តមួយស្រដៀងគ្នានេះ គឺជាការជិតឈានទៅដល់ការព្រមព្រៀងគ្នាជាឯកច្ឆន្ទក្នុងការបង្កើតទស្សនវិជ្ជាដែលថាការចូលរួមរបស់ប្រជាជនក្នុងស្រុកមានសារសំខាន់ណាស់សម្រាប់ការអភិវឌ្ឍយូរអង្វែងប្រកបដោយចីរភាព ។ ដូចដែលភាគច្រើនបំផុតនៃអ្នកគាំទ្រគំនិតនេះបានសង្កត់ធ្ងន់ទៅលើគំនិតរបស់លោក ដូលេស ភេតធី បានលើកឡើងថា «ការចូលរួម» បានក្លាយទៅជាពាក្យស័ព្ទបច្ចេកទេសនៃការអភិវឌ្ឍជាក់ស្តែង ។

ដើម្បីធ្វើឲ្យមានការជឿជាក់ថា យើងមានដំណោះស្រាយសមស្របសម្រាប់កំហុសពីអតីតកាល ប្រជាជនត្រូវយល់អំពីយន្តការផ្តល់យុត្តិធម៌ដែលកំពុងមានវត្តមាន ។ នៅទីបញ្ចប់ វាជាការចាំបាច់ណាស់ដែលត្រូវពន្យល់ប្រាប់ពួកគេថាមានការផ្តន្ទាទោសសមល្មមនឹងកំហុសនោះហើយ និងពន្យល់ឲ្យពួកគេគោរពការសម្រេចចិត្តរបស់តុលាការ ។ បញ្ហាស្ថិតនៅត្រង់ថា មិនត្រូវកំណត់និយមន័យយុត្តិធម៌សាជាថ្មីនោះទេ តែត្រូវយល់ថាទស្សនៈរបស់ប្រជាជនចំពោះយន្តការផ្តល់យុត្តិធម៌ក្រោយអំពើយង់ឃ្នងកើតមានឡើងគឺជារឿងសំខាន់ ។ ដូចនេះការគាំទ្ររបស់ប្រជាជននិងការយល់ច្បាស់អំពីស្ថាប័នគួរតែបង្ហាញឲ្យបានឃើញច្បាស់លាស់នៅក្នុងការបង្កើតវាយតម្លៃតុលាការកូនកាត់និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ។ តុលាការឧក្រិដ្ឋកម្មអន្តរកាលក្រោយជម្លោះត្រូវតែមានលទ្ធភាពទទួលបានការគាំទ្រពីប្រជាជន ។

ជាងនេះទៅទៀត ប្រសិនបើអាច តុលាការឧក្រិដ្ឋកម្មសង្គ្រាមគួរតែទប់ស្កាត់អ្នកប្រព្រឹត្តនៅក្នុងទីកន្លែងដែលមាននាពេលអនាគត ។ ហេតុផលសម្រាប់ការចំណាយប្រាក់រាប់លានដុល្លារ ធ្វើឲ្យមានជំនឿជឿជាក់ក្នុងករណីនីមួយៗ មិនត្រូវពឹងផ្អែកត្រឹមតែទៅលើជំនឿដែលថាយុត្តិធម៌សងសឹក ប្រឆាំងបទឧក្រិដ្ឋសង្គ្រាមមានសារសំខាន់ប៉ុណ្ណោះទេ វាក៏ត្រូវពឹងផ្អែកលើក្តីសង្ឃឹមដែលថាការចំណាយថវិកាដ៏ច្រើនសន្ធឹកសន្ធាប់នេះ ពិតជាមានតម្លៃ ប្រសិនបើតម្លៃនៃការកាត់ទោសជានិមិត្តរូបនេះទប់ស្កាត់មិនឲ្យមានជនដៃដល់ទៀតនាពេលអនាគត ។ ដើម្បីធ្វើឲ្យមានការខ្លាចរអា យោធានិងអ្នកមានអំណាចនយោបាយក្នុងស្រុក ត្រូវយល់និងទទួលយកសេចក្តីសម្រេចរបស់តុលាការនៅក្នុងប្រទេសរបស់ខ្លួននៅក្នុងកម្រិតមួយ ។ ក្រៅពីនេះ ពួកគេត្រូវធ្វើឲ្យមានការភ័យខ្លាចចំពោះការផ្តន្ទាទោសរបស់ប្រព័ន្ធយុត្តិធម៌ក្នុងស្រុក ។

អ្នកចេះដឹងដូចជាលោក សំពោង ពៅ ប្រកាន់ជំហរថា និយាមសីលធម៌ (ដូចអ្វីដែលបានលើកឡើងដោយស្ថាប័នយុត្តិធម៌អន្តរជាតិ) លែងមានដំណើរការនៅពេលមានការរីកសាយភាយនៃអំពើយង់ឃ្នងថា រចនាសម្ព័ន្ធដែលលែងដំណើរការនេះនាំទៅរកការគិតគូរក្នុងរយៈពេលខ្លី អំពីការរស់រានមានជីវិត និងថាជនល្មើសលែងគិតពីបញ្ហាផលប៉ះពាល់ផ្នែកច្បាប់នៅពេលអនាគត ។ ផ្ទុយទៅវិញ សូម្បីតែអ្នកចេះដឹងដូចជាលោក ពៅ ក៏អះអាងគាំទ្រក្នុងការពង្រឹងស្ថាប័ន ដូចជាស្ថាប័នយុត្តិធម៌ក្នុងស្រុកថា ជាគ្រឿងបន្ទាបដ៏មានឥទ្ធិពលចំពោះជនល្មើស ដែលនេះជាការគាំទ្រឲ្យមានតុលាការកូនកាត់ដូចដែលអត្ថបទនេះលើកឡើង ។

ប្រសិនបើប្រជាជនក្នុងស្រុកភាគច្រើនយល់ច្រឡំ និងមិនពេញចិត្តវត្តមានរបស់តុលាការដែលសំអាងថា ជាការគាបសង្កត់ពីខាងក្រៅ ហើយប្រឆាំងនឹងសេចក្តីសម្រេចរបស់តុលាការនិងមើលឃើញថា វាមិនមានភាពស្របច្បាប់នោះ ប្រជាជននឹងមិនងាយនឹងសម្របខ្លួនទៅតាមសេចក្តីសម្រេចរបស់តុលាការនេះទេ ។ វិបត្តិនឹងរីកកាន់តែធំឡើង ប្រសិនបើយុត្តិធម៌និងការអនុវត្តន៍ច្បាប់ក្នុងស្រុកមិនត្រូវបានពង្រឹងឲ្យបានសមស្របដើម្បីរារាំងការមិនពេញចិត្តទេនោះ ។ ***(នៅមានត)***

**អេរ៉ៃតេល ហ៊ីហ្គូនេត**

# ការលំបាកដែលខ្ញុំជួប

ខ្ញុំបាទ ភី ប៊ុនថាន់ ជាអនុប្រធានមន្ទីរអភិវឌ្ឍសហគមន៍ (ខេត្តកំពង់ចាមសម័យលន់នល់) ។ ក្រោយបែកឆ្នាំ១៩៧៥ ខ្ញុំលាក់ប្រវត្តិរូបរួចបន្ទំចូលធ្វើការជាកម្មករនៅសិប្បកម្មបារី-សាប៊ូភូមិភាគបូព៌ា ទើបអាចរស់រានមានជីវិតមកដល់សព្វថ្ងៃ ។ ខាងក្រោមនេះជាការរៀបរាប់ពីជីវិតនិងការងារដែលខ្ញុំឆ្លងកាត់នៅក្នុងរបបនេះ ។

ខ្ញុំកើតឆ្នាំ១៩៤៩ នៅភូមិកំពង់ឫស្សី ឃុំជីរោទិ៍១ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ នៅពេលអាយុ១៦ឆ្នាំ ខ្ញុំចូលរៀននៅសាលាបឋមសិក្សាកំពង់ឫស្សី បន្ទាប់មកឪពុកម្តាយខ្ញុំក៏បញ្ជូនទៅរៀនបន្តនៅអនុវិទ្យាល័យសូង ក្នុងស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

នៅពេលរៀនថ្នាក់ទី៤ ខ្ញុំជាប្រធានថ្នាក់ ។ បន្ទាប់មកក៏ត្រូវមិត្តរួមថ្នាក់បោះឆ្នោតជ្រើសរើសឲ្យធ្វើជាសមាជិកគណៈកម្មការយុវជនប្រចាំអនុវិទ្យាល័យ និងទទួលមុខងារជាអនុប្រធានគណៈកម្មការទទួលបន្ទុកខាងពិធីបុណ្យនិងការបំផុសចលនា ។ ខ្ញុំប្រើប្រាស់ថវិការបស់សមាគមខ្លះ ថវិកាផ្ទាល់ខ្លួនខ្លះ និងការគាំទ្រពីមិត្តរួមថ្នាក់ដែលមានទេពកោសល្យខាងគំនូរ ព្រមទាំងមានការជួយឧបត្ថម្ភពីសាលាចិនសូង ខ្ញុំក៏សម្រេចធ្វើប័ណ្ណជូនពរឆ្នាំថ្មីឆ្នាំមមីដែលមានរូបភាពទេសភាពស្រុកស្រែនិងសេះសមួយកំពុងរត់នៅលើផ្លូវថ្នល់ ចែកជូនទៅគ្រប់វិទ្យាល័យនិងអនុវិទ្យាល័យក្នុងខេត្តកំពង់ចាមដោយឥតគិតថ្លៃ ។ ទន្ទឹមនោះក៏មានដំណើរទស្សនកិច្ចរបស់សិស្សានុសិស្សអនុវិទ្យាល័យព្រៃទទឹងមកកាន់អនុវិទ្យាល័យសូង ដើម្បីផ្សារភ្ជាប់មនោសញ្ចេតនារវាងសិស្សទាំងពីរអនុ-វិទ្យាល័យ ។ លោកគ្រូ ឡោ សាន ជាសាស្ត្រាចារ្យផ្នែកភាសាបារាំង គាត់ចូលចិត្តខ្ញុំណាស់ ហើយគាត់តែងសរសើរនៅពេលខ្ញុំឆ្លើយសំណួររបស់គាត់ម្តងៗ ។

នៅឆ្នាំ១៩៦៧ ខ្ញុំបានដាក់ពាក្យប្រឡងធ្វើគ្រូនៅសាលាគរុកោសល្យកំពង់កន្ទួត ។ ក្រោយពីប្រឡងជាប់ ខ្ញុំត្រូវបានអនុញ្ញាតឲ្យស្នាក់នៅអន្តេវាសិកដ្ឋាន ។ សាលានោះតម្រូវឲ្យខ្ញុំកាត់សម្លៀកបំពាក់និងទិញសម្ភារៈប្រើប្រាស់ដោយខ្លួនឯង ។ ប៉ុន្តែដោយសារបងប្រុសច្បងខ្ញុំធ្លាប់រៀននៅទីនោះ ដូច្នេះសម្ភារៈទាំងអស់នេះខ្ញុំមិនចាំបាច់ទិញទេ ព្រោះមានរបស់បងខ្ញុំស្រាប់ ។

សៀក ប៉ោហេង ជាមិត្តរួមបន្ទប់ជាមួយខ្ញុំ ដែលមានផ្ទះ



សកម្មភាពជីកប្រឡាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

នៅក្បែរទីប្រជុំជនសៀមរាប (កំពង់កន្ទួត ខេត្តកណ្តាល) តែងតែមកជជែកលេងជាមួយមិត្តភក្តិអំពីបញ្ហាប្រទេសជាតិ និងច្រើនតែលើកឡើងអំពីអំពើពុករលួយ ការជិះជាន់កេងប្រវ័ញ្ចរបស់សង្គមចាស់ ហើយលើកសរសើរលោក ហ៊ូ នឹម, ហ៊ូ យន់, ខៀវ សំផន ជាមន្ត្រីស្អាតស្អំ និងមានការគាំទ្រពីប្រទេសចិនប្រជាមានិត ។ នៅល្ងាចមួយ ពេលកំពុងហូបបាយជាមួយគ្នា មិត្តភក្តិរបស់ខ្ញុំផ្សេងទៀតប្រាប់ថា នៅឯសៀមរាបកន្ទួតមានពិធីបុណ្យសម្តែងសិល្បៈ ។ បន្ទាប់មកមិត្តរួមបន្ទប់ខ្ញុំពីរនាក់ឈ្មោះ ទូច ប៉េងហ៊ាន និង ប៉ាន់ សេងហុង បានបបួលខ្ញុំទៅលេងបុណ្យនោះ ។ ម៉ោងប្រហែល១១យប់ ស្រាប់តែ ប៉ោហេង ប្រញាប់ប្រញាល់ទៅប្រាប់ខ្ញុំទាំងបីនាក់ថាឲ្យទៅសាលាវិញជាបន្ទាន់ ព្រោះមានសកម្មភាពបាចគ្រាក់នៅក្នុងសាលានិងតាមដងផ្លូវមុខសាលាស្រួលមិនស្រួលគេចោទមកលើយើង ។ ម៉ោង៤ទៀបភ្លឺថ្ងៃបន្ទាប់ ស្គរកញ្ចែបន្លឺឡើង តាមវិន័យគរុសិស្សត្រូវប្រមូលគ្នាប្រជុំជួរជាបន្ទាន់ ។ ពេលនោះសិស្សជិត៨០០នាក់បានឈរតម្រង់ជួរតាមផ្នែកនីមួយៗជុំវិញដងទង់ជាតិរួចជាស្រេច ។ លោកសាស្ត្រាចារ្យនិងអនុរក្សបានចូលទៅឆែកឆេរមើលគ្រប់បន្ទប់ស្នាក់នៅរបស់គរុសិស្ស ។ ប៉ុន្តែមិនឃើញមានអ្វីជាសំខាន់ទេ គ្រាន់តែដកហូតយកបានទស្សនាវដ្តីពីរក្បាលដែលសរសេរជាភាសាចិនប៉ុណ្ណោះ ។

## ជាគ្រូបង្រៀននៅទួលដំណាក់

ក្រោយពីបញ្ចប់វគ្គសិក្សានៅសាលាគរុកោសល្យ ខ្ញុំត្រូវបញ្ជូនឲ្យទៅបង្រៀននៅសាលាបឋមសិក្សាទួលដំណាក់ស្ថិតក្រោមជំនួយឧត្ថម្ភរបស់សហរដ្ឋអាមេរិក ស្ថិតនៅភូមិទួលដំណាក់ ឃុំចុងដូង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ នៅទីនោះខ្ញុំបានជួបលោកគ្រូ-អ្នកគ្រូថ្មីៗនៅលីវ៦នាក់ដែលទើបចេញពីសាលាគរុកោសល្យដូចគ្នារួមទាំងគ្រូចាស់ៗ និងលោកនាយកសរុបទាំងអស់មានសមាជិក១១នាក់ ។ ដំបូងគ្រូនៅលីវ៧ចំនួន៤នាក់រួមទាំងខ្ញុំផងបានស្នាក់នៅបន្ទប់គិលានដ្ឋានដែលទំនេរ ។ ក្រោយមកនៅសល់តែខ្ញុំនិងសិស្សម្នាក់ទៀតនៅដេកចាំយាមរាល់ពេលយប់ ព្រោះខ្លះរៀបការ ខ្លះដូរកន្លែងស្នាក់នៅ ។ ខណៈនោះ មានលេចឮថាខ្មែរក្រហមបានចាប់មន្ត្រីនិងប្រជាពលរដ្ឋយកទៅធ្វើបាបឬសម្លាប់ចោល ។ ពេលនោះខ្ញុំក៏សម្រេចចិត្តទៅរស់នៅជាមួយលោកគ្រូម្នាក់ដែលទើបរៀបការប្រពន្ធ ហើយគាត់ជួលផ្ទះស្នាក់នៅឯកំពង់ថ្ម ។ នៅក្នុងអំឡុងឆ្នាំ១៩៦៩ ចៅអធិការរងបឋមសិក្សាខេត្តកំពង់ធំ បានធ្វើការប្រជុំលោកគ្រូ-អ្នកគ្រូទាំងអស់នៅកន្លែងអធិការកិច្ចកំពង់ថ្ម ដោយបានសំណេះសំណាលផ្តាំផ្ញើឲ្យយកចិត្តទុកដាក់បង្រៀនចំណេះវិជ្ជាដល់សិស្ស និងឲ្យសិស្សានុសិស្សខិតខំហាត់ប្រាណឲ្យមានសុខភាពមាំមួនទើបមានកម្លាំងទប់ទល់នឹងការឈ្លានពានរបស់ពួកវៀតកុង ។

## ព្រឹត្តិការណ៍រដ្ឋប្រហារឆ្នាំ១៩៧០

នៅដើមខែមីនា ឆ្នាំ១៩៧០ ខ្ញុំបានស្តាប់វិទ្យុជាតិចាក់ផ្សាយអំពីបាតុកម្មរបស់សិស្សនិងនិស្សិតដេញយួនយៀកកុងនៅតាមព្រំដែនខេត្តស្វាយរៀង និងមានបាតុកម្មវាយស្ថានទូតសាធារណរដ្ឋសង្គមនិយមវៀតណាមនៅភ្នំពេញទៀតផង ។ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧០ ក៏មានការផ្សាយបន្តផ្ទាល់ពីអង្គមីទ្ទីងដ៏ធំមួយនៅពហុកីឡាដ្ឋានជាតិអូឡាំពិកដែលថ្កោលទោសយៀកកុង-យៀកមិញឈ្លានពានទឹកដីកម្ពុជា ។ លុះមកដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សេនាប្រមុខ លន់ នល់ បានប្រកាសជាសាធារណៈអំពីការទម្លាក់សម្តេច សីហនុ ពីព្រះប្រមុខរដ្ឋ និងបានប្រកាសឲ្យលោក ចេង ហេង ប្រធានរដ្ឋសភាឡើងជាប្រមុខរដ្ឋវិញ ។

ក្រោយមកសភាពការណ៍នេះកាន់តែជ្រួលច្របល់ឡើង កូនសិស្សលែងទៅរៀន ។ ប៉ុន្តែខ្ញុំនិងគ្រូ៦ទៀតនៅតែទៅសាលាជាប្រចាំ ។ ព្រឹកមួយខ្ញុំបានឃើញកងទាហានប្រាំពីរនាក់មានរថយន្តហ្ស៊ីបបើកដំបូលមួយគ្រឿងបំពាក់ដោយកាំភ្លើងយន្តនៅពីមុខនិងទាហាន៦ទៀតកាន់អាវុធគ្រប់ដៃឈប់ទន្ទឹមខ្លោងទ្វារសាលា និងចំកណ្តាលផ្លូវជាតិលេខ៦ប្រកបដោយទឹកមុខស្វាហាប់កំពុងត្រៀមចាំសភាពការណ៍អ្វីមួយ ។ ពេលនោះក៏មានហ្វូងបាតុករដើរចេញពីកំពង់ថ្មនិងត្រពាំងឈូកយ៉ាងច្រើនកុះករដោយមានបដាព្រះឆាយាលក្ខណ៍សម្តេចឪកាន់នៅដៃធ្វើដំណើរសំដៅទៅកំពង់ថ្មនិងកំពង់ធំ ។ មកដល់មុខសាលា ពលទាហានក៏ធ្វើសញ្ញាឲ្យថយក្រោយ ប៉ុន្តែហ្វូងបាតុករស្ទុះចូលដោយគ្មានញញើត ។ ទន្ទឹមនឹងនោះសំឡេងកាំភ្លើងយន្តផ្ទុះឡើងប្រាវសំដៅទៅលើបាតុករ ដែលព្រឹកនោះមានអ្នកស្លាប់នៅនឹងកន្លែងចំនួន៦នាក់

ហើយបាតុករបាននាំគ្នារត់បែកខ្ញែកគ្នាអស់ ។

**នៅក្រសួងអភិវឌ្ឍសហគមន៍**

ដោយសារសភាពការណ៍មិនស្រួលខ្ញុំក៏រត់ទៅភ្នំពេញ ។ នៅទីនោះខ្ញុំបានជួបបងជីដូនមួយខ្ញុំឈ្មោះ ទូន ឡាន ជាគ្រូបង្រៀននៅខេត្តរតនគីរីនិងមិត្តភក្តិខ្ញុំនៅបង្រៀនខេត្តក្រចេះនិងខេត្តកំពង់ធំ ។ ក្រោយមករដ្ឋាភិបាលប្រកាសបង្កើតក្រសួងអភិវឌ្ឍសហគមន៍ និងបានជូនដំណឹងដល់លោកគ្រូ-អ្នកគ្រូដែលមានចំណាប់អារម្មណ៍ចង់បម្រើការនៅក្នុងផ្នែកនេះ ។ ខ្ញុំនិងមិត្តភក្តិឈ្មោះ ទូច ម៉េងហ៊ាន និងបងជីដូនមួយឈ្មោះ ទូន ឡុន ក៏បានស្ម័គ្រចិត្តចូលបម្រើការនៅក្នុងក្រសួងនេះ ។ បេក្ខជនត្រូវធ្វើការប្រមូលផ្តុំឲ្យស្នាក់នៅសាលាបាក់ទូកនិងទៅរៀននៅសាលប្រជុំនៅមហាវិទ្យាល័យបច្ចេកទេសមិត្តភាពកម្ពុជា-សូវៀត ដោយមានរថយន្តទេសចរណ៍ជូនដំណើរទៅមករាល់ថ្ងៃ ប៉ុន្តែការហូបចុកត្រូវដោះស្រាយដោយខ្លួនឯង ។ យើងទំនាក់ទំនងការងារជាមួយក្រសួងអភិវឌ្ឍសហគមន៍ ដែលមានទីស្តីការនៅចន្លោះទីស្តីការគណៈរដ្ឋមន្ត្រីនិងក្រសួងការពារជាតិ ។ រៀនវគ្គបានមួយខែ ក្រសួងបានចាត់តាំងឲ្យមន្ត្រីទាំងអស់ទៅហាត់ក្បួនយុទ្ធសាស្ត្រនៅព្រៃសរយៈពេល៤ខែបន្ថែមទៀត ដោយឲ្យស្នាក់នៅទីនោះតែម្តង ។ ក្រោយពីបញ្ចប់វគ្គ សិស្សនិស្សិតមួយចំនួនបានសុំចូលបម្រើការងារជានាយទាហាន ពលបាល ព្រិទ្ធបាល និងអនុសេនីយ៍ទៅតាមកម្រិតសញ្ញាបត្រ ។ ចំណែកមន្ត្រីក្រសួងអភិវឌ្ឍសហគមន៍ទាំងអស់ត្រូវបានរៀបចំឲ្យមានរចនាសម្ព័ន្ធដែលមានទីស្តីការក្រសួងនៅកន្លែងដដែល និងមានក្រុមប្រតិបត្តិការនៅទឹកថ្លាដែលមានលោករដ្ឋមន្ត្រី ហង្ស ធុនហាក់ និងលោក គង់ អ៊ីន ជានាយកខុទ្ទកាល័យ ។ ខ្ញុំត្រូវបានចាត់តាំងឲ្យស្ថិតនៅក្នុងក្រុមប្រតិបត្តិការនេះ ដែលមានទីធ្លាធំទូលាយទំហំជិតមួយហិកតា មានផ្ទះវីឡាទំនើបមួយខ្នងកម្ពស់ពីរជាន់ (អតីតផ្ទះ ប៉ែត នុត) មានផ្ទះកម្មករ រោងឡាន ស្រះទឹក និងមានរបងព័ទ្ធជុំវិញ ។ ក្រោយមកខ្ញុំក៏បានចូលរៀនវគ្គបណ្តុះបណ្តាលបន្ថែមទៀតដោយមានគ្រូអ្នកជំនាញការជនជាតិហ្វីលីពីនតំណាងស្ថានទូតអ៊ីស្រាអែល និងមានរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍសហគមន៍ម៉ាឡេស៊ីផងដែរ ។ ចំណែកមន្ត្រីមួយចំនួនទៀតបានទៅរៀនបន្តនៅហ្វីលីពីន ទស្សនកិច្ចនៅតៃវ៉ាន់ និងប្រទេសថៃ ។ ធ្វើការបានមួយរយៈ ខ្ញុំបានសរសេរសំបុត្រសុំច្បាប់លោកនាយកខុទ្ទកាល័យក្រសួងឈប់សម្រាកចំនួនបីថ្ងៃ ដើម្បីទៅរៀបការប្រពន្ធនៅទីរួមខេត្តកំពង់ចាម នៅថ្ងៃទី២០ ខែមករា ឆ្នាំ១៩៧១ ។ បន្ទាប់ពីស្នាក់នៅកំពង់ចាមបានមួយសប្តាហ៍ ខ្ញុំបានត្រឡប់ធ្វើការនៅភ្នំពេញវិញដោយនាំប្រពន្ធមកជាមួយដែរ ។

**ផ្លាស់ទៅធ្វើការនៅកំពង់ចាម**

នៅចុងឆ្នាំ១៩៧១ ក្រសួងអភិវឌ្ឍសហគមន៍បានបញ្ជូនបុគ្គលិកទៅតាមខេត្ត ។ ខ្ញុំនិងបុគ្គលិក៥នាក់ទៀតត្រូវបានបញ្ជូនឲ្យទៅខេត្តកំពង់ចាមតាមការស្នើសុំរបស់សាមីខ្លួន ។ លោក គង់ អ៊ីន នាយកខុទ្ទកាល័យបានយករថយន្តក្រសួងមកជូនដំណើរទៅដល់សាលាខេត្តកំពង់ចាម និងជួបផ្តាំផ្ញើលោក តាំង សេងសំទួន ជាអភិបាលរងទី១ខេត្ត ព្រមទាំងហូបបាយរួមគ្នាទៀតផង ។ អភិបាលខេត្តបានរៀបចំអគារមួយខ្នងតូចរបស់សាលាស្រុកកំពង់សៀម ដែលនៅជិតសាលាខេត្តធ្វើជាទីស្នាក់ការ ។ ក្នុងចំណោមមន្ត្រីទាំង៦នាក់នេះមានលោក អ៊ិន ហេងគ្រី ជាប្រធាន ខ្ញុំជាអនុប្រធាន, ទូច ម៉េងហ៊ាន, ស៊ាង ឡៃស្រ៊ី, គន់ សុផល និង ឡុង ឈុនឡៃ ជាមន្ត្រី ។

ក្រុមខ្ញុំបានចាប់យកតំបន់បឹងស្នាយ នៅខាងត្បូងទីរួមខេត្តកំពង់ចាមនិងឃុំដំបងដែក ស្រុកកំពង់សៀម ដើម្បីបង្កើតជាសហគមន៍ដែលតំបន់នេះភាគច្រើនជាប្រជាជនជម្លៀស ។ យើងបានសម្របសម្រួលចែកដីធ្លីសង់លំនៅដ្ឋាននិងដីបង្កបង្កើនផលបានបន្តិចម្នាក់ និងបានរៀបចំសហគមន៍ដាំបន្លែ ចិញ្ចឹមសត្វនិងត្បាញ ។ ក្រសួងបានផ្តល់វិទ្យុច្រើនរយគ្រឿង ត្រីខកំប៉ុង ទឹកដោះគោដើម្បីបែងចែកទៅឲ្យជនភៀសខ្លួន និងបានផ្តល់រថយន្តហ្វុយហ្សូ (FUSO) មានសញ្ញាកាកបាទក្រហម ដើម្បីឲ្យប្រជាពលរដ្ឋខ្ចីដឹកដីធ្វើផ្លូវផងដែរ ។ ពាក់កណ្តាលខែកុម្ភៈ ឆ្នាំ១៩៧២ ក្រសួងបានចាត់តាំងឲ្យមន្ត្រីទាំងអស់ទៅរៀនវគ្គបណ្តុះបណ្តាលរយៈពេលមួយខែ ដោយមានបែងចែកជា២វគ្គ ។ ខ្ញុំសម្រេចចិត្តជ្រើសយកវគ្គទី១ ព្រោះខ្ញុំគិតថា ពេលបញ្ចប់វគ្គទើបប្រពន្ធខ្ញុំឆ្លងទន្លេ ប៉ុន្តែជិតដល់ថ្ងៃបញ្ចប់វគ្គស្រាប់តែប្រពន្ធខ្ញុំឈឺពោះសម្រាលបានកូនស្រីមួយ ។

សហគមន៍នៅដំបងដែកដែលខ្ញុំបានខិតខំរៀបចំត្រូវរលំ

រលាយដោយកងទ័ពរំដោះវាយដណ្តើមកាន់កាប់ ។ ខ្ញុំបានបង្វែរមុខព្រួញទៅឃុំកោះសំរោងនិងឃុំកោះជ្រូកវិញ ដែលស្ថិតនៅលើកោះកណ្តាលទន្លេមេគង្គក្នុងស្រុកកោះសំរោងខាងជើងទីរួមខេត្តកំពង់ចាមស្ថិតក្នុងស្រុកកំពង់សៀម ។ ដំបូងខ្ញុំបានរួមដំណើរជាមួយលោក ម៉ា ឡោពី ជាអភិបាលស្រុកកំពង់សៀម ដើម្បីចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋនៅទីនោះ ។ លោក សេង សុខលីម អភិបាលខេត្តទទួលបន្ទុកអភិបាលស្រុកកោះសំរោងក៏បានអមដំណើរទៅដែរ ។ ខ្ញុំបានបង្ហាញគម្រោងអភិវឌ្ឍន៍ស្រុកកោះសំរោងនេះជូនលោក គង់ អ៊ិន ជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍សហគមន៍ជំនួសមុខឲ្យលោក ហង្ស ធុនហាក់ ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រី។ គម្រោងនោះគឺយើងរៀបចំជាក្រុមនិងសហគមន៍ដាំបន្លែបង្ការ និងស្បៀង ដើម្បីផ្គត់ផ្គង់ទីរួមខេត្តកំពង់ចាម ហើយក៏ទទួលបានការកោតសរសើរពីលោករដ្ឋមន្ត្រី ព្រោះអាចផ្តល់ការងារជូនប្រជាពលរដ្ឋនៅទីនោះ និងអ្នកភៀសខ្លួនផងដែរ ។ ការងារនេះទើបតែចាប់ផ្តើមដំណើរការបានបន្តិច ស្រាប់តែស្រុកកោះសំរោងទាំងមូលត្រូវកងទ័ពរំដោះ(កងទ័ពប្រឆាំងលន់នល់) វាយដណ្តើមកាន់កាប់បានទាំងស្រុងទៀត ។

## ការដណ្តើមកាន់កាប់

នៅរដូវវស្សាឆ្នាំ១៩៧៣ តំបន់គ្រប់គ្រងរបស់របប លន់ នល់ នៅទូទាំងខេត្ត កាន់តែរួមតូចទៅៗនៅសល់តែទីរួមខេត្តតូចមួយប៉ុណ្ណោះ ដែលមានខ្សែក្រវាត់ខាងជើងត្រឹមថ្មគោល ខាងត្បូងត្រឹមព្រែកដើមចាន់ ខាងលិចត្រឹមវាលយន្តហោះភ្នំប្រុសភ្នំស្រី និងខាងកើតត្រឹមប៉មទល់មុខកំពង់ចាម ។ ខ្ញុំទទួលតួនាទីជាប្រធានស្តីទីប្រចាំខេត្តកំពង់ចាមជំនួសលោកប្រធានដែលត្រូវក្រសួងបញ្ជូនទៅឲ្យធ្វើទស្សនកិច្ចសិក្សានៅប្រទេសឥណ្ឌារយៈពេលមួយខែ ។ ស្ថិតនៅចំពោះមុខសភាពការណ៍ដុនដាបនេះ សេនាប្រមុខ លន់ នល់ បានបញ្ជូនឧត្តមសេនីយ៍ទោ ស ហោ និងឧត្តមសេនីយ៍ត្រី ស្រី យ៉ា អភិបាលខេត្តកំពង់ចាម ទៅជួយដឹកនាំប្រតិបត្តិការសឹក ។ ខ្ញុំបានចូលរួមកិច្ចប្រជុំជាមួយលោក ស ហោ និងលោក ស្រី យ៉ា ព្រមទាំងលោកប្រធានមន្ទីរជុំវិញខេត្ត ដោយមានលោកចៅហ្វាយខេត្ត ស្រី យ៉ា ឡើងរាយការណ៍ពីសភាពការណ៍វាយលុករបស់សត្រូវ ។ ក្រោយមកលោក ស ហោ បានមានប្រសាសន៍ថា គាត់មិនមែនមកជំនួសអភិបាលខេត្តទេគឺមកជួយអភិបាលខេត្ត ។ បន្ទាប់ពីកិច្ចប្រជុំនេះសមាជិកអង្គប្រជុំទាំងអស់បានធ្វើដំណើរទៅត្រួតពិនិត្យប៉ុស្តិ៍នៅតាមខ្សែក្រវាត់ក្រុងកំពង់ចាម ។ នៅយប់នោះក៏មានគ្រាប់ផ្លោងប្រមាណពីររយគ្រាប់ផ្លោងចូលទីរួមខេត្តកំពង់ចាម ។ ប្រជាពលរដ្ឋនិងមន្ត្រីរដ្ឋការមួយចំនួនត្រូវភៀសខ្លួនទៅតំបន់រំដោះ និងមួយចំនួនទៀតត្រូវភៀសខ្លួនចូលមកទីរួមខេត្តកំពង់ចាម ។ នៅព្រឹកថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៧៣ ស្ទូរផ្ទុះអាវុធហាក់ដូចជានៅជិតកន្លែងធ្វើការ ។ ខ្ញុំបានបញ្ជាឲ្យមន្ត្រីទាំងអស់ប្រមូលឯកសារអង្គុលីលេខ ទូរស័ព្ទ ដាក់លើរថយន្ត រួចឲ្យអ្នកបើកបរយកសម្ភារៈទាំងអស់នេះទៅទុកនៅទីស្នាក់ការសង្គមកិច្ចខេត្តរបស់លោក ដូ សុហាន ហើយកុំហកគាត់ថាទៅស្រស់ស្រូបបន្តិចសិន ប៉ុន្តែតាមពិត ខ្ញុំទៅជួបជុំគ្រួសារដែលបានប្តូរផ្ទះពីនៅភូមិមេម៉ាយ ទៅនៅឃ្លាំងមាត់ទន្លេជាប់កំពង់ស្រឡាងវិញ ។ ផ្ទះនេះសង់ពីថ្មមានពីរជាន់ ដែលអាចការពារគ្រាប់ផ្លោងបាន ។ សំឡេងគ្រាប់កាំភ្លើងទាំងតូច-ធំបន្លឺឡើងពេញក្រុងកំពង់ចាម ខ្ញុំនិងក្រុមគ្រួសារហូបបាយដែលដាំទុកពីព្រឹកទាំងញ័រភ័យ ដោយមានកម្ទេចធូលីនិងកម្ទេចគ្រាប់បើុងចូលតាមបង្អួច ។

## ជម្លៀសចេញពីផ្ទះ

ម៉ោងដប់ពីរថ្ងៃត្រង់ សំឡេងគ្រាប់ផ្ទុះបានស្រាកបន្តិច ខ្ញុំបើកទ្វារផ្ទះចេញមកក្រៅស្រាប់តែទាហានលន់នល់ឈរនៅលើម៉ារីនឈប់សំចតស្មើមាត់ច្រាំងដោយទឹកជំនន់នៅកំពង់ស្រឡាង បានលើកដៃធ្វើជាសញ្ញាឲ្យទៅទិសខាងត្បូង ។ ខ្ញុំប្រញាប់ប្រញាល់ចូលផ្ទះវិញយកថង់ខោអាវដាក់លើម៉ូតូ រួចឌុបប្រពន្ធនិងកូនធ្វើដំណើរតាមផ្លូវមាត់ទន្លេឆ្ពោះទៅកាន់ដីដុះ ។ តាមដងផ្លូវដែលមានទំហំប្រមាណប្រាំម៉ែត្រ ពោរពេញដោយប្រជាពលរដ្ឋជម្លៀសខ្លះស្រែកថ្ងូរដោយត្រូវរបួស ខ្លះអូសរទេះដឹកឪពុកម្តាយចាស់ជរាពិការ ខ្លះបណ្តើរកង់ដឹកអីវ៉ាន់បន្តិចបន្តួច ។ ខ្ញុំបណ្តើរម៉ូតូ ប្រពន្ធខ្ញុំពោះធំ ពកូនដើរសំដៅមកវត្តចម្ការសាមសិប ។ បន្ទាប់មកយើងនាំគ្នាប្រជ្រៀតចូលនៅក្នុងវត្តហើយស្នាក់លើព្រះវិហារដោយមិនបានទទួលទានអាហារពេលល្ងាច ។ ព្រឹកឡើងខ្ញុំបន្តដំណើរទៅមុខទៀត រួចសុំផ្ទះអ្នកធ្លាប់ធ្វើឡថ្នាំជាមួយឪពុកក្មេកខ្ញុំដើម្បីស្នាក់នៅ ។ ម្ចាស់ផ្ទះបានជួយរកទូកចម្លងឲ្យក្រុមគ្រួសារខ្ញុំ ។ នៅម៉ោង១២

អគ្រាត្រ គ្រួសារខ្ញុំក៏បានទៅដល់ត្រើយម្ខាងទៀត ។ យើងធ្វើដំណើរទៅដល់ដីហែ ហើយស្នាក់នៅផ្ទះអ្នកធ្លាប់ស្គាល់គ្នាមួយរយៈ ។ ចំណែកឪពុកម្តាយបងប្អូនបង្កើតរបស់ខ្ញុំបានធ្វើដំណើរទៅដល់ភូមិត្រពាំងស្នោ ឃុំមង់រៀវ ចម្ងាយប្រមាណពីរគីឡូម៉ែត្រពីទីប្រជុំជនសួង ។ ពេលនោះគាត់បានឲ្យ ឌិន ជាសាច់ញាតិរបស់ខ្ញុំជិះម៉ូតូមកយកប្រពន្ធនិងកូនខ្ញុំទៅនៅទីនោះ រីឯខ្ញុំជិះកង់តាមក្រោយ ។

មកដល់ភូមិត្រពាំងស្នោ ឃុំមង់រៀវ គ្រួសាររបស់ខ្ញុំនិងអ្នកជម្លៀសត្រូវមកប្រជុំនៅវត្តសំរោងបុរី ដែលមានមិត្ត ចិន្តា ជាប្រធានឃុំ និងមិត្ត ម៉ម សាប៊ុន ជាប្រធានស្រុកត្បូងឃ្មុំ ជាអ្នកឡើងខទ្ទេសនាម លើកឡើងពីសភាពការណ៍នៅលើពិភពលោក និងការរីកចម្រើនរបស់អង្គការបដិវត្តន៍កម្ពុជានៅលើគ្រប់វិស័យ ។ ក្រោយមក ខ្ញុំនិងប្រពន្ធបានទៅរស់នៅជាមួយឪពុកម្តាយនិងបងប្អូនបង្កើតនៅក្នុងផ្ទះសំណាក់តូចមួយដែលសង់ពីឈើប្រក់ស័ង្កសីខ្ពស់ផុតពីដី ។ ផ្ទះនោះខ្ញុំជួលពីមីងដោយសារតែកាលនោះនៅមានចាយលុយនៅឡើយ ប៉ុន្តែចាយតែក្រដាសរាយពីមួយរៀលដល់ក្រដាសមួយរយរៀលប៉ុណ្ណោះ បើលុយក្រដាសប្រាំរយរៀល គេថាលុយក្លែងក្លាយ ។ មិត្ត ទូច ផន មានតួនាទីជាសមាជិកគណសិប្បកម្ម ឧស្សាហកម្មភូមិភាគបូព៌ា ឬភូមិភាគ២០៣ និងត្រូវជាឪពុកធំរបស់ខ្ញុំបានរួមដំណើរជាមួយមិត្ត គង់ ជាអ្នកស្រុករកាខ្នុរ ស្រុកក្រូចឆ្មារ បានតាមសួររកក្រុមគ្រួសារខ្ញុំ ។ ពេលដែលបានជួបគ្នា ខ្ញុំនិងប្រពន្ធសប្បាយរីករាយណាស់ ព្រោះមានគាត់ជាបង្អែក ។

ខ្ញុំនិងប្រពន្ធកូនខ្ញុំ ព្រមទាំងក្រុមគ្រួសារឪពុកក្មេកខ្ញុំ បានស្នើសុំអង្គការភូមិត្រពាំងស្នោ ឃុំមង់រៀវ បន្តដំណើរទៅរស់នៅភូមិកំពង់ចន្ទុះលិច ឃុំពាមជីលាំង ស្រុកពាមជីលាំង តាមបណ្តាំរបស់ឪពុកធំខ្ញុំ ។ ទៅដល់ទីនោះមិត្ត ចម ជាអនុប្រធានស្រុកពាមជីលាំង បានចុះមកសួរសុខទុក្ខ ។ គ្រួសារខ្ញុំស្នាក់នៅផ្ទះរបស់ប្រពន្ធចុងមេស្រុកឈ្មោះ ឈាន ជាអតីតមេឃុំពាមជីលាំង និងត្រូវជាជន្លងរបស់ឪពុកក្មេកខ្ញុំ ។ បន្ទាប់មកខ្ញុំត្រូវបាន គង់ ប្រធានសិប្បកម្មចម្រុះរដ្ឋភូមិភាគបូព៌ា ប្រចាំការនៅឃុំបើស ស្រុកក្រូចឆ្មារ ទទួលយកខ្ញុំទៅធ្វើជាកម្មករដោយណែនាំឲ្យខ្ញុំតាំងខ្លួនជាប្រជាជនមូលដ្ឋាន មិនត្រូវនិយាយស្តីអ្វីធ្វើឲ្យប៉ះពាល់ដល់អង្គការឡើយ ។

## សិប្បកម្មភូមិភាគបូព៌ា

សិប្បកម្មភូមិភាគបូព៌ាមានទីតាំងនៅផ្សារបើស ឃុំបើស ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម មានចែកជា៤ផ្នែក គឺផ្នែកតំឡើងកង់ ផ្នែកស្លដែកចាក់ផាលចានឆ្នាំង ផ្នែកផលិតសាប៊ូ និងផ្នែកផលិតបារី ។ សិប្បកម្មនេះមានម៉ាស៊ីនភ្លើងមួយគ្រឿងបញ្ចេះបញ្ជូនអគ្គិសនីចែកចាយទៅកាន់ផ្នែកទាំងបួននេះ ។ មិត្ត គង់ បានចាត់តាំងឲ្យខ្ញុំធ្វើជាបុគ្គលិកផ្នែកតំឡើងកង់ជិះនិងត្រូវសម្រាកនៅទីនោះ ។ ការហូបចុកពេលនោះគឺត្រូវរកអង្ករនិងម្ហូបរៀងៗខ្លួន ហើយដាក់ហូបរួមគ្នា ។ បន្ទាប់មក គណៈសិប្បកម្មបានចាត់តាំងកម្លាំងស្រួច គូទ្រុយ ដែលមានផ្ទះនៅភូមិរកាខ្នុរទី១ ជាប្រធានមុខព្រួញនិងដកយកកម្លាំង១០នាក់ចេញពីផ្នែកទាំង៤នេះដើម្បីទៅអារ-កាត់រថក្រោះ ឬរថយន្តជាបំណែកដើម្បីយកដែកទៅស្ល



ចាក់ផាល ចានឆ្នាំង និងគ្រឿងបន្លាស់ម៉ាស៊ីន ។ ពេលទៅដល់ យើងនាំគ្នាដោះវាយយកស៊ីឡាំងម៉ាស៊ីនដែលជាដែកហ្កាំង និងអារយកតួរថក្រោះដែលជាដែកដេរ៉ា សែងយកទៅដាក់លើផ្លូវលំ ដើម្បីរង់ចាំការដឹកជញ្ជូន ។ ធ្វើការនៅសិប្បកម្មបើសបានជាង មួយខែ មិត្ត គង់ អនុញ្ញាតឲ្យខ្ញុំនាំយកប្រពន្ធកូនមករស់នៅជុំគ្នា ។ ខ្ញុំបានស្នើសុំផ្ទះម៉ារ៉ៃដែលស្ថិតនៅជាប់រោងម៉ាស៊ីនភ្លើងដើម្បីស្នាក់នៅ ។ ប្រពន្ធខ្ញុំធ្វើចុងភៅ ហើយ យី ស្រ៊ន់ និងបងប្អូននៅផ្សារបើសជាអ្នកដោះស្រាយខាងអង្ករ ។ ដោយមានលុយកាក់បន្តិចបន្តួចដែលសល់ពីមុន ប្រពន្ធខ្ញុំលួចទិញខ្ទឹមសនៅផ្សារបើសដែលមានតម្លៃថោកសម្រាប់យកទៅលក់នៅពាមជីលាំង ។ ពេលនោះខ្ញុំបានយកលេសដោយសុំ មិត្តគង់ នាំប្រពន្ធនិងកូនទៅលេងពាមជីលាំង ដើម្បីឆ្លៀតឱកាសយកខ្ទឹមទៅលក់នៅទីនោះ ។ ខ្ញុំចាំបានថាមានម្តងនោះ មិត្តចម ជាអនុប្រធានស្រុកពាមជីលាំង បានបើករថយន្តហ្ស៊ីបមកសួរសុខទុក្ខខ្ញុំ ឆ្លៀតពេលនោះ ខ្ញុំបានផ្ញើខ្ទឹមសមួយថង់តាមរថយន្តរបស់គាត់ទៅឲ្យឪពុកក្មេកលក់នៅពាមជីលាំងដែរ ។

នៅដើមឆ្នាំ១៩៧៨ ពេលព្រលប់ ប្រពន្ធខ្ញុំឈឺពោះឆ្លងទន្លេ ខ្ញុំក៏បានទៅអញ្ជើញពេទ្យអាណិកជនចិននៅផ្សារបើស ដែលជាពេទ្យប្រចាំសិប្បកម្មនេះជួយបង្កើត ។ អ្នកដែលអាចទទួលការព្យាបាលពីពេទ្យនេះបាន លុះត្រាតែជាអាណិកជនមានភាគហ៊ុននៅក្នុងនោះ ឬជាបុគ្គលិកសិប្បកម្ម ។ ពេលដែលពេទ្យអាណិកជនចិនមកដល់ ស្រាប់តែពេទ្យឃុំជិទាស់ ព្រោះថាខ្ញុំជាបុគ្គលិកខ្មែរដូច្នេះត្រូវឲ្យពេទ្យឃុំជួយវិញ ។ ចំរ៉ុង ដែលស្រឡាញ់រាប់អានខ្ញុំ និងដែលធ្វើការនៅសមាគមនារីស្រុកចុះមកប្រចាំការនៅឃុំបើស បាននាំអ្នកគ្រូពេទ្យឆ្មបម្នាក់ដែលជាអតីតឆ្មបពីសង្គមចាស់មកជួយបង្កើតវិញ ។ អ្នកលក់ដូរនៅផ្សារបើសដែលអាណិតអាសូរក្រុម



កម្មាភិបាលខ្មែរក្រហមកំពុងសាងសង់ការដ្ឋាន

គ្រួសារខ្ញុំ ក៏បានជួយមកដេកកំដរប្រពន្ធខ្ញុំរហូតដល់ថ្ងៃចេញពីពេទ្យ ។ កូនប្រុសដែលទើបនឹងកើតនេះថ្លោសត្រលុចគួរឲ្យស្រឡាញ់ ហើយត្រូវអ្នកជិតខាងនិងក្មេងៗបីថ្នាក់ថ្នមពីដៃមួយទៅដៃមួយ មិនដែលដាច់ ។ ខ្ញុំបានយកសាប៊ូដែលផលិតបាននៅក្នុងសិប្បកម្ម ចំនួន៤ដុំចែកជូនសមាគមនារីស្រុកក្រូចឆ្មារដែលប្រចាំនៅឃុំប៉ើស និងអ្នកគ្រូពេទ្យឆ្មប ។

ក្រោយមក ប្អូនថ្លៃរបស់ខ្ញុំឈ្មោះ ទូច ស៊ាងហុង បានរៀបការជាមួយ គង ក្រោមការឧបត្ថម្ភពីមិត្ត ចម ។ មង្គលការនេះមានចូលរួមពី តាសារូ មកពីភាគខាងជើងវៀតណាមជាប្រធានគណៈសិប្បកម្មភូមិភាគបូព៌ា តាហ៊ិន មកពីភាគខាងជើងជាអនុប្រធាន មិត្ត ទូច រស់ និងមិត្ត ទូច ឆន ជាសមាជិកព្រមទាំងកម្មាភិបាលសិប្បកម្មរដ្ឋ និងចម្រុះរដ្ឋជាច្រើនចូលរួម ។ ក្រោយពីពិធីមង្គលការចប់សព្វគ្រប់ មិត្ត គង បានហៅប្រពន្ធកូនខ្ញុំទៅជួយមើលការខុសត្រូវប្រពន្ធគាត់ ។

ដោយខ្វះអ្នកបូកសរុបទូទាត់បញ្ជីចំណូលចំណាយនិងចំណេញរបស់សិប្បកម្ម គង បានចាត់ឲ្យខ្ញុំទៅជួយមិត្ត គាង ជី ជាកូនកាត់ចិនមានតួនាទីជាគណនេយ្យករ ។ ខ្ញុំត្រូវបានគណៈសិប្បកម្ម-ឧស្សាហកម្មភូមិភាគបូព៌ាហៅទៅរៀនសូត្រនៅជំនីក អំពី CVM គឺការគណនាតម្លៃដើមរបស់ផលិតផល (C ជាតម្លៃវត្ថុធាតុដើម V ជាតម្លៃរំលស់ និង M ជាកម្លាំងពលកម្ម) ។ ខ្ញុំបានធ្វើការងារគណនេយ្យពីដំបូងជាជំនួយការរហូតដល់ទទួលការងារទាំងអស់ ពោលគឺរ៉ាប់រងការងារទាំងស្រុង ។

មានថ្ងៃមួយ គង បានចាត់តាំងឲ្យខ្ញុំនិងគណៈសិប្បកម្មមួយចំនួនទៅចូលរួមស្ដាប់បទឧទ្ទេសនាមរបស់ ភួង ជាអនុប្រធានភូមិភាគបូព៌ាទទួលបន្ទុកសេដ្ឋកិច្ចនៅក្នុងវត្តមួយនៅស្រុកក្រូចឆ្មារ អស់រយៈពេលមួយព្រឹក ដែលមានសេចក្ដីថ្លែងថា ភួង បានវាយប្រហារយ៉ាងខ្លាំងទៅលើកម្មាភិបាលដែលមានចរិតក្អេងក្អាង សេរីនិងអនុធន ។

រដូវវស្សាឆ្នាំ១៩៧៨ ខ្ញុំសង់បានផ្ទះថ្មីមួយ ធ្វើពីប៉ុស្សី ដែលទិញពីបងប្អូនចាមនៅកោះផល ។ ពេលនោះប្រពន្ធខ្ញុំមានមុខរបរថ្មីមួយទៀតគឺទិញស្ពៃស្រស់ពីប្រជាជនក្នុងភូមិយកទៅធ្វើស្ពៃជ្រក់ ។ ក្រៅពីការងារនៅក្នុងសិប្បកម្ម ខ្ញុំមានតួនាទីមួយទៀតគឺធ្វើជាអង្គរក្សរបស់ គង ។ ភារកិច្ចរបស់ខ្ញុំគឺស្ពាយកាំភ្លើងបង់ត្រឡោកជិះម៉ូតូតាមពីក្រោយ គង ដើរទាក់ទងការងារក្នុងតំបន់២១ តំបន់២២ និងឆ្លៀតទិញថ្នាំពេទ្យពីកន្លែងអង្គការយកមកឲ្យប្រពន្ធខ្ញុំលក់ ។ មានពេលខ្លះ គង បានឲ្យខ្ញុំនិងបុគ្គលិកសិប្បកម្មដែលជាសាច់ញាតិរបស់គាត់ លួចដើរទិញថ្នាំខ្មែរនិងថ្នាំសរសៃពីប្រជាជននៅកោះទល់មុខភូមិប៉ើសយកទៅលក់នៅកំពង់ចាម ។ ខ្ញុំដឹកជញ្ជូនថ្នាំនេះចូលឃ្លាំងសិប្បកម្មនៅពេលអធ្រាត្រ លុះត្រាតែបានច្រើនទើបឲ្យមិត្ត ចម យកឡានមកដឹកនៅពេលយប់យកទៅស្រុកពាមជីលាំង និងយកទៅក្រុងកំពង់ចាមទៀត ។

ដោយនឹករឭកឪពុកម្ដាយខ្ញុំដែលរស់នៅភូមិត្រពាំងស្នោ ខ្ញុំក៏ឌុបប្រពន្ធនិងកូនៗខ្ញុំទៅលេងគាត់មួយរយៈ ។ ក្រោយមកមានពេទ្យម្នាក់ដែលស្និទ្ធស្នាលជាមួយមិត្ត ទឹម សុង បានប្ដឹងទៅ គង អំពីខ្ញុំថា រំដោះប្រពន្ធប្រុងរត់ទៅតំបន់ខ្មាំង (តំបន់គ្រប់គ្រងដោយ លន់ នល់) ។ ពេលនោះ ខ្ញុំត្រូវបានបញ្ជាឲ្យទៅយកប្រពន្ធមកវិញ ។

នៅព្រលប់ថ្ងៃមួយ យើងមិនទាំងស្គាល់មុខប្រធានភូមិផង (ព្រោះយើងនៅក្នុងអង្គភាពសេដ្ឋកិច្ចមិនចំណុះរដ្ឋអំណាចទេ) ស្រាប់តែប្រធានភូមិបានមកសួរប្រពន្ធខ្ញុំរកទិញថ្នាំពេទ្យឲ្យកូន ។ ប្រពន្ធខ្ញុំបានឆ្លើយភ្លាមថាខ្ញុំគ្មានថ្នាំពេទ្យសម្រាប់លក់ទេគឺមានបន្តិចបន្តួចទុកសម្រាប់ខ្លួនឯង តែបើត្រូវការខ្ញុំជូនទទេ ។ ប្រពន្ធខ្ញុំក៏ហុចថ្នាំគ្រជាក់ពីរគ្រាប់ឲ្យទៅគាត់ ។ ក្រោយពីដឹងថា គាត់ជាប្រធានភូមិ ក្រុមគ្រួសាររបស់ខ្ញុំនាំគ្នាភ័យ ព្រោះថាមានអ្នករកស៊ីលក់ថ្នាំពេទ្យលួចលាក់មួយចំនួនត្រូវបានអង្គការនាំយកទៅបាត់រហូត ។

នៅចុងឆ្នាំ១៩៧៨ គឺជារដូវទឹកសម្រក អង្គការបានលើកទិសតំឡើងកម្រិតសិប្បកម្មចម្រុះរដ្ឋភូមិភាគបូព៌ានៅប៉ើសឲ្យក្លាយជាសិប្បកម្មរដ្ឋ ។ ពេលនោះខ្ញុំបានចូលរួមធ្វើបដិសណ្ឋារកិច្ចជូន អៀង សារី ទស្សនាសង្កាត់ផលិតកម្មទាំង៤កន្លែងក្នុងសិប្បកម្មនេះ ។ ការផ្ទេរពីចម្រុះរដ្ឋទៅជារដ្ឋទាំងស្រុង តម្រូវឲ្យបុគ្គលិកសិប្បកម្មទាំងអស់ រួមទាំង គង ផងត្រូវសរសេរប្រវត្តិរូបរបស់ខ្លួន ។ ស្ថិតក្នុងសភាពការណ៍តឹងតែងបែបនេះ ចម បានដឹកខ្ញុំនិងប្រពន្ធរបស់ខ្ញុំតាមរថយន្តហ្ស៊ីបឆ្ពោះទៅពាមជីលាំងវិញ ។

**(នៅមានត)**

**គី ប៊ុនថាន់**

# ដំណឹងសួររកបងស្រី

ខ្ញុំបាទឈ្មោះ សាយ សុខា រស់នៅភូមិព្រៃខ្លា ឃុំភក្តី ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ សូមសួរបងស្រីឈ្មោះ សាយ បឿន ដែលបានជួបគ្នាចុងក្រោយនៅម្តុំផ្ទះតាម៉ុក នៅក្នុងភូមិម្ជូ ស្រុកឈូក ខេត្តកំពត។ នៅឆ្នាំ១៩៧៥ សាយ បឿន បានមកលេងផ្ទះម្តង ហើយត្រូវកងយុវជននារីហៅត្រឡប់ទៅធ្វើការវិញ។ ឪពុកឈ្មោះ សាយ គួន ស្លាប់នៅឆ្នាំ១៩៩៣, ម្តាយឈ្មោះ ពេជ្រ ធឿង និងមានបងប្អូន៩នាក់ ÷ ១) សាយ មុំ ភេទស្រី,២) សាយ ហ៊ុន ភេទប្រុស (ស្លាប់) , ៣) សាយ បឿន ភេទស្រី, ៤) សាយ សំបូរ ភេទស្រី (សព្វថ្ងៃឈ្មោះ សាយ សុភី) , ៥) សាយ សម្បត្តិ ភេទស្រី, ៦) សាយ ប៊ិន ភេទស្រី, ៧) សាយ សុខា ភេទប្រុស, ៨) សាយ ទូច ភេទប្រុស, និង ៩) សាយ ហ៊ិន ភេទប្រុស (កើតនៅឆ្នាំ១៩៧៩) ។

បើបងប្អូនណាបានស្គាល់ឬដឹងដំណឹងអំពីឈ្មោះនេះសូមទំនាក់ទំនងមកឈ្មោះ វង្ស គួន ទូរស័ព្ទលេខ ០៩២ ៥៤២ ៣៣៩ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ភ្នំពេញ។ សូមអរគុណ។

# ដំណឹងសួររកបងប្រុស

ខ្ញុំបាទឈ្មោះ ញ៉ែម លុន រស់នៅភូមិត្រពាំងផុង ឃុំបសេដ្ឋ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ ស្វាយ សួង (ស្លាប់ក្នុងឆ្នាំ១៩៧៩) ម្តាយឈ្មោះ ដុល ផាត់ (ស្លាប់) មានបងប្អូន៨នាក់ សូមប្រកាសរកបងប្រុសឈ្មោះ ញ៉ែម លេង (អាយុ២៧ឆ្នាំ) ដែលបានបែកគ្នានៅក្នុងឆ្នាំ១៩៧១ដោយសារខ្មែរក្រហមចាប់ខ្លួននិងបង្ខំឲ្យចូលកងទ័ពខ្មែរក្រហម ហើយក៏បាត់ខ្លួនតាំងពីពេលនោះមក។

បើញាតិមិត្តបានស្គាល់ឬដឹងដំណឹងពីឈ្មោះនេះសូមផ្តល់ដំណឹងមកខ្ញុំបាទតាមអាសយដ្ឋានខាងលើ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ។

# ដំណឹងសួររកប្រពន្ធ និងកូន

ខ្ញុំបាទឈ្មោះ សូ ចិត្រ អាយុ ៥០ឆ្នាំ រស់នៅភូមិស្វាយជ្រុំ ឃុំសំរោង ស្រុកសូទ្រនិគម ខេត្តសៀមរាប សូមប្រកាសសួររកប្រពន្ធ និងកូនចំនួន៤នាក់ (ស្រី៣ ប្រុស១) ដែលបានបែកគ្នានៅជំរំអូរត្រាវក្នុងទឹកដីប្រទេសថៃ បន្ទាប់ពីរបបខ្មែរក្រហមត្រូវដួលរលំឆ្នាំ១៩៧៩ ។ ប្រពន្ធឈ្មោះ គីម លាង អាយុ៥០ឆ្នាំ រស់នៅភូមិឫស្សីចារ ឃុំថ្មគ្រែ ស្រុកក្រចេះ ខេត្តក្រចេះ និងកូនទាំងបួនៈ ១) ហៀង សិទ្ធ ភេទស្រី បច្ចុប្បន្នអាយុ២៥ឆ្នាំ, ២) ហៀង ភី ភេទស្រី បច្ចុប្បន្នអាយុ២២ឆ្នាំ, ៣) ហៀង វុទ្ធី ភេទប្រុស បច្ចុប្បន្នអាយុ១៨ឆ្នាំ, និង៤) កូនស្រីមិនទាន់មានឈ្មោះមុននឹងឪពុកបែកពីកូន ដែលពេលនោះនាងទើបអាយុ៤ខែ។

ឪពុកបានត្រឹមតែដឹងថា ប្រហែលជាអ្នកទាំងអស់គ្នារស់នៅភូមិឃុំខាងលើក្នុងខេត្តក្រចេះ ប៉ុន្តែដោយបែកគ្នាយូរ ហើយពុំដឹងសុខទុក្ខកូនៗយ៉ាងណា ព្រមទាំងឪពុកពុំមានលទ្ធភាពអាចទៅរកកូនបាន ហេតុនេះប្រសិនបើបងប្អូនណាបានឮដំណឹងនេះ ឬកូនៗទាំងអស់បានឮដំណឹងនេះហើយ សូមទាក់ទងមកតាមអាសយដ្ឋានភូមិឃុំខាងលើក្នុងខេត្តសៀមរាប ឬតាមលេខទូរសព្ទ័ ០១២ ៦៦៧ ៩៧១ ។

សូមអរគុណ។



ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨